សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំរាជធានីភ្នំពេញឲ្យមានលក្ខណៈស្តង់ដា

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧


តាក់តែងឡើងដោយ
និស្សិតឈ្មោះ : **គន់ ពន្លឺ**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ**រដ្ឋបាលសាធារណៈ**
ជំនាន់ទី១០

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **គន់ ពន្លឺ** ជានិស្សិតបរិញ្ញាបត្រ ឆ្នាំទី៤ ឆ្នាំសិក្សា២០១៦-២០១៧ ជំនាន់ទី ១០ ផ្នែករដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

សូមសំដែងនូវកិច្ចគោរពដឹងគុណដ៏ខ្ពង់ខ្ពស់ជូនចំពោះ៖

**លោកឪពុក និងអ្នកម្តាយ** ដែលបានផ្តល់កំណើតដល់រូបនាងខ្ញុំ ហើយលោកទាំងពីរបានខិតខំពុំពារគ្រប់ឧបសគ្គក្នុងការចិញ្ចឹមបីបាច់រូបនាងខ្ញុំ ថែរក្សា អប់រំ ប្រៀនប្រដៅរូបនាងខ្ញុំ និងបានផ្គត់ផ្គង់នាងខ្ញុំដោយសម្ភារៈ និងថវិកាសម្រាប់ការសិក្សា ។ ការជួយជ្រោមជ្រែងរបស់អ្នកទាំងពីរបានជម្រុញកូនឱ្យបានក្លាយជាសសរទ្រូងនៃប្រទេសជាតិ ជាធនធានសម្រាប់សង្គមជាតិ។ គុណរបស់លោកទាំងពីរបានផ្តល់ឱ្យកូនជាតម្លៃមួយដែលមិនអាចកាត់ថ្លៃបាន ។

**សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា** គឺជាសាស្ត្រាចារ្យម្នាក់ដែលប្រកបដោយព្រហ្មវិហារធម៌ចំពោះនិស្សិត និងប្រកបដោយគតិបណ្ឌិត ដែលលោកបានផ្តល់អនុសាសន៍សំខាន់ៗ និងមានតម្លៃសម្រាប់សារណារបស់នាងខ្ញុំ អោយបានសម្រេចនូវភាពជោគជ័យរួមជាមួយនឹងឯកសារជាច្រើន។

**លោក លោកស្រី សាស្ត្រាចារ្យ និងបុគ្គលិក** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំក្នុងការប្រឹងប្រែងបណ្តុះបណ្តាលដល់រូបនាងខ្ញុំ។

នាងខ្ញុំសូមសំដែងនូវការដឹងគុណអស់ពីដួងចិត្ត និងសូមឲ្យ **លោកអ្នកមានគុណទាំងពីរ** និង**លោកសាស្ត្រាចារ្យណែនាំ បណ្ឌិត អ៊ុន សកក្កដា** ប្រកបទៅដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ការរៀបចំរាជធានីភ្នំពេញឲ្យមានលក្ខណៈស្តង់ដា គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍសង្គមជាតិ ឲ្យមានលក្ខណៈរីកចម្រើន។ នៅគ្រប់បណ្តាប្រទេសទាំងអស់កំពុងខិតខំយកចិត្តទុកដាក់ក្នុងការរៀបចំក្រុងរបស់ពួកគេឲ្យមានលក្ខណៈប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

ចំពោះសារណានេះ ដែលមានចំណងជើងថា ការរៀបចំរាជធានីភ្នំពេញឲ្យមានលក្ខណៈស្តង់ដាគឺជាសារណាមួយប្រភេទដែលធ្វើការលើកឡើងពីប្រវត្តិនៃការរៀបចំ និងអត្ថបទគតិយុត្តិផ្សេងៗដែលពាក់ព័ន្ធ និងគោលការណ៍ដែលរាជរដ្ឋាភិបាលលើកឡើងពីការរៀបចំទីក្រុង ។ នាងខ្ញុំរៀបរៀងសារណានេះឡើង ដោយសារនាងខ្ញុំបានចាប់អារម្មណ៍ជាខ្លាំងទៅលើការសិក្សាអំពីការរៀបចំរាជធានីភ្នំពេញ ឲ្យមានលក្ខណៈស្តង់ដាដូចបណ្តាប្រទេសជឿនលឿនមួយចំនួននៅលើពិភពលោក ។ ទន្ទឹមនឹងនេះក្រៅពីការចង់ដឹង ចង់សិក្សាពីបញ្ហា និងវិធានការណ៍របស់រាជរដ្ឋាភិបាលដែលអនុវត្តកន្លងមកនោះ ។ ក្នុងនោះដែរដោយសារក្នុងកំឡុងពេលសិក្សានាងខ្ញុំមានចំណាប់អារម្មណ៍ទៅលើការអភិវឌ្ឍរាជធានី នោះនាងខ្ញុំមានឱកាសច្រើនក្នុងការសិក្សាស្រាវជ្រាវ និងមើលនូវឯកសារជាច្រើនពាក់ព័ន្ធនឹងនីតិវិធីនៃការរៀបចំរាជធានីភ្នំពេញ ។ ហេតុនេះនាងខ្ញុំក៏សម្រេចថា និងប្រើប្រាស់ឱកាសនេះ ដើម្បីស្រាវជ្រាវអំពីការរៀបចំរាជធានីភ្នំពេញឲ្យមានលក្ខណៈស្តង់ដានេះសម្រាប់ជាស្នាដៃ និងបំពេញបន្ថែមនូវចំណេះដឹងដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយដទៃទៀត។

នាងខ្ញុំជឿជាក់ថា ការចងក្រងសារណានេះឡើង ប្រាកដជាមិនទាន់មានភាពគ្រប់គ្រាន់ និងត្រឹមត្រូវគ្រប់ជ្រុងជ្រោយនោះទេ ប្រាកដជានិងមានកំហុសជាក់ជាមិនខាន។ រាល់កំហុស និងកង្វះខាតទាំងប៉ុន្មាន នាងខ្ញុំសង្ឃឹមថានឹងមានការយោគយល់ពីសំណាក់អស់លោក លោកស្រី អ្នកនាងកញ្ញា ទាំងអស់។ នាងខ្ញុំសូមទទួលយកនូវការរិះគន់ស្ថាបនាពីគ្រប់មជ្ឈដ្ឋាននានា ដើម្បីជាបទពិសោធន៍ និងជាកាកែលម្អនូវការខ្វះខាតទាំងឡាយ។

# មាតិកា

ទំព័រ


សេចក្តីផ្តើម ........................................................................................ ១

**ជំពូក១.ប្រវត្តិនៃការរៀបចំរាជធានីនាសម័យបុរាណនៃព្រះរាជាណាចក្រកម្ពុជា**

**១.១ ការរៀបចំក្រុងនាសម័យអង្គរ** ........................................................................ ៤

១.១.១ .លក្ខណៈពិសេសនៃទីតាំងភូមិសាស្រ្តតាមរយៈភូគម្ពសាស្រ្ត ........................................ ៤

១.១.២.លក្ខណៈពិសេសភូមិសាស្រ្តអាណាចក្រខ្មែរតាមរយៈប្រវត្តិសាស្រ្ត ................................ ៥

១.១.៣. លក្ខណៈពិសេសនៃការរៀបចំក្រុងនាសម័យអង្គរ ................................................ ៦

១.១.៣.១.ការរៀបចំក្រុងអង្គរ ........................................................................ ៦

១.១.៣.២. ការសាងសង់មន្ទីរពេទ្យ ................................................................... ៨

១.១.៣.៣. ការសាងសង់ធម្មសាលា និងសាលាសំណាក់ ............................................. ៨

១.១.៤. ការរៀបចំទីក្រុងរបស់ខ្មែរ និងទំនាក់ទំនងជាមួយទស្សនៈព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា (នៅសម័យអង្គរ) ........................................................................................ ៩

១.១.៥. នគរូបនីយកម្ម និងស្ថាបត្យកម្មនៅកម្ពុជាតាមសម័យកាល ....................................... ១១

១.១.៥.១.សម័យមុនអង្គរ និងសម័យអង្គរ ........................................................... ១១

១.១.៦. ប្រាសាទនានាដែលសាងសង់នៅសម័យអង្គរ ........................................................ ១៣

**១.២ ការរៀបចំនាសម័យសង្គមរាស្រ្តនិយម** ............................................................... ១៥

១.២.១. ប្លង់គោលអភិវឌ្ឍន៍រាជធានី ..................................................................... ១៥

១.២.២. សមិទ្ធផលនានាក្នុងការអភិវឌ្ឍន៍រាជធានីភ្នំពេញនាសម័យសង្គមរាស្រ្តនិយម ................. ១៦

១.២.៣. សមិទ្ធិផលនានាក្នុងចន្លោះឆ្នាំ១៩៦០ ដល់១៩៧០ ................................................ ២០

១.១.៦. សមិទ្ធិផលនានាក្នុងចន្លោះឆ្នាំ១៩៧០ ដល់១៩៧៥ ................................................. ២៥

**ជំពូក២.គោលការណ៍គតិយុត្តិក្នុងការរៀបចំរាជធានីភ្នំពេញ**

**២.១ គោលនយោបាយ និងយុទ្ធសាស្រ្តអភិវឌ្ឍន៍រាជធានី** ................................................ ២៧

២.១.១. យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ......................................................... ២៧

២.១.១.១.ផែនការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងវប្បធម៌ ..................................... **២៨**
២.១.២. ប្លង់គោលនៃការរៀបចំរាជធានីភ្នំពេញ ..................................... **២៩**
២.១.២.១.អនុភាពប្លង់គោលសម្រាប់លិខិតអនុញ្ញាតសាងសង់..................................... **២៩**
២.១.២.២.អនុភាពប្លង់គោលចំពោះលិខិតអនុញ្ញាតសាងសង់..................................... **៣០**
២.១.២.៣.អត្ថប្រយោជន៍នៃប្លង់គោល ..................................... **៣១**
២.១.៣. គោលនយោបាយក្នុងការរៀបចំទឹកដី និងលំនៅដ្ឋាន..................................... **៣២**
២.១.៣.១.ការៀបចំរាជធានី..................................... **៣២**
២.១.៣.២.ការរៀបចំសោភ័ណភាពរាជធានី ..................................... **៣៥**
**២.២. សមិទ្ធិផលដែលរដ្ឋបាលរាជធានីភ្នំពេញសម្រេចបានពេលកន្លងមក** ..................................... **៣៧**
២.២.១ ភាពរីកចម្រើនថ្មីរបស់រាជធានី..................................... **៣៧**
២.២.២ សមិទ្ធផលរបស់រាជរដ្ឋាភិបាល ..................................... **៣៧**
**សេចក្តីសន្និដ្ឋាន**..................................... **៣៩**
**អនុសាសន៍** ..................................... **៤១**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ក.លំនាំបញ្ហានៃការស្រាវជ្រាវ

ការវិវត្តនៃការីកចំរើន របស់ពិភពលោកបានធ្វើឲ្យប្រទេសនីមួយៗខិតខំកសាង កំណែទម្រង់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីឲ្យមានភាពលេចធ្លោ និងទាន់សម័យស៊ីវិល័យដោយការប្រកួតប្រជែងក្បូរក្បាច់រចនាសំណង់ និងបច្ចេកទេស។ទន្ទឹមនឹងនេះ នៅមានប្រទេសមួយចំនួន មិនទាន់អាចវិវត្តន៍ខ្លួនដូចប្រទេសមហាអំណាចសេដ្ឋកិច្ចធំៗ ដូចជា សហរដ្ឋអាមេរិច ចិន ជប៉ុន។ល ។ តែទោះជាយ៉ាងណា ប្រទេសដែលមិនទាន់រីកចម្រើនក៏មិនមែនថាខ្លួនមិនចង់វិវត្តនោះទេ តែដោយសារកត្តាធនធានមនុស្ស និងហិរញ្ញវត្ថុមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ជាក់ស្តែងប្រទេសកម្ពុជាពិតមែនទទួលបានសុខសន្តិភាពជាង ៣០ ឆ្នាំក៏ដោយតែប្រទេសកម្ពុជាបានងើបមកពីចំណុចសូន្យទាំងធនធានមនុស្ស និងហិរញ្ញវត្ថុដែលធ្វើឲ្យរាជរដ្ឋាភិបាលធ្វើការកសាងប្រទេសដោយបាតដៃទទេទាំងធនធានមនុស្ស ។ ជាក់ស្តែងបច្ចុប្បន្ននៃប្រទេសកម្ពុជាមិនមែនថាអាចប្រកួតប្រជែងជាមួយនិងប្រទេសដែលមានសុខសន្តិភាព និងប្រទេសដែលសម្បូរទៅដោយធនធានដែលអាចជួយកសាងប្រទេសឲ្យមានភាពរីកចម្រើន។

យ៉ាងណាមិញរាជធានីភ្នំពេញគឺជាបេះដូង នៃព្រះរាជាណាចក្រកម្ពុជាដែលស្ថិតនៅត្រង់ចំនុចចតុមុខទីតាំងប្រកបដោយប្រព័ន្ធអេកូឡូហ្ស៊ីទឹកសាបទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ដែលជាប្រភពធនធានធម្មជាតិរបស់ក្រុងតាំងពីសម័យអតីតកាល រហូតមកដល់សម័យបច្ចុប្បន្ន ។ រាជធានីភ្នំពេញមានផ្ទៃក្រលាសរុប ៦៧៨,៩១៦ គីឡូម៉ែត្រការ៉េ ដែលមានប្រជាជនរស់នៅប្រហែល ១,០៧៨,០០០ និងមានដង់ស៊ីតេប្រជាជន ២,២១៣នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ និងមានខណ្ឌចំនួន ១២ គឺខណ្ឌចំការមន ខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក ខណ្ឌមានជ័យ ខណ្ឌឫស្សីកែវ ខណ្ឌពោធិសែនជ័យ ខណ្ឌជ្រោយចង្វារ ខណ្ឌព្រែកព្នៅ ខណ្ឌច្បារអំពៅ ខណ្ឌដង្កោ និងខណ្ឌសែនសុខ។ ក្រៅពីនោះចំនួនប្រជាពលរដ្ឋសរុបក្នុងរាជធានីភ្នំពេញមានប្រមាណ ១,៥០១,៧៥២នាក់ និងបែងចែកជា ៩៦សង្កាត់ និង ៨៩៧ភូមិ។

ដោយហេតុថាការកើនឡើងនៃចំនួនប្រជាពលរដ្ឋ នៃរាជធានីភ្នំពេញមានការកើនឡើងជាបន្តបន្ទាប់នេះហើយទើបធ្វើឲ្យរាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់លើការរៀបចំរាជធានីឲ្យមានលក្ខណៈអភិវឌ្ឍន៍លើគ្រប់វិស័យ និងក្លាយជាទីក្រុងគុជនៃទ្វីបអាស៊ី។

## ខ.ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្នុងនោះដែរមានចំណោទបញ្ហាជាច្រើនដែលចោទឡើងក្នុងកិច្ចស្រាវជ្រាវនៃសារណានេះ។ ដូច្នេះហើយ ការស្រាវជ្រាវនេះ នឹងត្រូវធ្វើឡើងដើម្បីឆ្លើយតបទៅនឹងសំណួរមួយចំនួនដូចខាងក្រោមៈ

១.តើកត្តាអ្វីខ្លះដែលបណ្តាលឲ្យរាជរដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងការរៀបចំរាជធានីភ្នំពេញ?

២.តើការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវ ក្នុងរាជធានីភ្នំពេញទទួលការប្រឈមអ្វីខ្លះ?

៣.តើសាលារាជធានីភ្នំពេញមានគោលនយោបាយយ៉ាងណាដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍?

៤. តើការរៀបចំរាជធានីសម័យអតីតកាលដល់បច្ចុប្បន្នមានការប្រែប្រួលអ្វីខ្លះ?

## គ. គោលបំណងនៃការស្រាវជ្រាវ

មូលហេតុដែលនាងខ្ញុំលើកយកប្រធានបទនេះឡើងក្នុងគោលបំណងដើម្បីស្វែងរកដំណោះស្រាយ និងចំណោទបញ្ហាដែលសាលារាជធានីភ្នំពេញកំពុងវិវត្តន៍ខ្លួនឥតឈប់ឈរ ដែលមានហេដ្ឋារចនា-សម្ព័ន្ធ សំណង់អាគារ ដើម្បីឲ្យសមាមាត្រទៅនិងកំណើនប្រជាពលរដ្ឋ និងយានយន្តហើយនេះជាបញ្ហាមួយដែលសាលារាជធានីភ្នំពេញដើម្បីដោះស្រាយ។

## ឃ. ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សានេះគឺមិនមានភាពលំអៀងទៅរាល់ព្រឹត្តការណ៍ និងសំណេរសុទ្ធតែធ្វើឡើងដោយមានសំអាងហេតុផលត្រឹមត្រូវ។ ចំពោះវិសាលភាពនៃការសិក្សាស្រាវជ្រាវមួយនេះ គឺនាងខ្ញុំមានគោលបំណងលើកឡើងត្រឹមតែបញ្ហាប្រឈម និងផែនការយុទ្ធសាស្ត្រសម្រាប់ការរៀបចំរាជធានីភ្នំពេញឲ្យមានសោភ័ណ្ឌភាព និងសណ្តាប់ធ្នាប់។

## ង. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវទៅលើប្រធានបទមួយនេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ជាការរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍រាជធានីភ្នំពេញឲ្យមានលក្ខណៈល្អប្រសើរ និងជាមូលដ្ឋានគំនិតសម្រាប់ការស្រាវជ្រាវទៅលើមូលដ្ឋាននីតិនគរូបនីយកម្មវិទ្យា ។ ជាងនេះទៀតសារណាមួយនេះក៏បានរួមចំណែកក្នុងការផ្តល់អនុសាសន៍មួយចំនួន សម្រាប់ការរួមអភិវឌ្ឍន៍រឹតតែប្រសើរ និងទទួលស្គាល់ពីបណ្តាប្រទេសនៅលើពិភពលោក ដូច្នេះហើយការរៀបចំរាជធានីភ្នំពេញទាមទារឱ្យមានការចូលរួមពីសំណាក់រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋគ្រប់លំដាប់។

## ច. វិធីសាស្ត្រស្រាវជ្រាវ

- ការស្រាវជ្រាវនូវប្រធានបទខាងលើ បានលើកយកឯកសារប្រវត្តិសាស្ត្រ ច្បាប់ និងឯកសារទាំងឡាយដែលជាប់ទាក់ទងនិងការរៀបចំរាជធានីភ្នំពេញ។

- ការស្វែងរកឯកសារនានាដែលទាក់ទង នឹងការស្រាវជ្រាវខាងលើនេះត្រូវបានធ្វើឡើងនៅបណ្ណដ្ឋានជាតិ បណ្ណាល័យសាកលវិទ្យាល័យ និងបណ្ណាល័យអង្គការជាតិ និងអន្តរជាតិ ។
- ជាពិសេសការស្រាវជ្រាវនេះប្រព្រឹត្តទៅយ៉ាងរលូនដោយមានការពិភាក្សា និងរែកញែករកនូវដំណោះស្រាយពីសំណាក់ លោកសាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា។

**ឆ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**

សេចក្តីផ្តើម

ជំពូក១ ប្រវត្តិនៃការរៀបចំរាជធានីនាសម័យបុរាណនៃព្រះរាជាណាចក្រកម្ពុជា

ជំពូកទី២ គោលការណ៍គតិយុត្តិនៃការរៀបចំរាជធានី

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ជំពូក១
## ប្រវត្តិនៃការរៀបចំរាជធានីនាសម័យបុរាណ
## នៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី១

# ប្រវត្តិនៃការរៀបចំរាជធានីនាសម័យបុរាណនៃព្រះរាជាណាចក្រកម្ពុជា

## ១.១ ការរៀបចំក្រុងនាសម័យអង្គរ

អង្គរគឺជាសម័យកាលមួយដែលមានភាពរីកចម្រើនលើគ្រប់វិស័យ ក្រោមការដឹកនាំរបស់ព្រះបាទជ័យវរ្ម័នទី ៧ ។ សម័យអង្គរខ្មែរមានឈ្មោះថាជាមហាអំណាចនៅតំបន់អាស៊ីអាគ្នេយ៍ កត្តាទាំងនេះហើយបានធ្វើឲ្យអរិយធម៌ខ្មែរបានឡើងដល់កម្រិតកំពូលនៅសតវត្សទី១៣ ។ ភាពរុងរឿងនេះបានធ្វើឲ្យអង្គរបានធ្វើឲ្យគេអាចសម្គាល់ថាអង្គរមានផ្ទៃដីធំទូលាយ និងលាតសន្ធឹងសឹងតែពេញផ្ទៃឥណ្ឌូចិនទាំងមូលដោយប្រាសាទសិលាមានចំនួនច្រើនពាន់ប្រកបដោយក្បាច់រចនាគួរឲ្យស្ញប់ស្ញែងដោយផ្ទាំងសិលានោះមានទាំងភាសាសំស្ក្រឹតនឹងខ្មែរបុរាណ ឬជួនកាលមានភាសាទាំងពីរលាយចម្រុះគ្នាដោយរូបបដិមាគ្រប់ប្រភេទ និងបុរាណវត្ថុផ្សេងៗទៀត និងជាពិសេសសល់រហូតដល់ពេលសព្វថ្ងៃដូចជាបារាយ ទំនប់ទឹក ផ្លូវថ្នល់ ស្ពាន។ល។

### ១. ១.១ លក្ខណៈពិសេសនៃទីតាំងភូមិសាស្ត្រតាមរយៈភូគព្ភសាស្ត្រ

សណ្ឋានដីនៃអាណាចក្រអង្គរ កសាងឡើងពីចលនាតិចតូនិច និងតាមរយៈនៃដំណើរសំណឹកនិងកំទេចកំណ ដែលកើតឡើងនៅគ្រប់សម័យកាលធរណីទាំងអស់ ។ តំបន់នេះ ទទួលរងនូវចលនាខ្លាំងខ្លា នៃពំនើងផ្នត់ធំៗជាញឹកញាប់ គឺពំនើងផ្នត់កាលេដូញ៉ង និងអ៊ែស៊ីញ៉ាងនៃស័ក ទី១។ នាចុងសតវត្សទី២ មានពំនើងផ្នត់មួយទៀត គឺអាំងដូស៊ីញ៉ាងដែលបង្កតំបន់នេះមានដីប្រកបដោយទម្រង់ថ្មក្រៃ(ថ្មភក់) សឹងពាសពេញប្រទេសដូចជាតំបន់ជួរភ្នំក្រវាញ ជួរភ្នំដងរែក និងខ្ពង់រាបខាងកើត។ ចលនាបានធ្វើឲ្យផ្ទៃដែនដីតំបន់នេះ ងើបឡើងបន្តិច និងបញ្ចប់ទៅវិញ នៅត្រង់ជួរភ្នំដំរីក្នុងខេត្តកំពតជាប់នឹងសមុទ្រ ។ ចលនានេះបានធ្វើឲ្យភូមិភាគបឹងទន្លេសាបសព្វថ្ងៃស្រុតចុះ ហើយត្រូវគ្របដណ្តប់ដោយទឹកសមុទ្រនៅចុងស័កទី៣ ដែលធ្វើឲ្យផ្លូវទឹកនានាទទួលរងនូវការចាក់បង្ករកំទេចកំណហូរពីតំបន់ខ្ពស់ តាមទន្លេមេគង្គ(នៅប្រទេសកម្ពុជា) ទន្លេមេណាម(នៅប្រទេសថៃ) ទន្លេសាលូអង់(នៅប្រទេសមីយ៉ាន់មា) សុទ្ធតែមានប្រភពមកពីតំបន់ខ្ពស់ភាគខាងជើងនៃតំបន់ខ្ពង់រាបខាងកើតទីបេ ។ សណ្ឋានដីបានងើបបន្តិចម្តងៗដោយកម្លាំងចលានតិចតូនិច គួបផ្សំនឹងចលនាថយចុះទៅនៃទឹកសមុទ្របានធ្វើឲ្យគេមើលឃើញនូវទិដ្ឋភាពទំនាបកណ្តាលធំធេង នោះគឺដីល្បាប់ថ្មីឋិតនៅក្បែរផ្លូវទឹក(បឹងទន្លេសាប និងទន្លេមេគង្គ) ដីល្បាប់ចាស់ឋិតនៅក្បែរតំបន់ខ្ពស់(ជួរភ្នំក្រវាញ ជួរភ្នំដងរែក និងខ្ពង់រាបខាងកើត) ។ នៅតំបន់ទំនាបកណ្តាល គេសង្កេតមានកូនភ្នំតូចៗ លេចចេញឡើងដែល

ជាទូលសិលា នៅស័កទី៣ មានព្រឹត្តការណ៍ផ្ទុះភ្នំភ្លើងធ្វើឲ្យទឹកដីនៃអាណាចក្រខ្មែរទទួលរងនូវចលនាបំណាក់ស្រុត និងមានរំហៀរសិលាបាសាល់គ្របដណ្តប់តាមតំបន់ភូមិសាស្ត្របង្កើតបានជាខ្ពង់រាប ។ ក្រោមឥទ្ធិពលត្រូពិចម៉ូសុងក្តៅហើយសើម បានបង្កលក្ខណៈឲ្យសិលាបាសាល់ពុកផុយក្លាយជាដីក្រហាមមានជីជាតិ និងបម្រើឲ្យដល់ការដាំដុះ និងការលូតលាស់នៃរុក្ខជាតិនានា។ កត្តាអាកាសធាតុសណ្ឋាណដី ភោគទ្រព្យព្រៃឈើ ផ្លូវទឹក ធនធានដី ធនធានសត្វ គួបផ្សំនិងអាណាចក្រនេះ មានធនធានមនុស្សខ្មែរប្រកបដោយឧត្តមគតិស្នេហាជាតិខ្ពស់ លក្ខណៈសម្បត្តិជាអ្នកអង់អាច ឧស្សាហ៍ព្យាយាម មានទេពកោសល្យ អាចស្ថាបនាប្រទេសបង្កើតក្រុងអង្គរពោរពេញដោយកិត្តិស័ព្ទល្បីរន្ទឺនិងក្លាយជាប្រទេសថ្កុំថ្កើងរុងរឿងនិងសម្បូរសប្បាយ។

ដែនដីនៃអាណាចក្រខ្មែរជាដែនដី ដែលសម្បូរណ៍ដោយសិលាថ្មភក់(ថ្មក្រែ) ថ្មបាសាល់ថ្មបាយក្រៀម ថ្មក្រានីត ដែលសិលាទាំងនេះជាធាតុសំខាន់ ជាពិសេស សិលាក្រែ ថ្មបាយក្រៀមនិងថ្មកានីត ដែលបុព្វបុរសខ្មែរបានយកថ្មទាំងនេះមកសាងសង់ប្រាសាទ បន្សល់ទុករហូតដល់សព្វថ្ងៃមានចំនួនជាងពាន់ប្រាសាទ បិតនៅរាយពាសពេញលើដែនដីនៃព្រះរាជាណាចក្រខ្មែរសម័យនោះមានដូចជាប្រាសាទភិមៃ(នៅប្រទេសថៃ) ប្រាសាទវត្តភូ(នៅប្រទេសឡាវ) ប្រាសាទអូកែវ(ប្រទេសវៀតណាម)សព្វថ្ងៃ។

### ១.១.២ លក្ខណៈពិសេសភូមិសាស្ត្រអាណាចក្រខ្មែរតាមរយៈប្រវត្តិសាស្ត្រ

ទីតាំងភូមិសាស្ត្រនៅសម័យមហានគរ មានឥទ្ធិពលធំធេងដល់កំណកំណើត ការលូតលាស់របាយធនធានធម្មជាតិ ប្រជាជន សេដ្ឋកិច្ច វប្បធម៌... ដែលទឹកដីនេះបានផ្សារភ្ជាប់យ៉ាងជិតស្និតហើយភូមិភាគអាស៊ីអាគ្នេយ៍ ទាំងដីគោក និងដីកោះ លើលក្ខខណ្ឌធម្មជាតិ និងប្រវត្តិសាស្ត្រ។ហើយម្យ៉ាងទៀតដែនដីនេះ គឺវាស្ថិតក្នុងតំបន់អាកាសធាតុត្រូពិច នៃអឌ្ឍគោលខាងជើងសម្បូរដោយកំដៅនិងបិតក្នុងតំបន់អាស៊ីមូសុង សម្បូរដោយ ភ្លៀង ដែលជាតំបន់មានលក្ខណៈប្រសើរដល់ការលូតលាស់នៃរុក្ខជាតិ មានដំណាំត្រូពិចគ្រប់ប្រភេទ។

នៅដើមសតវត្សទី១ នៃគ្រឹស្តរាជ តំបន់នេះជាដែនដីសុវណ្ណភូមិ មានមនុស្សខ្មែរតាំងទីរស់នៅយូរលង់ណាស់មកហើយ ដោយបង្កើតបានជាសង្គមមានរបៀបរៀបចំច្បាប់រដ្ឋច្បាស់លាស់ដឹកនាំដោយស្ត្រីសោយរាជ្យឈ្មោះព្រះនាងសោមា តាមភាសាចិនហៅថាព្រះនាងលីវយី នៅនគរកោះគោកធ្លកដែលមាន អង្គរបុរី ជារាជធានីទី១(ខេត្តតាកែវសព្វថ្ងៃ)។ ព្រះនាងបានរៀបអភិសេកជាមួយព្រាហ្មណ៍ដែលមកពីប្រទេសឥណ្ឌា ឈ្មោះព្រះបាទកៅណ្ឌិន្យ តាមភាសាចិនហៅថាព្រះបាទហ៊ុនទៀន ហើយព្រះអង្គបាននាំមកនូវសាសនា ព្រាហ្មណ៍។

ឆ្លងកាត់ប្រវត្តិសាស្ត្រសម័យកាលនោះ អាណាចក្រភ្នំមានឈ្មោះបោះសម្លេងលើដែនអាស៊ី និងអ៊ឺរុប និងមានទំនាក់ទំនងពាណិជ្ជកម្មរវាងបណ្តាប្រទេសក្នុងតំបន់អាស៊ី មានចិន ចម្ប៉ា ឥណ្ឌា និងអ៊ឺរុប(ដូចជាចក្រភពរ៉ូម៉ាំងនៅសម័យកាលនោះ ចក្រភពរ៉ូមមានអំណាចខ្លាំងខ្លា)។

### ១.១.៣ លក្ខណៈពិសេសនៃការរៀបចំក្រុងនាសម័យអង្គរ

#### ១.១.៣.១ ការរៀបចំក្រុងអង្គរ

ឋិតនៅចន្លោះប្រទេសធំពីចិននិងឥណ្ឌា ដែលមានខឿនអរិយធម៌រុងរឿងតាំងពីយូរលង់ណាស់មកហើយ អាណាចក្រខ្មែរបានទទួលឥទ្ធិពលផ្នែកប្បធម៌ នយោបាយ នយោបាយសេដ្ឋកិច្ច តាំងពីកំណរកំណើតប្រទេសដើមគ្រឹះសករាជមកម្លេះ ។ តាមរយៈប្រវត្តិសាស្ត្របានបញ្ជាក់អោយឃើញថាទីតាំងភូមិសាស្ត្រនេះបានផ្តល់នូវលក្ខណៈធម្មជាតិ លក្ខណៈសង្គមមានអំណោយផលដល់កំពូលនាសម័យអង្គរ ក្លាយជាមហាអំណាចមួយនៅតំបន់អាស៊ី។

អាណាចក្រនេះគ្របដណ្តប់ដោយព្រៃឈើតំបន់ភ្នំ និងខ្ពង់រាប គួបផ្សំនិងដំណាំស្រូវ និងដំណាំអាហារផ្សេងៗលាតសន្ធឹងលើផ្ទៃដីតំបន់ទន្លេមេគង្គ ទំនាបទន្លេមេណាម ដែលនាំដីល្បាប់ដ៏មានជីជាតិ និងធនធានធម្មជាតិដ៏សម្បូរបែប ។ ខ្យល់មូសុងប្រាំង និង មូសុងវស្សាបក់កាត់នាំមកនូវទឹកភ្លៀង និងបង្កើតនូវចរន្តទឹកក្តៅ ទឹកត្រជាក់ឆ្លាស់ប្តូរគ្នាសម្បូរដោយមច្ឆាជាតិទឹកសាប ទឹកប្រៃ និងពួកសត្វសមុទ្រ ច្រើនផ្សេងទៀតដែលកត្តានេះបានបង្ក លក្ខណៈឲ្យខ្មែរមានលក្ខណៈសម្បត្តិអំណោយផលដល់ការកសាងប្រទេសជាតិ។

បុព្វបុរសខ្មែរមានមនុស្សមានគំនិតច្នៃប្រឌិត ដោយបានរៀបចំបុរី ព្រមទាំងធ្វើនយោបាយកសិកម្ម ផ្អែកលើរបៀបចាត់ចែង ប្រព័ន្ធទឹក ជាមូលដ្ឋាន។ ការរៀបចំប្រទេសមានសន្តិភាពមានកំលាំងគ្រប់គ្រាន់ និងជំនឿមុតមាំលើសាសនា ។ នយោបាយទឹកនៅសម័យព្រះបាទឥន្ទ្រវរ្ម័ន មានលក្ខណៈផុសផុលខ្លាំងខ្លាមានព្រែកខ្វាត់ខ្វែងជាប្រព័ន្ធស្អែកស្កៈ និងមានបារាយ ព្រមទាំងគូទឹកផ្សេងៗជាគោល។ នៅពេលដែលព្រះបាទឥន្ទ្រវរ្ម័នបានឡើងសោយរាជ្យភ្លាម ព្រះអង្គបានចាត់ចែងការកសាងប្រាសាទមួយដែលមានទំហំ ៨០០មែត្រដោយយកទឹកមកពីស្ទឹងរលួស ។ បារាយនេះមានឈ្មោះឥន្ទ្រតាសដាក ។ ទឹកដែលយកមកពីបារាយនោះគឺសម្រាប់បម្រើឲ្យវិស័យកសិកម្មនៅរដូវប្រាំង ។ វិស័យកសិកម្មរីកចម្រើនជាពិសេសគឺការធ្វើស្រែប្រាំងបានច្រើនឥតមានទំនេរ ។

អាស្រ័យហេតុផលនេះហើយ បានធ្វើអោយសេដ្ឋកិច្ចប្រទេសមានការរីកចម្រើនលឿន សង្គមមានស្ថិរភាព មានអំណាចរឹងមាំ និងធ្វើឲ្យអាណាចក្រខ្មែរថ្កុំថ្កើងរុងរឿងដោយសារការរៀបចំនគរពេលនោះមានលក្ខណៈពិសេស ដោយប្រទេសផ្តោតការយកចិត្តទុកដាក់លើនយោបាយទឹក ។

ក្សត្រគ្រងរាជនៅសម័យអង្គរ ក្នុងរជ្ជកាលនៃព្រះមហាក្សត្រនីមួយៗក៏ដូចជាប្រជារាស្ត្រទូទាំងប្រទេសដែល គឺមានបំណងចង់ធ្វើអោយទីក្រុងកាន់តែមានសោភ័ណ្ឌភាពលើសដើមជានិច្ច ។ តាមរយៈសំណង់ស្ថាបត្យកម្មដែលបានបន្សល់ទុក និងស្លាកស្នាមដែលបានសេសសល់ដល់សព្វថ្ងៃ។

ព្រះរាជាលើកដំបូង មានគំនិតរៀបចំរាជធានីអោយទៅជាទីក្រុងមួយដ៏អស្ចារ្យអច្ឆិរយៈ នោះគឺព្រះបាទជ័យវរ្ម័នទី១ បានសេចក្តីថាក្រុងទីមួយដែលមានប្លង់ម៉ត់ចត់ ហើយមានន័យទូលំទូលាយស្របតាមលក្ខណៈលោកធាតុនៃព្រហ្មណសាសនា ។ ព្រះរាជាបន្តមកទៀត បានរៀបចំក្រុងយសោធបុរអោយកាន់តែប្រសើរ ដូចជាព្រះបាទជាជិន្ត្រវរ្ម័នបានវិលត្រលប់ពីកោះកេរ្តិ៍ដោយមកតាំងរាជធានីនៅយសោធបុរ ដែលមានសិលាចារឹកមួយ បានថែងថាព្រះអង្គបានរៀបចំក្រុងនេះអោយកាន់តែទំនើប និងល្អឡើង ដោយសារទ្រង់បានកសាងប្រាសាទមាសមួយដ៏ភ្លឺចិញ្ចាចបីដូចជាប្រាសាទព្រះមហិន្ត្រនៅលើផែនដី ។

នៅក្នុងរាជព្រះបាទសូរិយោវរ្ម័នទី១ សង្ហារបរិក្ខាក្រុងអង្គរត្រូវរងការខូចខាតជាច្រើនដោយសារសង្គ្រាមស៊ីវិលម្លោះហើយព្រះបាទបញ្ជារអោយគេរៀបចំជុសជុល លុះក្រោយនោះមកបន្តិចព្រះអង្គក៏មានព្រះតម្រិះឈ្វេងយល់ថា ត្រូវបង្កើតទីក្រុងថ្មីមួយទៀតដើម្បីតម្រូវការជីវភាពរបស់ប្រជារាស្ត្រនិងដើម្បីកិត្តិយសព្រះរាជសន្តិវង្សព្រះអង្គផង។

ហេតុដូចនេះព្រះអង្គបានចាត់អោយគេរៀបចំប្លង់ទីក្រុងអង្គរទី២ ដែលស្ថិតនៅចំកណ្តាលមានប្រាសាទធំមួយ ។ គម្រោងប្លង់ត្រូវបានសម្រេចដោយស្នាព្រះហស្ថរបស់ព្រះបាទឧទ័យទិនវរ្ម័នទី២ ។ ព្រះរាជាទាំងពីរព្រះអង្គនេះបានចាត់ចែងអោយគេស្ថាបនាបារាយមួយនៅខាងលិចទីក្រុងថ្មីគឺបារាយខាងលិច ដែលមានទំហំ ៨០០០ម៉ែត្រគុណនិង ២២០ម៉ែត្រ សម្រាប់យកទឹកប្រើប្រាស់កសិកម្មក្នុងគោលបំណងចិញ្ចឹមប្រជាជន ដែលរស់នៅទីក្រុងថ្មីរបស់ព្រះអង្គនាពេលបច្ចុប្បន្ននិងទៅអនាគត ។ ព្រះបាទសូរិយវរ្ម័នទី២ បានបន្តការរៀបចំក្រុងអង្គរនេះតទៀត ដោយទ្រង់បានសាងប្រាសាទមួយដ៏អស្ចារ្យគឺប្រាសាទអង្គរវត្ត ដែលនាំអោយទីក្រុងថ្មីនេះកាន់តែមានសម្រស់ឆើតឆាយថែមទៀត។ ស្នាមព្រះហស្ថជាដំបូងរបស់ព្រះបាទជ័យវរ្ម័នទី៧ ក្នុងចំនោមស្នាព្រះហស្ថទាំងឡាយគឺការស្ថាបនាក្រុងអង្គរទី២ សព្វថ្ងៃយើងហៅថាអង្គរធំ ។ ទីក្រុងថ្មីមួយនេះសាងសង់នៅលើទួលជាទីកន្លែងរបស់ទីក្រុងចាស់ អង្គរ ២ ដែលត្រូវបានទទួលរងនូវការវិនាសអន្តរាយ ដោយកងទ័ពចាមចូលវាយលុក បំផ្លិចបំផ្លាញនៅឆ្នាំ១១៧៧។ ដូចនេះទីក្រុងអង្គរជាទីក្រុងមួយដែលស្ថាបនាឡើងដោយឈរលើទស្សនបែបព្រហ្មនិយមផង និងបែបព្រះពុទ្ធសាសនាមហាយានផង។

### ១.១.៣.២ ការសាងសង់មន្ទីរពេទ្យ

មន្ទីរពេទ្យចំនួន ១០២ ត្រូវបានព្រះអង្គកសាង នៅតាមខេត្តខណ្ឌនានាក្នុងព្រះរាជាណាចក្រ មាននៅលើទឹកដីសៀមមួយផ្នែក ទុកសម្រាប់ទំនុកបំរុងព្យាបាលប្រជានុរាស្ត្រ។ សិលាចារឹកខ្មែរនៅប្រាសាទតាព្រហ្ម និងសាយហ្វុង ក្នុងប្រទេសឡាវ បានកត់ត្រារៀបរាប់អធិប្បាយយ៉ាងក្បោះក្បាយអំពីមន្ទីរពេទ្យទាំងនោះ ទាំងផ្នែកចាត់ចែងគ្រប់គ្រងផ្គត់ផ្គង់ ទាំងផ្នែកចំនាយ និងឈ្មោះថ្នាំសង្កូវ។ មន្ទីរពេទ្យនីមួយៗមានគ្រូពេទ្យ និងបុគ្គលិករាជការរាប់រយនាក់ ដែលមានភារៈកិច្ចជួយថែរក្សាព្យាបាលអ្នកជំងឺ ប្រជាពលរដ្ឋខ្មែរទាំង ៤វណ្ណៈ មានសិទ្ធិសេរីភាព អាចមកព្យាបាលរោគជំងឺនៅទីនេះបាន។

មន្ទីរពេទ្យព្រះបាទជ័យវរ្ម័នទី៧ បានស្ថិតស្ថេរគង់វង្សរហូតមកដល់សព្វថ្ងៃខ្លះដែរ ។ មុនសម័យកម្ពុជាកើតមានសង្គ្រាមនាឆ្នាំ១៩៧០ អ្នកស្រាវជ្រាវបារាំង បានឃើញមន្ទីរពេទ្យព្រះបាទជ័យវរ្ម័នទី៧ ចំនួន៣៣ ក្នុងមន្ទីរពេទ្យទាំង១០២។ គេសង្កេតឃើញក្រៅអំពីនៅក្នុងស្រុកខ្មែរ មានរូបរាងនៅប្រទេសលាវ ប្រទេសសៀម និងយួន ។

### ១.១.៣.៣ ការសាងសង់ធម្មសាលា និងសាលាសំណាក់

ធម្មសាលា ឬ សាលាសំណាក់ ក៏មានពាសពេញទឹកដីខ្មែរដែរ ព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គបានសង់សាលាសំណាក់ទាំងអស់១២១ នៅតាមផ្លូវឆ្ងាយ ដែលចេញពីមហានគរ ទៅទីក្រុងសំខាន់ៗក្នុងនគរ ។ សិលាចារឹកខ្មែរជាច្រើន បានបញ្ជាក់បង្ហាញជាសក្ខីភាព នៃការកសាងផ្លូវថ្នល់គមនាគមន៍ក្នុងរជ្ជកាលរបស់ព្រះអង្គ។សិលាចារឹកប្រាសាទព្រះខ័ន បានចារឆ្លាក់ថាៈ

- ពីព្រះរាជធានីនគរធំ ទៅទីក្រុងចំប៉ា មានធម្មសាលា ៥៧ ដែលសង់ហូរហែតាមផ្លូវ សំរាប់ជាកន្លែងឈប់សំណាក់ដល់អ្នកដំណើរ ធម្មសាលានីមួយៗ សុទ្ធតែមានភ្លើងសំរាប់បំភ្លឺ។
- ពីនគរធំ ទៅទីក្រុងភិម័យ មានធម្មសាលា១៧។
- ពីរាជធានីនគរធំ ទៅទីក្រុងជ័យវត្តី ពីជ័យវត្តី ទៅទីក្រុងជ័យសិង្ហវត្តី ពីក្រុងជ័យសិង្ហវត្តីទៅទីក្រុងជ័យវីរវត្តីពីជ័យវីរវត្តី ទៅទីក្រុងជ័យរាជគីរី ពីជ័យរាជគិរីទៅទីក្រុងសុវីរបុរៈ ហើយជាបញ្ចប់ពីសុវីរបុរៈទៅព្រះរាជធានីយសោធបុរៈឬនគរធំ ធម្មសាលាមានចំនួន៤៤ ដោយមានភ្លើងសំរាប់បំភ្លឺដែរ។
- ធម្មសាលាមានតែមួយប៉ុណ្ណោះ សំរាប់ទីក្រុងនីមួយៗ នៅស្រីសុរិយាបរព័ត ស្រីវិជ័យអាទិត្យបុរៈ និងកល្យានសិទ្ធិក ។

ធម្មសាលាទាំងនេះ បើយើងគិតទៅតាមចំងាយផ្លូវ សង់ចន្លោះឃ្លាតឆ្ងាយពីគ្នា ពី១២គ.ម ទៅ ១៨.៥០ គ.ម ។ នេះជាសក្ខីភាពបញ្ជាក់អំពីផ្លូវគមនាគមន៍ អំពីទំហំទឹកដី សកម្មភាពដំណើរ និងធ្វើជំនួញនៅប្រទេសកម្ពុជា នាសម័យសតវត្សទី១២ ។ ដូច្នេះហើយ បានជាព្រះមហាក្សត្រខ្មែរ ព្រះបាទជ័យវរ្ម័នទី៧ បានខំប្រឹងកសាងបណ្តាញសេដ្ឋកិច្ច ដើម្បីសំរួលដល់ជីវភាពរបស់បណ្តារាស្ត្រ ។ ធម្មសាលា ឬសាលាសំណាក់ព្រះបាទជ័យវរ្ម័នទី៧ មានសល់រហូតមកដល់បច្ចុប្បន្ន នៅលើទឹកដីកម្ពុជានៅប្រទេសលាវ សៀម និងយួន។

**១.១.៤. ការរៀបចំទីក្រុងរបស់ខ្មែរ និងទំនាក់ទំនងជាមួយទស្សនៈព្រាហ្មណ៍សាសនា ព្រះពុទ្ធសាសនា** (**នៅសម័យអង្គរ**)

ផ្តើមចេញពីទស្សនៈនេះ ខ្មែរយើងបានរកឃើញរូបមន្តមួយ ដែលតម្រូវឱ្យកសាង និងរៀបចំទីក្រុង តាមរបៀបរៀបចំក្រុងមានរបៀបតែមួយមិនសូវខុសគ្នាប៉ុន្មានទេ ទោះបីមានការរៀបចំក្រុងនៅតាមខេត្តក្តី ក៏ដូចនៅតាមយសោធបុរៈដែរ។ តាមធម្មតាប្លង់ទីក្រុងបែកចេញជាពីរប្លង់ប្រាសាទដែលឋិតនៅចំកណ្តាល ហើយប្រាសាទទាំងនេះត្រូវហ៊ុំព័ទ្ធដោយកំពែងមួយជាន់ ឬពីរជាន់ ឯនៅខាងក្រៅកំពែងមានគូរទឹកហ៊ុំព័ទ្ធមួយជាន់ថែមទៀត ។ ប្រសាទកណ្តាលតំណាងឱ្យភ្នំព្រះសុមេរុ មានន័យថា នៅសម័យនោះអ្នករៀបចំស្ថាបនាទីក្រុង បានឈរលើស្មារតីដោយយកទីក្រុងជាតំណាងឱ្យពិភពលោកទាំងមូល ដែលមានកំពែង ធ្វើអំពីថ្មបាយក្រៀម និងមានក្លោងទ្វាររៀបលាយជាមួយថ្មភក់ ឬជាការប្រមើលគន់គូរគិត និងសន្និដ្ឋានថា ជាជួរភ្នំចក្រវាឡដែលព័ទ្ធជុំវិញពិភពលោក ឯគូរទឹកតំណាងអោយ មហាសាគរ ។ ប្លង់ទីក្រុងទាំងនោះ តែងរៀបចំឡើងដោយមានគំនិតទាក់ទងទៅនឹងតារាវិទ្យា។ ជាទូទៅ កំពែងមានរាងបួនជ្រុងស្មើ ដោយមានកំពែងក្នុងនិងកំពែងក្រៅ ។ កំពែងក្នុងហៅថា កំពែងប្រាសាទ ឯកំពែងក្រៅហៅថា កំពែងវិស័យ ។ នៅចន្លោះកំពែងទាំងពីរគឺជាទីប្រជុំជន ។ ទីប្រជុំជនភូមិ គឺមានផ្ទះរបស់បណ្តារាស្ត្រប្រក់ស្លឹក ឬស្បូវ រួមមានវាលស្រែ និងចំការព្រមទាំងផ្លូវទឹកតូចធំ ។ នៅចំកណ្តាលនៃជ្រុងកំពែងនីមួយៗ មានផ្លូវក្រាលថ្មពុះជ្រុទាំងឡាយនោះទៅប្រសព្វមុខគ្នានៅទីប្រាសាទភ្នំ បានសេចក្តីថា មានបែងចែកផ្ទៃក្រឡាដីនៅក្នុងបរិវេណប្រសាទជាបួនភាគស្មើគ្នា។ ជាទូទៅនៅមិនឆ្ងាយប៉ុន្មានពីប្រសាទ ឬទីក្រុងមានការជីកបារាយណ៍ជីកត្រពាំងតូច ឬត្រពាំងធំ សំរាប់ផ្តល់ទឹកទៅឱ្យគូរទឹកដែលស្ថិតនៅជុំវិញប្រាសាទ ឬផ្តល់ទឹកទៅ

ឱ្យទីក្រុងទាំងនោះ មិនឱ្យទៅប្រាសាទដទៃទៀត ដែលស្ថិតនៅក្នុងបរិវេណទីក្រុងដូចជាអង្គរធំ ។ ការរៀបចំក្រុងធ្វើតាមរបៀបនេះ គឺដើម្បីឱ្យប្រជាពលរដ្ឋគ្រប់ៗគ្នា មានទឹកប្រើប្រាស់គ្រប់គ្រាន់សម្រាប់ធ្វើកសិកម្មផង និងមានទឹកសម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈផង ។ នៅក្នុងកំពែងអង្គរធំ លោក ជីវ ថាក្វាន់ (រាជទូតគោចរមកពីប្រទេសចិន) បានពិនិត្យមើលឃើញថា មានគេហដ្ឋានរបស់អ្នកស្រុកជាច្រើន សង់ឡើងដោយប្រក់ស្លឹក ឬប្រក់ស្បូវ (ព្រោះមិនហ៊ានប្រក់ក្បឿងទេ) ។ ចំពោះផ្ទះមន្ត្រីនាម៉ឺនៗគេហដ្ឋានសង់ឡើងសុទ្ធតែធំៗ និងមានប្រក់ក្បឿង (នេះក៏ជាការបង្ហាញឱ្យឃើញពីវណ្ណៈសង្គមដែលមាននៅសម័យអង្គរ) ។ ផ្ទះទាំងនេះ សង់ខ្ពស់ផុតពីដីដូចជាផ្ទះខ្មែរសម័យបច្ចុប្បន្ននេះដែរ ហើយតែងនិយមសង់បែរមុខទៅទិសខាងកើតទាំងអស់ ។ គេមិនបានដឹងពីរបៀបរៀបរយនៃបណ្តុំផ្ទះទាំងអស់នោះទេ តែគេគ្រាន់តែអាចដឹងថា ទំហំផ្ទះទាំងនោះត្រូវសង់ទៅតាមលំដាប់ឋានៈយសសក្តិនៃម្ចាស់ផ្ទះ ។ ចំពោះប្រាង្គប្រាសាទវិញ លោក ជីវ តាក្វាន់ លឺសូរគេនិយាយតែពីប្រាសាទមាស ប្រាសាទស្ពាន់ ។ល។ តែគេអាចដឹងខ្លះ ពីរបៀបរៀបរយនៃប្រាសាទទាំងនោះ ព្រោះមាននៅគង់វង្សរហូតដល់សព្វថ្ងៃនេះ។

ដោយសារស្ថានភាពដីនៅក្រុងអង្គរ ទេរបន្តិចចុះពីជើងឆ្ពោះមកត្បូង គឺខ្ពស់ជាងទិសឥសាន្ត និងទិសនិរតី អ្នករៀបចំក្រុងសម័យអង្គរបានរកឃើញមធ្យោបាយដើម្បីបង្ហូរទឹកកខ្វក់ ឬទឹកសំអុយចេញពីបរិវេណក្រុងតាមប្រឡាយជាច្រើនមកចាក់ចោលក្នុងត្រពាំងមួយហៅថា "បឹងធំ" ឋិតនៅជាប់ដំពែងខាងត្បូងឈៀងខាងលិច។ គេសង្កេតឃើញថា ក្រៅពីទិដ្ឋភាពដ៏បរិមានៃកំពែង ព្រមដោយ "គោបុរៈ" ទាំងប្រាំ និងលម្អរដ៏អស្ចារ្យនៃប្រាសាទសិលាទាំងឡាយនៅសម័យនោះ គេមិនអាចចាត់ទុក នគរធំ ថាជាក្រុងមួយដូចដែលយើងឃើញនោះទេ។ ប៉ុន្តែទោះបីទីប្រជុំជនជាច្រើន មានសភាពជាទីប្រជុំភូមិយ៉ាងណាក៏ដោយ ក៏ក្រុងអង្គរបានធ្វើឱ្យឈ្ងុញបរទេសជំនាន់ លោក ជីវ តាក្វាន់ និងបេសកសង្ឃព័រទុយហ្គេ អេស្ប៉ាញ៉ុលជាច្រើន នៅជំនាន់ក្រោយៗមកទៀត លាន់មាត់ស្ញើចសរសើរមិនមានដាច់ ។ ម្យ៉ាងទៀតអ្នកប្រាជ្ញសម័យបច្ចុប្បន្នជាច្រើន ដូចជា ព្យែរគូរ៉ូ (Pierre Gourou) ជាជនជាតិបារាំងបានកោតសរសើរពីកោសល្យដ៏អស្ចារ្យ នៃក្រុងអង្គរដែលចេះផ្សំជំនឿផ្នែកសាសនាជាមួយទ្រឹស្តីនយោបាយ ជាមួយផលិតផលវិទ្យាកសិកម្ម ឱ្យកើតចេញជារបៀបរៀបចំទឹកដីម្យ៉ាងដ៏ប៉ិនប្រសព្វ ទាំងនេះគឺជាគំនិតសំយោគមួយដែលពុំមានប្រជាជនណាលើលោកនេះអាចធ្វើបាន

ដូចទីប្រជុំជនក្រុងសម័យអង្គរ ក្រៅពីប្រាង្គប្រាសាទដែលជាស្ថាបត្យកម្មធ្វើអំពីសិលានោះ សំណង់ដែលជាលំនៅឋានរបស់ប្រជាជនភាគច្រើន សង់ឡើងនៅលើទីទួលធ្វើអំពីឈើ ឬស្សី ប្រក់ក្បឿង ឬស្លឹក ទៅតាមការបែងចែកវណ្ណៈសង្គមនាសម័យកាលនោះ តែសំណង់ទាំងនេះនៅបច្ចុប្បន្នមិនមាននៅសេសសល់ឡើយ ដោយសារសង្គ្រាម និងការបំផ្លិចបំផ្លាញ ដែលធ្វើឡើងពីសំណាក់ខ្មាំងសត្រូវ។ ផ្ទះសម្បែងត្រូវបានទទួលរងការដុតបំផ្លាញក៏ដូចជាត្រូវទទួលរងនូវការបាក់បែកពុកផុញ ដោយសារអាកាសធាតុត្រូពិចមូសុងក្តៅហើយសើម ដែលធ្វើឱ្យសំណង់ប្រភេទនោះ (ធ្វើអំពីឈើ ឬឬស្សី) ងាយនឹងរងនូវការពុកផុយបាក់បែកណាស់ មិនអាចមានជីវិតឋិតនៅរាប់សតវត្សបានឡើយ តែគេគ្រាន់តែអាចសន្និដ្ឋានថា ភូមិទាំងនោះច្រើនសាងសង់ឡើងលើទឹកដីទួល។ ដូចនេះអ្វីៗ ដែលមានបន្សល់ទុកឱ្យកូនចៅខ្មែរជំនាន់ក្រោយបានឃើញ និងដឹងឮសព្វថ្ងៃ គឺមានតែសំណង់ជាប្រាង្គប្រាសាទសិលាទេ ដែលនៅមានអាយុលើលោកយើងនេះ។

បច្ចុប្បន្នតាមការស្រាវជ្រាវផ្នែកបុរាណវិទ្យា បានបង្ហាញឱ្យកូនខ្មែរជំនាន់ក្រោយដឹងពីទីតាំងទាំងនោះ តាមរយៈកំណាយដែលគេសង្កេតឃើញមានសម្ភារៈមានជាឧបករណ៍ ដែលបុព្វបុរសជំនាន់នោះ បានប្រើប្រាស់ ចាន ឆ្នាំង ក្អម....និងសំណល់ដែលសល់ពីការហូបចុកដូចជា ឆ្អឹងសត្វ ឆ្អឹងត្រី....ឆ្អឹងជាសំណល់សាកសពមនុស្សជាដើម ។ នៅព្រះរាជាណាចក្រកម្ពុជាមានស្ថានីយបុរេប្រវត្តិសាស្ត្រ និងស្ថានីយប្រវត្តិសាស្ត្រជាច្រើន ដែលបានបង្ហាញពីភស្តុតាងនៃការរស់នៅរបស់បុព្វបុរសខ្មែរសម័យកាល តាំងពីរាប់ពាន់ឆ្នាំមុនគ្រិស្តសករាជ ដូចជាស្ថានីយបុរេប្រវត្តិសាស្ត្រនៅល្អាងស្ពានជាដើម ដែលបច្ចុប្បន្នក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកំពុងបន្តធ្វើការសិក្សានិងស្រាវជ្រាវ។

## ១.១.៥. នគររូបនីយកម្ម និងស្ថាបត្យកម្មនៅកម្ពុជាតាមសម័យកាល

### ១.១.៥.១ សម័យមុនអង្គរនិងសម័យអង្គរ

តាមសិលាចារិក ក៏ដូចជាឯកសារស្រាវជ្រាវប្រវត្តិសាស្ត្រ បានបង្ហាញឲ្យឃើញពីទេពកោសល្យរបស់កូនខ្មែរ និងបានបន្សល់ទុកនូវស្នាដៃដ៏ច្រើនលើសលុប តាំងពីសម័យមុនអង្គរ និងសម័យអង្គរ ដែលសព្វថ្ងៃគេឃើញមានប្រាសាទមួយចំនួនធំនៅសេសសល់រហូតដល់សព្វថ្ងៃ មានប្រាសាទភ្នំជា ប្រាសាទបាយ័ង់ នៅខេត្តតាកែវ និងប្រាសាទសម្បូរណ៍ព្រៃគុហ៍ នៅខេត្តកំពង់ធំជាដើម ។ អ្វីដែលជាភស្តុតាងបន្សល់ទុកដើម្បីឲ្យបុរាណវិទូអាចធ្វើការស្រាវជ្រាវ និងសម្រាប់យកទៅធ្វើការវិភាគបាន

នោះគឺកូនខ្មែរមានទេព្យកោសល្យខ្ពស់ខាងសំណងស្ថាបត្យកម្ម និងចម្លាក់ ដោយបានសាងសង់ប្រាសាទធ្វើអំពីដីឥដ្ឋដុត និងជាពិសេសថ្មភក់ ឬថ្មក្រៃ ថ្មបាយក្រៀម ឬថ្មក្រានីត យកមករៀបបន្ទុបត្រួតពីលើគ្នា ស្ថាបនាបានជាប្រាង្គប្រាសាទ និងមានឆ្លាក់ជាក្បាច់លោត ឬក្បាច់ផុស ដោយបង្ហាញជារឿងតាមទេវកថា ឬជារឿងរាវដែលស្តែងចេញ ពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរសម័យនោះ ឬជាប្រវត្តិសង្គ្រាមដែលបានកើតឡើងជាមួយប្រទេសចម្ប៉ាជាដើម ។ ស្នាដៃចម្លាក់ទាំងនោះ បានទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិឲ្យជាប់ចិត្តជិតអារម្មណ៍ និងគយគន់មិនជិនណាយ ពីភាពរស់រវើកនៃក្បាច់ចម្លាក់ជារឿងរ៉ាវទាំងនោះ។

តាមរយៈស្នាដៃដែលបុព្វបុរសខ្មែរបានបន្សល់ទុកនៅសម័យអាណាចក្រខ្មែរ បានបង្ហាញឲ្យឃើញពីធនធានមនុស្សខ្មែរ ប្រកបដោយទេព្យកោសល្យ និងមានគំនិតឆ្នៃប្រឌិតខ្ពស់ ។ នៅតំបន់ភ្នំគូលែន ឬនៅប្រាសាទព្រះវិហារ បុព្វបុរសយើងបានយកថ្ម ដែលមានទម្ងន់រាប់សិបម៉ឺនតោនមកតម្រៀបបន្ទុបលើគ្នាបង្កើតបានជាប្រាសាទភ្នំ ដោយគ្មានប្រើដែកមួយសរសៃណាឡើយ ។ នេះជាគំនិតច្នៃប្រឌិតខ្ពស់បង្ហាញពីសមត្ថភាព និងគំនិតប្រាជ្ញាផ្នែករូបសាស្ត្រ គណិតសាស្ត្រ ដែលស្ថាបត្យករខ្មែរមានទេព្យកោសល្យក្នុងការរកទីប្រជុំទម្ងន់ ដើម្បីរក្សាលំនឹងនៃតួប្រាង្គប្រាសាទទាំងនោះ ដែលមានទម្រង់សុទ្ធសឹងជាប្រាសាទភ្នំ មានកំពូលស្រួច កាន់តែឡើងទៅលើខ្ពស់ នោះកំពូលប្រាសាទកាន់តែស្តួចទៅៗ សំដៅភ្ជាប់ឋានមនុស្សលោកនិងឋានសួគ៌នៃព្រះអាទិទេព។

វិស្វករ និងស្ថាបត្យករខ្មែរ បានកសាងប្រាសាទពាសពេញផ្ទៃប្រទេស ដោយសុទ្ធតែប្រើនូវទម្រង់ធរណីមាត្រទាំងអស់ ដែលមានរាងចតុកោណកែង ឬចតុកោណកែងស្មើ ។ ប្រាសាទកណ្តាលរបស់អង្គរវត្ត មានកម្ពស់ប្រហែល ៥៥ម៉ែត្រ និងជុំវិញប្រាសាទទាំងអស់ មានពង្រឹងដោយកំពែងការពារធ្វើពីថ្មបាយក្រៀម និងបារាយណ៍ទឹកព័ទ្ធជុំវិញដែលមានប្រវែង ៥,៥គីឡូម៉ែត្រ មិនមានប្រព័ន្ធធារាសាស្ត្រស៊ាំញ៉ាំ មានព្រែកជីក អាងស្តុកទឹកសម្រាប់ស្រោចស្រព និងផ្គត់ផ្គង់ទឹកដល់ប្រជាជនដែលរស់នៅជុំវិញទីក្រុងអង្គរបុរាណនេះ ។ អាងស្តុកទឹកធំជាងគេ មានទំហំ ៨គីឡូម៉ែត្រ គុណនឹង ២,២គីឡូម៉ែត្រ ដែលមានសមត្ថភាពស្តុកទឹកទុក ប្រហែល៧០លាអនម៉ែត្រគ្រីគុណ។ តំបន់នេះជារាជធានីមួយ ដែលនៅតែបង្ហាញពីភាពថ្កុំថ្កើងរុងរឿង នៃអាណាចក្រអង្គរកាលពីសតវត្សទី៨ ដល់សតវត្សទី១៣។

នៅតាមអ័ក្សនីមួយៗ មានអមដោយស្រះតូចៗរាងជាការ៉េ ។ ជាទូទៅប្រាសាទនានាសាងសង់ឡើងសុទ្ធតែផ្អែកលើលក្ខណៈវិទ្យាសាស្ត្រ បើមិនដូច្នោះទេប្រាសាទទាំងនោះនឹងបើមិនដូច្នោះទេប្រាសាទទាំងនោះនឹងមិនអាចទ្រាំទ្រនូវទម្ងន់ថ្មដ៏ធ្ងន់រាប់សិបតោន និងមិនអាចឋិតនៅគង់វង្សរាប់សតវត្សបានឡើយ។

ចំពោះការជ្រើសរើសទីតាំងក្នុងការសាងសង់ប្រាសាទ សុទ្ធតែសមប្រកបនឹងសណ្ឋានដីដែលទាក់ទងទៅនឹងភូគម្ពសាស្ត្រ ដោយមិនធ្វើឱ្យស្រុតខូចទម្រង់ប្រាសាទ ឬកំពូលប្រាសាទ្រេតសោះឡើយ ។ មិនតែប៉ុណ្ណោះ វិស្វករ និងស្ថាបត្យករខ្មែរ បានប្រើប្រាស់ភាពប៉ិនប្រសប់របស់ខ្លួនដែលជាទូទៅគេសង្កេតឃើញថា ប្រាសាទនីមួយៗ មានលក្ខណៈស៊ីមេទ្រីគ្នា និងបង្អួតរាងល្អឥតខ្ចោះតាមបែបធរណីមាត្រ រំលេចដោយក្បាច់បង្កប់ និងក្បាច់ផុសរស់រវើក។ស្ថាបត្យកម្មទាំងនេះបានបង្ហាញពីភាពរុងរឿងដ៏អស្ចារ្យនៃអាណាចក្រខ្មែរកាលពីសម័យនោះដែលកើតមានពីបញ្ញាញាណច្នៃប្រឌិតខ្ពស់ល្អឯកគ្មានពីរលើលោក និងកំពុងពញ្ញាក់ស្មារតីដាស់អារម្មណ៍មនុស្សជាតិឱ្យកោតសរសើរស្ញប់ស្ញែង និងស្ងើចសរសើរមិនដាច់ពីមាត់នូវស្នាដៃដ៏អស្ចារ្យនេះ។

### ១.១.៦ ប្រាសាទនានាដែលសាងសង់នៅសម័យអង្គរ

ក្នុងប្រវត្តិសាស្ត្រខ្មែរ ព្រះបាទជ័យវរ្ម័ទី៧ ជាព្រះមហាក្សត្រដែលបានសង់ប្រាង្គប្រាសាទជាច្រើនជាងក្សត្រឯទៀត ។ ប្រាសាទទាំងនោះច្រើនស្ថិតនៅជិតឬក្នុងរង្វង់នគរធំថ្មីដែលព្រះអង្គទើបតែសំរេចចិត្តកសាង។

នគរធំ ឬមហានគរ ដែលត្រូវឆេះបាក់បែកខូចអន្តរាយអស់ជាច្រើន ត្រូវបានព្រះបាទជ័យ-វរ្ម័នទី៧ រៀបចំចាត់ចែងឱយកសាងជាថ្មី ។ នេះជាលើកទី៣ហើយ ដែលមហានគរត្រូវសាងសង់នគរធំរបស់ព្រះបាទជ័យវរ្ម័ទី៧ ត្រូវបានគេចាត់ទុក ជាស្នាដៃឯកប្លែកខុសពីធម្មតា ដែលមានក្នុងសិល្បៈខ្មែរ ។ គឺខ្មែរជំនាន់នោះបានប្រឌិតបង្កើតសិល្បៈថ្មីមួយ ដែលវិវត្តទៅតាមចលនារបស់សង្គមជាតិ។ នគរធំ ដែលស្ថិតនៅរៀងរហូតមកដល់សព្វថ្ងៃ ជាស្នាដៃយ៉ាងធំធេងចំបងរបស់ព្រះបាទជ័យវរ្ម័នទី៧។

នគរធំ ឬមហានគរ មានជ្រុងនីមួយៗ ប្រវែង៣គីឡូម៉ែត្រ ហើយមានទំហំប្រហែល៩គីឡូម៉ែត្រក្រលា នគរធំមានកសិណ(២) ដែលមានទទឹងប្រវែង ១០០ម និងជំរៅ ៥ម ទៅ ៦ម ព័ទ្ធជុំវិញ ដើម្បីចូលទៅក្នុងមហានគរ គេត្រូវឆ្លងកាត់ស្ពានថ្ម អមទៅដោយរូបចំលាក់ទេវតា និងយក្ខ

ដែលកំពុងនាំគ្នាទាញនាគសុវកិ ទេវតា និងយក្ស ម្ខាងៗមានគ្នា ៥៤នាក់ បន្ទាប់មកយើងចូលមកដល់ខ្លោងទ្វារមហានគរ ដែលនៅខាងលើមានរូប ព្រះលោកេស្វរៈ។ ជ្រុងនីមួយៗមានខ្លោងទ្វារមួយនៅចំកណ្តាល បែរទៅទិសទាំងបួន។ លើកលែងតែជ្រុងខាងកើត ដែលមានទ្វារពីរ គឺទ្វារជ័យមួយទៀត ដែលចាក់ចំទៅរកប្រាសាទភិមានអាកាស។ តាមខ្លោងទ្វារទាំងបួនទិស មានផ្លូវ៤ ទៅជួបគ្នាកាត់ចំកណ្តាលទីក្រុងនគរធំ ដែលនៅទីនោះព្រះបាទជ័យវរ្ម័នទី៧ បានសាងប្រាសាទមួយដែលមានលក្ខណខុសប្លែកពីប្រាសាទមុនៗ។ តភ្ជាប់នឹងខ្លោងទ្វារ មានជញ្ជាំងថ្មយ៉ាងខ្ពស់សំរាប់ការពារទីក្រុង ដែលគេអាចដើរយាមកាមចុះឡើងបាន ។ នៅជាប់កំផែងនោះ មានប្រលាយទឹកតូចមួយទៀត ព័ទ្ធជុំវិញមហានគរ ហើយហូរភ្ជាប់ចូលទៅក្នុងស្រះធំមួយឈ្មោះ បឹងធំ ដែលមានបណ្តោយប្រវែង ៤០០ម និងទទឹង ២០០ម។

ដោយសំអាងទៅតាមទំហំដីស្រែចំការនៅជុំវិញ ដែលមានបញ្ជាក់នៅក្នុងសិលាចារឹក ដោយយោងទៅតាម នយោបាយទឹករបស់ព្រះមហាក្សត្រខ្មែរ ដែលមានចំនួនបារាយ ស្រះព្រែក និងគូជាច្រើន បូករួមទាំងប្រជាជន ដែលប្រកបមុខរបរផ្សេងទៀតផង នគរធំ ឬមហានគរត្រូវមានប្រជាពលរដ្ឋប្រហែលពី ៧០០.០០០ - ៧៥០.០០០ នាក់។ នេះជាការគន់គូរប៉ាន់ស្មានរបស់អ្នកប្រវត្តិវិទូរ និង អ្នកបុរាណវិទ្យា។

តាមអ្នកឯកទេស ដែលសិក្សាអំពីបូរាណវិទ្យា នគរធំត្រូវបានសង់ទៅតាមបែបផែន ទ្រឹស្តីព្រះពុទ្ធសាសនា ទស្សនៈអ្នកកាន់ព្រះពុទ្ធសាសនាយល់ថា នៅកណ្តាលចក្រវាល មានភ្នំមួយយ៉ាងធំដែលលោកអោយឈ្មោះថា ភ្នំព្រះសុមេរុ ភ្នំនេះមានកំពូលប្រាំ ហើយនៅលើកំពូលភ្នំមានមានស្ថានសួគ៌បីជាន់។ ឯការសាងសង់នគរធំ ក៏មានលក្ខណៈដូចគ្នានេះដែរ គឺជាទីក្រុងមួយរាងបួនជ្រុងដែលនៅចំកណ្តាល មានប្រាសាទមួយទៀត ជាតំណាងភ្នំព្រះសុមេរុ ប្រាសាទនេះគឺប្រាសាទបាយ័នដែលខ្មែរច្រើនហៅថា ព្រហ្មយ័ន។

ប្រាសាទបាយ័ន គឺជាឈ្មោះប្រាសាទថ្មី ដែលព្រះអង្គបានសង់ឡើងសំរាប់ឧទ្ទិសថ្វាយជូនចំពោះព្រះពុទ្ធសាសនា ។ ប្រាសាទបាយ័នបែរមុខទៅទិសខាងកើតមាន បណ្តោយប្រវែង ១៤០ម ទទឹង ១៣០ម មានកំពូល ៥៤ ដូចចំនួនទេវតា និងយក្ស ដែលយាមតាមស្ពានចូលនគរធំ ។ កំពូលកណ្តាល ដែលខ្ពស់ជាគេ មានកំពស់៤២ម ។ កំពូលនីមួយៗមានរូបចំលាក់ព្រះលោកេស្វរៈ

ព្រះភ័ក្ត្របួន ដែលខ្មែរសាមញ្ញនិយមហៅថាព្រះព្រហ្ម ។ ដូច្នេះលើប្រាសាទបាយ័ន មានព្រះភក្ត្រលោកេស្វរៈទាំងអស់ ២១៦ ដែលញញឹម បែរសំលឹងមើលទៅរកកូនចៅខ្មែរ និងត្រៀមខ្លួនប្រុងប្រយ័ត្ន ចាំថែរក្សាការពារគនរកម្ពុជា ទប់ទល់ប្រឆាំងនឹងខ្មាំងសត្រូវគ្រប់ទិសទី ។

លក្ខណៈប្រាសាទបាយ័នមួយទៀត ដែលខុសប្លែកអំពីប្រាសាទជំនាន់មុន គឺស្ថិតនៅត្រង់សិល្បករខ្មែរ បានយកទិដ្ឋភាពជីវភាពរស់នៅក្នុងសង្គមខ្មែរសង្គ្រាមរវាងខ្មែរនឹងចាម និងទស្សនៈសាសនាមកឆ្លាក់ដាក់ថ្មីម ក្នុងបរិវេនជាមួយគ្នា តាមចំលាក់ទាំងនោះ គេអាចឃើញនូវទំនាក់ទំនងជិតជាប់គ្នារវាងព្រះពុទ្ធ ស្ថានសួគ៌ និងលោកិយ។ ដែលជាទិដ្ឋភាពមួយមិនធ្លាប់មានក្នុងរូបចំលាក់ជំនាន់ដើម ដែលលើកយកតែប្រវត្តិព្រះអាទិទេព និងទេវកថាផ្សេងៗ មកបកស្រាយ។

ប្រាសាទតាព្រហ្ម ប្រាសាទព្រះខ័ន ប្រាសាទបន្ទាយក្តី ប្រាសាទតាសោម ប្រាសាទនាគព័ន្ធ ស្រះស្រង់ ប្រាសាទទាំងនេះនៅសៀមរាប ប្រាសាទព្រះខ័នកំពង់ស្វាយខេត្តកំពង់ធំ ប្រាសាទបន្ទាយឆ្មារ បាត់ដំបង ប្រាសាទភិម័យ នៅប្រទេសសៀមសុទ្ធសឹងជាស្នាដៃដ៏សំខាន់ដែលព្រះបាទជ័យវរ្ម័នទី៧ បានកសាង ។ ព្រះបាទជ័យវរ្ម័នទី៧ បានឧទ្ទិសប្រាង្គប្រាសាទទាំងនោះថ្វាយជូនទៅមាតាបិតា ជីដូនជីតា គ្រូបាធ្យាយ អ្នកប្រាជ្ញ និងវិរបុរសខ្មែរជាច្រើនដែលធ្លាប់មានគុណបំណាច់មកលើប្រទេសជាតិ ។ នៅតាមប្រាសាទ គេសង្កេតឃើញព្រះបដិមាករ និង រូបចំលាក់ខ្លះមានព្រះភក្ត្រមុខមាត់ ដូចតួអង្គដែលគេគោរពបូជា និងរំលឹក។

## ១.២ ការរៀបចំនាសម័យសង្គមរាស្ត្រនិយម

បន្ទាប់ពីបានទទួលឯករាជ្យពីបារាំងរួចមករាជធានីភ្នំពេញ ទទួលបានការរីកចម្រើនជាខ្លាំងក្រោមការដឹកនាំរបស់ ព្រះបរមរតនកោដ្ឋ ព្រះនរោត្តម សីហនុ បើទោះបីជាប្រទេសកម្ពុជាទើបតែផុតពីអាណានិគមបារាំងយូរឆ្នាំក៏ដោយ ក៏ប្រទេសកម្ពុជាទទួលបានការអភិវឌ្ឍន៍ជាច្រើនពីសំណាក់ប្រទេសបារាំងទាំងហេដ្ឋារចនាសម្ព័ន្ធ និងអាគារសាធារណៈផ្សេងៗទៀត។

### ១.២.១ ប្លង់គោលអភិវឌ្ឍន៍រាជធានី

ដោយយោងតាមការស្រាវជ្រាវព្រះរាជាណាចក្រកម្ពុជានៅសម័យនោះ គឺមានតែប្លង់គោលឆ្នាំ១៩៥០ តែមួយគត់ដែលបានអនុម័តជាផ្លូវការដោយក្រសួងកសិកម្មនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៥០ ។ ហើយនៅក្នុងឆ្នាំ១៩៧០ មានការិយាល័យនគរូបនីយកម្មដឹកនាំដោយលោក **លុយ បានហាប់** ក៏មានបំណងរៀងចំកែប្រែ និងពង្រីកទីក្រុងភ្នំពេញបន្ថែមទៀតប៉ុន្តែមិនបានសម្រេច។ ហើយតំបន់

អទិភាពក្នុងការអភិវឌ្ឍដំបូងបង្អស់ក្នុងសម័យនោះនៃរាជធានីភ្នំពេញ គឺបានចាប់ផ្ដើមនៅក្នុងតំបន់ទន្លេបាសាក់ដោយមានការកសាងសង់ជាផ្ទះថ្មីៗនិងកន្លែងសាធារណៈផ្សេងៗជាច្រើន។ម៉្យាងទៀត តំបន់ខ្ពស់រាបនៅជុំវិញបឹងទន្លេសាបភាគខាងលិចនៃរាជធានីគឺស្ថិតនៅក្រោមកំរិតទឹកទន្លេ។ ដូច្នេះ តំបន់នៅខាងមុខមាត់ទន្លេ ត្រូវបានកំណត់ជាតំបន់ដែលត្រូវអភិវឌ្ឍមុនគេបង្អស់ដោយសារតែវាជាតំបន់ខ្ពង់រាប ហើយអាចធ្វើជាគំរូល្អសម្រាប់ទីក្រុងទាំងមូល។

**១.២.២ សមិទ្ធផលនានាក្នុងការអភិវឌ្ឍន៍រាជធានីនាសម័យសង្គមរាស្ត្រនិយម**

ក្នុងអំឡុងពេលឆ្នាំ ១៩៥០ ដល់១៩៦០ រាជធានីភ្នំពេញមានចំនួនប្រជាជនសរុបមិនលើសពី ៤០០,០០០នាក់នោះទេ ប៉ុន្តែរាជធានីភ្នំពេញត្រូវបានគេចាត់ទុកជាទីក្រុងថាជាទីក្រុងជឿនលឿនបំផុតមួយក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយជាទីក្រុងដែលមានការច្នៃប្រឌិតខ្ពស់ប្រកបដោយផែនការច្បាស់លាស់។ លោក **វណ្ណ ម៉ូលីវណ្ណ** ដែលជាស្ថាបត្យករដ៏ល្បីល្បាញជាអន្តរជាតិបានរចនាផែនការប្លង់មេសម្រាប់រាជភ្នំពេញ។ គំនិតជាមូលដ្ឋាននៃផែនការបង្កើតឡើងវិញនេះគឺដើម្បីធ្វើការសាងសង់អាគារទំនើបទាន់សម័យច្រើន ដោយប្រើប្រាស់ស្ថាបត្យកម្មប្រពៃណីខ្មែរបញ្ចូលគ្នាជាមួយរចនាបថរបស់បារាំង។ ហេដ្ឋារចនាសម្ព័ន្ធជាច្រើននៅក្នុងទីក្រុងនេះត្រូវបានកសាងឡើងដូចជាវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សាលារៀន សារមន្ទីរជាតិ ដែលត្រូវបានបង្កើតឡើងនៅក្នុងរាជធានីភ្នំពេញក្នុងសម័យឯករាជ្យដែលជាទីក្រុងគុជនៅតំបន់អាស៊ីអាគ្នេយ៍ក្នុងឆ្នាំ១៩៥០ និង១៩៦០ ហើយរាជធានីនេះត្រូវបានពង្រីកកាន់តែធំទៅតាមផែនការស្ថាបត្យកម្មយ៉ាងល្អ នៅក្រោយពេលដែលបានសិក្សាដោយជនជាតិសិង្ហបុរី ហើយស្ថាបត្យកររូបនេះបានយកគម្រោងសម្រាប់ការអភិវឌ្ឍទីក្រុងសិង្ហបុរី។ រាជធានីភ្នំពេញនេះជាទីក្រុងសំខាន់របស់ប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៦០ ដែលការសាងសង់ត្រូវបានធ្វើឡើងជាមួយនឹងការរចនាច្នៃប្រឌិតដោយលោក **វណ្ណ ម៉ូលីវណ្ណ** និងស្ថាបត្យករផ្សេងទៀតសម្រាប់ការកសាងអគារខ្ពស់ៗនៅតាមបណ្ដោយមហាវិថីព្រះមុនីវង្ស លំនៅដ្ឋានថ្មីរបស់ទីក្រុងនៅទូទាំងរាជធានីភ្នំពេញ (ប្រព័ន្ធខ្យល់អាកាសល្អ, ប្រព័ន្ធលូបង្ហូរល្អ, ស្តង់ដារសម្រាប់ការរស់នៅ និងគួរឱ្យចាប់អារម្មណ៍ជានេះទៀតនោះគឺមានដូចជាវិមានឯករាជ្យ ពហុកីឡាដ្ឋានអូឡាំពិច វត្តភ្នំ ផ្សាររុស្ស៊ី (ផ្សារទួលទំពូង) ស្ពានមិត្តភាពសម័យទំនើបរបស់ជប៉ុននៅប្រទេសកម្ពុជា ធនាគារជាតិកម្ពុជា សួនច្បារ ស្ពានព្រះមុនីវង្ស ព្រលានយន្តហោះពោធិ៍ចិនតុង (សព្វថ្ងៃប្រលានយន្តហោះអន្តរជាតិភ្នំពេញ)

សាលចតុមុខ មហោស្រពទន្លេបាសាក់ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP)។ ក្នុងនោះផងដែរ សកម្មភាពសេដ្ឋកិច្ចនយោបាយ និងវប្បធម៌ជាមួយបណ្តាទីក្រុងផ្សេងទៀត នៅក្នុងតំបន់អាស៊ី-អាគ្នេយ៍ ហើយរាជធានីភ្នំពេញទាក់ទង ភ្ញៀវទេចរបរទេសឱ្យរីករាយជាមួយនឹងជីវិតនៅក្នុងរាជធានីភ្នំពេញបន្ទាប់ពីក្រុងអង្គរដោយភាគច្រើន នៃក្រុមហ៊ុនបរទេស ដូចជាក្រុមហ៊ុនបារាំងដែលមានអារម្មណ៍ថាមានទំនុកចិត្តក្នុងការ ជ្រើសយករាជធានីភ្នំពេញដើម្បីប្រតិបត្តិការមុនជំនួយរបស់ពួកគេ ឧទាហរណ៍: ក្រុមហ៊ុន Air France ដែលជាក្រុមហ៊ុនមួយប្រតិបត្តិការសេវាដឹកជញ្ជូនផ្លូវអាកាសនៅក្នុងចំណោមក្រុមហ៊ុនដែលបារាំងបានដាក់ក្នុងអំឡុងពេលនោះដោយប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅក្នុងរាជធានីភ្នំពេញបានយ៉ាងល្អ ។ ដោយស្ថិតនៅក្នុងភាពនៃសន្តិភាព និងភាពរីកចម្រើនរបស់ទីក្រុងភ្នំពេញនៃប្រទេសកម្ពុជា ទើបគេប្រសិទ្ធិនាមក្នុងរបបសង្គមរាស្ត្រនិយមថាជារបបនៃកោះសន្តិភាព ដោយបានកសាងវិស័យការទូតយ៉ាងល្អ និងមានការទុកចិត្តនៅក្នុងឆាកអន្តរជាតិ។

អាគារគំរូមួយចំនួនដែលលេចធ្លោក្នុងចន្លោះឆ្នាំនេះរួមមានដូចជា៖

**១.១ វិមានឯករាជ្យ**



វិមានឯករាជ្យ (ភាសាអង់គ្លេស: Independence Monument) ត្រូវបានកសាងនៅឆ្នាំ១៩៥៨ ក្នុងរាជ្យព្រះបាទនរោត្តម សុរាម្រិត(១៩៥៥- ១៨៦០) ជានិមិត្តរូបបញ្ជាក់ថា កម្ពុជាបានទទួលឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ ។ វិមានឯករាជ្យមានទីតាំងស្ថិតនៅផ្លូវប្រសព្វគ្នារវាងមហាវិថីព្រះនរោត្តម និងមហាវិថីព្រះសីហនុ ចំកណ្តាលទីក្រុង ភ្នំពេញ ។ វិមានឯករាជ្យមានទីតាំងស្ថិតនៅផ្លូវប្រសព្វគ្នារវាងមហាវិថីព្រះនរោត្តម និងមហាវិថីព្រះសីហនុ ចំកណ្តាលទីក្រុង ភ្នំពេញ។ វិមានឯករាជ្យមានកំពស់ ២០ម៉ែត្រ មាន៥ជាន់ លំអដោយក្បាលពស់នាគរាជចំនួន១០០សង់តាមគំរូរចនាបថរបស់អង្គរ ហើយធ្វើការរចនាប្លង់ដោយស្ថាបត្យករខ្មែរដ៏ល្បីល្បាញគឺលោក **វណ្ណ មូលីវណ្ណ**

នៅចុងឆ្នាំ២០០៧ សាលាក្រុងភ្នំពេញ បានស្ថាបនាកែលំអវិមានឯករាជ្យឱ្យមានសម្រស់កាន់តែប្រសើរឡើងថែមមួយកំរិតទៀត គួរជាទីទាក់ទាញ ដែលការកែរលំអរនេះចំនាយថវិកាអស់ប្រហែល៥០០លានរៀល។

### ១.២ សាលសន្និសិទ្ទចតុមុខ



<u>**សាលសន្និសិទ្ធិចតុមុខ (សាលមហោស្រពចតុមុខ) ក្នុងឆ្នាំ១៩៦១**</u>

សាលាសន្និសិទ្ធចតុមុខត្រូវបានរចនាដោយស្ថាបត្យករ **វណ្ណ ម្ខលីវណ្ណ** ហើយទីកន្លែងនេះត្រូវបានបើក អោយប្រើប្រាស់ជាលើកដំបូងក្នុងឆ្នាំ១៩៦១ ហើយបានដាក់ឈ្មោះថា "សាលសន្និសិទ្ធិចតុមុខ" ។ ហើយវាបានធ្វើអោយព្រះមហាក្សត្រគាប់ព្រះហឫទ័យយ៉ាងខ្លាំងដែលបានសាងសាលសន្និសិទ្ធិនេះឡើង ។ ម្យ៉ាងទៀតវាត្រូវបានបង្កើតឡើងដោយលំនាំទៅតាមការរចនាបថបែបប្រពៃណី នៃប្រាសាទខ្មែរបុរាណ និងស្ថិតនៅជិតព្រះបរមរាជវាំងហើយនៅជាប់នឹងមាត់ទន្លេដែលអាចមើលឃើញភាពប្រសព្វទន្លេចតុមុខនេះទៀតផង។

**១.៣ ធនាគារជាតិនៃកម្ពុជា**



<u>**ធនាគារជាតិកម្ពុជាក្នុងឆ្នាំ១៩៥៤**</u>

ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥៤ បន្ទាប់ពីប្រទេសជាតិបានទទួលឯករាជ្យ ពីអាណានិគមនិយមបារាំង និងបន្ទាប់ពីវិជ្ជាស្ថាន បោះប្រាប់ឥណ្ឌូចិនត្រូវបានបិទទ្វារ ។ ធនាគារជាតិនៃកម្ពុជាបានផ្សាយប្រាក់រៀលឯករាជ្យរបស់ខ្លួនដើម្បីបញ្ចប់ជាស្ថាពរនូវសម្ព័នភាពជាមួយប្រាក់វៀតណាមនិង ឡាវ ។ ពេលនោះប្រព័ន្ធធនាគារក្នុងប្រទេសត្រូវបានបង្កើតឡើងដោយមាន ធនាគាររដ្ឋ និងធនាគារឯកជនធ្វើប្រតិបត្តិការទន្ទឹមគ្នាលើដែនដីប្រទេស

កម្ពុជា ។ ហើយក្រោយមកទៀតនៅឆ្នាំ១៩៦៤ ដើម្បីបំរើឱ្យគោលនយោបាយកសាងជាតិនៃសង្គមរាស្ត្រនិយមរដ្ឋបានធ្វើ ការកែទម្រង់ ប្រព័ន្ធធនាគារជាបន្តបន្ទាប់ដើម្បីតម្រូវទៅតាមសេចក្តីត្រូវការនៃសេដ្ឋកិច្ចជាតិនាសម័យនោះដោយបានប្រែក្លាយធនាគារជាតិ នៃកម្ពុជាពីទម្រង់ស្ថាប័នពាក់កណ្តាលស្វ័យតទៅ ជាធនាគាររដ្ឋក្រោមទម្រង់ស្ថាប័នសាធារណៈដែល មានលក្ខណៈឧស្សាហកម្មនិងពាណិជ្ជកម្ម ចំណែកឯកធនាគារឯកជនជាតិ និងបរទេសត្រូវ បានបិទទ្វារហើយរដ្ឋបានបង្កើតធនាគារដែលកាន់កាប់ដោយរដ្ឋមួយចំនួនដូចជា ធនាគារឥណទាន ជាតិធនាគារអភិវឌ្ឍន៍និង ធនាគារកសិកម្មជនបទ។

### ១.២.៣ សមិទ្ធិផលនានាក្នុងចន្លោះឆ្នាំ១៩៦០ ដល់១៩៧០

នៅក្នុងស្ថានភាព នៃប្រទេសជាតិពោរពេញទៅដោយភាពរីកចម្រើនដែលបានជាប់ឈ្មោះជាកោះសន្តិភាពក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្រោមការដឹកនាំរបស់ព្រះបាទនរោត្តម សីហនុ ដោយបានធ្វើអោយរាជធានីភ្នំពេញមានការរីកចម្រើនឥតឈប់ឈរពីមួយឆ្នាំទៅមួយឆ្នាំ ។ ជាមួយគ្នានោះលោក វណ្ណ មូលីវណ្ណ ដែលជាអ្នកទទួលបន្ទុកនូវការរចនាប្លង់គ្រប់បែបយ៉ាងក្នុងការអភិវឌ្ឍទីក្រុងភ្នំពេញទាំងមូលដោយបង្កើតនូវស្ថាបត្យកម្ម នៃរចនាបថយ៉ាងល្អបែបទៅតាមការច្នៃប្រឌិតបែបសម័យទំនើប និងបុរាណហើយបន្តនូវការអភិវឌ្ឍនូវអាគារផ្សេងៗបន្ថែមរហូតនៅក្នុងរាជធានីមួយនេះ ។ ជាមួយគ្នានោះក្នុងឆ្នាំ ១៩៦៦ នៅពហុកីឡាដ្ឋានអូឡាំពិកប្រារព្ធពីធីបដិសណ្ឋារកិច្ចល្អដោយប្រជាជនក្នុងរាជធានីភ្នំពេញនិងការបង្ហាញកងទ័ពខ្មែរ ។ នៅក្នុងរាជធានីភ្នំពេញមានសកម្មភាពបានកើនឡើងយ៉ាងឆាប់រហ័សនូវ វប្បធម៌សិល្បៈខ្មែរ ដែលបង្កើតឡើងនៅក្នុងយុគសម័យមានដែលត្រូវបានកោតសរសើរដល់ថ្ងៃ នេះមានដូចជារបាំប្រពៃណី ភាពយន្តខ្មែរ ចម្លាក់ សិប្បកម្ម បទចម្រៀងនិងតន្រ្តី គំនូរ អក្សរសាស្ត្រខ្មែរ (ការសរសេររឿង កំណាព្យ វចនានុក្រមខ្មែរ ជាដើម) ។ល។ បុគ្គលល្បីជាច្រើនត្រូវបានគេស្គាល់ផងដែរដូចជា សម្តេច ជួន ណាត លោក កេង វ៉ាន់សាក់ លោក ពៅ ស៊ីផូ លោក គង់ ប៊ុនឈឿន ព្រះមហាក្សត្រិយានីស៊ីសុវត្ថិ កុសមៈនារីរ័ត្ន លោក លី ប៊ុនយីម, លោកស្រី ឌី សាវ៉េត, អ្នកនាង រស់ សេរីសុទ្ធា, លោកស្រី ហួយ មាស អ្នកស្រី ប៉ែន រ៉ន លោក សុះ ម៉ាត់ ។ល។ ហើយរថយន្តដែលប្រើប្រាស់ភាគច្រើនបំផុតគឺជារថយន្តក្នុងស្រុកដែលបានធ្វើឱ្យរាជធានីភ្នំពេញហាក់ដូចជាមានការរៀបចំយ៉ាងល្អសម្រាប់ ចរាចរណ៍ប្រចាំថ្ងៃ

និងងាយស្រួលក្នុងការធ្វើដំណើរដោយសារតែប្រជាជនពោរពេញដោយចំណេះដឹង ហើយប្រជាជនក្នុងតំបន់បានធ្វើការចរាចរនៅក្នុងទីក្រុងទាំងអស់មានការសប្បាយចិត្ត ជាមួយនឹងការអភិវឌ្ឍនៃរាជធានីមួយនេះ ។

អាគារគំរូមួយចំនួនដែលលេចធ្លោក្នុងចន្លោះឆ្នាំនេះរួមមាន៖

**២.១ ពហុកីឡាដ្ឋានជាតិអូឡាំពិក**



១៩៦៤ ដោយស្ថាបត្យករខ្មែរលោក វណ្ណ មូលីវណ្ណ ដែលបានធ្វើឱ្យការប្រើប្រាស់ដីទ្រង់ទ្រាយធំដើម្បីបង្កើតពហុកីឡាដ្ឋាននេះដោយបានប្រើដីអស់ចំនួន ៥០០ ០០០ម៉ែត្រគូប ។ ពហុកីឡាដ្ឋាននេះត្រូវបានកសាងឡើងដើម្បីធ្វើម្ចាស់ផ្ទះ នៃការប្រកួតកីឡានៅឧបទ្វីបអាស៊ីអាគ្នេយ៍ក្នុងឆ្នាំ១៩៦៣ ប៉ុន្តែការប្រកួតនេះត្រូវបានលុបចោលដោយសារបញ្ហានយោបាយនៅកម្ពុជា ។ ម្យ៉ាងទៀតពហុកីឡាដ្ឋានបានរួមចំនែកតូចមួយក្នុងឆ្នាំ ១៩៦៦ របស់ FIFA World Cup ។ ដោយសារតែប្រទេសកូរ៉េខាងជើងខ្វះការទំនាក់ទំនងល្អរវាង ប្រទេសភាគច្រើនជាមួយនឹងការរកទីកន្លែងសមរម្យសម្រាប់ការប្រកួត (កូរ៉េ និង អូស្ត្រាលី) នេះបានបង្ហាញពីការលំបាក ពេលនោះប្រមុខរដ្ឋសម្តេច

នរោត្តម សីហនុ ដែលបានសម្ព័ន្ធមិត្តរបស់លោក គីម អ៊ីលស៊ុងបានឱ្យដឹងថាការប្រកួតនេះអាចត្រូវបានធ្វើឡើងនៅក្នុងរាជធានីភ្នំពេញ ។ ការប្រកួតនេះបានទាក់ទាញទស្សនិកជនបាន ៥០០០០ នាក់ ជាមួយនឹងភាពរីករាយដោយមានពាក់កណ្តាលគាំទ្រសម្រាប់ប្រទេសអូស្ត្រាលី ហើយពាក់កណ្តាលទៀតគាំទ្រសម្រាប់ប្រទេសកូរ៉េខាងជើង។ ការប្រកួតធ្វើឡើងនៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ១៩៦៥ និងនៅថ្ងៃទី ២៤ ខែវិច្ឆិកាឆ្នាំ ១៩៦៥ ជាមួយកូរ៉េខាងជើងបានទទួលជ័យជម្នះទាំងពីរ (៦-១ និង ៣-១)។

**២.២ សាលមហោស្រពទន្លេបាសាក់**



<u>សាលមហោស្រពទន្លេបាសាក់ ក្នុងឆ្នាំ១៩៦៦</u>

សាលមហោស្រពទន្លេបាសាក់ត្រូវបានចាប់ផ្តើមនូវការសាងសង់ និងរចនាស្ថាបត្យករជាតិលោក វណ្ណ មូលីវណ្ណ ក្នុងឆ្នាំ ១៩៦៦ ហើយវាបានបើកអោយដំណើរក្នុងឆ្នាំ ១៩៦៨ ដោយហៅថាសាលមហោស្រពព្រះបាទនរោត្តមសុរាម្រិត ។ ការរចនានៃសាងសង់គឺស្រដៀងទៅនឹងនាវានៅលើច្រាំងទន្លេបាសាក់មួយកន្លែងនៃរាជធានី ។ ហេតុនេះវាត្រូវបានគេស្គាល់ថាវាជាកន្លែងដ៏ធំទូលាយសម្រាប់ការសម្តែងល្ខោននិងតន្ត្រីផ្សេងៗនៅក្នុងរាជធានីជាដើម ។ ប៉ុន្តែនៅក្នុងឆ្នាំ១៩៩៤

សាលមហោស្រពមួយនេះត្រូវបានអគ្គីភ័យមហន្តរាយដែលបានបំផ្លាញសាលប្រជុំទាំងមូល ហើយវាត្រូវបានគេវាយកំទេចចោលនៅក្នុងឆ្នាំ២០០៨។

### ២.៣ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ



**សាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងឆ្នាំ១៩៦០**

សាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវបានបង្កើតឡើងដំបូងនៅឆ្នាំ១៩៦០ ដែលរចនាដោយស្ថាបត្យករខ្មែរលោក **វណ្ណ ម៉ូលីវណ្ណ** និងស្ថិតក្រោមការដឹកនាំរបស់ព្រះបាទនរោត្តម សីហនុ ក្នុងអំឡុងពេលដែលប្រទេសកម្ពុជាមានការរីកចំរើនយ៉ាងខ្លាំងក្លា ហើយសាកលវិទ្យាល័យនេះមានឈ្មោះដើមថាសាកលវិទ្យាល័យភូមិន្ទខ្មែរ ។ នៅពេលនោះភាសាដែលត្រូវបានគេប្រើប្រាស់គឺជាភាសាបារាំង ។ នៅសម័យខ្មែរសាធារណរដ្ឋ សាកលវិទ្យាល័យបានត្រូវប្តូរឈ្មោះជាសាកលវិទ្យា - ល័យភ្នំពេញ ។ នៅសម័យខ្មែរក្រហម សាកលវិទ្យាល័យនៅទូទាំងប្រទេសត្រូវបានបិទទ្វារ ហើយសាស្ត្រាចារ្យទាំងអស់បានក្លាយជាមុខសញ្ញានៃការសំលាប់របស់ពួកខ្មែរក្រហម ។ នៅឆ្នាំ១៩៨១ វិទ្យាស្ថានភាសាបរទេស IFL ត្រូវការបើកការបណ្តុះបណ្តាលសាស្ត្រចារ្យ ភាសារុស៊ី និងភាសាវៀតណាម ។ ក្រោយមកវិទ្យាល័យនេះត្រូវបានបញ្ចូលនិងបង្កើតជាសាកលវិទ្យាល័យភ្នំពេញ ដែលត្រូវប្តូរឈ្មោះដូចបច្ចុប្បន្ននៅឆ្នាំ១៩៩៦ ។ នៅក្នុងទស្សវត្សចុងក្រោយនេះ សាកលវិទ្យាល័យបានបែងចែងជាគ្រឹះស្ថានគឺមហាវិទ្យាល័យវិទ្យាសាស្ត្រ មហាវិទ្យាល័យសង្គមសាស្ត្រនិងមនុស្សសាស្ត្រ

និងវិទ្យាស្ថានភាសាបរទេស IFL ។ ហើយនៅឆ្នាំ២០០១ សាកលវិទ្យាល័យបានបើកការបណ្តុះបណ្តាលថ្នាក់ក្រោមឧត្តម។

**២.៤ ផ្ទះ១០០**




**ផ្ទះ១០០ខ្នង ក្នុងឆ្នាំ១៩៦៣**

ធនាគារជាតិនៃកម្ពុជាបានជ្រើសរើសលោក **វណ្ណ មូលីវណ្ណ** សម្រាប់ធ្វើជាគណៈកម្មការឯកជនមួយដើម្បីធ្វើការរៀបចំនូវលំនៅដ្ឋានសម្រាប់កម្មកររបស់ខ្លួនចំនួន១០០ផ្ទះ ដែលមានលក្ខណៈដូចៗគ្នាទាំងអស់នៅក្នុងរាជធានីភ្នំពេញដោយស្ថិតនៅតាមបណ្តោយផ្លូវទៅកាន់ព្រលានយន្តហោះពោធិ៍ចិនតុង ការធ្វើផ្ទះចំនួនមួយរយៈនេះ គេបានមានផែនការនៃការធ្វើជាផ្ទះឈើ ហើយរចនាបថទៅតាមស្ថាបត្យកម្មប្រពៃណីខ្មែរហើយក្នុងផ្ទះនោះគេបានធ្វើអោយមានបន្ទប់គេងតូចមួយ និងបន្ទប់ទទួលភ្ញៀវលក្ខណៈគ្រួសារមួយដែលមានទំហំធំមួយ ហើយខាងក្រោយត្រូវបានបែងចែកចេញជា២ដោយម្ខាងជាផ្ទះបាយ និងម្ខាងទៀតជាបង្គន់។

### ១.២.៤សមិទ្ធិផលនានាក្នុងចន្លោះឆ្នាំ១៩៧០ ដល់១៩៧៥

ស្ថានភាពសេដ្ឋកិច្ច និងសង្គមប្រទេសកម្ពុជានាសម័យសាធារណៈរដ្ឋខ្មែរ ឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ គឺជាស្ថានភាពសេដ្ឋកិច្ចមួយ ដែលស្ថិតនៅក្នុងសភាពវិបត្តិដ៏ធ្ងន់ធ្ងរបំផុត និងមានលក្ខណៈរីកររហើយឆ្ពោះទៅរកការរលាយសាបសូន្យ លើគ្រប់មូលដ្ឋានគ្រឹះនៃវិស័យសេដ្ឋកិច្ចជាតិទាំងមូល។ ជាក់ស្តែង វិស័យឧស្សាហកម្មផលិតកម្មត្រូវបានផ្អាក់ស្ទើទាំងស្រុង វិស័យកសិកម្ម ក៏មិនអាចដំណើរការបាននិងវិស័យសេវាកម្ម ពាណិជ្ជកម្ម ក៏ដំណើរការបានតែទីក្រុង និងទីប្រជុំជនធំៗតែប៉ុណ្ណោះ។ ជាលទ្ធផល សង្គ្រាមរយៈពេល៥ឆ្នាំ និង១ខែ ធ្វើអោយរោងចក្រឧស្សាហកម្ម ៤/៥ ត្រូវបានបំផ្លិចបំផ្លាញ ចំការដំណាំកៅស៊ូ ២/៣ ត្រូវបានបាត់បង ផ្លូវថ្នល់ និងផ្លូវដែកពី ៧០% ទៅ ៨០% ត្រូវបានខូចខាត កំពង់ផែ និង កំពង់ចម្លង ត្រូវបានខ្ទេចខ្ទាំសំណង់សាធារណៈតាមទីប្រជុំជន និងគ្រឹះស្ថានសិក្សាបានរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរ ពី ៨០% ទៅ ៩០%។ ភាពថ្មីនៃសាកលភាវូបនីយកម្មពិភពលោកដូចជាបណ្តាទីក្រុង ជាយក្រុងថ្មីជុំវិញទីក្រុងចាស់របស់រាជធានីភ្នំពេញ អគារខ្ពស់សម្រាប់ការជួលការិយាល័យនិងលំនៅដ្ឋានសណ្ឋាគារប្រណីត ផ្ទះល្វែង និងផ្ទះសំណាក់បែបខ្មែរគ្រប់ប្រភេទភោជនីយដ្ឋានអាហារ ល្ខោនសម័យទំនើប សួនច្បារ កាស៊ីណូធំៗ សួនកម្សាន្ត សួនទឹករោងភាពយន្តសម័យទំនើប ឧទ្យានថ្មីនៅតាមបណ្តោយទន្លេសាប និងជាអគារថ្មីនៃស្ថាប័នរដ្ឋាភិបាលដែលជាតំបន់គួរអោយចាប់អារម្មណ៍ជាទីបំផុតនៅក្នុងរបបសង្គមរាស្ត្រនិយមនោះនៅមាន ប៉ុន្តែបានតែមួយចំនួនដោយមានលក្ខណៈចាស់ទ្រុឌទ្រោម និងរងនូវការបំផ្លាញដោយសង្គ្រាម។ ជាងនោះទៅទៀតរាជធានីភ្នំពេញពីឆ្នាំ១៩៧០ នេះតទៅមិនទាន់បានឃើញនូវការអភិវឌ្ឍជាច្រើនដោយសារតែសង្គ្រាមស៊ីវិលនៅកម្ពុជា។ ចំនួនប្រជាជនដើមនៃទីក្រុងភ្នំពេញ ៩០០.០០០ បានកើនឡើងដល់ជាង ២.០០០.០០០ នៅចុងបញ្ចប់នៃសង្គ្រាមនៅឆ្នាំ ១៩៧៥ ដោយសារតែជនភៀសខ្លួនសង្គ្រាមមកពីជនបទនេះ។ ផ្ទុយមកវិញហេដ្ឋារចនាសម្ព័ន្ធជាច្រើនត្រូវបានបំផ្លាញដោយការវាយប្រយុទ្ធនៃសង្គ្រាម។ នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានរុករកឃើញស្ពានជ្រោយចង្វារដែលទីបំផុតវាត្រូវបានគេបំផ្លាញចោល។

ពិសេសជាងនេះទៅទៀត ភាគីខ្មែរទាំងសងខាង ប្រមាណជាង ១លាននាក់ បានស្លាប់ និងរងរបួស អ្នកនៅរស់ក្លាយជាអ្នកទោស ខ្វះជម្រក ខ្វះស្បៀងអាហារ មនុស្សចាស់ និងកុមារភាគច្រើនស្លាប់ ដោយសារភាពអត់ឃ្លាន។

និយាយរួម មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិទាំងមូលដែលបានកសាងអស់រយៈពេលជាច្រើនទសវត្សរ៍កន្លងមកនេះ ត្រូវបានបំផ្លាញចោលខ្ទេចខ្ទីស្ទើរគ្មានសល់ ដោយសារតែលទ្ធផលនៃសង្គ្រាមស៊ីវិលរវាងខ្មែរគ្នាឯង តាមរយៈថ្នាំបំពុលនៃមនោគមវិជ្ជាលោភលន់ វាទីនិយមរបស់បរទេស ក្នុងមហិច្ឆតាទុច្ចរិត ដែលយើងទាំងអស់គ្នាមិនអាចបំភ្លេចបានជាប្រវត្តិសាស្ត្រ។

# ជំពូក២

## គោលការណ៍គតិយុត្តិក្នុងការរៀបចំរាជធានីភ្នំពេញ

# ជំពូកទី ២
# គោលការណ៍គតិយុត្តិក្នុងការរៀបចំរាជធានីភ្នំពេញ

## ២.១ គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍រាជធានី

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់អាទិភាពនយោបាយមួយសម្រាប់អាណិត្តទី៥ នៃរដ្ឋសភាបានការរៀបចំយុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍន៍ទីក្រុង ទីប្រជុំជន ។ គោលបំណងនេះគឺដើម្បីចូលរួមចំណែកកែលំអ ប្រសិទ្ធភាពសេដ្ឋកិច្ចជាតិ និងការប្រកួតប្រជែង លើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋ ហើយនិងធានាអំពីនិរន្តភាពបរិស្ថាន ដោះស្រាយអំពីបញ្ហាដឹកជញ្ជូន និងជំនះការកកស្ទះចរាចរណ៍ តាមរយៈសង្គតិភាព / ស្របនិងគោលនយោបាយទាក់ទងនឹងទីក្រុង ទីប្រជុំជនការរៀបចំដែនដី ការរៀបចំក្រុង ការអភិវឌ្ឍន៍ក្រុង និងការគ្រប់គ្រង់ក្រុង ។ ក្របខណ្ឌទាំងនេះគឺផ្ដល់គំនិតស៊ីជម្រៅមួយចំនួន ទៅក្នុងបញ្ហា និងការប្រឈម ដែលចាំបាច់ ត្រូវដោះស្រាយ ក៏ដូចជាការផ្ដល់គោលការណ៍ណែនាំ និងលើកទឹកចិត្តសម្រាប់ការពិភាក្សាលើធាតុចូលមុន និងអភិវឌ្ឍយុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍន៍ទីក្រុង។

### ២.១.១ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ត្រូវបានប្រកាសអោយប្រើប្រាស់នៅថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០៤ ក្នុងគោលបំណងដើម្បីអភិវឌ្ឍការងារសមភាព និងប្រសិទ្ធភាព ផែនការយុទ្ធសាស្ត្រចតុកោណដំណាក់ការលទី៣ បានកំណត់នូវអាទិភាព៤ ក្នុងនោះដែរដើម្បីឆ្លើយតបនិងការអភិវឌ្ឍក្រុង ក្នុងចតុកោណទី ២ មុំទី១ បានកំណត់ផងដែរអំពីការងារដែររដ្ឋាភិបាលភិបាលធ្វើដើម្បីបន្តផ្ដល់អាទិភាពខ្ពស់លើការសាងសង់ ស្ពានទៅលើប្រព័ន្ធគមនាគមន៍ដូចជាស្ពាន ថ្នល់អាកាសយានដ្ឋាន កំពង់ផែ ដែលតភ្ជាប់រវាងគ្រប់ទាំងទីក្រុង និងទីប្រជុំជន ដោយផ្ដល់នូវទំនុកចិត្តប្រសិទ្ធភាពមានការប្រសើរឡើង មានការកើនឡើងនូវការវិនិយោគ និងតម្លៃដឹកជញ្ជូនទាប ដែលទាំងនេះគឺជាការចូលរួមចំណែករបស់រាជរដ្ឋាភិបាលក្នុងការធ្វើអោយទីក្រុងមានការរីកចម្រើន។

### ២.១.១.១ ផែនការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងវប្បធម៌

ដើម្បីឆ្លើយតបនិងតម្រូវការមូលដ្ឋានរបស់មនុស្ស ចាំបាច់ត្រូវពិចារណាលើទិដ្ឋភាពទាំងឡាយមានជាអាទិ៍កន្លែងកំសាន កន្លែងលេងកីឡា លម្អបៃតង ជាសួន ឧទ្យាន តំបន់បេតិកភ័ណ្ឌវប្បធមិ ។ ដើម្បីធ្វើការរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធសាលារាជធានីបានៈ

- លើកកម្ពស់នៃការអភិវឌ្ឍន៍: សាលារាជធានីបានបង្កើតនូវកាលានុវត្តភាពថ្មី ដោយរក្សានូវតំបន់សំណង់វប្បធម៌ដែលតភ្ជាប់ឡើងវិញនូវបណ្តាញផ្លូវដែលតភ្ជាប់តំបន់ខាងលិច និងខាងជើងមកតំបន់ទីក្រុងចាស់ផ្នែកខាងត្បូងនិងខាងកើតនៃបឹងកក់ ។ ការបន្តពីផ្ទៃបៃតងដែលមានទំនាក់ទំនងរវាងពហុកីឡាដ្ឋានជាតិទៅជាកន្លែងថ្មីមួយដែលផ្លូវទាំងនោះសម្រាប់ទទួលនូវកន្លែងកំសាន្តទាំងឡាយ ។ ការលើកកម្ពស់បឹងនានាដែលជាការរៀបចំលើវិស័យនគរូបនីកម្មថ្មីមួយនៅកណ្តាលទីក្រុងថ្មី ដោយរក្សាទុកបឹងមួយចំនួនដែលមានសារៈសំខាន់ក្នុងាករទទួលការបង្ហូរទឹកចេញពិទីក្រុងដូចជាទំនប់កប់ស្រូវ និងទន្លេសាប និងចុងក្រោយគឺការរៀបចំចម្រោះទឹកកង្វក់ក្នុងបឹងមួយចំនួនដូចជាបឹងជើងឯក បឹងទំពុន បឹងត្របែកដោយបន្សុតទឹកកង្វក់របស់ទីក្រុងតាមរយៈការធ្វើអាងសម្អាតជាបន្តបន្ទាប់ដោយក្នុងនោះដែរការរៀបចំទាមទារឲ្យមានទំហំ៥២០ហិចតា។

- ការបែងចែកនូវតំបន់ពិសេសៗ: តំបន់ចតុមុខជាទីរមណីយដ្ឋានមួយដ៏សំខាន់របស់រាជធានី ហើយរួមមានស្ថាប័នកំពូលៗរបស់ព្រះរាជាណាចក្រកម្ពុជា ដូចជាព្រះរាជវាំង តុលាការកំពូល ក្រសួងយុត្តិធមិជាដើម។ ដោយមើលឃើញពីគុណសម្បិត្តដ៏ពិសេសពិសាលនៃតំបន់នេះតាមរយៈការវិភាគចំចំណុចមុំកណ្តាល នៃចំណុចប្រសព្វរបស់ទន្លេទាំងបួន គឺទន្លេមេគង្គលើទន្លេមេគង្គក្រោម ព្រះបរមរាជវាំង ជ្រោយចង្វារ តំបន់អរិយក្សត្រ។ផ្ទុយទៅវិញប្រសិនបើរាជធានីកោះពេជ្រដែលនៅទល់មុខសួនច្បារសម្តេច ហ៊ុនសែន មិនទាន់បានអភិវឌ្ឍន៍ដល់កម្រិតនោះទេទីតាំងពិសេសនៃមុំទាំងបីក៏មិនរីកចម្រើនដោយខ្លួនឯងបានដែរ ម្លោះហើយបានជាកោះពេជ្រសព្វថ្ងៃកំពុងប្រែមុខមាត់ខ្លួនឯងបន្តិចម្តងៗក្លាយជាទីក្រុងរណបមុនសិន។ ក្នុងចំណោមទីតាំងពិសេសៗទាំង៤ គេសង្កេតឃើញមានទីតាំង៣ដែលពុំទាន់ទទួលបានការអនុវត្តនៅឡើយ។

### ២.១.២ ប្លង់គោលនៃការរៀបចំរាជធានីភ្នំពេញ

ប្លង់គោលប្រើប្រាស់ដីត្រូវបានគេចាត់ទុកថាជាប្លង់គ្រឹះសម្រាប់រៀបចំដែនដី នៃរាជធានី ក៏ដូចជាខេត្តក្រុងផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា ។ ប្លង់គោលមានតួនាទីជាអ្នកតម្រង់ទិស សម្រាប់ការបែងចែក និងកំណត់ទិសសំណង់សាធារណៈ តំបន់ទេសចរណ៍ បណ្តាញប្រព័ន្ធទឹក តំបន់ធម្មជាតិ និងកសិកម្ម បណ្តាញផ្លូវ ការដឹកជញ្ជូនទំនិញ និងតំបន់ដែលត្រូវអភិរក្ស និងអភិវឌ្ឍន៍។

ជាទូទៅទស្សន នៃការអនុវត្តប្លង់គោលសម្រាប់តែរាជធានី ខេត្តតែប៉ុណ្ណោះ ហើយប្លង់នេះដែរ ត្រូវបានកំណត់ដោយច្បាប់ស្តីពី ការរៀបចំទឹកដី នគរូបនីកម្ម និងសំណង់ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ១៩៩៤។

ប្លង់គោលនេះមានទិសដៅកំណត់ពីរសំខាន់ៗ **ទី១** កំណត់តំបន់ដែលជាដីសាធារណៈ របស់រដ្ឋនិងតំបន់ហាមសាងសង់ ព្រមទាំងតំបន់ប្រើប្រាស់ជារួម ឬបម្រុងទុកជាសម្បត្តិរដ្ឋ និងលំហានានា ដូចជាលំហាកម្ពស់សម្រាប់បរិក្ខារសាធារណៈធំៗផ្សេងទៀត ។ **ទី២** បង្កើតអនុសាសន៍ជាយុទ្ធសាស្ត្រ អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ទីក្រុង ។ បំណងនេះគឺសំដៅរៀបចំតម្រង់ទិសសម្រាប់ ថ្ងៃអនាគតនូវការវិនិយោគរបស់រដ្ឋនិងឯកជន។

បច្ចុប្បន្ន ប្លង់គោលរាជធានីភ្នំពេញ ស្ថិតក្រោមការរៀបចំរបស់ការិយាល័យនគរូបនីយកម្ម ដែលជាអង្គភាពចំណុះអោយសាលារាជធានីភ្នំពេញ និងជួយសាលារាជធានីភ្នំពេញក្នុងកិច្ចការ នគរូបនីយកម្ម។ នៅក្នុងការវិភាគអំពីអានុភាពរបស់ប្លង់គោល គេសង្កេតឃើញថា មានច្បាប់បី ដែលមានការ ពាក់ព័ន្ធសំខាន់ជាងគេគឺ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤ អនុក្រឹត្យលេខ៨៦ ស្តីពីលិខិតអនុញ្ញាតសាងសង់ និងគោលនយោបាយជាតិស្តីពីលំនៅដ្ឋាន។

#### ២.១.២.១អនុភាពប្លង់គោលសម្រាប់លិខិតអនុញ្ញាតសាងសង់

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ គឺជាប្លង់មួយដែលដើរតួនាទីសំខាន់មួយដែរ ក្នុងការរៀបចំ រាជធានី ខេត្ត ក្រុងឲ្យមានសណ្តាប់ធ្នាប់ និងពោរពេញទៅដោយសោភ័ណ្ឌភាព ហើយមានលក្ខណៈ ត្រឹមត្រូវស្របតាមច្បាប់នគរូបនីយកម្ម ។ ប្លង់នេះមានចែងអំពី កម្ពស់សំណង់ គម្លាតសំណង់ ជួររត់ តម្រង់នៃសំណង់ ក្នុងគោលបំណងជួយកែលម្អសោភ័ណ្ឌភាពរាជធានីឲ្យកាន់តែប្រសើរឡើង។

នៅក្នុងច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់នេះ មានកំណត់ផងដែរ

ពីប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ដែលជាប្លង់មួយចាំបាច់សម្រាប់រាជធានី ខេត្ត ក្រុងឲ្យត្រូវរៀបចំឡើងដោយទាមទារមានការគោរពពីសំណាក់ឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន ។ ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ សម្រាប់រាជធានី និងខេត្ត ក្រុងនីមួយៗដែលត្រូវបានរៀបចំឡើងក៏តម្រូវឲ្យមានការទទួលយកពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត ។ ប្លង់នេះមានតួនាទីសំខាន់ណាស់ក្នុងការកំណត់អំពីតំបន់ដែលត្រូវប្រើប្រាស់សម្រាប់ការ ការពារជាតិ សម្រាប់កសិកម្ម សម្រាប់ពាណិជ្ជកម្ម សម្រាប់ឧស្សាហកម្ម សម្រាប់សិប្បកម្ម សម្រាប់វប្បធម៌ សម្រាប់ទេសចរណ៍ សម្រាប់សាសនា ព្រមទាំងសម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខារសាធារណៈ ហើយប្លង់នេះក៏មានកំណត់នូវលទ្ធភាពសម្រាប់ការសាងសង់ផងដែរ ។ ប៉ុន្តែទោះជាយ៉ាងណាតាមរយៈមាត្រា៨ នៃច្បាប់នេះដដែលក៏បានចែងថា ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវគោរពតាមប្លង់គោល ។ នេះបញ្ជាក់ថា ប្លង់គោលពិតជាមានអនុភាពគតិយុត្តិលើប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ យ៉ាងពិតប្រាកដ មានន័យថារាល់តំបន់ដែលប្លង់គោល បានកំណត់ថាទីតាំងណាមួយសម្រាប់សាងសង់អាគារខ្ពស់ៗ តំបន់បេតិកភ័ណ្ឌជាតិ ប្លង់ប្រើប្រាស់ដីធ្លី មិនអាចរំលោភបំពានលើប្លង់គោលបានទេ។

### ២. ១.២.២ អនុភាពរបស់ប្លង់គោលចំពោះលិខិតអនុញ្ញាតសាងសង់

លិខិតអនុញ្ញាតសាងសង់ គឺជាឯកសារគតិយុត្តនគរូបនីយកម្ម ដែលដាក់ចេញដោយអាជ្ញាធរសាធារណៈក្នុងការអនុញ្ញាតឲ្យមានការសាងសង់ ឬប្តូរទ្រង់ទ្រាយអាគារណាមួយដូចមានចែងក្នុងច្បាប់ស្តីលិខិតអនុញ្ញតសាងសង់ ។ លិខិតអនុញ្ញាតសាងសងក៏ជាផ្នែកក្នុងការថែរក្សាសណ្តាប់ធ្នាប់ សុវិត្ថភាពសាធារណៈ សោភណ្ឌភាពសាធារណៈ និងបរិស្ថានក្នុងរាជធានី ខេត្ត ។ រាល់សំណង់ទាំងឡាយត្រូវស្ថិតក្រោមលិខិតអនុញ្ញាតសាងសង់ ប៉ុន្តែមានករណីលើកលែងចំពោះសំណង់នៅឆ្ងាយពីតំបន់ទេសចរណ៍ តំបន់អភិរក្ស តំបន់រក្សាទុកការពារមិនគិតពីទំហំ ឬសម្ភារៈប្រើប្រាស់ឡើយ ទីសក្ការៈបូជា សាលាសំណាក់សាធារណៈ បណ្ណាការ្យសិល្បៈ របស់រដ្ឋសម្រាប់សេវាសាធារណៈ ដែលរដ្ឋជាម្ចាស់កិច្ចការ។

ការចេញលិខិតអនុញ្ញាតសាងសង់ តម្រូវឲ្យអាជ្ញាធរដែលមានសមត្ថកិច្ច ត្រួតពិនិត្យជាមុននូវប្រភេទសំណង់ ថាតើសំណង់នោះគោរពទៅតាមប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី និងសំណង់

ដែរឬទេ?ក្នុងករណីដែលសំណង់ពុំមានលក្ខណៈសមស្របទៅនិងប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ទេនោះ ការសាងសង់ក៏មិនត្រូវបានការអនុញ្ញាតដែរ ត្រង់ចំណុចនេះបញ្ជាក់ឲ្យឃើញថា លិខិតអនុញ្ញាតសាងសង់គឺត្រូវគោរពទៅតាមប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ។ ប៉ុន្តែក្នុងករណីដែលពុំមានប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ទេ ការចេញលិខិតអនុញ្ញាតសាងសង គឺគេត្រូវបង្កើតគណៈកម្មាធិការមួយសម្រាប់ចេញលិខិតអនុញ្ញាត ហើយគណៈកម្មាធិការនេះត្រូវដឹកនាំដោយប្រតិភូរដ្ឋាភិបាល ប្រចាំរាជធានី ឬអភិបាលខេត្ត។

អ្វីដែលគួរឲ្យចាប់អារម្មណ៍គឺលិខិតអនុញ្ញាតសាងសង់ និងមិនផ្តល់ជូនឡើយចំពោះទឹកដីដែលអាចមានមហន្តរាយតំបន់បាក់ស្រុតរលំ តំបន់ដីសើម ដែលត្រូវការពារតាមមាត់ច្រាំងទន្លេ ព្រែកស្ទឹង បឹងបួរដែលពុំមានភាពរឹងមាំគ្រប់គ្រាន់ ហើយអាចបណ្តាលឲ្យមានគ្រោះថ្នាក់សម្រាប់សុវត្ថិភាពមនុស្ស និងទ្រព្យសម្បត្តិ លើកលែងតែភូមិដ្ឋានទាំងនោះបានអនុម័តតាមប្លង់គោលរួចហើយ។ ជាងនេះដែរលិខិត អនុញ្ញាតក៏មិនអាចសាងសង់បានទេប្រសិនបើការសាងសង់នោះប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សំណង់ឬ អាគារដែលមានសារៈប្រយោជន៍ដល់ផ្នែក បុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភណ្ឌភាព បច្ចេកទេស ឬប៉ះពាល់ដល់តំបន់ដែលមានធនធានធម្មជាតិ ។

ក្នុងករណីដែរមានការសាងសង់ដោយល្មើសច្បាប់ ក្នុងតំបន់ហាមឃាត់ទាំងនេះ អាជ្ញាធរដែនដីត្រូវបង្ខំអោយជនល្មើសរុះរើដោយខ្លួនឯង ហើយធ្វើឲ្យកន្លែងនោះមានសភាពដូចដើមក្នុងរយៈកាលកំណត់ ។

ក្នុងករណីដែលមិនអនុវត្តតាមការកំណត់ អាជ្ញាធរដែនដីត្រូវធ្វើការដាកពិន័យ និងចាត់វិធានការអោយជនល្មើសនោះរុះរើ និងធ្វើឲ្យកន្លែងនោះមានសភាពដូចដើម ដោយចាប់បង្ខំជនល្មើសត្រូវតែចេញសោហ៊ុយ ចំណាយទាំងអស់នោះ ឬក្នុងករណីចាំបាច់អាជ្ញាធរមូលដ្ឋានត្រូវប្តឹងទៅតុលាការដើម្បីឲ្យចេញដីកាប្រញាប់បញ្ជាឲ្យរុះរើ។

### ២.១.២.៣អត្ថប្រយោជន៍នៃប្លង់គោល

ការរៀបចំប្លង់គោលបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ការអភិវឌ្ឍន៍រាជធានីដូចជាៈ

- ធ្វើឲ្យរាល់ការសាងសង់មានបទដ្ឋានកំណត់ច្បាស់លាស់តាមការកំណត់របស់ប្លង់គោល

- រាល់ឧទ្យានសួនច្បារ រមនីយដ្ឋាន មហោស្រព ទីធ្លាកំសាន្ត ត្រូវបានសាងសងដោយមានសណ្តាប់ធ្នាប់។
- រាជធានីមានសោភ័ណភាពស្រស់បំព្រង គ្មានសំណង់អាណាធិបតេយ្យ មានអនាម័យ គ្មានភក់ ជ្រាំចម្លងមេរោគ។
- រាល់ការសាងសង់ពុំមានភាពច្របូកច្របល់
- ប្លង់គោលបានបង្ហាញពីសោភ័ណភាព សណ្តាប់ធ្នាប់ មានបណ្តាញផ្គត់ផ្គង់ទឹក បណ្តាញ លូបង្ហូរទឹកភ្លៀង និងទឹកស្អុយ មានបណ្តាញអគ្គិសនី មានទីកំសាន្ត មានសាលារៀន ដីសំរាប់កីឡាដ្ឋាន រដ្ឋបាល ទីធ្លាសំរាប់ផ្សារ គ្រឹះស្ថានពាណិជ្ជកម្ម និងវប្បធម៌...។

### ២.១.៣ គោលនយោបាយក្នុងការរៀបចំទឹកដី និងលំនៅដ្ឋាន

#### ២.១.៣.១ ការរៀបចំទីរាជធានី

ការអនុវត្តគោលនយោបាយលំនៅដ្ឋាន គឺជាយុទ្ធសាស្ត្រមួយរបស់រដ្ឋក្នុងការដោះស្រាយភាពខ្វះខាតលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ដោយមានប្រយោជន៍ដើម្បីកាត់បន្ថយភាពក្រីក្រ ។ គោលនយោបាយនេះត្រូវបានរុញនៅក្នុងប្លង់គោល តាមរយៈផែនការផ្លាស់ប្តូរលំនៅដ្ឋាន ពីតំបន់សំណង់អនាធិបតេយ្យកណ្តាលរាជធានីទៅតំបន់ជាយរាជធានីវិញ ។ ស្របទៅនិងទូលរាជធានីដែលមានកំណើនប្រជាជនរាជធានីភ្នំពេញកើនឡើងជាលំដាប់ដែលមានប្រហែល ៥០,០០០នាក់ក្នុងមួយឆ្នាំ ជាល្បឿនកំណើនមួយប្រហែលគ្នានឹងកំណើនប្រជាជនមុនពេលសង្គ្រាមដែរ។ គោលនយោបាយកសិកម្មមួយមុខ មិនអាចកាត់បន្ថយបាននូវការធ្វើចំណាកស្រុក ពីជនបទមកកាន់ទីក្រុងបានទេ ។ គោលនយោបាយជាតិស្តីពីលំនៅដ្ឋាន នឹងរួមចំណែកដល់ការដោះស្រាយសំណង់បណ្តោះអាសន្ននានា ដោយសុច្ឆន្ទះ ក្នុងការលើកតម្កើនឡើងវិញ នូវតំបន់ កណ្តាលក្រុងនៃរាជធានីផង និងផ្តល់នូវលក្ខខណ្ឌជីវិត ដ៏ប្រសើរដលើប្រជាជនទាំងឡាយផង។ សកម្មភាពនៃការផ្តល់ទីតាំងថ្មី ដល់អ្នករស់នៅក្នុងសំណាងអនាធិបតេយ្យទាំងឡាយផង។

សកម្មភាពនៃការផ្តល់ទីតាំងថ្មី ដល់អ្នករស់នៅតំបន់អនាធិបតេយ្យទាំងឡាយ(១៩៩៨-២០០២) បានធ្វើបម្លាស់ទីប្រជាជនជាង ១០,០០០គ្រួសារពីកណ្តាលក្រុងទៅកាន់ជាយក្រុងជាមួយ និងបទពិសោធន៍ ដែលទោះជាបានរៀបចំនិងព្រមព្រៀងគ្នាយ៉ាងណាក៏ដោយ ក៏ការធ្វើបម្លាស់ទីរបស់

ប្រជាជនខ្លះមានការជួបប្រទះនូវការលំបាកមួយចំនួនដោយសារវាបានបង្កើតឲ្យមាន ចលនាវិលទៅរកតំបន់អនាធិបតេយ្យដែលស្ថិតនៅកណ្តាលក្រុងរបស់ខ្លួនវិញ ក្រោមកិច្ចលូកដៃរបស់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ។ ដូច្នេះវាបានបំផ្លាញចោលមួយផ្នែកនូវកិច្ចខិតខំប្រឹងប្រែងនានាដែលបានធ្វើមួយរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះដែលជាអាទិ៍ទាក់ទងនឹងការសាងសងនីតិរដ្ឋដោយសារកត្តានេះហើយការកាន់កាប់ទីកន្លែង ដោយភាពមិនស្របច្បាប់ ហាក់បីដូចជាបានក្លាយទៅជាមធ្យោបាយមួយទាក់ទាញឲ្យមានការចូលមកក្នុងទីក្រុង ដោយប្រជាជនក្រីក្រ ។ ក្នុងពេលបច្ចុប្បន្នមានគោលនយោបាយអភិវឌ្ឍន៍សហគមន៍បណ្តោះអាសន្នចំនួន ១០០ឆ្នាំ និងសារាចរណែនាំស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ នៅតាមរាជធានី ទីក្រុង និងទីប្រជុំជន។ នេះជាគោលបំណងដ៏មានមហិច្ឆិតាធំណាស់។ ក៏ប៉ុន្តែគោលនយោបាយនេះតែមួយមុខ មិនអាចទប់ស្កាត់នឹងកំនើនយ៉ាងលឿនរបស់ប្រជាជនចំណូលថ្មី ដែលជាបញ្ហាបណ្តោះអាសន្នដែលមានស្រាប់នេះ គឺមិនមានអនាគតល្អទេដោយវាមិនអាចដោះស្រាយនូវបញ្ហាចំណូលថ្មីបន្ថែមនៃប្រជាជនក្រីក្រ ដែលមានចំនួន ២៥,០០០នាក់ ក្នុងមួយឆ្នាំ(ជាង ៦០០០ គ្រួសារក្នុង១ឆ្នាំ) ដែលពួកគេដែលជាប្រជាជនដែលគ្មានផ្ទះសំបែង ឬដីធ្លីនោះឡើយ។

តាមពិតទៅការធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌរស់នៅរបស់ប្រជាជនទាំងមូល ដូចគ្នានេះដែរការធ្វើឲ្យរឹងមាំនៃទីផ្សារដីធ្លី និងអចលនទ្រព្យដែលយើងបានឃើញតាំងពីប៉ុន្មានឆ្នាំមកហើយនោះកាន់តែបានឆ្លើយតបជាបណ្តើរៗដល់សេចក្តីត្រូវការផ្នែកលំនៅដ្ឋាន ដែលនាំឲ្យមានការកាត់បន្ថយសម្ពាធនៃការបង្កើតសហគមន៍បណ្តោះអាសន្ន។ ក៏ប៉ុន្តែប្រជាជនមួយចំនួនគឺមិនបានទទួលនូវសេវាកម្មទីផ្សារលំនៅដ្ឋានជាក់លាក់ទេ។ ការដែរគ្មានការផ្គត់ផ្គង់នូវលំនៅដ្ឋានដែលមានតម្លៃថោកនៅលើទីផ្សារលំនៅដ្ឋានដែលមានបរិក្ខារគ្រប់គ្រាន់ និងជាក់លាក់ ឬការខ្វះខាតការផ្គត់ផ្គង់នូវដីធ្លីសាងសង់សម្រាប់ប្រជាជនក្រីក្រគឺជាបញ្ហាដ៏លំបាកដោះស្រាយបំផុត។ ការផ្តោតសំខាន់ជាមួយនឹងជំនួយអន្តរជាតិទៅលើសហគមន៍បណ្តោះអាសន្នដែលមានស្រាប់នានា គ្រាន់តែអាចជួយដោះស្រាយបញ្ហា ក្នុងរយៈពេលខ្លីតែប៉ុណ្ណោះប្រហែលជាត្រូវជំរុញនូវគំនិតដែលជាមធ្យោបាយតែមួយគត់ដើម្បីចូលមកទីក្រុងសម្រាប់ទីក្រុងសម្រាប់ប្រជាជនក្រីក្រគឺភូមិអ្នកក្រីក្រនិងទីក្រុងអនាធិបតេយ្យទៅវិញទេ ។ ដូច្នេះការបង្កើតភូមិអ្នកក្រនៅតែបន្តកើតមានរហូតហើយថែមទាំងរីកចម្រើនថែមទៀតផង

ពីព្រោះថាគ្មានដំណោះស្រាយជាចីរភាពណាមួយត្រូវបានធ្វើឡើងដោយ នយោបាយកាត់បន្ថយភាពក្រីក្រទេ។

ការតម្រង់ទិសទាំង ៥ចំណុចត្រូវបានយកចិត្តទុកដាក់ ដើម្បីដោះស្រាយបញ្ហាលំនៅដ្ឋានគឺរួមមាន**ចំណុចទី១** ធ្វើឲ្យទីផ្សារដីធ្លី និងអចលទ្រព្យដើម្បីឲ្យមានការអភិវឌ្ឍន៍ការផ្គត់ផ្គង់លំនៅដ្ឋាននៃក្រុមហ៊ុនឯកជន សម្រាប់ប្រជាជនលើគ្រប់ស្រទាប់វណ្ណៈ ភ្នាក់ងារសង្កេតទីផ្សារដី និងអចលនវត្ថុមួយជាមួយនឹងការប្រជុំជាទៀងរាល់ឆមាសដែលប្រមូលផ្តុំគ្រប់មហាជន និងដៃគូអភិវឌ្ឍដែលពាក់ព័ន្ធនានាត្រូវរៀបចំឡើង ដោយសាលារាជធានីភ្នំពេញបានចែកចាយជាព័ត៌មាន និងសម្រួលសកម្មភាពរបស់វិនិយោគិនទាំងឡាយ។ ភ្នាក់ងារអង្កេតដីធ្លីនេះនឹងត្រូវបន្ថែម ដោយការអភិវឌ្ឍជាមួយនិងការវនិយោគប្រាក់ដែលមានភាពទាក់ទាញបំផុត សម្រាប់ឲ្យចំនួនប្រជាជនដ៏ច្រើនបំផុតបង្វិលទឹកប្រាក់សងវិញបាន ។ **ទីពីរ** ធ្វើការអភិវឌ្ឍលើការផ្គត់ផ្គង់ផ្នែកដីធ្លីដោយផ្តល់អាទិភាព ដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានទាំងឡាយ (ផ្លូវថ្នល់ ទឹកស្អាត ភ្លើងអគ្គិសនី ការបង្ហូរទឹក) នៅតាមតំបន់ជាយក្រុងនានាដែលនឹងអាចទទួលបាននូវការស្រូបយកកំណើនថ្មី នៃប្រជាជនក្រុងចំនួន ៩០% ពីពេលនេះរហូតដល់ឆ្នាំ២០១៣៥ ។ **ទីបី** ធ្វើការអភិវឌ្ឍដីធ្លីដែលបម្រុងទុកសម្រាប់ប្រជាជនក្រីក្រទាំងឡាយ នៅលើដីឯកជនរបស់រដ្ឋ(សម្បទានដីសង្គមកិច្ច ដីទិញដោយភ្នាក់ងារអចលនទ្រព្យនានា) នៅតំបន់ជាយក្រុង ដោយរៀបចំជាចំណែកដីឡូត៍តូចៗប្រកបដោយសម្ភារៈបរិក្ខារគ្រប់គ្រាន់។ **ទីបួន** ធ្វើការអភិវឌ្ឍទីផ្សារជួលដែលមានលក្ខណៈសង្គមកិច្ច ជាឯកជននៅតំបន់កណ្តាលក្នុងក្រុងដោយអនុវត្តឯកជនដោយមានការគ្រប់គ្រងដង់ស៊ីតេ នៃអាគារលំនៅដ្ឋានរួមចាស់ៗនានានៃតំបន់កណ្តាលក្រុងប្រវត្តិសាស្ត្រ(ខណ្ឌដូនពេញ) និងដោយសារមានវិធានការក្នុងការជំរុញវិស័យនេះ ។ **ទីប្រាំ** ការកាត់បន្ថយនៃការបំផ្លាញចោលនូវអាគារលំនៅដ្ឋានសហកម្មសិទ្ធ ដែលមានស្រាប់ហើយបង្កើតគោលនយោបាយឧបត្ថម្ភមួយសម្រាប់ការស្តារឡើងវិញនូវអាគារចាស់ៗ ដើម្បីធ្វើការអភិវឌ្ឍទីផ្សារកណ្តាលមួយ(តម្លៃថោកសមរម្យ) រវាងទីផ្សារនៃលំនៅដ្ឋានថ្មី និងទីផ្សារនៃលំនៅដ្ឋាននៅភូមិអ្នកក្រ និង**ទីប្រាំមួយ** ដែលអនុវត្តតាមសារាចរលេខ ០៣ ស.រ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់នៅតាមរាជធានី ទីក្រុង និងទីប្រជុំជន ដោយធ្វើសមាហរណកម្មទៅនឹងទីក្រុងនូវទីតាំងសហគមន៍

បណ្តោះអាសន្ន នៅលើដីសាធារណៈរបស់រដ្ឋទាំងឡាយណា ដែលអាចអភិវឌ្ឍនៅនឹងកន្លែង ដោយមានលក្ខណៈមិនអាចក្លាយជាដីឯកជនបានក្នុងករណីណាក៏ដោយ ដូចមានចែងក្នុងសារាចរ (ផ្លូវដែក បឹង ផ្លូវនានាកំពង់ផែស្ថានីយរថភ្លើង សួនច្បារសាធារណៈ ច្រាំងទន្លេ ប្រឡាយនានា...)

ជម្រើសគោលនយោបាយក្នុងការតម្រង់ទិសការអភិវឌ្ឍ ឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារ (រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣) និងការបង្កើនល្បឿននៃការសម្រេចនូវកម្មសិទ្ធិដីដែលផ្តើមនៅក្នុងក្របខណ្ឌនៃគម្រោងរដ្ឋបាលដីធ្លី LMAP របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់តម្រូវឲ្យយើងយកចិត្តទុកដាក់ ដល់ការកំណត់នូវដីបំរុងសាធារណៈរបស់រដ្ឋ ដើម្បីបំរុងនូវទីតាំងចាំបាច់នានាសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធធំៗ ដែលជាលក្ខខណ្ឌកំណត់នូវការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចលើសពីគម្រោងប្លង់គោលនគរូបនីយកម្មសំរាប់ឆ្នាំ២០៣៥ ទៀតផង។ ដូច្នេះយុទ្ធសាស្រ្តតម្រង់ទិសអភិវឌ្ឍនេះត្រូវបានធ្វើឡើងសម្រាប់រយៈពេលពីឆ្នាំ២០១៥-២០៣៥។ ប៉ុន្តែយុទ្ធសាស្រ្តនេះបញ្ចូលតែការពិចារណាទាំងឡាយនៃក្របខណ្ឌក្នុងកំរិត និងស្ថិតក្នុងភាពបណ្តោះអាសន្នតប៉ុណ្ណោះ។ ដូចនេះ សាលារាជធានីត្រូវរៀបចំផែនការសកម្មភាពរបស់ខ្លួនដើម្បីអភិវឌ្ឍឲ្យបានជោគជ័យតាមបំណង់ប្រាថ្នារបស់ខ្លួន។

### ២. ១.៣.២ការរៀបចំសោភ័ណភាពរាជធានី

បើយើងក្រលេកមើលរាជធានីភ្នំពេញ គឺយើងនឹងឃើញមានការលើកកម្ពស់ទៅលើការរក្សានូវសោភ័ណភាព និងការកែលម្អឡើងវិញនូវរាជធានីទាំងមូល ហើយរាជធានីនេះពិតជាមានសារៈសំខាន់ណាស់ព្រោះវាជួយឲ្យរាជធានីទាំងមូលមើលទៅមានភាពស្រស់ស្អាត ទាក់ទាញគ្រប់បណ្តាភ្នែកនៃមនុស្សទាំងឡាយ។ ប្រាកដណាស់ភាពស្រស់ស្អាត និងទាក់ទាញនេះមិនអាចធ្វើទៅបានឡើយបើគ្មានបណ្តាញខៀវ និងបណ្តាញបៃតង។

បណ្តាញខៀវ គឺជាធាតុមួយសម្រាប់ធ្វើការកែលម្អរនូវសម្រាប់រាជធានីមួយរយៈការកែច្នៃទឹក។ បើយើងក្រលេកទៅមើលផែនទីភូមិសាស្រ្តរបស់រាជធានីភ្នំពេញទាំងមូលនោះយើងឃើញថារាជធានីខាងជើង និងខាងត្បូងហាក់ដូចជាខ្សែក្រវ៉ាត់ពណ៌ខៀវដ៏ស្រស់ត្រកាល។ នៅភាគខាងជើងនៃទីរាជធានីមានបឹងមួយចំនួនដូចជា បឹទំពុន បឹងត្របែក បឹងជើងឯក។ល។ បឹងទាំងនេះមានសារៈ

សំខាន់ណាស់ ដែលផ្ទៃទឹកត្រូវរក្សាទុក ដើម្បីការពារបានជាអតិបរមានូវហានិភ័យនៃគ្រោះទឹកជំនន់។ យើងសង្កេតឃើញថា បឹងទាំងនេះហាក់ដូចជាអាងស្តុកបណ្តោះអាសន្ននូវទឹកភ្លៀងទាំងឡាយដែរ ព្រោះតែភាពទន់ភ្លន់នៃប្រព័ន្ធលូរបស់ទីរាជធានីដែលមិនអាចហូរទាន់ពេល ។ ក្រៅពីពួកវាផ្តល់សម្រស់ទឹកពណ៌ខៀវ ដែលបន្ថែមលើទេសភាពបៃតងមានស្រាប់ ធ្វើឲ្យរាជធានីភ្នំពេញមានលក្ខណៈធម្មជាតិសុទ្ធសាធ និងទាក់ទាញបំផុតតាមរយៈរូបភាពពីលើអាកាស។

ដោយសង្កេតឃើញភាពអំណោយផលបែបនេះ ទើបការិយាល័យទទួលបន្ទុកផ្នែកនគរូបនីយកម្ម ដែលមានទីតាំងក្នុងសាលារាជធានីភ្នំពេញដូចជាបឹងកក់ បឹងក្រពើ បឹងទំពុន និងបឹងត្របែក។ វាពិតជាមានភាពចាំបាច់ណាស់ក្នុងការកំណត់នូវបណ្តាញមួយ គឺបណ្តាញផ្ទៃទឹកនេះឯង ដែលត្រូវរក្សាទុកជាអតិបរមានូវហានិភ័យនៃគ្រោះទឹកជំនន់ជាអាទិ៍(អាចធ្វើការស្តុកទុកជាបណ្តោះអាសន្ន)។ នេះគឺជាលក្ខខណ្ឌសំខាន់ៗដែលត្រូវគោរព ហើយការរៀបចំទំហំនៃផ្ទៃទឹកនេះត្រូវបានគណនាដោយម៉ត់ចត់បំផុតតាមអ្វីអាចធ្វើទៅបាន។ ការកំណត់នូវផ្ទៃបឹងនិងបណ្តាញប្រឡាយនានា ដែលត្រូវថែរក្សាទុក និងអាចឲ្យយើងរៀបចំផងដែរនូវក្របខណ្ឌនៃការរៀបចំអភិវឌ្ឍប្រកបដោយគុណភាពខ្ពស់ដើម្បីការអភិវឌ្ឍរាជធានីភ្នំពេញ។

បណ្តាញទៀតនេះគឺបណ្តាញបៃតង ដែលត្រូវមានតួនាទីអមជាមួយនឹងបណ្តាញពណ៌ខៀវសម្រាប់ជួយលម្អនូវសម្រស់រាជធានី ក្នុងនោះមានការបន្តពង្រីកដាំដើមឈើជាជួរៗ នៅតាមបណ្តោយវិថី មហាវិថី និងទីលានលំហែកាយ ដែលការដាំនេះគឺតម្រូវទៅតាមប្រភេទដីនីមួយៗពោលគឺត្រូវសមាមាត្រទៅនឹងទំហំផ្លូវ។ បណ្តាញនេះមានមួយផ្នែកជាតំបន់លាតសន្ធឹងរបស់បឹងនានាក្នុងរដូវវស្សា ហើយដែលត្រូវប្រើប្រាស់ជាតំបន់បៃតងសាធារណៈ នៅរដូវប្រាំងដែលមានអាកាសធាតុក្តៅ។ តំបន់ភូមិនានាក៏ត្រូវបានស្នើឡើងដែរ ដែលតំបន់ទាំងនេះត្រូវបានកំណត់សម្គាល់ដោយចំណែកដីដែលមានលក្ខណៈជាភូមិបុរាណ ចំណែកដីទាំងនេះមានការលំបាកក្នុងការធ្វើការរៀបចំនានា ដោយសារតែវត្តមាននៃដើមឈើយ៉ាងច្រើនទើប ចំណែកដីទាំងនេះត្រូវបានចាត់ទុកក្នុងបណ្តាញពណ៌បៃតងផងដែរ។ គោលការណ៍ដែលត្រូវបានស្នើរឡើងនេះនឹងកាត់បន្ថយនូវការរៀបចំនានាក្នុងតំបន់ដែលមានដង់ស៊ីតេទាប(សង្កាត់ភូមិគ្រឹះនានា) ហើយការរក្សារទុកនូវតំបន់ពណ៌បៃតងនឹងធ្វើឡើងជាអតិបរមានូវទីនោះ។

## ២.២ សមិទ្ធផលដែលរដ្ឋបាលរាជធានីភ្នំពេញសម្រេចបានពេលកន្លងមក

### ២. ២.១ភាពរីកចម្រើនថ្មីរបស់រាជធានី

យោងទៅលើអនុក្រឹតស្តីពីការគ្រប់គ្រងដីរដ្ឋ សម្បទានដីសង្គមកិច្ច គោលនយោបាយលំនៅឋានបានជំរុនអោយមាន ការចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងការរៀបចំដីប្រទានកម្មរបស់រដ្ឋជូនទៅប្រជាពលរដ្ឋនៅក្នុងសហគមន៍ក្រីក្រផ្សេងៗដើម្បីតាំងទីលំនៅនិងការសាងសងសារជាថ្មី ប្រកបទៅដោយសមធម៌ និងយុត្តិធម៌ជូនប្រជាពលរដ្ឋដែលជាការចូលរួមពិភាក្សាដោយសាលារាជធានីភ្នំពេញលើអនុក្រឹត្យនេះ។ ជាក់ស្តែងការសរុបលទ្ធផលជាង ៥ឆ្នាំនេះ ជាការអនុវត្តនៃការចុះបញ្ជីជាលក្ខណៈប្រព័ន្ធបាន ៦៩៨៨០ក្បាលដី ការចែកវិញ្ញាណបនប័ត្រសម្គាល់ការកាន់កាប់លើអចលវត្ថុ បាន ៣១៩៦៥បណ្ណ និងចែកដីប្រទានកម្មរបស់រដ្ឋជូនប្រជាពលរដ្ឋដែលស្ថិតនៅក្នុងស្ថានភាពក្រីក្របានចំនួន ៦២៧៥គ្រួសារ។ ជាមួយគ្នានេះដែរ ការផ្លាស់ប្តូរកំរិតជីវភាពប្រជាពលរដ្ឋក៏បានបង្ហាញឲ្យឃើញតាមរយៈកំនើនផ្ទះពីឆ្នាំ ២០០៤-២០០៦ គឺអាគារតេដ្ឋ ឬ បេតុង ពី ៤៨,៦៣៨ផ្ទះអាគារ ដល់ ៦៣២១៦ ផ្ទះ អាគារ ហើយចំនួនផ្ទះឈើបានថយចុះពី ១០១៣៦៦ផ្ទះ មក ៩៨៦៣៩ផ្ទះ និងផ្ទះស្លឹកពី ៥៧២៦ផ្ទះ មកត្រឹម ៣៣២៧ផ្ទះ។ នៅក្នុងនោះមានសមិទ្ធផលជាច្រើនផងដែរលេចជារូបរាងតាមរយៈគម្រោងរៀបចំដីធ្លី និងលំនៅដ្ឋាននៃទស្សនវិស័យទី១ របស់សាលារាជធានី ទាំងទៅលើការរៀបចំតំបន់សំណង់អាគារខ្ពស់ៗ តំបន់ផ្ទះល្វែង ការរៀបចំបណ្តាញខៀវ និងបៃតង ការរក្សាបេតិកភ័ណ ព្រមទាំងស្ពាន ផ្លូវថ្នល់ជាដើម។ ជាក់ស្តែង អាគារខ្ពស់ៗជាច្រើនកំពុងសំញែងខ្លួននៅក្នុងរាជធានីភ្នំពេញដូចជា( អាគារកាណាឌីយ៉ា វិមានវឌ្ឍនៈ...)។ មិនតែប៉ុណ្ណោះចំពោះការរៀបចំសណ្តាប់ធ្នាប់នៅរាជធានីភ្នំពេញទៅលើសំណង់ និងលំនៅដ្ឋាន ដោយធ្វើការលុបបំបាត់នូវសំណង់អាណាធិបតេយ្យ និងការតាំងលំនៅ តាមបណ្តាយច្រាំងទន្លេ ការកែលម្អនូវប្រព័ន្ធលូនានា ក៏ទទួលបានលទ្ធផលល្អប្រសើរដែរ។ ពេលឃើញថារាជធានីភ្នំពេញនៅពេលបច្ចុប្បន្នភាពមានបែងចែកនូវតំបន់ផ្ទះល្វែង តំបន់ផ្ទះវីឡា ពោលគឺមានការអនុញ្ញាតឲ្យឯកជនធ្វើការសាងសងលំនៅដ្ឋានជាលក្ខណៈបុរីដូចជា បុរីពិភពថ្មី ប៉េងហួតជាដើម។ រីឯការលុបបំបាត់សំណង់អាណាធិបតេយ្យគឺ អនុវត្តបាននៅលើតំបន់បុរីកីឡា តំបន់បឹងកក់ តំបន់ទន្លេសាប ហើយធ្វើការអភិវឌ្ឍន៍ទៅជា ទីតាំងមួយដែលមានភាពទាក់ទាញ ចំណាប់អារម្មណ៍និងមានសណ្តាប់ធ្នាប់។

### ២. ២.២សមិទ្ធផលរបស់រាជរដ្ឋាភិបាល

រដ្ឋបាលរាជធានីភ្នំពេញក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល បានខិតខំអនុវត្តតាមតួនាទីភារកិច្ច អភិវឌ្ឍ កែលំអ រាជធានីភ្នំពេញ ដើម្បីអោយសាកសមជាបេះដូងនៃព្រះរាជាណាចក្រ

កម្ពុជា ក្នុងន័យជាទីតាំងរដ្ឋបាលប្រមូលផ្តុំផង ជាតំបន់ទេសចរណ៍វប្បធម៌ និងប្រវត្តិសាស្ត្រ និងជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ជំរុញកំណើនសេដ្ឋកិច្ច និងដំណើរការនៃកិច្ចអភិវឌ្ឍជាតិប្រកបដោយចីរភាព ក្នុងអត្ថន័យនេះ រដ្ឋបាលរាជធានីភ្នំពេញ សម្រេចបានសមិទ្ធផលធំៗជាច្រើន ដែលមានដូចជា

- ការកសាងស្ពានអាកាសតាមកន្លែងចរាចរប្រមូលផ្តុំដែលងាយបង្កការស្ទះចរាចរ ដូចជា ស្ពានអាកាសក្បាលថ្នល់ ស្ពានអាកាសស្ទឹងមានជ័យ ស្ពានអាកាសតិចណូ ស្ពានអាកាសពេទ្យលោកសង្ឃជាដើម ។
- បន្តកសាង និងកែលំអផ្លូវនានាក្នុងរាជធានីភ្នំពេញ ដែលមានមន្ទីរសាធារណការរាជធានីភ្នំពេញ ជាអង្គភាពសាមីុ ធ្វើការអនុវត្តផែនការអភិវឌ្ឍរាជធានីភ្នំពេញអោយកាន់តែល្អប្រសើរ ។
- យកចិត្តទុកដាក់កែលំអ ប្រព័ន្ធលូបង្ហូរទឹក ដើម្បីកាត់បន្ថយការជន់លិចនៅពេលមានភ្លៀងធ្លាក់ ពិនិត្យស្តារស្ថានភាពតាមបណ្តា ស្ថានីយ៍បូមទឹកកខ្វក់ និងបូមទឹកបញ្ចេញក្រុង ។
- រៀបចំបន្តការតម្លើងបង្គោលភ្លើងបំភ្លឺតាមផ្លូវសាធារណៈ តាមសួនច្បារសារធាណៈ កែលម្អភ្លើងសញ្ញាចរាចរ ស្លាកសញ្ញាចរាចរ និងគំនូសសញ្ញាចរាចរ ដើម្បីពង្រឹងការអនុវត្តច្បាប់ចរាចរ ក្នុងឱកាសដែលច្បាប់ចរាចរថ្មីកំពុងចូលជាធរមាននេះផងដែរ ។
- បន្តរៀបចំសួនច្បារ តាមទីតាំងសារធារណៈមួយចំនួនដើម្បីប្រជាពលរដ្ឋងាយស្រួលលំហែរ និងអាចយកជាទីតាំងហាត់ប្រាណផងដែរ ។
- ផ្តល់ភាពងាយស្រួលជូនបណ្តាវិនិយោគិន ជាតិ និងអន្តរជាតិ ដែលមានបំណងវិនិយោគសាងសង់អាគារទំនើបៗ សំណង់ពាណិជ្ជកម្ម លំនៅដ្ឋាននានា ក្នុងគោលដៅសោភ័ណ្ឌភាព និងភាពស៊ីវិល័យ នៃរាជធានីភ្នំពេញ ។

ខាងលើនេះគឺជាសមិទ្ធផលដែលខ្ញុំលើកយកមកបង្ហាញជាសង្ខេបដើម្បីភ្ជាប់ទៅនឹងទិសដៅជាយុទ្ធសាស្ត្រអភិវឌ្ឍទីក្រុង ក៏ដូចជាគោលដៅជាអាទិភាពដែលរដ្ឋបាលរាជធានីភ្នំពេញបានអនុវត្ត កំពុងអនុវត្ត និងបន្តអនុវត្ត នាពេលបច្ចុប្បន្ន ។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី ការរៀបចំរាជធានីភ្នំពេញឲ្យមានលក្ខណៈស្តង់ដារួចមកយើងឃើញថា កត្តាដែលធ្វើឲ្យរាជធានីមានភាពរីកចម្រើននោះមានតែការអនុវត្តឲ្យបានត្រឹមត្រូវទៅតាម ប្លង់គោលរាជធានីដែលដាក់ចេញដោយរាជរដ្ឋាភិបាលក្នុងគោលដៅ ធ្វើឲ្យមានការរីកចម្រើនតាមរយៈការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ឲ្យមានលក្ខណៈសណ្តាប់ធ្នាប់ និង សោភ័ណភាព ។ ការដាក់ចេញប្លង់គោលអាចនិងមិនមានលក្ខណៈពេញលេញទាំងស្រុងនោះទេ ប្រសិនបើមិនមានលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀតដើម្បីជំរុញក្នុងការអនុវត្តដូចជា ផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ជាតិ ។ ជាងនេះដែរការអភិវឌ្ឍន៍រាជធានីភ្នំពេញឲ្យមានលក្ខណៈល្អប្រសើរក៏ទាមទារឲ្យរាជរដ្ឋាភិបាលយកចិត្តទុកដាក់ទៅ កត្តាប្រវត្តិសាស្ត្រដែលជាកត្តាលីករមួយជំរុញឲ្យមើលឃើញពីកត្តាមួយចំនួនដែលប្រមុខថ្នាក់ដឹកនាំ នាសម័យនោះយកមកប្រើប្រាស់សម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេសឲ្យមានភាពរីកចម្រើន ទាំងនេះមិនមែនសបញ្ជាក់ទាំងស្រុងថារាជរដ្ឋាភិបាលត្រូវតែអនុវត្តឲ្យបានទាំងស្រុងនោះទេ ក៏ប៉ុន្តែវាគ្រាន់តែជាគោលគំនិតមួយចំនួនដែលគួរតែលើកយកមកអនុវត្តឲ្យរាជធានីភ្នំពេញមានការអភិវឌ្ឍ ។ ជាងនេះទៅទៀត ការចូលរួមពីសំណាក់អង្គភាពពាក់ព័ន្ធ និងសកលភាវូបនីយកម្មជាកត្តាដែលនាំឲ្យមានការរៀបចំរាជធានីនោះទៀតសោត ក៏មិនទាន់មានលក្ខណៈសំខាន់ដូចជាការការចូលរួមពីសំណាក់សាលារាជធានីភ្នំពេញខ្លួនឯងផ្ទាល់ដែលជាស្ថាប័នសាមីក្នុងការលុបបំបាត់នូវភាពអនាធិបតេយ្យនៅក្នុងរាជធានី ការកែលម្អប្រព័ន្ធលូ ផ្លូវថ្នល់ សួនច្បារជាដើម។ល។

ជាក់ស្តែងការរៀបចំរាជធានីឲ្យមានលក្ខណៈស្តង់ដា បានទទួលផលប្រយោជន៍ជាច្រើនសម្រាប់ប្រជាជន និងប្រទេសជាតិទាំងមូលព្រោះថារាជធានីភ្នំពេញគឺជាបេះដូងនៃប្រទេសកម្ពុជាទាំងមូល ។ ដូច្នេះការរៀបចំវាឲ្យមានលក្ខណៈល្អនោះវាបានហុចផលជាច្រើនដល់ការអភិវឌ្ឍប្រទេសជាតិតាមកំណើនវិស័យទេសចរណ៍ កិច្ចសហប្រតិបត្តការអន្តរជាតិជាច្រើន ក៏ដូចជាការលើកកិត្យានុភាពមុខមាត់ប្រទេសកម្ពុជា ឲ្យទៅសកលលោកបានដឹងថាប្រទេសកម្ពុជាជាប្រទេសដែលមាននូវបរិស្ថានស្អាត សុខសុវត្ថិភាព ការរៀបរយនៃសំណង់ ហេដ្ឋារចនាសម្ព័ន្ធមានការលូតលាស់ ដែលកត្តាទាំងនេះហើយជាកត្តាលីករជំរុញឲ្យប្រទេសមានការអភិវឌ្ឍ។ ការធ្វើកំណែទម្រង់ហេដ្ឋារចនាសម្ព័ន្ធពិតណាស់មិនអាចជៀសផុតពីការរងការប៉ះពាល់ជាមួយ និងមជ្ឈដ្ឋានប្រជា-ពលរដ្ឋបានទេ ក៏ប៉ុន្តែយ៉ាងណានោះវាទាមទារឲ្យរាជរដ្ឋាភិបាលគួរតែមានយុទ្ធការក្នុងការដោះស្រាយនូវផលប៉ះពាល់ដែលរងពីការរៀបចំហេដ្ឋារចនាសម្ព័ន្ធនោះ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីស្រាវជ្រាវលើប្រធានបទខាងលើនេះរួចមក នាងខ្ញុំអាចផ្តល់ជាអនុសាសន៍ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបានកើតឡើងនាពេលបច្ចុប្បន្នដែលនាំអោយមាន ភាពយឺតយ៉ាវក្នុងការជម្រុញការរៀបចំរាជធានីរបស់យើងអោយមានសោភណ្ឌភាពប្រសើរ និងអោយកាន់តែសាកសមជាបេះដូង នៃព្រះរាជាណាចក្រកម្ពុជារបស់យើង ។ អនុសាសន៍ទាំងនោះរួមមានៈ

ជម្រុញអោយមានការគ្រប់គ្រងសម្រាម អោយបានត្រឹមត្រូវទាំងការវេចខ្ចប់ទាំងការដឹកជញ្ជូន បញ្ចៀសអោយបានការប្រមូលសម្រាមដោយខ្ជីខ្ជារ ដែលប្រការនេះយើងក្រឡេកមកមើលទិដ្ឋភាពបច្ចុប្បន្នការប្រមូលសម្រាមរបស់ ក្រុមហ៊ុនឯកជនដែលគ្រប់គ្រងការប្រមូលសម្រាមក្នុងរាជធានីយើងគឺមានភាពរញ៉េរញ៉ៃ មិនយកចិត្តទុកដាក់ ចំពោះឧបករណ៍ទៀតសោត គឺមានសភាពចាស់ដែលបណ្តាលអោយកាកសំណល់ខ្លះត្រូវបានជ្រុះរាយប៉ាយ តាមផ្លូវដែលរថយន្តប្រមូលសម្រាមនោះឆ្លងកាត់ ធ្វើអោយរាជធានីយើងមានភាពកខ្វក់ កន្លែងខ្លះមានក្លិនមិនល្អដោយសារការប្រមូលមិនអស់ ការជ្រុះសម្រាមចេញពីឡាន មកវិញ ។ ប្រការទាំងនេះហើយដែលយើងអាចនិយាយជារួមថាវាបណ្តាអោយបរិយាកាស ក្នុងរាជធានីយើងមិនល្អ ទាំងនេះគឺសុទ្ធតែត្រូវមានការកែប្រែជាមុនសិន មុននឹងយើងទៅគិតដល់បញ្ហាហេដ្ឋារចនាសម្ព័ន្ធជារូបវន្ត ព្រោះបញ្ហាបរិយាកាសល្អ បរិស្ថានល្អជាហេតុនាំអោយការរស់នៅក្នុងរាជធានីមានផាសុកភាព មានសុខភាពទើបមនុស្សគិតដល់បញ្ហាផ្សេងៗទៀតបាន ។ ចំនុចនេះគឺយើងត្រូវដោះស្រាយយ៉ាងណាធ្វើអោយរាជធានីយើងគ្មានការបំពុលទាំង៣ដែលមានដូចជា បំពុលដី បំពុលទឹក បំពុលខ្យល់ ដែលការបំពុលទាំង៣នេះគឺបណ្តាមកពីសម្រាមដូចនេះយើងត្រូវយកចិត្តទុកដាក់ធ្វើអោយបានល្អជាទីបំផុតលើបញ្ហានេះ ។

ជម្រុញការអនុវត្តលិខិតអនុញ្ញាតសាងសង់ បញ្ចៀសអោយខានតែបានការសាងសង់ដែលមិនសុំលិខិតអនុញ្ញាតសាងសង់ ការសាងសង់មិនគោរពអ្វីដែលបានកំណត់ក្នុងលិខិតអនុញ្ញាតសាងសង់ ដែលនាំអោយមានភាពអណាធិបតេយ្យក្នុងការសាងសង់សំណង់ ជាពិសេសនៅទីប្រជុំជន់សំខាន់ ដើម្បីធានាបាននិរន្តរភាពនៃសំណង់ (អោយសង់រួចក្រោយមកអោយវាយកម្ទេចចេញវិញ) ដែលនាំអោយមានភាពមិនពេញចិត្តពីប្រជាពលរដ្ឋ ។ ហើយការអនុវត្តចំណុចនេះទៀតសោតគឺត្រូវអនុវត្តដោយស្មើភាព គ្មានស្តង់ដារពីនៃការអនុវត្ត ទើបការអនុវត្តនោះមានប្រសិទ្ធិភាព និងអាចទទួលយកបានពីគ្រប់ភាគី ។

ជម្រុញការអនុវត្តដែលគោរពតាមប្លង់គោលរាជធានី អោយបានត្រឹមត្រូវស្របតាមអ្វីដែលបានកំណត់ទុកទាំងការអនុញ្ញាតសាងសង់សំណង់ ទាំងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍរាជធានីដែលប្រការនេះវានឹងធ្វើអោយ រាជធានី មានស្តង់ដារមួយដោយជាក់លាក់ ។

# ඩෂසායොව

## ឯកសារយោង


១. ច្បាប់ភូមិបាលចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១

២. ច្បាប់ស្តីពីការរៀបចំទឹកដី នគររូបនីយកម្ម និងសំណង់ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤

៣. អនុក្រឹត្យលេខ ១៨១ អនក្រ.បក ស្តីពីការដាក់ឲ្យប្រើប្រាស់ដីរាជធានីចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១៥

៤.គោលនយោបាយប្រជាជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១

៥.គោលនយោបាយប្រជាជាតិស្តីពី លំនៅស្ថាន ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៤

៦. ច្បាប់ស្តីពីការសិទ្ធិកម្មសិទ្ធលើចំណែកឯកជននៃអាគារសហកម្មសិទ្ធដល់ជនបរទេស ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០

៧. អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅឃុំសង្កាត់ ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០០៩

៨. សេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ និងផែនការប្រើប្រាស់ដីរាជធានី ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤

៩. អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

១០. យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០០៨

១១. គម្រោងប្លង់គោលរាជធានីភ្នំពេញ ឆ្នាំ២០០០

១២. គម្រោងប្លង់គោលរាជធានីភ្នំពេញ ឆ្នាំ២០៣៥

១៣. ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០

១៤. សៀវភៅនីតិនគររូបនីយវិទ្យារៀបរៀងដោយ សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា

១៥.សៀវភៅអរិយធម៌ខ្មែរ និពន្ធដោយលោកស្រី ត្រឹង ងារ

១៦. ប្រវត្តិសាស្រ្តនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១២ ឥន្ទ ឱមសាម៉េង

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធជារូបភាព**

ឧបសម្ព័ន្ធទី ១ យុទ្ធសាស្ត្រចតុកោណ នៃរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធទី២ និមិត្តសញ្ញា នៃសាលារាជធានីភ្នំពេញ

ឧបសម្ព័ន្ធទី ៣ ការរៀបចំបណ្ដាញខៀវ និងបៃតងនៃរាជធានីភ្នំពេញ

ឧបសម្ព័ន្ធទី ៤ ការរុះរើអាគារប៊ូឌិញ

ឧបសម្ព័ន្ធទី៥ សំណង់អាគារខ្ពស់នៅរាជធានីភ្នំពេញ

ឧបសម្ព័ន្ធទី៦ ផែនទីប្លង់គោលអភិវឌ្ឍរាជធានីឆ្នាំ២០៣៥

ឧបសម្ព័ន្ធទី៧ ការកែលម្អទ្រូងផ្លូវ

ឧបសម្ព័ន្ធទី ៨ ការកែលម្អប្រព័ន្ធលូ

ឧបសម្ព័ន្ធទី៩ ការកែលម្អពង្រីកផ្លូវ

ឧបសម្ព័ន្ធទី១០ ស្ថានភាពសាងសង់តំបន់បឹងកក់

ឧបសម្ព័ន្ធទី១១ ផែនទីបណ្ដាញខៀវ និងបៃតង

- **ឧបសម្ព័ន្ធជាលិខិតបទដ្ឋានគតិយុត្តិ**

ឧបសម្ព័ន្ធទី១ គោលនយោបាយ ស្ដីពី ការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធទី២ គោលនយោបាយជាតិ ស្ដីពី លំនៅឋាន

ឧបសម្ព័ន្ធទី៣ ក្របខណ្ឌយុទ្ធសាស្ត្រជាតិ ស្ដីពី ការអភិវឌ្ឍទីក្រុង

ឧបសម្ព័ន្ធទី៤ អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្ដីពី លិខិតអនុញ្ញាតសាងសង់

# ឧបសម្ព័ន្ធជារូបភាព

# ឧបសម្ព័ន្ធទី១

## យុទ្ធសាស្ត្រចតុកោណនៃរាជរដ្ឋាភិបាល

គំនូសបំព្រួញស្តីពី " យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៣"



# ឧបសម្ព័ន្ធទី ២

## និមិត្តសញ្ញានៃសាលារាជធានីភ្នំពេញ

សាលារាជធានីភ្នំពេញ

# ឧបសម្ព័ន្ធទី៣

ការរៀបចំបណ្ដាញខៀវ និងបៃតងក្នុងរាជធានីភ្នំពេញ





# ឧបសម្ព័ន្ធទី៤

## ការរុះរើអាគារប៊ូឌិញ





# ឧបសម្ព័ន្ធទី៥

## សំណង់អាគារខ្ពស់នៅរាជធានីភ្នំពេញ



# ឧបសម្ព័ន្ធទី៦

## ផែនទីប្លង់គោលអភិវឌ្ឍរាជធានីឆ្នាំ២០៣៥



# ឧបសម្ព័ន្ធទី៧

## ការកែលម្អទ្រូងផ្លូវ






# ឧបសម្ព័ន្ធទី ៨

## ការកែលម្អប្រព័ន្ធលូ






# ឧបសម្ព័ន្ធទី៩

## ការកែលម្អពង្រីកផ្លូវ





# ឧបសម្ព័ន្ធទី១០

## ស្ថានភាពសាងសង់តំបន់បឹងកក់






# ឧបសម្ព័ន្ធទី១១

ផែនទីបណ្តាញខៀវ និង បណ្តាញបៃតង



# ឧបសម្ព័ន្ធជាឯកសារគតិយុត្តិ

# ឧបសម្ព័ន្ធទី ១

# គោលនយោបាយជាតិ

# ស្តីពី ការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល

# គោលនយោបាយជាតិ
# ស្តីពី
# ការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១

រៀបចំដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

# មាតិកា


**១-សេចក្តីផ្តើម**

**២-ចក្ខុវិស័យ**

**៣-គោលបំណង និង គោលដៅ**

៣.១-គោលបំណង

៣.២-គោលដៅ

**៤-យុទ្ធសាស្ត្រនៃការរៀបចំដែនដី**

៤.១- ការអភិវឌ្ឍដែនដីក្នុងព្រះរាជាណាចក្រកម្ពុជា

៤.២- ការកំណត់តំបន់ស្នូល តំបន់អាទិភាពសម្រាប់ការស្នាក់នៅ ប៉ូលអភិវឌ្ឍ និងអ័ក្សនៃការអភិវឌ្ឍ

៤.៣- ការកសាងផែនការគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ច និងឱកាសការងារ

៤.៤- ការកសាងផែនការរៀបចំហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌

៤.៥- ការកសាងផែនការ និងការគ្រប់គ្រងធម្មជាតិដែលទ្រទ្រង់ដល់ជីវិតរស់នៅ

៤.៦- ការកសាងផែនការគ្រប់គ្រងដីព្រៃឈើ ដីកសិកម្ម ជលផល ឧស្សាហកម្ម រ៉ែ ថាមពល និងតំបន់អភិរក្ស

៤.៧- ការកសាងផែនការហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស និងសេវាកម្ម

**៥-ផែនការសកម្មភាព**

៥.១-យន្តការនៃផែនការរៀបចំដែនដី និងឋានានុក្រម

ក-ថ្នាក់ជាតិ

ខ-ថ្នាក់ក្រោមជាតិ

១-ថ្នាក់រាជធានី ខេត្ត

២-ថ្នាក់ក្រុង ស្រុក ខណ្ឌ

៣-នៅថ្នាក់ឃុំ សង្កាត់

៥.២-មូលដ្ឋានគតិយុត្ត និងឧបករណ៍ចាំបាច់នៃការរៀបចំដែនដី

**៦-សេចក្តីសន្និដ្ឋាន**

**វាក្យសព្ទ**

# ១-សេចក្តីផ្តើម

ទឹក និងដី គឺជាធនធានធម្មជាតិដ៏សំខាន់ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងសម្រាប់ទ្រទ្រង់ជីវិត។ ដោយសារកំណើនប្រជាសាស្ត្រ កំណើននៃការប្រើប្រាស់ធនធានធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ គ្រប់ស្ថាប័នពាក់ព័ន្ធទឹកនិងដី ត្រូវមានយន្តការដឹកនាំការគ្រប់គ្រង និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងចីរភាព ពិសេសវិស័យកសិកម្ម ព្រៃឈើ ជលផល ធនធានទឹក រ៉ែ ទេសចរណ៍ ឧស្សាហកម្ម ការដឹកជញ្ជូន ការរៀបចំទីក្រុង ជនបទ និងសំណង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម។ ការងារនេះ តម្រូវឲ្យមានការឯកភាពគ្នា និងមានការប្តេជ្ញាចិត្តពីគ្រប់ស្ថាប័ន ប្រជាជន និងអ្នកទទួលផលប្រយោជន៍ផ្សេងៗ សំដៅធានាបាន នូវជំនឿទុកចិត្ត ការទទួលខុសត្រូវរួមគ្នា មានតម្លាភាព និងមានប្រសិទ្ធភាពនៅក្នុងការគ្រប់គ្រង ការប្រើប្រាស់ និងការអភិវឌ្ឍដីធ្លី និងធនធានធម្មជាតិឲ្យមានចីរភាព និងចំសក្តានុពល។

ដោយឡែក ក្នុងបរិបទនៃសកលភាវូបនីយកម្ម ការរៀបចំដែនដី ដែលជាផ្នែកចម្បងមួយនៃគោលនយោបាយដីធ្លី ត្រូវមានលក្ខណៈទន់ភ្លន់ និងតម្រង់ទិសគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមឲ្យមានប្រសិទ្ធភាព និងចីរភាព។ នេះជាប្រការដ៏សំខាន់ចំពោះព្រះរាជាណាចក្រកម្ពុជាដែលទើបទទួលបាននូវសុខសន្តិភាព ឯកភាពជាតិនិងទឹកដី និងមានគោលដៅយុទ្ធសាស្ត្រដើម្បីបន្តពង្រឹងការបង្រួបបង្រួមសង្គមកម្ពុជាទាំងមូល ការធ្វើសមាហរណកម្មសេដ្ឋកិច្ចផ្ទៃក្នុង ការថែរក្សា និងការពង្រឹងស្មារតីសាមគ្គីភាព ការស្រឡាញ់ទឹកដី ធនធានធម្មជាតិ វប្បធម៌ អរិយធម៌ជាតិ ដែលបានបាក់ស្រុតដោយសង្គ្រាមអូសបន្លាយអស់រយៈពេលរាប់ទសវត្ស និងការបំផ្លិចបំផ្លាញធ្វើឲ្យក្រឡាប់ចាក់សង្គមទាំងមូល និងការសម្លាប់រង្គាលដ៏ឃោរឃៅក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត។ ដូច្នេះការរៀបចំដែនដី ត្រូវផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី ព្រមទាំងតម្រង់ទិសទៅរកការអភិវឌ្ឍភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង ខេត្ត រាជធានី និងប្រទេសទាំងមូល សំដៅពង្រឹងមូលធនសង្គម កសាងទំនាក់ទំនងក្នុងសង្គមឲ្យកាន់តែជិតស្និទ្ធ តាមរយៈការផ្តល់សេវាកម្មផ្សេងៗខាងសេដ្ឋកិច្ច សង្គម ការកំសាន្ត ទេសចរណ៍។ល។

# ២-ចក្ខុវិស័យ

ចក្ខុវិស័យនៃគោលនយោបាយជាតិរៀបចំដែនដី សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឲ្យរលូននូវវិធាន និងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។ ក្នុងន័យនេះ គោលនយោបាយជាតិរៀបចំដែនដីគប្បីបញ្ចៀសឲ្យបាននូវការខ្វែងគំនិតយោបល់គ្នា ដោយត្រូវគោរពទៅតាមឋានានុក្រមនៃផែនការ (ថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ) ហើយត្រូវមានបញ្ញត្តិកំណត់ជាក់លាក់នូវមុខងារនៃដីក្នុងទីតាំងនីមួយៗ និងការប្រើប្រាស់ដី។

# ៣-គោលបំណង និងគោលដៅ

## ៣.១- គោលបំណង

**គោលបំណង** នៃគោលនយោបាយជាតិរៀបចំដែនដី គឺ ៖

- ធានាការប្រើប្រាស់ដី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព ចីរភាព និងសមធម៌ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ការធានាសន្តិសុខស្បៀង កិច្ចការពារជាតិ និងលំនឹងធម្មជាតិ
- តម្រង់ទិសដល់ការអភិវឌ្ឍជាតិឲ្យមានតុល្យភាពនៅទូទាំងប្រទេសលើផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសង្គម សេដ្ឋកិច្ចនិងបរិស្ថាន និងមានភាពងាយស្រួលដល់ការទាក់ទងពីតំបន់មួយទៅតំបន់មួយទៀតនៅក្នុងប្រទេស ក្នុងតំបន់ និងអន្តរជាតិ
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងគោលនយោបាយតាមវិស័យ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ។

## ៣.២- គោលដៅ

**គោលដៅ** នៃគោលនយោបាយជាតិរៀបចំដែនដី គឺសំដៅ ៖

- អភិវឌ្ឍប្រកបដោយចីរភាព ដោយធានាបាននូវការផ្គត់ផ្គង់សេចក្តីត្រូវការ និងការទទួលខុសត្រូវ ចំពោះផលប្រយោជន៍របស់មនុស្សបច្ចុប្បន្ន និងមនុស្សជំនាន់ក្រោយ
- គ្រប់គ្រង ការពារ ប្រើប្រាស់ និងអភិវឌ្ឍធនធានធម្មជាតិ ដោយកំណត់ឲ្យច្បាស់លាស់ជាមុននូវទីតាំងឬតំបន់ដែលប្រើប្រាស់សម្រាប់ការអភិវឌ្ឍ
- រក្សានូវការប្រើប្រាស់ដីធ្លីសម្រាប់រយៈពេលវែង ដើម្បីឲ្យមានតុល្យភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន
- ប្រើប្រាស់នូវសក្តានុពលជាអំណោយផលធម្មជាតិនៃដី និងជាសេចក្តីត្រូវការនៃការអភិវឌ្ឍ និងធ្វើឲ្យប្រសើរឡើងនូវលក្ខណៈភូមិសាស្ត្រពិសេសដោយឡែកៗ តាមបរិបទនៃតំបន់នីមួយៗនៅក្នុងប្រទេស
- លើកកម្ពស់កម្រិតជីវភាពប្រជាជនឲ្យកាន់តែប្រសើរឡើង និងកាត់បន្ថយជាអតិបរមានូវគម្លាតរវាងតំបន់ផ្សេងៗទូទាំងប្រទេស
- ធានាការប្រើប្រាស់ ការអភិវឌ្ឍ និងការគ្រប់គ្រងដី តាមផែនការរៀបចំដែនដី និងផែនការប្រើប្រាស់ដីប្រកបដោយសមធម៌ សមភាពយេនឌ័រ ព្រមទាំងការការពារ និងគាំទ្រដល់ជីវភាពរស់ នៅរបស់សហគមន៍ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះ
- រៀបចំបន្សុីការគ្រប់គ្រង ការអភិវឌ្ឍ និងការការពារតំបន់នីមួយៗ ឲ្យស្របទៅនឹងលក្ខខណ្ឌ និងកត្តាតម្រូវនៃការរៀបចំដែនដីទូទាំងប្រទេស ដោយពិចារណាអំពីលក្ខខណ្ឌ និងកត្តាតម្រូវនៃតំបន់ជាក់លាក់នីមួយៗ ដើម្បីឲ្យផែនការរៀបចំដែនដីនោះអាចអនុវត្តទៅបានដោយរលូន
- ទប់ស្កាត់ និងកាត់បន្ថយនូវហានិភ័យនៃគ្រោះធម្មជាតិ ដែលបណ្តាលមកពីគម្រោងផែនការអភិវឌ្ឍ។

ដើម្បីសម្រេចបាននូវគោលបំណង និងគោលដៅខាងលើ ការរៀបចំដែនដីត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម ៖

- ការចូលរួមស្របតាមលទ្ធិប្រជាធិបតេយ្យ និងតម្លាភាព
- ភាពស្របច្បាប់ ដើម្បីធានាបាននូវយុត្តិធម៌ និងការគោរពសិទ្ធិមនុស្ស
- គោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ
- ការលើកកម្ពស់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលធនធាន ឬសមត្ថភាព នៅមានកម្រិត
- អភិបាលកិច្ចល្អក្នុងដំណើរការធ្វើផែនការ និងលើកកម្ពស់ការស្រុះស្រួលគ្នា

- ការឯកភាពគ្នាលើឋានានុក្រមនៃផែនការ (ថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ) និងវិធីសាស្ត្រនៃការធ្វើផែនការ
- ការគោរពលក្ខណៈទ្វេទិស (ពីក្រោមទៅលើ/ពីលើមកក្រោម) នៃរាល់ការសម្រេចចិត្ត
- ការធ្វើសមាហរណកម្មគ្រប់ថ្នាក់ គ្រប់វិស័យ និងតំបន់ភូមិសាស្ត្រដែលមានទំនាក់ទំនងនឹងគ្នា
- រក្សាតុល្យភាពរវាងការអភិវឌ្ឍ និងការបែងចែកផលដែលទទួលបានដល់គ្រប់តំបន់
- ការផ្ដល់អាទិភាពលើផែនការអភិវឌ្ឍតំបន់ងាយរងគ្រោះ ជាពិសេសតំបន់ដែលនឹងអាចរងគ្រោះ និងក្បែរៗនោះ ឲ្យទាន់ពេលវេលា និងដោយប្រុងប្រយ័ត្ន
- ការរក្សាតុល្យភាពរវាងការប្ដេជ្ញាចិត្ត និងភាពបត់បែននៃគោលនយោបាយ និង
- ការប្រើប្រាស់ផែនទីដែលមានទិន្នន័យយោងមួយឯកភាពគ្នា។

# ៤-យុទ្ធសាស្ត្រនៃការរៀបចំដែនដី

## ៤.១- ការអភិវឌ្ឍដែនដីក្នុងព្រះរាជាណាចក្រកម្ពុជា

ដើម្បីរក្សាតុល្យភាពរវាងការពង្រីកទីក្រុងទៅលើតំបន់ជនបទ និន្នាការនៃការពង្រីកទីក្រុងដែល ពុំមានផែនការច្បាស់លាស់ត្រូវតែបញ្ឈប់។ ការពង្រីកទីក្រុងត្រូវមានទស្សនាទាននៃការធ្វើសមាហរណកម្មទីក្រុង និងជនបទដើម្បីកាត់បន្ថយអតុល្យភាពនៃសក្ដានុពលដែលមានស្រាប់ហើយ។ សម្រាប់តំបន់ទីក្រុង ដែលបានរៀបចំជាមជ្ឈមណ្ឌលរដ្ឋបាល ការស្នាក់នៅ ការផលិត និងសេវាកម្ម ត្រូវគិតគូរដោះស្រាយទំនោរនៃភាពកកស្ទះ និងពង្រីកលទ្ធភាពនៃការអភិវឌ្ឍ តាមរយៈការបង្កើតប្រព័ន្ធទីក្រុង ដែលមានបណ្ដាញគមនាគមន៍ផ្សារភ្ជាប់គ្នា។ ចំពោះតំបន់ជនបទគួរត្រូវបានរក្សាលំនឹង និងអភិវឌ្ឍសក្ដានុពលរបស់ខ្លួន ដើម្បីពង្រឹងឲ្យមានឯករាជភាពជាតំបន់ស្នាក់នៅតំបន់សម្បទានដីសង្គមកិច្ច និងសម្បទានដីសេដ្ឋកិច្ច។ ដូច្នេះការធ្វើវិមជ្ឈការផែនការរៀបចំដែនដីរួមទាំងសេវាកម្មគួរត្រូវបានពង្រីក និង ពង្រឹងដើម្បីកសាងសមត្ថភាពស្ថាប័នគ្រប់គ្រងក្នុងមូលដ្ឋាននិងប្រើប្រាស់ឲ្យមានប្រសិទ្ធភាពនូវតំបន់ដែលបានអភិវឌ្ឍនានា។

## ៤.២- ការកំណត់តំបន់ស្នូល តំបន់អាទិភាពសម្រាប់ការស្នាក់នៅ ប៉ូលអភិវឌ្ឍ និងអ័ក្សនៃការអភិវឌ្ឍ

ការរៀបចំដែនដីនៅប្រទេសកម្ពុជាធ្វើឡើងក្នុងក្របខណ្ឌទូទាំងប្រទេស ដើម្បីធានាបាននូវចីរភាព សមធម៌ តុល្យភាព និងការធ្វើសមាហរណកម្មទាំងក្នុងប្រទេស ក្នុងតំបន់ និងក្នុងក្របខណ្ឌអន្តរជាតិ។ ដោយធនធានមានកំណត់ និងដើម្បីធានានូវការផ្គត់ផ្គង់ ការរៀបចំដែនដីត្រូវធ្វើទៅតាមលំដាប់នៃអាទិភាពចំពោះតំបន់ដែលមានកំណើនប្រជាជន និងសេដ្ឋកិច្ចខ្ពស់មានជាអាទិ៍ ប៉ូលអភិវឌ្ឍរាជធានីភ្នំពេញ ប៉ូលអភិវឌ្ឍសៀមរាប និងប៉ូលអភិវឌ្ឍព្រះសីហនុ គឺជាប៉ូលនៃកំណើនខ្ពស់ដែលបានលេចចេញជារូបរាងពិតប្រាកដតាមរយៈសក្ដានុពល និងសកម្មភាពព្រមទាំងអ័ក្សនៃការអភិវឌ្ឍរួមមានអ័ក្សភ្នំពេញ-ព្រះសីហនុ តាមបណ្ដោយផ្លូវជាតិលេខ៤ ឬភ្នំពេញ-តំបន់ឆ្នេរ តាមបណ្ដោយផ្លូវជាតិ លេខ៣ និងលេខ៤ អ័ក្សភ្នំពេញ-សៀមរាប តាមបណ្ដោយផ្លូវជាតិលេខ៦ អ័ក្សភ្នំពេញ-បាវិត តាមបណ្ដោយផ្លូវជាតិលេខ១ អ័ក្សភ្នំពេញ-ប៉ោយប៉ែត តាមបណ្ដោយផ្លូវជាតិលេខ៥ អ័ក្សភ្នំពេញ-ភូមិភាគឦសាន ភ្ជាប់ទៅប្រទេសវៀតណាម និងឡាវ តាមបណ្ដោយផ្លូវជាតិលេខ៦ និងលេខ៧ និងអ័ក្សតំបន់ឆ្នេរ ដែលភ្ជាប់ពីប្រទេសថៃ កាត់តាមខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែបទៅប្រទេសវៀតណាម គឺជាអ័ក្សដែលស្ថិតនៅក្នុងក្របខណ្ឌជាតិ និងក្របខណ្ឌតំបន់ និងអន្តរជាតិ ដូចជាអាស៊ាន និងមហាអនុតំបន់ទន្លេមេគង្គ ជាមួយគ្នានេះមានអ័ក្សនៅតាមបណ្ដោយផ្លូវទឹក រួមមានទន្លេមេគង្គ ទន្លេសាប បឹងទន្លេសាប និងទន្លេបាសាក់។ ដើម្បីទាញយកផលជាអតិបរមា តំបន់ស្នូល ដែលស្ថិតនៅតាមបណ្ដោយអ័ក្សនៃការអភិវឌ្ឍនេះ រួមជាមួយនឹងតំបន់

ស្នូលជាយុទ្ធសាស្ត្រជួរមុខ នៅតាមបណ្ដោយព្រំដែន គួរត្រូវបានយកចិត្តទុកដាក់ខ្ពស់ផងដែរ។ ដោយឡែករាជរដ្ឋាភិបាលកំពុងជំរុញយុទ្ធសាស្ត្រ ដើម្បីឲ្យលេចចេញជាប៉ូលមួយទៀតនៅភូមិភាគឦសាននាពេលអនាគត ដោយមានកិច្ចសហការឲ្យមានជាតំបន់ត្រីកោណក្នុងក្របខណ្ឌតំបន់ និងអន្តរជាតិ។

ថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលទទួលបន្ទុកក្នុងការរៀបចំដែនដី និងផែនការប្រើប្រាស់ដីជាអ្នកទទួលខុសត្រូវផ្ទាល់ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ មុខងារ និង ភារកិច្ចជាមូលដ្ឋានមួយចំនួនដែលឃុំមិនអាចធ្វើបាន ត្រូវផ្ដល់ការទទួលខុសត្រូវនៅកម្រិតរដ្ឋបាលថ្នាក់ខ្ពស់ជាង ដែលជាតំបន់ស្នូល ដោយត្រូវបន្សី រវាងតំបន់ស្នូល និងតំបន់ទ្រនាប់ដែលនៅជុំវិញ និងត្រូវតភ្ជាប់គ្នាដោយបណ្ដាញគមនាគមន៍ ដែលជាអ័ក្សនៃការអភិវឌ្ឍ។

វិធានការនៃការរៀបចំដែនដី ក៏ត្រូវពិចារណាលើទិដ្ឋភាពសមធម៌សង្គម ដូចជាតម្រូវការខាងលំនៅឋានសមស្រប និងមានតុល្យភាពរវាងលទ្ធភាពដែលគ្រួសារក្រីក្រ និងអ្នកមានប្រាក់ចំណូលទាប អាចរកបានលំនៅឋានសមរម្យ និងតម្រូវការសេដ្ឋកិច្ចរបស់រដ្ឋ និងផ្នែកឯកជន។ ផែនការអភិវឌ្ឍទីក្រុង ក្រៅពីផ្ដល់ការងារធ្វើ ត្រូវគិតគូរជាអាទិភាពដល់ការរៀបចំកន្លែងសម្រាកលំហែសាធារណៈ ធានាបាននូវការរស់នៅប្រកបដោយគុណភាព សុវត្ថិភាព បរិស្ថានល្អ និងសោភ័ណភាព ព្រមទាំងការកំណត់ តំបន់គ្រប់គ្រងពិសេសសម្រាប់រៀបចំតំបន់ខ្សែក្រវាត់បៃតងក្រុង...។

ការកសាងផែនការ និងការអភិវឌ្ឍលំនៅឋាន ត្រូវផ្សារភ្ជាប់នឹងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចផ្សេងៗ ជាពិសេសតំបន់ឧស្សាហកម្ម ដើម្បីចូលរួមចំណែកដល់ការធ្វើឲ្យមានតុល្យភាពនៃរបាយប្រជាជនទូទាំងប្រទេស និងសមធម៌នៃការទទួលបានផលនៃការអភិវឌ្ឍសេដ្ឋកិច្ច។

**៤.៣- ការកសាងផែនការគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ច និងឱកាសការងារ**

ត្រូវរៀបចំឲ្យមានរចនាសម្ព័ន្ធសេដ្ឋកិច្ចមួយប្រកបដោយតុល្យភាព ដែលអាចធានានូវការអភិវឌ្ឍរយៈពេលវែង ក្នុងបរិបទនៃសកលភាវូបនីយកម្ម និងដើម្បីផ្ដល់នូវកាលានុវត្តភាពសម្រាប់ការបណ្ដុះបណ្ដាល និងការងារធ្វើដល់ប្រជាពលរដ្ឋ។ គោលបំណងសំខាន់គឺដើម្បីចៀសវាងចលនាបម្លាស់ទីរបស់ប្រជាពលរដ្ឋ ក្នុងការស្វែងរកការងារដែលនៅឆ្ងាយពីលំនៅឋាន។ ដូច្នេះ ការកសាងផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ច ត្រូវផ្សារភ្ជាប់នឹងការអភិវឌ្ឍលំនៅឋាន ដើម្បីកាត់បន្ថយការចំណាយលើការធ្វើដំណើរ និង រួមចំណែកកាត់បន្ថយគម្លាតពីតំបន់មួយទៅតំបន់មួយទៀត។

វិធានការសំខាន់ផ្នែកសេដ្ឋកិច្ច គឺការប្រើប្រាស់សក្ដានុពលនៃប្រភេទធនធានធម្មជាតិផ្សេងៗ ដើម្បីបម្រើដល់ការអភិវឌ្ឍវិស័យរ៉ែ ឧស្សាហកម្ម ថាមពល ពាណិជ្ជកម្ម ធុរកិច្ច សេដ្ឋកិច្ចជាតិ និង ទេសចរណ៍។ លក្ខខណ្ឌសមស្រប និងការធ្វើអាជីវកម្មលើធនធានប្រេង ឧស្ម័នធម្មជាតិ និងធនធានរ៉ែផ្សេងៗទៀត ត្រូវគ្រប់គ្រងឲ្យមាននិរន្តរភាព។

**៤.៤- ការកសាងផែនការរៀបចំហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌**

ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋានរបស់មនុស្ស ចាំបាច់ត្រូវពិចារណាលើទិដ្ឋភាពទាំងឡាយមានជាអាទិ៍ កន្លែងលំហែកាយឬកំសាន្ត កន្លែងសម្រាប់លេងកីឡា ទីកន្លែងសាធារណៈ លម្ហបៃតង ជាសួន និងឡានមជ្ឈមណ្ឌលវប្បធម៌ និងសាសនា ការផ្ដល់សុខុមាលភាពដល់មនុស្សគ្រប់វ័យ (កុមារ យុវជន ស្ត្រី បុរស មនុស្សចាស់ ជនពិការ) ឲ្យមានលទ្ធភាពទទួលបាននូវសេវាសុខភាព សេវាអប់រំ...។ល។ ទាំងអស់នេះជាប្រការ+ចាំបាច់ ដើម្បីផ្ដល់នូវការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្សដោយនិរន្តរភាព។

### ៤.៥- ការកសាងផែនការ និងការគ្រប់គ្រងធម្មជាតិ ដែលទ្រទ្រង់ដល់ជីវិតរស់នៅ

បរិស្ថានអំណោយផលល្អ គឺជាការរួមចំណែកជាធាតុដល់ជីវិតរស់នៅរបស់មនុស្សជាតិ។ ដូច្នេះ ចាំបាច់ត្រូវការពារធម្មជាតិនៃប្រព័ន្ធជីវៈចម្រុះ និងទេសភាពធម្មជាតិ ជាពិសេសតំបន់ធម្មជាតិសំខាន់ៗ។ បច្ចុប្បន្នធនធានធម្មជាតិកំពុងប្រឈមនឹងហានិភ័យ និងការបាត់បង់ ដែលបង្កឡើងដោយកត្តាជាច្រើន មានជាអាទិ៍ ភាពក្រីក្រ និងចំណាកស្រុក របស់ប្រជាពលរដ្ឋដែលចាំបាច់ត្រូវចៀសវាង ឬមានវិធានការ ទប់ស្កាត់។ ដូចនេះ ធនធានធម្មជាតិ ដូចជាដី ទឹក ពពួកសត្វ និងរុក្ខជាតិ រួមទាំងធនធានព្រៃឈើ ត្រូវគ្រប់គ្រងឲ្យបានត្រឹមត្រូវ និងស្របតាមគោលការណ៍នៃកិច្ចការពារបរិស្ថាន។

### ៤.៦- ការកសាងផែនការគ្រប់គ្រងដីព្រៃឈើ ដីកសិកម្ម ជលផល ឧស្សាហកម្ម រ៉ែ ថាមពល និងតំបន់អភិរក្ស

ដីកសិកម្ម និងដីព្រៃឈើ ជាប្រភពចម្បងសម្រាប់ផលិតកម្មដំណាំស្បៀង ដំណាំកសិ-ឧស្សាហកម្ម និងសម្រាប់រក្សានូវបរិស្ថានធម្មជាតិ ដែលតម្រូវឲ្យមានការកំណត់និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព តាមរយៈការរៀបចំឲ្យមានបទដ្ឋានគតិយុត្តលើការប្រើប្រាស់ អភិរក្ស ការពារ និងអភិវឌ្ឍ ប្រកបដោយចីរភាព។ ដូច្នេះត្រូវធ្វើការពិនិត្យកែលម្អលើការប្រើប្រាស់ដីកសិកម្ម ដីព្រៃឈើ និងជលផល ឲ្យបានសមស្របក្នុងគោលដៅបង្កើនការវិនិយោគលើវិស័យកសិកម្ម ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ ក៏ត្រូវរៀបចំឲ្យមានការអភិវឌ្ឍឧស្សាហកម្ម រ៉ែ និងថាមពលដែលមិនប៉ះពាល់ ឬអាចមានផលប៉ះពាល់បរិស្ថានតិចបំផុត។

### ៤.៧- ការកសាងផែនការហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស និងសេវាកម្ម

ប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស គឺជាលក្ខខណ្ឌតម្រូវចាំបាច់មួយសម្រាប់ជីវិត សេដ្ឋកិច្ច និងសង្គម និងការធ្វើឲ្យប្រសើរឡើងនូវសមត្ថភាព និងមុខងារនៃការរៀបចំដែនដី។ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនប្រព័ន្ធព័ត៌មាន និងទំនាក់ទំនង ព្រមទាំងការផ្គត់ផ្គង់ថាមពលអគ្គិសនី ទឹកស្អាត និងទូរគមនាគមន៍ ត្រូវតែពង្រឹង និងកែលំអតាមរយៈការស្តារនីតិសម្បទា ឬ/និងការសាងសង់ឡើងវិញ ជាពិសេសត្រូវធានាថាប្រជាពលរដ្ឋនៅតាមតំបន់ជនបទអាចទទួលបាននូវសេវាផ្គត់ផ្គង់ចរន្តអគ្គិសនី ទូរគមនាគមន៍ សេវាសុខភាពសាធារណៈមានគុណភាពទឹកស្អាត និងប្រព័ន្ធអនាម័យត្រឹមត្រូវ។ ដូច្នេះ វិធានការនៃការរៀបចំដែនដីត្រូវគិតគូរជាពិសេសដល់ការអភិវឌ្ឍវិស័យថាមពល និងវិស័យគមនាគមន៍ តាមរយៈការស្តារ និងការសាងសង់រោងចក្រអគ្គិសនី និងបណ្តាញផ្លូវគមនាគមន៍ទូទាំងប្រទេស។

## ៥-ផែនការសកម្មភាព

### ៥.១-យន្តការ ការរៀបចំ និងឋានានុក្រមនៃផែនការរៀបចំដែនដី

អនុលោមតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងផ្អែកលើមូលដ្ឋាននៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ សមត្ថកិច្ចក្នុងការផ្តួចផ្តើមការរៀបចំ ការសម្របសម្រួល និងការសម្រេចលើផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីនៅតាមថ្នាក់រដ្ឋបាលនីមួយៗ ត្រូវបានកំណត់ ៖

**ក-ថ្នាក់ជាតិ** ៖ ផែនការរៀបចំដែនដីថ្នាក់ជាតិ និងថ្នាក់តំបន់(**ដែលមានច្រើនខេត្ត**) ត្រូវផ្តួចផ្តើម និងរៀបចំឡើងដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដឹកនាំដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ ផែនការរៀបចំដែនដីថ្នាក់ជាតិ និងថ្នាក់តំបន់ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ និង

មានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ និងអាចកែសម្រួលបានក្រោយរយៈពេល ១០ (ដប់) ឆ្នាំម្តង តាមសំណើរបស់រាជរដ្ឋាភិបាល លើកលែងតែមានការចាំបាច់ ទើបអាចធ្វើការកែសម្រួលមុនរយៈពេលនេះ។

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ។

**ខ-ថ្នាក់ក្រោមជាតិ**

**១-នៅថ្នាក់រាជធានី ខេត្ត :** ថ្នាក់រាជធានីមានប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ថ្នាក់រាជធានី។ នៅថ្នាក់ខេត្តមានផែនការរៀបចំដែនដីថ្នាក់ខេត្ត។ ប្លង់គោលប្រើប្រាស់ដី និងផែនការ ប្រើប្រាស់ដីថ្នាក់រាជធានី និងផែនការរៀបចំដែនដីថ្នាក់ខេត្ត ត្រូវផ្តួចផ្តើមនិងរៀបចំឡើងដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ដោយមានការឯកភាពពីក្រុមប្រឹក្សារាជធានីខេត្ត។ ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី និងផែនការរៀបចំដែនដីថ្នាក់ខេត្ត ត្រូវសុំការយល់ព្រមពីគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ និងសម្រេចដោយអនុក្រឹត្យ។ ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានីនិងផែនការរៀបចំដែនដីថ្នាក់ខេត្ត ត្រូវមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច២០(ម្ភៃ) ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥ (ប្រាំ) ឆ្នាំម្តង។

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវបង្កើតឡើងដោយអនុក្រឹត្យ។

**២-ថ្នាក់ក្រុង ស្រុក ខណ្ឌ :** ថ្នាក់ក្រុង មានប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ថ្នាក់ក្រុង។ ថ្នាក់ស្រុក ខណ្ឌ មានប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ។ ប្លង់គោលប្រើប្រាស់ដីនិង ផែនការប្រើប្រាស់ដីថ្នាក់ក្រុងនិងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើម និងរៀបចំដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង និងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌនេះត្រូវមានការឯកភាពពីក្រុមប្រឹក្សារាជធានី ខេត្ត តាមរយៈគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត និងត្រូវសម្រេចដោយប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។ ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង និងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ ត្រូវមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥ (ដប់ប្រាំ) ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ) ឆ្នាំម្តង។

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតឡើងដោយអនុក្រឹត្យ។

**៣-នៅថ្នាក់ឃុំ សង្កាត់ :** ថ្នាក់ឃុំ សង្កាត់ មានផែនការ ប្រើប្រាស់ដីឃុំ សង្កាត់។ ផែនការប្រើប្រាស់ដីឃុំសង្កាត់ ត្រូវផ្តួចផ្តើម រៀបចំដោយក្រុមប្រឹក្សាឃុំ សង្កាត់ សម្របសម្រួល និងគាំទ្របច្ចេកទេស ពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុង ស្រុក ខណ្ឌ និងត្រូវមានការឯកភាពពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ ផែនការប្រើប្រាស់ដីឃុំ សង្កាត់ ត្រូវសុំការសម្រេចពីក្រុមប្រឹក្សារាជធានី ខេត្ត តាមរយៈគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត។ ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវមានចក្ខុវិស័យសម្រាប់រយៈពេលពី ១០(ដប់) ទៅ១៥(ដប់ប្រាំ) ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល ៥ (ប្រាំ)ឆ្នាំម្តងតាមការចាំបាច់ ស្របតាមស្ថានភាពអភិវឌ្ឍន៍នៅមូលដ្ឋាន ជាពិសេសកម្មវិធីវិនិយោគឃុំ សង្កាត់។

**៥.២-មូលដ្ឋានគតិយុត្ត និងឧបករណ៍ចាំបាច់នៃការរៀបចំដែនដី**

គោលនយោបាយរៀបចំដែនដី ត្រូវរៀបចំឡើងឲ្យស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងចក្ខុវិស័យនៃគោលនយោបាយដីធ្លី ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។

ការអនុវត្តគោលនយោបាយរៀបចំដែនដី គឺជាយុទ្ធសាស្ត្រគន្លឹះក្នុងការធ្វើឲ្យសម្រេចនូវការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព សមធម៌ និងធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្របខណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តមួយចំនួនត្រូវបានអនុម័តជាបន្តបន្ទាប់ មានជាអាទិ៍ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់អស្សាមិករណ៍ អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដី នៅក្នុងឃុំ សង្កាត់ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិ និងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា ។

ទន្ទឹមនឹងនេះ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនក៏ត្រូវធ្វើវិសោធនកម្ម និងត្រូវកសាងបំពេញបន្ថែម ដើម្បីគាំទ្រ និងណែនាំការអនុវត្តឲ្យបានសមស្របដែលក្នុងនោះមាន ៖

- វិសោធនកម្មច្បាប់ភូមិបាល
- វិសោធនកម្មច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤
- កែសម្រួលអនុក្រឹត្យលេខ៨៦ អនក្រ.បក ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- រៀបចំក្រមនគរូបនីយកម្ម
- រៀបចំច្បាប់សំណង់
- រៀបចំច្បាប់ស្តីពីដីកសិកម្ម
- រៀបចំច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- រៀបចំអនុក្រឹត្យស្តីពីការរៀបចំដែនដីថ្នាក់ខេត្ត ថ្នាក់តំបន់
- រៀបចំអនុក្រឹត្យស្តីពីប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រៀបចំអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ទីក្រុង និងទីប្រជុំជន
- រៀបចំអនុក្រឹត្យស្តីពីនីតិវិធីអនុវត្តគម្រោងកែលំអទីក្រុង និងផែនការទីក្រុងថ្មី
- រៀបចំក្របខណ្ឌគតិយុត្តទាក់ទងនឹងការបង្រួម ការបំបែកក្បាលដី ការកែសម្រួលក្បាលដី ការប្តូរប្រភេទនៃការប្រើប្រាស់ដី ការអភិវឌ្ឍដី និងធនធានដែលមានលើដី និងក្រោមដី ។ល។
- រៀបចំច្បាប់ស្តីពីផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក...
- រៀបចំច្បាប់ស្តីពីនាវាចរណ៍ និងការគ្រប់គ្រងកំពង់ផែ
- រៀបចំក្របខណ្ឌគតិយុត្តស្តីពីប្រព័ន្ធព័ត៌មានដីធ្លី
- រៀបចំឲ្យមានបទដ្ឋានគតិយុត្ត និងការណែនាំលំអិតអំពីនីតិវិធីសម្រាប់ការអនុវត្តផ្សេងទៀត ។ល។

តាមរយៈការអនុវត្តនូវក្របខណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តដូចមានរៀបរាប់ខាងលើនេះ ឧបករណ៍នានាត្រូវបានរៀបចំឡើងដែលមានជាអាទិ៍ ផែនការប្រើប្រាស់ដី ផែនការអភិវឌ្ឍទីប្រជុំជន និងជនបទ ការកំណត់តំបន់ប្រើប្រាស់ដី រួមទាំងនីតិវិធីរៀបចំដីមិនទាន់អភិវឌ្ឍ ការត្រួតពិនិត្យប្លង់ទីតាំងសំណង់ បទដ្ឋាននិងស្តង់ដាសំណង់ ការត្រួតពិនិត្យការអភិវឌ្ឍ ។ល។

## ៦-សេចក្តីសន្និដ្ឋាន

ការកើនឡើងជាប្រចាំនៃចំនួនប្រជាជន និងការប្រែប្រួលផ្នែកសេដ្ឋកិច្ច និងវប្បធម៌ ក្នុងបរិបទនៃសកលភាវូបនីយកម្ម តម្រូវឲ្យមានការរៀបចំដែនដីប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ ដូច្នេះ ការរៀបចំដែនដីនៅគ្រប់ថ្នាក់ គ្រប់វិស័យ គឺជាយុទ្ធសាស្ត្រមួយដ៏សំខាន់ សម្រាប់ប្រឈមទៅនឹងការប្រែប្រួលនៃសង្គម សេដ្ឋកិច្ច និង

បរិស្ថាន។ ការគ្រប់គ្រង ការប្រើប្រាស់ និងបែងចែកដីធ្លី ធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គម ប្រកបដោយវិចារណញ្ញាណ និងមានការទទួលខុសត្រូវច្បាស់លាស់ ស្របទៅតាមឋានានុក្រមនៃការរៀបចំដែនដី ដែលនឹងអភិវឌ្ឍដោយឈរលើមូលដ្ឋាននៃការចូលរួម និងកិច្ចសហការអនុវត្តជិតស្និទ្ធរវាងគ្រប់ស្ថាប័ននិងអ្នកពាក់ព័ន្ធ ទៅតាមក្របខណ្ឌគតិយុត្តជាធរមាន គឺជាយុទ្ធវិធីដើម្បីសម្រេចភាពជោគជ័យនៃការអនុវត្តកម្មវិធីកំណែទម្រង់នានា របស់រាជរដ្ឋាភិបាល ពិសេសកំណែទម្រង់ដីធ្លីតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ។

"គោលនយោបាយជាតិរៀបចំដែនដី" ដែលបានរៀបចំឡើងដោយមានការចូលរួមប្រកបដោយភាពសុខដុមរមនារវាងគ្រប់វិស័យពាក់ព័ន្ធ និងអមដោយយន្តការពិសេសនៃការវាយតម្លៃអំពីផលប៉ះពាល់បរិស្ថាននិងសង្គម លើការរៀបចំដែនដីគ្រប់ជ្រុងជ្រោយ នឹងបានជាឧបករណ៍ដ៏មានសារៈសំខាន់ សម្រាប់តម្រង់ទិសរាល់ការអភិវឌ្ឍពាក់ព័ន្ធនឹងរូបសាស្ត្រ និងរក្សាបាននូវសោភ័ណភាពតាមតំបន់ ក៏ដូចជាការបែងចែកផលនៃកំណើនសេដ្ឋកិច្ចនិងការងារធ្វើប្រកបដោយតុល្យភាពសមធម៌ក្នុងតំបន់រវាងស្ត្រីនិងបុរសឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច។

ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជន ដល់ផ្នែកធុរកិច្ច និងសង្គមស៊ីវិល និងដើម្បីរួមចំណែកតាមដាន និងវាយតម្លៃផែនការអភិវឌ្ឍនានា រាជរដ្ឋាភិបាលនឹងផ្សព្វផ្សាយជាទៀងទាត់នូវរបាយការណ៍ស្តីពីការអភិវឌ្ឍរីកចម្រើនផ្នែករៀបចំដែនដីនៅទូទាំងប្រទេស និងតាមរាជធានី ខេត្ត។

---------------

# វាក្យសព្ទ

**ផែនការរៀបចំដែនដីថ្នាក់ជាតិថ្នាក់តំបន់ ថ្នាក់ខេត្ត:**

ជាផែនការដែលកំណត់ចក្ខុវិស័យ និងយុទ្ធសាស្ត្រតម្រង់ទិសនៃការប្រើប្រាស់ដី និងការអភិវឌ្ឍផ្នែករូបវន្ត ដោយផ្អែកលើសក្តានុពលនៃភូមិសាស្ត្រ និង តំបន់នីមួយៗ ក្នុងក្របខណ្ឌថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ខេត្ត។

**ប្លង់គោលប្រើប្រាស់ដីធ្លីថ្នាក់រាជធានី ថ្នាក់ក្រុង ថ្នាក់ស្រុក ថ្នាក់ខណ្ឌ :**

ជាផែនការដែលកំណត់ចក្ខុវិស័យ និងយុទ្ធសាស្ត្ររួមសម្រាប់ការអភិវឌ្ឍផ្នែករូបវន្តនិងកំណត់អំពីប្រភេទដី ព្រមទាំងបង្ហាញអំពីបណ្តាញហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍សំខាន់ៗ និងការធ្វើសមាហរណកម្ម ក្របខណ្ឌថ្នាក់រាជធានី ថ្នាក់ក្រុង ថ្នាក់ស្រុក និងថ្នាក់ខណ្ឌ ទៅថ្នាក់តំបន់ និងថ្នាក់ជាតិ។

ប្លង់គោលប្រើប្រាស់ដី គឺជាប្លង់ដែលត្រូវបានអនុម័តឲ្យប្រើប្រាស់ជាផ្លូវការរួច។

**ផែនការប្រើប្រាស់ដីថ្នាក់រាជធានី ថ្នាក់ក្រុង :**

ជាផែនការលម្អិតចេញពីប្លង់គោល ដែលកំណត់អំពីប្រភេទនៃការប្រើប្រាស់ដីនៅតំបន់នីមួយៗ កំណត់អំពីបទប្បញ្ញត្តិប្រើប្រាស់ដី ការអភិវឌ្ឍដី និងលទ្ធភាពនៃការសាងសង់ក្នុងតំបន់នីមួយៗ ព្រមទាំងបង្ហាញអំពីប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងការធ្វើសមាហរណកម្មទៅថ្នាក់តំបន់ និងថ្នាក់ជាតិ។

**ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ :**

គឺសំដៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជនរបស់បុគ្គលឯកជន ដោយប៉ាន់ប្រមាណពីសក្តានុពលដីនិងធនធានទឹក លទ្ធភាពផ្សេងៗ ក្នុងការប្រើប្រាស់ដី ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីធ្វើការជ្រើសរើសនូវជម្រើសសមស្របក្នុងការប្រើប្រាស់ដី។

**ការបង្រួមក្បាលដី :**

ការបូកបញ្ចូលក្បាលដីមួយៗ ដែលជាប់គ្នារបស់ម្ចាស់តែមួយ និងប្រភេទនៃការប្រើប្រាស់ដូចគ្នា ឲ្យក្លាយទៅជាក្បាលដីតែមួយ ដើម្បីធ្វើការចុះបញ្ជីតែមួយ សម្រាប់ងាយស្រួលដល់ការអភិវឌ្ឍ និងប្រើប្រាស់ ឬការធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ។

**ការបំបែកក្បាលដី :**

ក្បាលដីតែមួយបំបែកជាក្បាលដីច្រើន ដើម្បីប្រើប្រាស់ ឬអភិវឌ្ឍន៍ស្របតាមបទប្បញ្ញត្តិជាធរមាន និង/ឬ ការធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ។

**ការកែសម្រួលក្បាលដី :**

ការរៀបចំក្បាលដីឡើងវិញដើម្បីធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងបង្កើនលទ្ធភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ដី ស្របតាមបទប្បញ្ញត្តិជាធរមាន។

**ការប្តូរប្រភេទនៃការប្រើប្រាស់ដី :**

ការផ្លាស់ប្តូរការប្រើប្រាស់ដីពីប្រភេទមួយទៅជាប្រភេទផ្សេងទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

**នីតិវិធីរៀបចំដីមិនទាន់អភិវឌ្ឍ :**

នីតិវិធីរៀបចំដីដែលមិនទាន់មានប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី។

**ការត្រួតពិនិត្យការអភិវឌ្ឍ :**

ការត្រួតពិនិត្យការអនុវត្ត ស្របតាមប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងស្របតាមបទប្បញ្ញត្តិជាធរមាន។

**តំបន់ស្នូលនៃការអភិវឌ្ឍ :**

តំបន់ដែលមានសក្តានុពលខ្ពស់ ឬតំបន់ដែលមានការអភិវឌ្ឍខ្ពស់សម្រាប់គាំទ្រដល់តំបន់ជុំវិញដែលមានសក្តានុពលទាប។

**អ័ក្សនៃការអភិវឌ្ឍ :**

បណ្តាញផ្លូវគមនាគមន៍ ឬច្រករបៀងតភ្ជាប់ពីតំបន់អភិវឌ្ឍន៍មួយទៅតំបន់អភិវឌ្ឍន៍មួយទៀត ដែលអាចឲ្យតំបន់ជាប់ជិតខាងតាមអ័ក្សទាញយកប្រយោជន៍ពីការអភិវឌ្ឍតាមអ័ក្សនេះបាន។

**ប៉ូលអភិវឌ្ឍ :**

តំបន់ដែលមានសក្តានុពលខ្ពស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។

# ឧបសម្ព័ន្ធទី២

# គោលនយោបាយជាតិ ស្តីពី លំនៅឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ

# ស្ដីពី

# លំនៅឋាន

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# មាតិកា


១- សេចក្តីផ្តើម ........ ១

២- ចក្ខុវិស័យ ........ ២

៣- គោលបំណងនិងគោលដៅ ........ ២

៣.១- គោលបំណង ........ ២

៣.២- គោលដៅ ........ ២

៤- យុទ្ធសាស្ត្រ ........ ៣

៥- ផែនការសកម្មភាព ........ ៤

៥.១- ការរៀបចំយន្តការសម្រាប់ការងារលំនៅឋាន ........ ៥

៥.២- ការសម្របសម្រួលស្ថាប័ននិងការចូលរួមរបស់អ្នកពាក់ព័ន្ធ ........ ៦

៥.៣- តម្រូវការក្របខ័ណ្ឌគតិយុត្ត ........ ៨

៥.៤- ជម្រើសដើម្បីទទួលបានលំនៅឋាន ........ ៨

៥.៥- ជម្រើសផ្នែកហិរញ្ញវត្ថុដើម្បីទទួលបានលំនៅឋាន ........ ១១

៥.៦- នគរូបនីយកម្មនិងផែនការអភិវឌ្ឍតំបន់ថ្មី ........ ១៣

៥.៧- ដំណោះស្រាយបញ្ហាចំពោះមុខ ........ ១៤

ក- ការធានាសិទ្ធិកាន់កាប់មានរយៈពេលកំណត់ចំពោះម្ចាស់សំណង់បណ្តោះអាសន្ន ........ ១៤

ខ- ការស្ទាបស្ទង់មតិ ការប្រមូលព័ត៌មាន និងការវិភាគទិន្នន័យ ........ ១៥

គ- សេវាកម្មមូលដ្ឋានគាំទ្រដល់ការអនុវត្តការងារលំនៅឋាន ........ ១៦

៦- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ ........ ១៧

៧- សេចក្តីសន្និដ្ឋាន ........ ១៧/៣៥

## ១- សេចក្តីផ្តើម

លំនៅឋានគឺជាទ្រព្យសម្បត្តិមានតម្លៃសេដ្ឋកិច្ចនិងសង្គមដ៏សំខាន់សម្រាប់គ្រួសារនីមួយៗ។ ជាទូទៅប្រជាពលរដ្ឋតែងសន្សំទ្រព្យសម្បត្តិ ប្រាក់កាសសម្រាប់ការសាងសង់លំនៅឋានសមរម្យមានផាសុកភាព ស្របទៅតាមកម្រិតនៃទ្រព្យធននិងចំណូលរបស់គ្រួសារដែលអាចរកបាន។ នៅកម្ពុជាបន្ទាប់ពីឆ្លងកាត់មហាវិនាសកម្មនៃសង្គ្រាមឆ្នាំ១៩៧០-១៩៧៥ ជាពិសេស មហាវិនាសកម្មក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ឆ្នាំ១៩៧៥-១៩៧៩ ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមត្រូវបានបំផ្លិចបំផ្លាញ ក្នុងនោះមានលំនៅឋានប្រជាពលរដ្ឋមួយចំនួនធំក៏ត្រូវបានបំផ្លិចបំផ្លាញដែរ។ ក្រោយឆ្នាំ១៩៧៩ការបាត់បង់កំណត់ត្រាដីធ្លីក្នុងរបបប៉ុលពត ការបង្កើតឡើងវិញនូវរបបកម្មសិទ្ធិលើដីធ្លី គួបផ្សំនឹងអត្រាកំណើនប្រជាជនខ្ពស់ក្រោយសង្គ្រាម ការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួន ការប្រែប្រួលតម្លៃដីធ្លី លំនៅឋាន និងជាពិសេសកំណើនសេដ្ឋកិច្ចខ្ពស់នៅរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ បានបង្កឱ្យមានលំហូរប្រជាជនមួយចំនួនធ្វើបម្លាស់ទីពីជនបទមកកាន់ទីក្រុងនិងទីប្រជុំជន ដែលមានសក្តានុពលសេដ្ឋកិច្ចធ្វើឱ្យទីក្រុងនិងទីប្រជុំជនមានសម្ពាធកាន់តែធ្ងន់ធ្ងរថែមទៀតទៅលើតម្រូវការលំនៅឋាននិងដីធ្លី។

តាមទិន្នន័យជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ កម្ពុជានឹងមានប្រជាជនប្រមាណជាង១៨លាននាក់នៅឆ្នាំ២០៣០ គឺត្រូវកើនប្រមាណជាង៤លាននាក់ថែមទៀត ហើយកំណើននេះភាគច្រើននឹងកើតឡើងនៅតាមទីប្រជុំជនធំៗដែលមានសក្តានុពលសេដ្ឋកិច្ច។ ជំរឿនឆ្នាំ២០០៨ ក៏បានបង្ហាញផងដែរនូវនិន្នាការនៃការចុះថយទំហំគ្រួសារ ដែលអាចនឹងប៉ាន់ប្រមាណថារហូតដល់ឆ្នាំ២០៣០ កម្ពុជាអាចត្រូវការលំនៅឋានថ្មីប្រមាណជាង១,១លានបន្ថែមទៀត ដោយមិនរាប់បញ្ចូលកង្វះលំនៅឋាននាពេលបច្ចុប្បន្ន។ ប្រការនេះធ្វើឱ្យសេចក្តីត្រូវការដីធ្លីនិងលំនៅឋានកាន់តែកើនឡើងនិងអាចបង្កឱ្យមានការតាំងលំនៅបណ្តោះអាសន្នថ្មីកើតឡើងថែមទៀត ប្រសិនបើមិនបានធ្វើផែនការរៀបចំដែនដី គោលនយោបាយលំនៅឋាន និងវិធានការចាំបាច់នានា ដើម្បីធានាសិទ្ធិទទួលបានលំនៅឋានសមរម្យសម្រាប់អ្នកមានប្រាក់ចំណូលមធ្យមនិងអ្នកមានប្រាក់ចំណូលទាប។ លំនៅឋានត្រូវបានចាត់ទុកជាផ្នែកមួយដ៏សំខាន់នៃជីវិតរបស់មនុស្សដូចជាការធ្វើអាជីវកម្មពេញលេញក្នុងលំនៅឋាននិងជាប្រភពមួយក្នុងការរកប្រាក់ចំណូលសម្រាប់គ្រួសារឬរកចំណូលបន្ទាប់បន្សំក្នុងផ្ទះ។

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ មាត្រា២៥-១ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ឆ្នាំ១៩៦៦មាត្រា១១-១បានចែងថា *"មនុស្សគ្រប់រូបមានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ដើម្បីធានាសុខភាព និងសុខុមាលភាពរបស់ខ្លួននិងគ្រួសាររួមមានចំណីអាហារសម្លៀកបំពាក់និងលំនៅឋាន..."*។ មាត្រា៣១នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស។ រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តក្នុងការអនុវត្តគោលការណ៍សិទ្ធិមនុស្សទាំងនេះ ជាអាទិ៍ សិទ្ធិទទួលបាននូវលំនៅឋានសមរម្យ

សម្រាប់ស្នាក់នៅរបស់ប្រជាជនគ្រប់រូប ដោយដាក់ចេញនូវយុទ្ធសាស្ត្រនានា មានយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ផែនការសកម្មភាពអភិបាលកិច្ច ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិនិងយុទ្ធសាស្ត្រចតុកោណជាដើម ដោយធានានូវសិទ្ធិទទួលបានលំនៅឋានសមរម្យរបស់ប្រជាជនទូទៅនៅកម្ពុជាជាពិសេសជនក្រីក្រនិងក្រុមជនងាយរងគ្រោះ។

## ២- ចក្ខុវិស័យ

ប្រជាជនគ្រប់រូបមានសិទ្ធិមានលំនៅឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានជីវភាពគ្រប់គ្រាន់ ធានាបាននូវការរស់នៅក្នុងភាពជាឯកជននៃគ្រួសារ និងសុវត្ថិភាពក្នុងការកាន់កាប់លំនៅឋានស្របច្បាប់។ ចក្ខុវិស័យនៃគោលនយោបាយជាតិស្តីពីលំនៅឋានគឺសំដៅធ្វើឱ្យប្រជាជនទូទាំងប្រទេសមានលំនៅឋានសមរម្យ អាចរស់នៅបានប្រកបដោយសុខុមាលភាពសុវត្ថិភាពនិងសេចក្តីថ្លៃថ្នូរ ជាពិសេសប្រជាពលរដ្ឋដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ។ នេះជាផ្នែកមួយនៃការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភាដែលចែងថា "...កសាងគោលនយោបាយជាតិស្តីពីលំនៅឋាន ដើម្បីដោះស្រាយលំនៅឋានជូនប្រជាជនក្រីក្រសម្រាប់ការរស់នៅប្រកបដោយសុវត្ថិភាព សុខុមាលភាព និងសេចក្តីថ្លៃថ្នូរ"។

## ៣- គោលបំណងនិងគោលដៅ

### ៣.១-គោលបំណង

គោលបំណងនៃគោលនយោបាយជាតិស្តីពីលំនៅឋានគឺ

- ផ្តល់ដល់ប្រជាជនទូទៅនូវលទ្ធភាព មធ្យោបាយដែលអាចទទួលបានលំនៅឋានសមរម្យឬជួសជុលកែលម្អលំនៅឋាន ជាពិសេសក្រុមគ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ ដើម្បីទទួលបានសិទ្ធិលំនៅឋានសមរម្យ
- ជំរុញការអភិវឌ្ឍទីក្រុង ទីប្រជុំជន និងជនបទ
- ដោះស្រាយជូនប្រជាជនដែលរស់នៅបណ្តោះអាសន្នក្នុងទីតាំងមិនរៀបរយ ដើម្បីទទួលបានលំនៅឋានសមស្រប មានសុវត្ថិភាព និងមានផាសុកភាពសម្រាប់ការស្នាក់នៅនិង/ឬប្រកបរបរចិញ្ចឹមជីវិត
- ជំរុញកិច្ចសហការជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល សប្បុរសជន និងវិស័យឯកជនដើម្បីកសាងកម្មវិធីលំនៅឋានថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិសម្រាប់រយៈពេលខ្លី មធ្យម និងវែង។

### ៣.២-គោលដៅ

គោលដៅនៃគោលនយោបាយជាតិស្តីពីលំនៅឋានគឺ៖

- រៀបចំចងក្រងនិងធ្វើបច្ចុប្បន្នកម្មទិន្នន័យនៃសេចក្តីត្រូវការលំនៅឋានសមរម្យ ជាពិសេសសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ
- ផ្សព្វផ្សាយនិងផ្តល់ការណែនាំដល់ប្រជាជននូវវិធីសមស្របដែលជាលទ្ធភាពអាចទទួលបានលំនៅឋានសមរម្យតាមរយៈក្របខ័ណ្ឌហិរញ្ញប្បទានផ្សេងៗក្នុងការសាងសង់ ជួសជុលកែលម្អលំនៅឋាន ជាពិសេសគ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ
- កាត់បន្ថយនូវចំនួនគ្រួសារដែលរស់នៅច្រើនគ្រួក្នុងលំនៅឋានតូចចង្អៀតឬដែលរស់នៅបណ្តោះអាសន្នតាមទីតាំងមិនរៀបរយឬទីតាំងសាធារណៈ
- ផ្តល់សុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងគិតគូរកំណត់ទីតាំងនិងប្រភេទសំណង់សមស្របដោយយកចិត្តទុកដាក់បញ្ចូលកម្មវិធីលំនៅឋានទៅក្នុងគម្រោងនគរូបនីយកម្មឬគម្រោងអភិវឌ្ឍន៍ទីក្រុង ទីប្រជុំជន និងជនបទ
- សហការជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល សប្បុរសជន និងវិស័យឯកជន ដោយរៀបចំគម្រោងអភិវឌ្ឍសហគមន៍ គម្រោងស្ថាបនាមូលនិធិសង្គមសម្រាប់លំនៅឋានឬគម្រោងអភិវឌ្ឍដីសម្រាប់សាងសង់លំនៅឋាន គម្រោងសាងសង់លំនៅឋានមានតម្លៃទាបសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះដោយការបង់រំលស់ឬសម្រាប់ជួល
- រៀបចំរចនាសម្ព័ន្ធមូលនិធិលំនៅឋានថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន ដើម្បីផ្តល់ហិរញ្ញប្បទានដល់គ្រួសារក្រីក្រនិងសិក្សាបង្កើតធនាគារលំនៅឋានសម្រាប់ដោះស្រាយសេចក្តីត្រូវការលំនៅឋានឬការជួសជុលកែលម្អលំនៅឋាន
- ជំរុញការអនុវត្តសារាចររបស់រាជរដ្ឋាភិបាលលេខ០៣ស.រ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន
- ជំរុញការអភិវឌ្ឍលំនៅឋានសាធារណៈនិងឯកជន សម្រាប់ជួលឬលក់ក្នុងតម្លៃទាបសមរម្យដោយការបង់រំលស់។

## ៤- យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រនៃគោលនយោបាយជាតិស្តីពីលំនៅឋានគឺជាការឆ្លើយតបទៅនឹងសិទ្ធិមនុស្សជាមូលដ្ឋានក្នុងការទទួលបានលំនៅឋានសមរម្យ ការគិតគូរពីតម្រូវការលំនៅឋានចំពោះមុខនិងការបម្រុងទុកនូវទីតាំងសម្រាប់ការសាងសង់លំនៅឋាន ការបង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជន ការកសាងរចនាសម្ព័ន្ធមូលនិធិលំនៅឋាន និងវិធានការចំពោះមុខនៃការដោះស្រាយរាល់ការតាំងទីលំនៅបណ្តោះអាសន្នជាអាទិ៍។

ក- គម្រង់ទិសនៃការដោះស្រាយតម្រូវការលំនៅឋាននាពេលអនាគតដោយផ្តោតសំខាន់លើតម្រូវការលំនៅឋានរបស់ក្រុមគ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ។

ខ- អនុញ្ញាតឱ្យអ្នកតាំងទីលំនៅមិនស្របច្បាប់និងសហគមន៍ក្រីក្ររស់នៅជាបណ្តោះអាសន្នមានរយៈពេលកំណត់ដើម្បីសិក្សាស្វែងរកដំណោះស្រាយតាមករណីនៃទីតាំងសំណង់បណ្តោះអាសន្ននីមួយៗ។

គ- ធានាថាការផ្លាស់ប្តូរទីតាំងលំនៅឋានដែលជាជម្រើសចុងក្រោយនឹងត្រូវអនុវត្តស្របតាមនីតិវិធី គោលការណ៍ស្ម័គ្រចិត្ត គោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាពនិងគណនេយ្យភាពនិងមានការចូលរួមពីអ្នករងផលប៉ះពាល់។

ឃ- ធ្វើសមាហរណកម្មការតាំងទីលំនៅជាថ្មីទៅក្នុងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទីក្រុងទីប្រជុំជន។

ង- ខិតខំធានានិងរក្សានិរន្តរភាពសង្គម រចនាសម្ព័ន្ធ និងតួនាទីនៃលំនៅឋានចាស់និងលំនៅឋានថ្មីដោយមានការចូលរួមពីសហគមន៍ផ្ទាល់។

ច- សិក្សាលទ្ធភាពនិងនីតិវិធីនៃការរៀបចំរចនាសម្ព័ន្ធមូលនិធិសម្រាប់លំនៅឋាននិងការបង្កើតធនាគារសម្រាប់លំនៅឋាន។

ឆ- ជួយគាំទ្រនិងផ្តល់សិទ្ធិចូលរួមសម្រេចរបស់ប្រជាជននិងសហគមន៍មូលដ្ឋាន។

## ៥- ផែនការសកម្មភាព

លំនៅឋាននិងការតាំងទីលំនៅថ្មីជាបញ្ហាពាក់ព័ន្ធនឹងការអភិវឌ្ឍទីក្រុង ដែលត្រូវមានការចូលរួមពីវិស័យនានាទាំងនៅថ្នាក់ជាតិទាំងនៅថ្នាក់ក្រោមជាតិក្នុងការកសាងផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី ការងារសំណង់ ការងារស្ថាបត្យកម្ម វិស្វកម្ម ការរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ ការស្វែងរកហិរញ្ញប្បទាននិងប្រភពធនធាន ការវាយតម្លៃអំពីផលប៉ះពាល់បរិស្ថាននិងសង្គម។ល។ ដូច្នេះ ត្រូវមានការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធនិងការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗឆ្លើយតបទៅនឹងគោលនយោបាយលំនៅឋាន មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធតាមលំដាប់ថ្នាក់របស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន និងសហគមន៍ផ្ទាល់។ គោលនយោបាយលំនៅឋានត្រូវសង្កត់ធ្ងន់លើយុទ្ធសាស្ត្រគាំទ្រ ដូចជាការចូលរួមសម្រេចរបស់សហគមន៍មូលដ្ឋាន ការផ្តល់ហិរញ្ញប្បទានសម្រាប់ជួសជុលឬសាងសង់លំនៅឋាន ការសាងសង់លំនៅឋានថ្មីដើម្បីដោះស្រាយតម្រូវការចំពោះមុខ ការកំណត់មូលដ្ឋានសម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដីនៅទីក្រុង ទីប្រជុំជន និងជនបទ ការរៀបចំប្រភេទផ្សេងៗនៃលំនៅឋានស្របតាមតម្រូវការផ្សេងៗគ្នារបស់ប្រជាជន ការរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ និងការកំណត់តម្លៃសេវានៃការអនុញ្ញាតសាងសង់។ល។

## ៥.១- ការរៀបចំយន្តការសម្រាប់ការងារលំនៅឋាន

ផ្អែកលើវិសាលភាពដ៏ទូលំទូលាយនិងភាពចាំបាច់ចំពោះមុខនិងយូរអង្វែង យន្តការនៃការងារលំនៅឋានដែលនឹងត្រូវបង្កើតឡើងត្រូវមានដំណើរការជាអចិន្ត្រៃយ៍ មានមន្ត្រីជំនាញបំពេញការងារជាប្រចាំទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ។ ក្រៅពីសម្របសម្រួលនិងសហការជាមួយស្ថាប័ននិងអ្នកពាក់ព័ន្ធ យន្តការនេះត្រូវធ្វើសមាហរណកម្មផែនការការងាររបស់ខ្លួនទៅក្នុងផែនការប្រើប្រាស់ដី ផែនការរៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ កម្មវិធីវិនិយោគ៣(បី)ឆ្នាំរំកិលនិងផែនការអភិវឌ្ឍរយៈពេល៥(ប្រាំ)ឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ដើម្បីឆ្លើយតបទៅនឹងការធានាសិទ្ធិមានលំនៅឋានសមរម្យ យន្តការដែលនឹងបង្កើតឡើងថ្មីនេះត្រូវមានប្រភពហិរញ្ញប្បទាននិងអាចដើរតួជាប្រតិបត្តិករនិងជាអ្នករៀបចំគម្រោងការជាក់ស្តែងដោយមានកិច្ចសហការជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ទៅតាមស្ថានភាពនៃមូលដ្ឋាននីមួយៗ។

### ១- ថ្នាក់ជាតិ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំយន្តការអចិន្ត្រៃយ៍ទទួលបន្ទុកការងារលំនៅឋានដោយត្រូវបង្កើតអគ្គនាយកដ្ឋានលំនៅឋាន ដើម្បីដឹកនាំ គ្រប់គ្រង សម្របសម្រួល រៀបចំផែនការការងារទាក់ទងនឹងការធានានូវសិទ្ធិលំនៅឋានរបស់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ។

អគ្គនាយកដ្ឋានលំនៅឋាន ត្រូវបង្កើតដោយអនុក្រឹត្យ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានអគ្គនាយកដ្ឋានលំនៅឋានជាសេនាធិការត្រូវផ្តួចផ្តើម៖

- សិក្សាអំពីស្ថានភាពបច្ចុប្បន្ននៃលំនៅឋាន តម្រូវការលំនៅឋាន ការផ្គត់ផ្គង់លំនៅឋាននិងការរៀបចំដីសម្រាប់លំនៅឋានចំពោះមុខនិងនៅពេលអនាគត
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តសំដៅធានានូវសិទ្ធិមានលំនៅឋានសមរម្យរបស់ប្រជាជន
- កៀរគរហិរញ្ញប្បទានអន្តរជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន សប្បុរសជន និងប្រភពហិរញ្ញប្បទានជាតិសម្រាប់ការងារលំនៅឋាននិងការតាំងទីលំនៅថ្មី
- តាមដាននិងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តដែលបានដាក់ឱ្យអនុវត្តតាមលំដាប់ថ្នាក់និង
- បំពេញការងារផ្សេងៗទៀតពាក់ព័ន្ធនឹងការងារលំនៅឋាន។

អគ្គនាយកដ្ឋានលំនៅឋានត្រូវរៀបចំវេទិកាស្តីពីលំនៅឋានយ៉ាងតិចមួយដងក្នុងមួយឆ្នាំដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដើម្បីកសាងយុទ្ធសាស្ត្រនិងកម្មវិធីលំនៅឋាន ការតាំងទីលំនៅថ្មីនិងគោលការណ៍ណែនាំអនុវត្តកម្មវិធីនិងគម្រោងនានា។/.

២-ថ្នាក់ក្រោមជាតិ

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីខេត្ត ត្រូវបង្កើតការិយាល័យលំនៅឋាន ដើម្បីផ្តួចផ្តើម៖

- ចងក្រងទិន្នន័យអំពីស្ថានភាពបច្ចុប្បន្ននៃលំនៅឋាននិងទីតាំងលំនៅលើដីរដ្ឋដោយខុសច្បាប់ តម្រូវការលំនៅឋានចំពោះមុខនិងលទ្ធភាពនៃការផ្គត់ផ្គង់លំនៅឋាន
- ស្វែងរកដំណោះស្រាយចំពោះការតាំងលំនៅឋានដោយខុសច្បាប់លើដីសាធារណៈរបស់រដ្ឋនិងតាមដានការអនុវត្តគម្រោងផ្សេងៗពាក់ព័ន្ធនឹងការងារលំនៅឋាន
- សហការស្វែងរកប្រភពហិរញ្ញប្បទានជាតិនិងអន្តរជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិលវិស័យឯកជន និងប្រភពហិរញ្ញប្បទានផ្សេងៗសម្រាប់ដោះស្រាយបញ្ហាលំនៅឋាននិងការតាំងលំនៅឋានថ្មី
- តាមដាននិងវាយតម្លៃការអនុវត្តការតាំងទីលំនៅថ្មីនិងការអនុវត្តគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារលំនៅឋាន
- ធ្វើការប្រជុំតាមការចាំបាច់ដើម្បីលើកកម្មវិធីការងារលំនៅឋានប្រចាំឆមាស ប្រចាំឆ្នាំនិងផែនការអនុវត្តគម្រោងផ្សេងៗដែលមានការគាំទ្រពីភាគីឬដៃគូអភិវឌ្ឍនិងដោះស្រាយបញ្ហាលំនៅឋានចំពោះមុខ និង
- បំពេញការងារផ្សេងៗទៀតតាមការកំណត់របស់ថ្នាក់ជាតិ។

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតឱ្យមានផ្នែកលំនៅឋានដើម្បីផ្តួចផ្តើម៖

- ស្រង់ស្ថិតិអំពីស្ថានភាពបច្ចុប្បន្ននៃបញ្ហាលំនៅឋាននិងធ្វើអត្តសញ្ញាណកម្មទីតាំងលំនៅឋានលើដីរដ្ឋដោយខុសច្បាប់តម្រូវការលំនៅឋានចំពោះមុខលទ្ធភាពនៃការផ្គត់ផ្គង់ដីធ្លីឬលំនៅឋាន
- លើកសំណើអំពីដំណោះស្រាយចំពោះការតាំងលំនៅឋានដោយខុសច្បាប់លើដីរដ្ឋនិងតាមដានការអនុវត្តគម្រោងផ្សេងៗពាក់ព័ន្ធនឹងការងារលំនៅឋាន
- ស្វែងរកហិរញ្ញប្បទានសម្រាប់ដោះស្រាយបញ្ហាលំនៅឋាននិងការតាំងលំនៅឋានថ្មី
- លើកកម្មវិធីផែនការអនុវត្តការងារលំនៅឋានប្រចាំឆមាស ប្រចាំឆ្នាំ
- ធ្វើរបាយការណ៍វាយតម្លៃការអនុវត្តគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារលំនៅឋាននិងការតាំងទីលំនៅថ្មីទៅតាមកាលកំណត់។

## ៥.២- ការសម្របសម្រួលស្ថាប័ននិងការចូលរួមរបស់អ្នកពាក់ព័ន្ធ

លំនៅឋាននិងការតាំងលំនៅឋានជាថ្មីពាក់ព័ន្ធជិតស្និទ្ធនឹងការអភិវឌ្ឍទីក្រុង ទីជនបទការរៀបចំហេដ្ឋារចនាសម្ព័ន្ធ។ល។ដែលតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ៖

**ក- រាជរដ្ឋាភិបាល** : យន្តការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិទទួលបន្ទុកការងារលំនៅឋានមានតួនាទីក្នុងការ៖

- ដឹកនាំធ្វើអត្តសញ្ញាណកម្មទីតាំងដីសមស្របសម្រាប់ការសាងសង់លំនៅឋាននិងធ្វើសមាហរណកម្មដីដែលបានធ្វើអត្តសញ្ញាណកម្មរួចហើយទៅក្នុងផែនការប្រើប្រាស់ដីនៅទីក្រុង ទីប្រជុំជន និងទៅក្នុងផែនការប្រើប្រាស់ដីនៅថ្នាក់ឃុំ សង្កាត់
- ដឹកនាំការធ្វើផែនការនានាដោយពិចារណាជាអាទិភាពទៅលើលទ្ធភាពនៃការទទួលបានលំនៅឋានសម្រាប់គ្រួសារក្រីក្រតាមទីប្រជុំជននិងជនបទ
- ដឹកនាំអនុវត្តយុទ្ធសាស្ត្រដែលបានសម្របសម្រួលរវាងភាគីពាក់ព័ន្ធនឹងដំណោះស្រាយការតាំងទីលំនៅនិងគ្រប់គ្រងការអភិវឌ្ឍ
- លើកទឹកចិត្តចំពោះការផ្តួចផ្តើមគំនិតនានារបស់សហគមន៍ឱ្យមានភាពម្ចាស់ការក្នុងការជួយខ្លួនឯង ការសន្សំប្រាក់ក្នុងសហគមន៍ និងការប្រើប្រាស់ប្រាក់សហគមន៍
- ជួយបង្កលក្ខណៈក្នុងការទទួលបានឥណទានខ្នាតតូចដល់ក្រុមគ្រួសារក្រីក្រ
- ផ្តល់ការគាំទ្រពិសេសដល់ក្រុមគ្រួសារក្រីក្របំផុតដែលមិនមានលទ្ធភាពរកលំនៅឋានដោយខ្លួនឯង
- ជួយគាំទ្រហេដ្ឋារចនាសម្ព័ន្ធនិងសេវាចាំបាច់ជាមូលដ្ឋានដែលតម្រូវឱ្យមានការសម្របសម្រួលរវាងស្ថាប័ននិងភាគីពាក់ព័ន្ធនិង
- លើកទឹកចិត្តនិងសហការជាមួយផ្នែកឯកជនដែលមានឆន្ទៈចូលរួមដោះស្រាយបញ្ហាលំនៅឋាន សម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ។

**ខ- សហគមន៍មូលដ្ឋាន(ពិសេសសហគមន៍ក្រីក្រ) :** ប្រជាជនដែលប្រឈមនឹងបញ្ហាលំនៅឋានគប្បីចងក្រងជាសហគមន៍ រៀបចំគម្រោងផែនការសន្សំប្រាក់ជាសមូហភាពសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវានានារបស់សហគមន៍ និងចូលរួមធ្វើសេចក្តីសម្រេចចិត្តនានារបស់សហគមន៍។

**គ- សង្គមស៊ីវិល :** ចូលរួមក្នុងការចងក្រងសហគមន៍និងជួយពង្រឹងសហគមន៍ឱ្យចេះដឹកនាំការអភិវឌ្ឍសហគមន៍ខ្លួនឯង ចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តព្រមទាំងផ្តល់លទ្ធភាពផ្នែកហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះ គប្បីចូលរួមក្នុងដំណើរការសិក្សានិងការដោះស្រាយទីតាំងលំនៅឋានបណ្តោះអាសន្នជាមួយក្រុមការងារអន្តរស្ថាប័ន ដើម្បីរៀបចំផែនការអនុវត្តគម្រោងនានាឱ្យបានសមស្រប។

**ឃ- ផ្នែកឯកជន :** ចូលរួមជួយចងក្រងនិងអភិវឌ្ឍសហគមន៍តាមរូបភាពផ្សេងៗ តាមរយៈកិច្ចសហការជាមួយរដ្ឋនិង/ឬជាមួយសហគមន៍ ដូចជាការអនុវត្តគម្រោងសាងសង់លំនៅឋានមានតម្លៃទាបសម្រាប់លក់ឬជួល គម្រោងសាងសង់លំនៅឋានក្នុងសមាមាត្រណាមួយសម្រាប់អ្នកមានប្រាក់ចំណូលមធ្យមនិងប្រាក់ចំណូលទាប គម្រោងអភិវឌ្ឍន៍នៅនឹងកន្លែង ការរៀបចំគម្រោងហិរញ្ញប្បទានសម្រាប់ជួសជុល សាងសង់លំនៅឋាន ការរៀបចំគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនិងសេវានានា។ល។

## ៥.៣- តម្រូវការក្របខ័ណ្ឌគតិយុត្ត

ដើម្បីសម្រេចបាននូវចក្ខុវិស័យនៃការផ្គត់ផ្គង់លំនៅឋានសមរម្យសម្រាប់ប្រជាជនគ្រប់រូប ជាពិសេស សម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះចាំបាច់ត្រូវជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាធរមានទាំងឡាយ មានជាអាទិ៍ ច្បាប់ភូមិបាល ក្រមរដ្ឋប្បវេណី គោលនយោបាយនិងអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ គោលនយោបាយនិងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច គោលនយោបាយស្តីពីសម្បទានដីសេដ្ឋកិច្ចផ្សារភ្ជាប់នឹងសម្បទានដីសង្គមកិច្ច អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សារាចរស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ សារាចរស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុងនិងទីប្រជុំជន។ល។

ទន្ទឹមនឹងជំរុញការអនុវត្តគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តជាធរមានខាងលើក៏ចាំបាច់ត្រូវរៀបចំឱ្យមានលិខិតបទដ្ឋានគតិយុត្តមួយចំនួនថែមទៀតពាក់ព័ន្ធនឹងការងារលំនៅឋាននិង/ឬអាចធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តជាធរមានឱ្យឆ្លើយតបនឹងគោលនយោបាយលំនៅឋានដែលមានជាអាទិ៍៖

- លិខិតបទដ្ឋានគតិយុត្តនិងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងលំនៅឋាន ការតាំងទីលំនៅ ការរៀបចំដែនដី ការដកហូតដី ការវាយតម្លៃថ្លៃដីនិងថ្លៃអចលនវត្ថុជាប់នឹងដី
- នីតិវិធីណែនាំអំពីមូលនិធិសម្រាប់បម្រើដល់ការអនុវត្តកម្មវិធីលំនៅឋាន
- លិខិតបទដ្ឋានគតិយុត្តដើម្បីអនុវត្តជម្រើសនានាដែលតម្រង់ទិសឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចូលរួមអនុវត្តការងារលំនៅឋានប្រកបដោយតម្លាភាពនិងគណនេយ្យភាព
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអភិវឌ្ឍទីក្រុង សំណង់ និងនគរូបនីយកម្ម
- លិខិតបទដ្ឋានគតិយុត្តស្តីពីការកែសម្រួលក្បាលដី។ល។

## ៥.៤- ជម្រើសដើម្បីទទួលបានលំនៅឋាន

ដើម្បីអនុវត្តយុទ្ធសាស្ត្រនៃគោលនយោបាយជាតិស្តីពីលំនៅឋានគួរបង្កើតក្របខ័ណ្ឌគតិយុត្តដែលផ្តល់ជម្រើសសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះអាចទទួលបានលំនៅឋានសមរម្យ៖

### ជម្រើសទី១ : លំនៅឋានមានតម្លៃទាប

រាជរដ្ឋាភិបាលអាចរៀបចំឱ្យមានកម្មវិធីលំនៅឋានសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះដោយសាងសង់លំនៅឋានតម្លៃទាបសម្រាប់លក់ក្នុងតម្លៃសមរម្យនិង/ឬឱ្យបង់រំលស់ថ្លៃលំនៅឋានក្នុងរយៈពេលវែង។ល។

ជម្រើសទី២ : កិច្ចសហការជាមួយវិស័យឯកជន

(ក). រាជរដ្ឋាភិបាលជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានដីឬគ្មានដីសម្រាប់សាងសង់ អាចធ្វើសហប្រតិបត្តិការជាមួយក្រុមហ៊ុនឯកជនជាអ្នកអភិវឌ្ឍអចលនវត្ថុដែលក្រោយពីការសាងសង់រួចរាល់ ក្រុមហ៊ុនអាចលក់លំនៅឋានមួយចំនួនក្នុងតម្លៃទីផ្សារដល់អតិថិជនរបស់ខ្លួន ហើយលំនៅឋានមួយចំនួនទៀតត្រូវផ្តល់ជូនរដ្ឋតាមកិច្ចសន្យាដែលបានឯកភាពគ្នា ដើម្បីឱ្យរដ្ឋអាចជួលឬលក់លំនៅឋាននោះក្នុងតម្លៃទាបសមរម្យដល់គ្រួសារដែលមានប្រាក់ចំណូលមធ្យមនិងប្រាក់ចំណូលទាប តាមរយៈការបង់រំលស់។

(ខ). រដ្ឋអាចផ្តល់ដីដល់ក្រុមអ្នកអភិវឌ្ឍអចលនវត្ថុដើម្បីសាងសង់លំនៅឋានលើចំណែកណាមួយនៃដីដែលបានទទួលពីរដ្ឋ សម្រាប់ផ្តល់ជូនគ្រួសារឬសហគមន៍ដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះដោយតម្រូវឱ្យអ្នកទទួលផលបង់រំលស់ក្នុងរយៈពេលវែង គ្មានការប្រាក់(អាច១៥ឆ្នាំឬ២០ឆ្នាំ)។ ប្រាក់ថ្លៃរំលស់ដែលទទួលបានត្រូវរក្សាទុកក្នុងគណនីរបស់យន្តការណាមួយនៅថ្នាក់ក្រោមជាតិដើម្បីប្រើប្រាស់នៅទីតាំងផ្សេងទៀត។

(គ). ករណីដែលផ្នែកឯកជនមានដីនិងទុនវិនិយោគសម្រាប់អភិវឌ្ឍន៍គម្រោងលំនៅឋាន រដ្ឋអាចចូលរួមសហការនិងលើកទឹកចិត្តដល់ការវិនិយោគនោះ ដូចជាជួយរៀបចំតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គម ការផ្តល់សេវាសាធារណៈចាំបាច់នៅនឹងទីតាំងឬក្បែរទីតាំងនៃគម្រោងអភិវឌ្ឍន៍ ហើយជាការឆ្លើយតប វិស័យឯកជនដែលជាអ្នកអភិវឌ្ឍអចលនវត្ថុត្រូវផ្តល់ជូនរដ្ឋវិញនូវលំនៅឋានក្នុងសមាមាត្រណាមួយ ដើម្បីឱ្យរដ្ឋអាចប្រើប្រាស់សម្រាប់លំនៅឋានសង្គមកិច្ច ដល់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ។

ជម្រើសទី៣ : កិច្ចសហការជាមួយដៃគូអភិវឌ្ឍនិងសង្គមស៊ីវិល

ដៃគូអភិវឌ្ឍនិងសង្គមស៊ីវិលអាចសហការគ្នាដើម្បីផ្តល់នូវលំនៅឋានសមរម្យមានតម្លៃទាបដល់គ្រួសារមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះតាមក្របខណ្ឌផ្សេងៗ។

ជម្រើសទី៤ : លំនៅឋានសម្រាប់ជួល

(ក). រដ្ឋអាចសង់លំនៅឋានសម្រាប់ជួលឱ្យគ្រួសារមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះដោយមានកិច្ចសន្យាច្បាស់លាស់សម្រាប់រយៈពេលមិនលើសពី១៥ឆ្នាំក្នុងតម្លៃទាបសមរម្យដែលពួកគេមានលទ្ធភាពជួលបាន។

(ខ). ប្រសិនបើវិស័យឯកជនចូលរួមវិនិយោគក្នុងការសាងសង់លំនៅឋានសម្រាប់ជួលក្នុងតម្លៃទាបដល់អ្នកមានប្រាក់ចំណូលមធ្យមនិងប្រាក់ចំណូលទាប រដ្ឋអាចផ្តល់ការលើកទឹកចិត្តដូចជាបន្ធូរបន្ថយលើមុខសញ្ញាពន្ធនិងអាករមួយចំនួន។

វហ្វតមកដល់បច្ចុប្បន្នលំនៅឋានសម្រាប់ជួលជាជម្រើសដែលពុំទាន់បានយកចិត្តទុកដាក់នៅឡើយ ទោះបីមានការផ្តល់ជាជម្រកសម្រាប់កម្មករ កម្មការិនីនៅតាមរោងចក្រមួយចំនួននិងការផ្តល់ជម្រកសម្រាប់និស្សិតនិងគ្រូបង្រៀនស្នាក់នៅក្តី។ ករណីនេះត្រូវមានលក្ខណៈបត់បែនសម្រាប់អ្នកមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ ឬសម្រាប់បម្លាស់ទីរបស់អ្នកជួលដែលចាំបាច់ត្រូវធ្វើការសិក្សាអំពីស្ថានភាពនៃការជួលលំនៅឋានដើម្បីរិះរកដំណោះស្រាយឱ្យកាន់តែប្រសើរ។ កន្លងមកលំនៅឋានសាធារណៈសម្រាប់ជួលឬការជួលដីរបស់រដ្ឋសម្រាប់សង់លំនៅឋាន ជួលឱ្យអ្នកមានប្រាក់ចំណូលមធ្យមនិងប្រាក់ចំណូលទាប នៅមិនទាន់មាននៅឡើយ។ ដូច្នេះ គួរលើកទឹកចិត្តឱ្យមានលំនៅឋានសម្រាប់ជួលនិង/ឬការជួលដីរបស់រដ្ឋដល់គ្រួសារក្រីក្រ ដែលការជួលនេះអាចអនុញ្ញាតឱ្យបន្តដល់កូនចៅបានប្រសិនបើរដ្ឋមិនទាន់ត្រូវការទីតាំងនោះយកទៅបម្រើប្រយោជន៍សាធារណៈផ្សេងទៀត។ នេះជាជម្រើសមួយដែលបន្ថែមតម្លៃទៅលើទីផ្សារលំនៅឋានជាតិដូចជា៖

ទី១- ការជួលដីស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់អាជ្ញាធរឃុំ សង្កាត់ដែលអាចអនុញ្ញាតឱ្យបន្តជួលដល់កូនចៅប្រសិនបើមាន ឬការជួលដីរបស់រដ្ឋឬដីសម្រាប់ជួល។

ទី២- រាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌដែលមិនអាចផ្តល់មូលនិធិដល់កម្មវិធីសម្រាប់ទំនុកបម្រុងដល់ការងារលំនៅឋាន អាចបន្ធូរបន្ថយលើមុខសញ្ញាពន្ធនិងអាករមួយចំនួនដើម្បីគាំទ្រឬជួយដល់ម្ចាស់ផ្ទះដែលមានប្រាក់ចំណូលមធ្យមនិងប្រាក់ចំណូលទាប ហើយមានឆន្ទៈចង់កែលម្អផ្ទះរបស់ខ្លួនសម្រាប់ជួលឬជួយដល់អ្នកអភិវឌ្ឍអចលនវត្ថុដែលចង់វិនិយោគលើលំនៅឋានថ្មីសម្រាប់ជួល ឬកែលម្អលំនៅឋានដែលមានស្រាប់សម្រាប់ជួលក្នុងតម្លៃសមស្របឱ្យអ្នកមានប្រាក់ចំណូលមធ្យមនិងប្រាក់ចំណូលទាប។

**ជម្រើសទី៥ : រដ្ឋផ្តល់ដីដល់គ្រួសារក្រីក្រឬសហគមន៍ផ្ទាល់សម្រាប់សាងសង់លំនៅឋាន**

(ក). រដ្ឋអាចផ្តល់ដីសម្រាប់សាងសង់និងផ្តល់ប្រាក់កម្ចីសម្រាប់សាងសង់លំនៅឋានដល់សាមីជនឬដល់សហគមន៍ផ្ទាល់ដោយតម្រូវឱ្យសងមកវិញក្នុងរយៈពេលវែង។ ករណីនេះគួរជ្រើសរើសយកទីតាំងណាដែលនៅជិតទីប្រជុំជន មានហេដ្ឋារចនាសម្ព័ន្ធនិងសេវាផ្សេងៗជាមូលដ្ឋាន។ ការអនុវត្តជម្រើសនេះ គួររៀបចំសម្រាប់ច្រើនគ្រួសារក្នុងទ្រង់ទ្រាយធំ ប្រសិនបើអាចធ្វើបានដោយភ្ជាប់ជាមួយនឹងទីប្រជុំជនធំ ដើម្បីអាចដោះស្រាយបញ្ហាសំណង់បណ្តោះអាសន្ននៅទីតាំងផ្សេងៗ និងអាចធ្វើឱ្យចំណាយលើការតភ្ជាប់សេវាផ្គត់ផ្គង់ផ្សេងៗតែមួយដងសម្រាប់អតិថិជនច្រើនដែលនឹងធ្វើឱ្យតម្លៃរាយសម្រាប់គ្រួសារនីមួយៗចុះទាប។ ម្យ៉ាងទៀតការរៀបចំជាទំហំធំបែបនេះក៏ជាចំណុចទាក់ទាញដល់ការចូលរួមវិនិយោគពីវិស័យឯកជនផងដែរ។ ក្នុងករណីនេះ រដ្ឋអាចផ្តល់ដីដល់គ្រួសារឬសហគមន៍ដែលមានប្រាក់ចំណូលមធ្យមនិងប្រាក់ចំណូលទាប ក្នុងទម្រង់ជាប្រទានកម្ម ជាសម្បទានដីសង្គមកិច្ច ជាការលក់ឬជួលអចិន្ត្រៃយ៍ក្នុងតម្លៃទាបសម្រាប់គោលដៅសាងសង់លំនៅឋាន។/.

(ខ).រដ្ឋអាចផ្តល់ដីដល់សហគមន៍ដោយផ្ទាល់ ហើយប្រជាជនក្នុងសហគមន៍ជាអ្នកទទួលខុសត្រូវក្នុងការសាងសង់លំនៅឋានដោយខ្លួនឯងដោយចំណាយផ្ទាល់ខ្លួន ឬដោយទទួលប្រាក់កម្ចីពីមូលនិធិលំនៅឋាន ឬពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬពីសង្គមស៊ីវិល។

ជម្រើសទី៦ : ការប្តូរទីតាំងទៅកាន់កន្លែងថ្មី

ការប្តូរទីតាំងទៅកាន់កន្លែងថ្មីអាចត្រូវអនុវត្តចំពោះគ្រួសារដែលបានចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ជាអាទិ៍នៅលើដីចំណីផ្លូវ ដីចំណីផ្លូវរថភ្លើង ដីចំណីទន្លេ ដីសាលារៀន មន្ទីរពេទ្យ សួនសាធារណៈ តំបន់ងាយរងគ្រោះ ដីតំបន់ហាមឃាត់ លើទីតាំងហេដ្ឋារចនាសម្ព័ន្ធនានា និងនៅលើដីកម្មសិទ្ធិឯកជនឬដីដែលឯកជនបានទទួលសិទ្ធិស្របច្បាប់ក្នុងការកាន់កាប់។ ការតាំងទីលំនៅជាថ្មីគួររៀបចំនៅកន្លែងជិតទីប្រជុំជន ដែលអាចមានហេដ្ឋារចនាសម្ព័ន្ធ និងសេវានានាជាមូលដ្ឋាន អាចមានលក្ខខណ្ឌងាយស្រួលក្នុងការរកការងារធ្វើនិងធានាបាននូវសុវត្ថិភាពលំនៅឋាន។

ជម្រើសទី៧ : ការអភិវឌ្ឍនៅនឹងកន្លែង

ក្នុងការអភិវឌ្ឍនៅនឹងកន្លែង រដ្ឋ ដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ ភ្នាក់ងារអភិវឌ្ឍនានា សង្គមស៊ីវិល ផ្នែកឯកជន និងសហគមន៍ត្រូវចូលរួមជួយធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាផ្សេងៗ។ ប៉ុន្តែប្រជាពលរដ្ឋជាអ្នកទទួលខុសត្រូវក្នុងការកែលម្អលំនៅឋានផ្ទាល់ខ្លួន ដែលអាចផ្សារភ្ជាប់ទៅនឹងការខិតខំជួយខ្លួនឯងតាមរយៈប្រាក់សន្សំនិងប្រាក់កម្ចីដែលផ្តល់ដោយសហគមន៍។

ជម្រើសទី៨ : គោលនយោបាយព្រៃឈើសម្រាប់លំនៅឋានជាលក្ខណៈគ្រួសារ

ដើម្បីរួមចំណែកលើកស្ទួយដល់លំនៅឋានសមរម្យ សហគមន៍ក្នុងមូលដ្ឋានជាពិសេសប្រជាពលរដ្ឋក្រីក្រនិងក្រុមជនងាយរងគ្រោះក្នុងសហគមន៍ព្រៃឈើ អាចដកហូតឈើក្នុងសហគមន៍ព្រៃឈើរបស់ខ្លួន សម្រាប់គោលដៅសាងសង់លំនៅឋាន ដោយមានការយល់ព្រមជាមុនពីអាជ្ញាធរមានសមត្ថកិច្ច។

ជម្រើសទី៩ : ការធានាលំនៅឋានសម្រាប់កម្មករនិយោជិត

គួរជំរុញឱ្យនិយោជកចូលរួមចំណែកក្នុងការរៀបចំលំនៅឋានឬកន្លែងស្នាក់នៅសមរម្យ មានប្រព័ន្ធទឹកស្អាត អគ្គិសនី មានអនាម័យ និងបរិស្ថានល្អសម្រាប់កម្មករនិយោជិត ដែលប្រសិទ្ធភាពនៃការអនុវត្តអាចធ្វើទៅបានតាមរយៈច្បាប់ស្តីពីការងារ។

## ៥.៥- ជម្រើសផ្នែកហិរញ្ញវត្ថុដើម្បីទទួលបានលំនៅឋាន

ក្នុងប្រទេសកំពុងអភិវឌ្ឍ ការផ្គត់ផ្គង់លំនៅឋានជាបញ្ហាប្រឈមមួយដ៏ធ្ងន់ធ្ងរពីព្រោះត្រូវការវិនិយោគដ៏ធំធេងទៅលើដីធ្លីនិងសំណង់ ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ព្រមទាំងសេវាផ្សេងៗ។ ដូច្នេះទាមទារឱ្យមានទំនាក់ទំនងជិតស្និទ្ធរវាងរដ្ឋជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍ និងផ្នែកផ្សេងទៀត។ ជម្រើសគោលនយោបាយសម្រាប់ហិរញ្ញប្បទានលើលំនៅឋានគប្បីរួម

ពិចារណាទៅលើវិធីសាស្ត្រដែលអាចធ្វើបានដូចជាកម្មវិធីកែលម្អក្របខណ្ឌហិរញ្ញវត្ថុ ការលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ការរៀបចំអភិវឌ្ឍសហគមន៍និងប្រាក់សន្សំសហគមន៍ ការបង្កើតឱកាសផ្សេងៗក្នុងការបង្កើនប្រាក់ចំណូលតាមរយៈការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងការផ្តល់ឥណទានអាជីវកម្មជាដើម។ ជម្រើសផ្នែកហិរញ្ញវត្ថុសំខាន់ៗមានដូចជា៖

**១- ការសន្សំនិងប្រាក់កម្ចី** ៖ គោលនយោបាយជាតិស្តីពីលំនៅឋានត្រូវជំរុញការលើកទឹកចិត្តឱ្យបង្កើតសហគមន៍និងពង្រីកក្រុមសន្សំប្រាក់ក្នុងសហគមន៍ផ្ទាល់នៅទូទាំងប្រទេស ដែលអាចមានការចូលរួមពីដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន សប្បុរសជន និងរាជរដ្ឋាភិបាលដើម្បីផ្តល់ប្រាក់កម្ចីសម្រាប់កែលម្អលំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍ និងអាចកែលម្អជីវភាពរស់នៅរបស់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ ឬបង្កើនឱកាសអភិវឌ្ឍទីតាំងលំនៅឋានថ្មី។ វិធីសាស្ត្រនេះច្រើនអនុវត្តចំពោះក្រុមគ្រួសារដែលមានប្រាក់ចំណូលមធ្យមនិងប្រាក់ចំណូលទាប ដោយលើកទឹកចិត្តដល់ **"ការជួយខ្លួនឯង"** ដែលតម្រូវឱ្យមានការចូលរួមផ្ទាល់ជាកម្លាំងពលកម្មក្នុងការសាងសង់លំនៅឋានរបស់ខ្លួន។

**២- ការសន្សំប្រាក់តាមកិច្ចសន្យា** ៖ គ្រួសារនីមួយៗឬសហគមន៍ត្រូវធ្វើការសន្សំប្រាក់ ហូតដល់កម្រិតណាមួយទើបអាចសុំខ្ចីបំពេញបន្ថែមបាន។ រដ្ឋលើកទឹកចិត្តនិងគាំទ្រដល់ភ្នាក់ងារមីក្រូហិរញ្ញវត្ថុ ស្ថាប័នហិរញ្ញវត្ថុខ្នាតតូចដែលផ្តល់ឥណទានខ្នាតតូចដល់សហគ្រាសផលិតសម្ភារៈសំណង់សម្រាប់លក់ជូនគ្រួសារមានចំណូលមធ្យមនិងចំណូលទាបដោយការបង់រំលស់។ ករណីនេះ គឺដូចជាការផ្តល់កម្ចីបន្ថែមដល់អ្នកមានប្រាក់ចំណូលមធ្យមនិងប្រាក់ចំណូលទាបដើម្បីយកទៅអភិវឌ្ឍលំនៅឋាន ឬបង្កើតឱកាសថ្មីសម្រាប់ជីវភាពគ្រួសារដោយយកអត្រាការប្រាក់ទាប។ ជម្រើសនេះអាចមានលក្ខណៈសមស្របចំពោះគ្រួសារមានប្រាក់ចំណូលមធ្យមនិងប្រាក់ចំណូលទាបដោយតម្រូវឱ្យគ្រួសារដែលទទួលផលចូលរួមជាកម្លាំងពលកម្មកម្រិតណាមួយក្នុងការសាងសង់លំនៅឋាន។

**៣- មូលនិធិពិសេសសម្រាប់លំនៅឋាន** ៖ ជាការផ្តល់ប្រាក់ឧបត្ថម្ភ និង/ឬប្រាក់កម្ចីដើម្បីកែលម្អលំនៅឋានឬទិញដីសម្រាប់សាងសង់លំនៅឋានដល់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ ដែលត្រូវការថវិកាចាំបាច់និងការផ្គត់ផ្គង់ហិរញ្ញវត្ថុពីរដ្ឋ ដៃគូអភិវឌ្ឍ វិស័យឯកជន សប្បុរសជន ឬពីសង្គមស៊ីវិល។ ប៉ុន្តែ ជាទូទៅ ការផ្តល់មូលនិធិពិសេសបែបនេះមិនសូវឆ្លើយតបនឹងតម្រូវការរបស់អ្នកក្រីក្របំផុតនៃបណ្តាអ្នកក្រីក្រឡើយ ពីព្រោះពួកគេមិនអាចបំពេញតាមលក្ខខណ្ឌនៃវិធីដាក់ប្រាតិភោគឬកម្ចីបែបនេះហើយ ការផ្តល់ប្រាក់កម្ចីបែបនេះក៏មិនបានគ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃតម្រូវការរបស់អ្នកក្រីក្រឡើយ។ ដូច្នេះជាលទ្ធភាព គួរផ្តល់នូវឥណទានដល់គ្រួសារ ឬសហគមន៍ផ្ទាល់ដែលមិនទាមទារនូវការដាក់ប្រាតិភោគក្នុងការទទួលបានប្រាក់កម្ចី។

អ្នកអភិវឌ្ឍអចលនវត្ថុដែលធ្វើការអភិវឌ្ឍដីដោយសុំប្តូរប្រភេទប្រើប្រាស់ដីសម្រាប់គម្រោងលំនៅឋានត្រូវបង់ពន្ធជូនរដ្ឋ។

**៤- ធនាគារផ្តល់ប្រាក់កម្ចីទិញផ្ទះដោយសងរំលស់តាមកាលកំណត់** : គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឯកជនអាចផ្តល់ប្រាក់កម្ចីសម្រាប់ទិញផ្ទះហើយត្រូវបង់រំលស់តាមកាលកំណត់ ដោយរដ្ឋអាចមានគោលការណ៍អនុគ្រោះធ្វើឱ្យប្រាក់កម្ចីមានការប្រាក់ទាបជាងទីផ្សារ។ ជម្រើសជាប្រពៃណីនេះភាគច្រើនសម្រាប់តែគ្រួសារដែលមានប្រាក់ចំណូលមធ្យមនិងខ្ពស់ប៉ុណ្ណោះ ដោយហេតុថាធនាគារឯកជនតម្រូវឱ្យគោរពតាមលក្ខខណ្ឌតឹងរ៉ឹងរបស់គេដូចជាការដាក់ប្រាតិភោគជាដើម។

**៥- ធនាគាររដ្ឋផ្តល់ប្រាក់កម្ចីសម្រាប់កែលម្អឬសាងសង់លំនៅឋាន** : គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុរបស់រដ្ឋអាចផ្តល់ប្រាក់កម្ចីសម្រាប់កែលម្អឬសាងសង់លំនៅឋានដល់គ្រួសារដែលមានប្រាក់ចំណូលមធ្យមនិងប្រាក់ចំណូលទាប ដែលពេលខ្លះរដ្ឋអាចដើរតួជាអ្នកអភិវឌ្ឍអចលនវត្ថុឬធ្វើតាមរយៈក្រុមហ៊ុនអចលនវត្ថុ។ តែករណីនេះអាចមិនឆ្លើយតបទៅនឹងអ្នកក្រីក្របំផុតក្នុងចំណោមអ្នកក្រីក្រទូទៅនោះឡើយ ពីព្រោះពួកគេមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមការតម្រូវឱ្យមានការដាក់ប្រាតិភោគ។ ជាវិធីជំនួសវិញគឺការផ្តល់ប្រាក់កម្ចីទៅសហគមន៍ផ្ទាល់ដើម្បីឱ្យសហគមន៍ទទួលខុសត្រូវ ហើយបែងចែកប្រាក់កម្ចីនោះបន្តទៅឱ្យគ្រួសារដែលជាសមាជិកសហគមន៍របស់ខ្លួន។

**៦- ការលក់កាតសន្សំប្រាក់សម្រាប់លំនៅឋាន** : ការលក់កាតសន្សំប្រាក់នេះ គឺដូចគ្នានឹងការលក់កាតទូរស័ព្ទដែរ។ គ្រួសារក្រីក្រអាចទិញកាតនេះតាមលទ្ធភាពទឹកប្រាក់ដែលគេរកបានប្រចាំថ្ងៃឬពេលណាមួយ រួចហើយគេកោសលេខសម្ងាត់ប្រាប់ទៅធនាគារណាដែលគេបានបើកគណនីសន្សំប្រាក់ ធនាគារនោះនឹងបញ្ចូលចំនួនទឹកប្រាក់តាមតម្លៃកាតទៅក្នុងគណនីរបស់គេ ហើយរដ្ឋអាចផ្តល់ប្រាក់បន្ថែមកម្រិតណាមួយជាការលើកទឹកចិត្តដល់ការសន្សំប្រាក់សម្រាប់គោលដៅលំនៅឋាន។ នេះជាទម្រង់មួយនៃការសន្សំប្រាក់សម្រាប់ទិញដីសាងសង់លំនៅឋាន ជាពិសេស នៅតំបន់ជនបទដែលប្រជាពលរដ្ឋអាចបើកគណនីសម្រាប់សន្សំប្រាក់បាន។

**៧- ប្រាក់សន្សំក្នុងគណនីពិសេសក្នុងធនាគារ** : គឺជាប្រភេទគណនីដែលផ្តល់អត្រាការប្រាក់ថេរនិងផលប្រយោជន៍បង្កើនទ្រព្យសម្បត្តិ សម្រាប់និយោជិតដែលមានប្រាក់ខែនិងប្រាក់លើកទឹកចិត្តប្រចាំឆ្នាំឬសម្រាប់អ្នកទទួលប្រាក់បៀវត្សពីរដ្ឋ ដែលតាមធម្មតា មានរយៈពេលកំណត់ចំនួន៧(ប្រាំពីរ)ឆ្នាំគឺម្ចាស់គណនីមិនអាចដកប្រាក់សន្សំមកចំណាយមុនឆ្នាំទី៨(ប្រាំបី)ឡើយ។ ជម្រើសនេះច្រើនអនុវត្តចំពោះគ្រួសារដែលមានប្រាក់ចំណូលមធ្យមនិងជាទៀងទាត់។

## ៥.៦- នគរូបនីយកម្មនិងផែនការអភិវឌ្ឍតំបន់ថ្មី

តម្រូវការថ្មីៗនៃការប្រើប្រាស់ដីក្នុងទីក្រុងនិងទីប្រជុំជនអាចមានផលប៉ះពាល់ដល់ប្រជាជនមួយចំនួនដែលត្រូវផ្លាស់ប្តូរទីតាំងថ្មី។ ដើម្បីបញ្ចៀសឬកាត់បន្ថយផលវិបាកអវិជ្ជមានទាំងនេះ អាជ្ញាធរថ្នាក់ក្រោមជាតិត្រូវផ្តួចផ្តើមគំនិតកសាងផែនការប្រើប្រាស់ដីឬផែនការអភិវឌ្ឍទីក្រុង ទីប្រជុំជន និងជនបទដោយសម្របទៅតាមតម្រូវការថ្មីនៃដីធ្លីនិងកំណត់ទីតាំងថ្មីដើម្បីសាងសង់លំនៅឋានសម្រាប់អ្នកមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជន/.

ងាយរងគ្រោះ។ ចំពោះផែនការអភិវឌ្ឍក្នុងតំបន់ថ្មី ត្រូវយកចិត្តទុកដាក់លើទីតាំងសមស្រប ដែលមានទ្រង់ទ្រាយប្រមូលផ្តុំ និងអាចអនុគ្រោះដល់ការតភ្ជាប់បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិង សេវានានាដែលមានស្រាប់ ព្រមទាំងជំរុញឱ្យមានការសិក្សាដើម្បីអភិវឌ្ឍប្រភេទផ្សេងៗនៃ លំនៅឋានជាផ្ទះបែបឯកជនមួយៗ ជាផ្ទះលំនាំជាប់គ្នា ជាផ្ទះពាក់កណ្តាលជាប់គ្នា ជាផ្ទះជាប់ គ្នាច្រើនជាន់សម្រាប់ច្រើនគ្រួសារ និងអគារសម្រាប់ជួល ព្រមទាំងលំនៅឋានរបស់រដ្ឋនិង ស្ថាប័នសាធារណៈដើម្បីទាក់ទាញការវិនិយោគក្នុងតំបន់នោះក៏ដូចជាទាក់ទាញអ្នកដែល ត្រូវប្តូរមកតាំងទីលំនៅថ្មី។

## ៥.៧- ដំណោះស្រាយបញ្ហាចំពោះមុខ

ដំណោះស្រាយចំពោះការតាំងលំនៅឋានសម្រាប់ប្រជាជនក្រីក្រនៅទីក្រុងទាក់ទងជិត ស្និទ្ធទៅនឹងយុទ្ធសាស្ត្រនៃការរកប្រាក់ចំណូលរបស់គ្រួសារ លទ្ធភាពដែលអាចទទួលបាន សេវាជាមូលដ្ឋាន និងឱកាសការងារ។ កន្លងមក ភាគច្រើននៃការតាំងទីលំនៅបណ្តោះអាសន្ន កើតមាននៅលើដីសាធារណៈរបស់រដ្ឋ ធ្វើឱ្យពួកគេប្រឈមទៅនឹងការផ្លាស់ប្តូរទីតាំងទៅកាន់ កន្លែងថ្មី។ បទពិសោធនៃការអនុវត្តបានបង្ហាញថាគម្រោងផ្លាស់ប្តូរទីតាំងសំណង់បណ្តោះ អាសន្នជាច្រើនធ្វើឡើងក្នុងគោលបំណងកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថានទីក្រុង កាត់ បន្ថយសំណង់បណ្តោះអាសន្ននិងភាពក្រីក្រក្នុងទីក្រុង។ ប៉ុន្តែក្នុងករណីខ្លះ ក៏បានធ្វើឱ្យប៉ះ ពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រមួយចំនួនផងដែរ ជាពិសេសនៅឆ្នាំដំបូងៗនៃការ ទៅតាំងទីលំនៅនៅកន្លែងថ្មី។

### ក- ការធានាសិទ្ធិកាន់កាប់មានរយៈពេលកំណត់ចំពោះម្ចាស់សំណង់បណ្តោះអាសន្ន

ការធានាឱ្យមានសិទ្ធិកាន់កាប់សម្រាប់រយៈពេលអនុគ្រោះជាក់លាក់មួយ(ពី៣ឆ្នាំទៅ ៥ឆ្នាំ)ដល់អ្នករស់នៅក្នុងទីតាំងសំណង់បណ្តោះអាសន្នគឺជាចំណុចចាប់ផ្តើមក្នុងការស្វែង រកដំណោះស្រាយនិងការរៀបចំលក្ខខណ្ឌចាំបាច់សម្រាប់អភិវឌ្ឍជីវភាពរស់នៅរបស់ពួកគាត់។ ជាទូទៅ ភាពមិនច្បាស់លាស់ក្នុងការតាំងទីលំនៅគឺជាឧបសគ្គមួយនៃការអភិវឌ្ឍនិងការ វិនិយោគទៅលើលំនៅឋានហើយក៏ជាស្ថានភាពមួយមិនអំណោយផលដល់អ្នកតាំងលំនៅ ឋានជាថ្មីនិងដល់សេដ្ឋកិច្ចជាតិដែរ។ ដូច្នេះទាមទារឱ្យមានដំណោះស្រាយសមរម្យនិងការ រៀបចំផែនការរយៈពេលមធ្យមនិងរយៈពេលវែងនៃការប្រើប្រាស់ដីធ្លីដើម្បីឆ្ពោះទៅសម្រេច យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុង ទីប្រជុំជន និងជនបទ។

ការធានាសុវត្ថិភាពនៃអ្នកកាន់កាប់ដីធ្លីផ្តល់នូវភាពឯករាជ្យផ្នែកសេដ្ឋកិច្ចយ៉ាងសំខាន់ និងលើកទឹកចិត្តដល់ប្រជាជនក្នុងការវិនិយោគលើវិស័យអចលនទ្រព្យនិងការអភិវឌ្ឍលំនៅឋាន។ ដូច្នេះ ត្រូវមានការធានាសិទ្ធិកាន់កាប់បណ្តោះអាសន្នក្នុងរយៈពេលកំណត់មួយជាក់លាក់ដល់ អ្នកតាំងលំនៅឋានបណ្តោះអាសន្នទាំងអស់ ដើម្បីឱ្យអ្នកទាំងនោះអាចត្រៀមខ្លួនក្នុងការចូល រួមអភិវឌ្ឍនៅនឹងកន្លែងឬការប្តូរទៅទីតាំងថ្មី។ ក្នុងរយៈពេលនៃការផ្តល់ការកាន់កាប់បណ្តោះ អាសន្ននេះ ត្រូវធ្វើការពិនិត្យអំពីលក្ខខណ្ឌច្បាប់នៃគ្រួសារក្នុងសហគមន៍តាមវិធីសាស្ត្រជាក់លាក់ ដើម្បីស្រាវជ្រាវនិងកំណត់អ្នកដែលមានស្ថានភាពសមស្របសម្រាប់ការអភិវឌ្ឍនៅនឹងកន្លែង

អ្នកដែលជ្រើសរើសយកការផ្លាស់ប្តូរទីតាំង អ្នកដែលជ្រើសរើសយកការបែងចែកដីតាមរូបភាពផ្សេងៗ និងអ្នកដែលជ្រើសរើសយកសំណងឬគោលនយោបាយជាថវិកាឬសម្ភារៈ។ ទន្ទឹមនឹងនេះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវសហការស្វែងរកដៃគូអភិវឌ្ឍវិស័យឯកជន និងសង្គមស៊ីវិលក្នុងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មនានាដោយមានការចូលរួមពីផ្នែកផ្សេងៗទៀតដូចជាផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងសមត្ថភាពក្នុងការធ្វើផែនការ។

ចំពោះប្រជាជនដែលកាន់កាប់អចលនវត្ថុស្របច្បាប់ ប្រសិនបើគាត់យល់ព្រមផ្លាស់ប្តូរទៅទីតាំងថ្មីត្រូវធ្វើការវាយតម្លៃត្រឹមត្រូវតាមទីផ្សារនូវថ្លៃអគារនិងដីសម្រាប់ការទូទាត់សំណងអនុលោមទៅតាមច្បាប់ស្តីពីអស្សាមិករណ៍និងច្បាប់ភូមិបាល។ ឯប្រជាជនឬសហគមន៍ដែលមានសិទ្ធិកាន់កាប់អចលនវត្ថុស្របច្បាប់ ហើយដែលចាំបាច់ត្រូវប្តូរឱ្យទៅតាំងទីលំនៅថ្មីដោយសារតម្រូវការទីតាំងដើម្បីបម្រើផលប្រយោជន៍សាធារណៈ ហើយការផ្លាស់ប្តូរនេះជាជម្រើសចុងក្រោយ អ្នករងផលប៉ះពាល់ត្រូវទទួលបានសំណងសមរម្យនិងមានសិទ្ធិកាន់កាប់ស្របច្បាប់លើដីធ្លីនិងលំនៅឋានថ្មីដែលមានលក្ខណវិនិច្ឆ័យគ្រប់គ្រាន់ អាចរស់នៅបានក្នុងទីតាំងណាមួយដែលមានចម្ងាយសមរម្យទៅកន្លែងធ្វើការងារ មានហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានជាអាទិ៍ ផ្លូវថ្នល់ ទឹកស្អាត ប្រព័ន្ធលូ កន្លែងចាក់សំរាម អគ្គិសនី(តាមលទ្ធភាពជាក់ស្តែង) និងសេវាចាំបាច់សំខាន់ផ្សេងៗទៀតដូចជាសេវាសុខភាព អប់រំ សុវត្ថិភាព សណ្តាប់ធ្នាប់។ រាល់ការតាំងទីលំនៅ ទោះបីជានៅកន្លែងចាស់ឬនៅទីតាំងថ្មីក៏ដោយត្រូវធ្វើការសិក្សាជាមុននូវវិធានការសម្រាប់ឆ្លើយតបនឹងហានិភ័យដូចជាអគ្គិភ័យ ទឹកជំនន់ ការប៉ះពាល់ខាងបរិស្ថាន។ ដំណោះស្រាយនៃការទទួលបានលំនៅឋានឬការកែលម្អលំនៅឋានចាំបាច់ត្រូវអនុវត្តតាមនីតិវិធីច្បាប់និងគោលការណ៍នៃការចូលរួម មានតម្លាភាពនិងគណនេយ្យភាព ដោយត្រូវធ្វើការអង្កេតច្បាស់លាស់ដើម្បីរៀបចំផែនការអភិវឌ្ឍនិងអនុវត្តផែនការដែលបានឯកភាពគ្នា។

ចំពោះករណីអ្នកកាន់កាប់អចលនវត្ថុខុសច្បាប់គួរិះរកគោលនយោបាយដែលអាចអនុគ្រោះផ្តល់ដីសម្រាប់ជួល ឬជម្រកសម្រាប់ជួលរយៈពេលវែង ឬជាកញ្ចប់ថវិកា សម្ភារៈ ទៅតាមករណីនីមួយៗ។ ប្រសិនបើទីតាំងសំណង់បណ្តោះអាសន្នណាមួយអនុគ្រោះដល់ការបន្តកាន់កាប់នៅនឹងកន្លែង សិទ្ធិកាន់កាប់នេះគួរធ្វើការចុះបញ្ជីតាមនីតិវិធីដូចជាការផ្តល់សិទ្ធិផលុបភោគ ការផ្តល់ភតិសន្យារយៈពេលវែងជាដើម។

ចំពោះសហគមន៍ដែលទីតាំងរបស់ខ្លួនមានភាពអនុគ្រោះ ការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិនឹងផ្តល់ឱកាសដល់ពួកគាត់នូវលទ្ធភាពក្នុងការទាក់ទាញទុនវិនិយោគពីវិស័យឯកជនសម្រាប់ការដោះស្រាយបញ្ហាលំនៅឋាននិង/ឬសម្រាប់ដំណើរការអភិវឌ្ឍសហគមន៍។

## ខ-ការស្ទាបស្ទង់មតិ ការប្រមូលព័ត៌មាន និងការវិភាគទិន្នន័យ

មានបញ្ហាជាច្រើនក្នុងការដោះស្រាយសំណង់បណ្តោះអាសន្នដែលតម្រូវឱ្យមានការស្វែងយល់អំពីកម្លាំងចលករដើម្បីរួមចំណែកជួយធ្វើឱ្យសហគមន៍មានការរីកចម្រើន។ ដូច្នេះ គោលការណ៍នៃការតាំងលំនៅឋានត្រូវកំណត់ឱ្យមាន "ការស្ទាបស្ទង់មតិមុននឹងធ្វើផែនការ (ការ

ហើយធ្វើផែនការដោយមានការចូលរួមមុននឹងអភិវឌ្ឍ"។ ផ្អែកលើមូលដ្ឋាននៃការដោះស្រាយសំណង់បណ្ដោះអាសន្ននិងផ្អែកលើមូលដ្ឋានច្បាប់ ការកែលម្អជីវភាពរស់នៅរបស់អ្នកតាំងលំនៅឋានស្របច្បាប់និងមិនស្របច្បាប់ គឺជាការវិនិយោគមួយមានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃតំបន់ទីក្រុងនិងជនបទ។ ដូច្នេះក្នុងការស្ទាបស្ទង់មតិដំបូងចាំបាច់ត្រូវធ្វើការប្រមូលទិន្នន័យអំពីស្ថានភាពជាក់ស្ដែងនៃលំនៅឋាន ការរៀបចំជាកម្រងសំណួរដើម្បីធ្វើសម្ភាសន៍ម្ចាស់សំណង់បណ្ដោះអាសន្ននិង/ឬតំណាងសហគមន៍តាមទីតាំងនីមួយៗ និងការវិភាគទិន្នន័យដែលប្រមូលបានតាមការវិភាគបែបបរិមាណនិងតាមការវិភាគបែបគុណភាព។

លទ្ធផលនៃការសិក្សាស្រាវជ្រាវដំបូងត្រូវប្រកាសផ្សាយជាសាធារណៈ ហើយត្រូវផ្ដល់លទ្ធភាពដើម្បីពិភាក្សាធ្វើសេចក្ដីសម្រេចលើជម្រើសដំណោះស្រាយណាមួយផ្អែកលើស្ថានភាពនៃទីតាំងសំណង់បណ្ដោះអាសន្ននិងជីវភាពរស់នៅរបស់អ្នកស្នាក់នៅ ដោយមានការចូលរួមពីសហគមន៍ផ្ទាល់។

## គ- សេវាកម្មមូលដ្ឋានគាំទ្រដល់ការអនុវត្តការងារលំនៅឋាន

ការតាំងលំនៅឋានទាំងការអភិវឌ្ឍនៅនឹងកន្លែង ទាំងការផ្លាស់ប្ដូរទៅទីតាំងថ្មី ត្រូវអនុវត្តទៅតាមក្របខ័ណ្ឌច្បាប់ដែលត្រូវធានានូវហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន សេវាកម្មចាំបាច់ លំហបៃតង និងទីកម្សាន្ត។ល។

ការសាងសង់លំនៅឋានបន្ថែមត្រូវចាត់ទុកជាដំណោះស្រាយមួយចំពោះគ្រួសារដែលកំពុងរស់នៅកកកុញ និងគ្រួសារដែលរស់នៅក្នុងលំនៅឋានមិនសមរម្យ។ ការសិក្សាអំពីតម្រូវការលំនៅឋាននិងទីកន្លែងសាងសង់លំនៅឋាននៅទីតាំងថ្មី គួររៀបចំឱ្យមានលំហសមរម្យនិងមានភាពរឹងមាំសម្រាប់លំនៅឋានដែលបង្កលទ្ធភាពឱ្យអ្នកទទួលផលអាចបន្តកែលម្អនាពេលអនាគត។ ដូច្នេះការតាំងលំនៅឋានត្រូវគិតគូរដល់៖

- លទ្ធភាពងាយស្រួលក្នុងការស្វែងរកការងារនិងការបណ្ដុះបណ្ដាលវិជ្ជាជីវៈផ្សេងៗ ក្នុងគោលបំណងផ្ដល់ឱកាសរកចំណូលឱ្យកាន់តែប្រសើរឡើង ហើយប្រសិនបើអាចគឺការងារនៅក្នុងទីតាំងសហគមន៍ផ្ទាល់
- ការរៀបចំនិងអនុវត្តបទដ្ឋានបច្ចេកទេសសាងសង់ដែលមានតម្លៃទាបធានាគុណភាពនិងសុវត្ថិភាពនិងការបង្កលក្ខណៈងាយស្រួលដល់ការអនុញ្ញាតសាងសង់និងការផ្ដល់សិទ្ធិកាន់កាប់ដី
- ការគាំទ្រដល់ការប្រើប្រាស់សម្ភារៈសំណង់ដែលមានក្នុងមូលដ្ឋាននិងកិច្ចសហការបង្កើនការផ្គត់ផ្គង់សម្ភារៈសំណង់ដល់សហគមន៍ក្នុងតម្លៃទាប
- ការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដោយបញ្ចូលទៅក្នុងផែនការសកម្មភាព
- ការគាំទ្រដល់ការសិក្សាស្រាវជ្រាវនិងការបណ្ដុះបណ្ដាល ដើម្បីធ្វើឱ្យកាន់តែប្រសើរនូវប្រសិទ្ធភាពនៃធនធាននៅក្នុងមូលដ្ឋានផ្ទាល់ ដូចជាបច្ចេកវិទ្យាជំនាញនិងគុណភាពសម្ភារៈសំណង់ជាដើម និង

- ការស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍ ផ្នែកឯកជន សង្គមស៊ីវិលនិង/ឬសហគមន៍ក្នុងការអភិវឌ្ឍវិធានការទាំងនេះ។

## ៦- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ដើម្បីប្រសិទ្ធភាពនិងនិរន្តរភាពការងារ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវមានមន្ត្រីអនុវត្តការងារនេះជាប្រចាំក្នុងគោលបំណងសិក្សា ស្រាវជ្រាវរកចំណុចខ្លាំង ចំណុចខ្សោយ បទពិសោធល្អៗ និងកាលានុវត្តភាពដើម្បីសម្រេចផែនការរបស់ខ្លួន។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំវេទិកាស្ដីពីលំនៅឋានយ៉ាងតិចមួយដងក្នុងមួយឆ្នាំដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដើម្បីកសាងយុទ្ធសាស្ត្រលំនៅឋានផ្សារភ្ជាប់នឹងគោលការណ៍ណែនាំ កម្មវិធី និងគម្រោងនានា។ ចំពោះគម្រោងដែលពាក់ព័ន្ធនឹងការផ្ដល់លំនៅឋានសមរម្យដល់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះដែលបានដាក់ចេញ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវតាមដានការអនុវត្តនិងវាយតម្លៃជាប្រចាំដើម្បីធានាប្រសិទ្ធភាពអនុវត្តនិងផលប៉ះពាល់ជាវិជ្ជមាន។

## ៧- សេចក្ដីសន្និដ្ឋាន

គោលនយោបាយជាតិស្ដីពីលំនៅឋានគឺជាផែនទីចង្អុលផ្លូវរបស់រាជរដ្ឋាភិបាលសំដៅរួមចំណែកដោះស្រាយបញ្ហាសង្គម ដោយការលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើងតាមរយៈការខិតខំតាមគ្រប់រូបភាព ដើម្បីធានាថាប្រជាជនគ្រប់រូបអាចទទួលបាននូវលំនៅឋានសមរម្យនិងមានសុវត្ថិភាព។

គោលនយោបាយលំនៅឋានគឺធ្វើឡើងសម្រាប់ប្រជាជនកម្ពុជាគ្រប់រូបដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ឋានៈសង្គម ធនធានឬស្ថានភាពឯទៀតឡើយ។ អភិបាលកិច្ចល្អលើការងារលំនៅឋានគួបផ្សំនឹងការរៀបចំផែនការប្រើប្រាស់ដីសម្រាប់លំនៅឋាន គឺជាការធានានូវសិទ្ធិអាចទទួលបានលំនៅឋានសមរម្យរបស់ប្រជាជន ជាពិសេស គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ។

ដូច្នេះ ការអនុវត្តគោលនយោបាយដីធ្លីនិងលំនៅឋាននឹងរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនិងការបង្កើតឱកាសការងារ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើងដែលនឹងធ្វើឱ្យសម្រេចនូវគោលនយោបាយជាតិកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលនិងការសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

# ឧបសម្ព័ន្ធទី៣

# ក្របខណ្ឌយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុង

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់

# ក្របខណ្ឌយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុង

គម្រោងកសាងសមត្ថភាពសម្រាប់ការគ្រប់គ្រងទីក្រុង-ទីប្រជុំជន

**(CDTA 8121-CAM)**

ឧបត្ថម្ភដោយ ធនាគារអភិវឌ្ឍន៍អាស៊ី

Green Goal

GROUP FOUR Architects + Engineers

# មាតិកា


មាតិកា ........ 2

អក្សរនិងពាក្យកាត់ ........ 3

ការថ្លែងអំណរគុណ ........ 4

1. សេចក្តីផ្តើម ........ 5

2. ហេតុផលដែលបណ្តាលឲ្យមានគម្រោងកសាងសមត្ថភាព ........ 5

3. សំណើក្របខណ្ឌយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុង ........ 6

3.1. បរិបទគោលនយោបាយ ........ 6

3.2. គោលនយោបាយនិងយុទ្ធសាស្ត្រ ........ 9

3.3. បញ្ហាប្រឈមនានារបស់ទីក្រុង ........ 9

3.4. ចក្ខុវិស័យ – អាទិភាពរយៈពេលវែងខ្លីនិងមធ្យម ........ 11

3.5. គោលដៅនិងវត្ថុបំណង ........ 11

3.6. សមាសធាតុយុទ្ធសាស្ត្រ / តំបន់ដែលគ្រោងទុក ........ 16

3.7. វិធីដោះស្រាយ/របៀបដោះស្រាយ ........ 22

3.8. ការអនុវត្ត ការគ្រប់គ្រង និងការពិនិត្យតាមដានរបស់យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុង ........ 24

A ឧបសម្ព័ន្ធ ........ 27

A.i. ឯកសារយោង ........ 27

A.ii. សេចក្តីពន្យល់សង្ខេបអំពីបញ្ហាប្រឈមគន្លឹះ ........ 28

A.iii. ការកំណត់តំបន់មិនមែនជាទីក្រុង ........ 31

A.iv. សន្ទានុក្រមនៃពាក្យ ........ 33

# អក្សរនិងពាក្យកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី<br>Asian Development Bank |
| AEC | សហគមន៍សេដ្ឋកិច្ចនៃប្រជាជាតិអាស៊ីអគ្នេយ៍<br>ASEAN Economic Community |
| ASEAN | សមាគមន៍នៃប្រជាជាតិអាស៊ីអគ្នេយ៍<br>Association of South East Asian Nations |
| CDTA | គម្រោងជំនួយបច្ចេកទេសកសាងសមត្ថភាព<br>Capacity Development Technical Assistance Project |
| D&D | វិមជ្ឈការនិងវិសហមជ្ឈការ<br>Decentralization and Deconcentration |
| GMS | មហាអនុតំបន់ទន្លេមេគង្គ<br>Greater Mekong Sub-Region |
| ISIC | ស្តង់ដារអន្តរជាតិសម្រាប់ចំណាត់ថ្នាក់ឧស្សាហកម្ម<br>International Standard for Industrial Classification |
| JFPR | មូលនិធិជប៉ុនសម្រាប់កាត់បន្ថយភាពក្រីក្រ<br>Japan Fund for Poverty Reduction |
| LDC | ប្រទេសមានការអភិវឌ្ឍន៍តិចតួច<br>Less Development Country |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>Ministry of Agriculture Fisheries and Forestry |
| MIH | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>Ministry of Industry and Handicrafts |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>Ministry of Land Management Urban Planning and Construction |
| MME | ក្រសួងរ៉ែ និងថាមពល<br>Ministry of Mines and Energy |
| MoE | ក្រសួងបរិស្ថាន<br>Ministry of Environment |
| MoEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>Ministry of Economy and Finance |
| MoI | ក្រសួងមហាផ្ទៃ<br>Ministry of the Interior |
| MoP | ក្រសួងផែនការ<br>Ministry of Planning |
| MoWRAM | ក្រសួងធនធានទឹក និងឧតុនិយម<br>Ministry of Water Resources and Meteorology |

| | | |
|---|---|---|
| MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន<br>Ministry of Public Works and Transport |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ<br>National Committee for Sub-national Democratic Development |
| NCGG | ក្រុមប្រឹក្សាជាតិស្តីពីការអភិវឌ្ឍបៃតង<br>National Council on Green Growth |
| NCLMUP | គណៈកម្មាធិការជាតិសម្រាប់គ្រប់គ្រងដែនដី និងផែនការក្រុង<br>National Committee for Land Management & Urban Planning |
| NIS | វិទ្យាស្ថានជាតិស្ថិតិ<br>National Institute of Statistics |
| NSDP | យុទ្ធសាស្ត្រជាតិស្តីពីផែនការអនុវត្តឆ្នាំ២០១៤-២០១៨<br>National Strategic Development Plan 2014-2018 |
| NUDS | យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុង<br>National Urban Development Strategy |
| PUC | សាកលវិទ្យាល័យបញ្ញាសាស្ត្រាកម្ពុជា<br>Pannasastra University of Cambodia |
| RGC | រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។<br>Royal Government of the Kingdom of Cambodia |
| RSIII | យុទ្ធសាស្ត្រចតុកោណសម្រាប់ការអភិវឌ្ឍ ការងារ សមធម៌ និងប្រសិទ្ធភាព<br>Rectangular Strategy for Growth, Employment, Equity and Efficiency- Phase III |
| SDGs | ទិសដៅអភិវឌ្ឍប្រកបដោយចីរភាព<br>Sustainable Development Goals (to be adopted in 2015) |
| UN-Habitat | កម្មវិធីលំនៅដ្ឋានអង្គការសហប្រជាជាតិ<br>United Nations Human Settlements Programme |

# ការថ្លែងអំណរគុណ

## 1. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់អាទិភាពគោលនយោបាយមួយ សម្រាប់អណត្តិទី៥នៃរដ្ឋសភា គឺការរៀបចំ យុទ្ធសាស្រ្តជាតិស្តីពីការអភិវឌ្ឍទីក្រុង.ទីប្រជុំជន។ គោលបំណងនេះគឺដើម្បីរួមចំណែកកែលំអ ប្រសិទ្ធភាពសេដ្ឋកិច្ចជាតិ និងការប្រកួតប្រជែង លើកកំពស់សុខមាលភាពប្រជាពលរដ្ឋ ហើយនិងជានាអំពីនិរន្តរភាពបរិស្ថាន ដោះស្រាយអំពីបញ្ហាដឹកជញ្ជូន និងជំនះការកកស្ទះចរាចរណ៍ តាមរយៈសង្គតិភាព/ស្របនឹង គោលនយោបាយទាក់ទងនឹងទីក្រុង-ទីប្រជុំជន ការរៀបចំដែនដី ការរៀបចំក្រុង ការអភិវឌ្ឍក្រុង និង ការគ្រប់គ្រងក្រុង។ ក្របខណ្ឌទាំងនេះគឺផ្តល់គំនិតស៊ីជម្រៅមួយចំនួន ទៅក្នុងបញ្ហា និងការប្រឈម ដែលចាំបាច់ ត្រូវដោះស្រាយ ក៏ដូចជាផ្តល់គោលការណ៍ណែនាំនិងលើកទឹកចិត្ត សម្រាប់ការពិភាក្សាលើជាតុចូល មុននឹង អភិវឌ្ឍយុទ្ធសាស្រ្តជាតិស្តីពីការអភិវឌ្ឍទីក្រុង។

## 2. ហេតុផលដែលបណ្តាលឲ្យមានគម្រោងកសាងសមត្ថភាព

នគរូបនីយកម្មជាដំណើរការឌីណាមិចមួយដែលមានកត្តានិងឥទ្ធិពលធំៗជាច្រើន( ពាក់ព័ន្ធនឹងកំណើនជា សកល និងតំបន់ប៉ុន្តែពាក់ព័ន្ធជាពិសេសមិនត្រឹមតែជាមួយកត្តាសេដ្ឋកិច្ច ប្រជាសាស្រ្តប៉ុណ្ណោះទេថែមទាំង ជាមួយ កត្តានយោបាយផងដែរ)។ នគរូបនីយកម្មគឺជាកត្តាជម្រុញផងនិងជាអ្នកទទួលរងនូវការអភិវឌ្ឍនិង កំណើន សេដ្ឋកិច្ចផងដែលបណ្តាលមកពីការប្រមូលផ្តុំនៃប្រជាជននិងឧស្សាហកម្មដែលជាបច្ច័យ មានឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមាន។

ជាលទ្ធផលវិជ្ជមានរួមមានសេវាកម្មទូលំទូលាយនិងប្រកបដោយគុណភាព ក៏ដូចជាទំនិញច្រើនក្នុងតម្លៃថោក ធ្វើឲ្យមានការដឹកជញ្ជូនទំនិញ ការងារសេវាកម្មនិងឧស្សាហកម្មកាន់តែសម្បូរបែប និងមានប្រសិទ្ធភាព។ ការប្រមូលផ្តុំឧស្សាហកម្មនិងសកម្មភាពសេដ្ឋកិច្ចនៅក្នុងទីប្រជុំជន ក៏មានសក្តានុពល ក្នុងការរក្សានិងគាំទ្រដល់ សហគ្រាសធុនតូចនិងមធ្យមដែលផ្តល់សេវាកម្មដល់ឧស្សាហកម្មធំៗ និងសហគ្រាសធុនធំ។ តាមរយៈជំរឿន សេដ្ឋកិច្ចប្រទេសកម្ពុជាឆ្នាំ២០១៤ របស់ក្រសួងផែនការកន្លងទៅនេះ បានរកឃើញថាមានសហគ្រាស ចំនួន៥១៣៧៥៩ ដែលក្នុងនោះប្រហែល៤៦% (២៣៦៣២៩ សហគ្រាស) មានទីតាំងនៅក្នុងក្រុងចំនួន២៧។

ផលប៉ះពាល់ជាអវិជ្ជមានរួមមានការប្រើប្រាស់ដីធ្លីពុំសូវមានប្រសិទ្ធភាព កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មការលាតសន្ធឹងនៃទីក្រុងធំឡើងៗ មានការលំបាកខ្លាំងឡើង និងតម្លៃខ្ពស់ក្នុងការផ្តល់ និងពង្រីក ហេដ្ឋារចនាសម្ព័ន្ធក្រុង ដោយមូលហេតុ ការគ្រប់គ្រង ការរៀបចំនិងផែនការអភិវឌ្ឍក្រុងនៅមានកំរិត ការកើនឡើងចរាចរណ៍និងបង្កការកកស្ទះចរាចរណ៍ ហានិភ័យក្នុងការបំពុលដី បំពុលទឹក បំពុលខ្យល់ ហើយ បង្កជា ហានិភ័យដល់សុខភាពប្រជាជន។ ជារួមកត្តាទាំងនេះអាចជះឥទ្ធិពលអវិជ្ជមានដល់ការលូតលាស់ សេដ្ឋកិច្ច និងការ ប្រកួតប្រជែងនៃអាជីវកម្មក្នុងតំបន់ក្រុង និងទីប្រជុំជនមួយចំនួន។ ផលប៉ះពាល់ទាំងនេះ ចាំបាច់ត្រូវ ដោះស្រាយ ដើម្បីបន្ធូរបន្ថយក្នុងតំបន់ក្រុង និងទីប្រជុំជនមួយចំនួននោះ ព្រមទាំងផលប៉ះពាល់លើប្រជាជន។

ជាប្រវត្តិសាស្រ្ត អត្រានិងភាគរយនៃនគរូបនីយកម្មក្នុងប្រទេសកម្ពុជាពីដើមមានកម្រិតទាប មានកំហិត និងមានការបង្អាក់ដោយប្រវត្តិសាស្រ្តថ្មីៗកន្លងមកនេះរហូតដល់ចុងសតវត្សទី២០។ ទោះយ៉ាងណាក៏ដោយចាប់ពីទសវត្សឆ្នាំ

១៩៩០ អត្រានៃនគរូបនីយកម្មចាប់ផ្តើមងើបនិងកើនឡើងវិញ។ បរិមាណនិងគុណភាពអ្វីដែលទីក្រុងមាន និងការប្រឈម។ ក្រសួងផែនការបានធ្វើចំណាត់ថ្នាក់ប្រជាសាស្ត្រឡើងវិញចំនួនពីរដង ក្នុងរយៈពេលតិចជាង មួយទស្សវត្ស (គឺនៅឆ្នាំ២០០៤ និង២០១១) ដោយយោងលើនិយមន័យទីក្រុង-ទីប្រជុំជន(urban) ហើយ ចំណាត់ថ្នាក់ចុងក្រោយបង្អស់ (ឆ្នាំ២០១១) សង្កេតឃើញថា ចំនួនប្រជាជនរស់នៅក្នុងតំបន់ទីប្រជុំជន បានកើនឡើងពី២០% ដល់ ២៧% ក្នុងឆ្នាំ ២០០៨ បន្ទាប់មកមានការកើនឡើងប្រហែលជា៣០%ត្រឹមដំណាច់ឆ្នាំ ២០១៥។ លើសពីនេះ តំបន់មួយចំនួនត្រូវបានពិចារណាជាទីក្រុង-ទីប្រជុំជន បានកើនឡើងដល់ទៅ៧៨% ពីឃុំ/ សង្កាត់ចំនួន១៦២ក្នុងឆ្នាំ ២០០៤ ដល់ទៅចំនួន២៨៩ ត្រឹមឆ្នាំ២០១១។

ជាក់ស្តែងគឺ ក្រុងនិងទីប្រជុំជនដ៏ទៃទៀតមានការកើនឡើងដោយអត្រាខុសៗគ្នា។ ដោយឡែករាជធានីភ្នំពេញ មានប្រជាជនជាក់ស្តែងចំនួនលើសពី ១.៨លាននាក់ (ក្នុងឆ្នាំ២០១៤) ហើយបើរួមជាមួយនឹងតំបន់ជិតទីក្រុង គឺមានប្រជាជនលើសពី ២លាននាក់។ ប្រជុំជននៃក្រុងចំនួន៥ទៀតមានប្រជាជនសរុបលើសពី ១០០០០០នាក់ រីឯក្រុងចំនួន១៥ ក្នុងចំណោមក្រុងចំនួន២៧ មានប្រជាជនក្នុងក្រុងចំនួនតិចជាង៥០០០០នាក់។ តម្រូវការក្នុងការធ្វើឲ្យប្រសើរឡើងក្នុងការគ្រប់គ្រងការអភិវឌ្ឍនិងរៀបចំផែនការ (និងអភិបាលកិច្ចក្រុង)គឺមាន សារៈសំខាន់ណាស់សម្រាប់ការគាំទ្រទីក្រុងឲ្យមានលក្ខណៈប្រសើរសម្រាប់ការរស់នៅព្រមទាំងមានចីរភាពនៃ បរិស្ថាននិងសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យមទៅរយៈពេលវែង។ ហើយក៏កាន់តែមានភាពចាំបាច់ផងដែរ ក្នុងការរៀបចំរចនាសម្ព័ន្ធនិងប្រព័ន្ធប្រកបដោយប្រសិទ្ធភាពនិងគ្រប់ជ្រុងជ្រោយដែលអាចជួយឲ្យមានតុល្យភាព ក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

## 3. ការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុង

### 3.1. បរិបទគោលនយោបាយ

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដើម្បីអភិវឌ្ឍការងារសមភាពនិងប្រសិទ្ធភាពដំណាក់កាលទី៣និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ឆ្នាំ២០១៤-១៨ ដាក់ចេញនូវគោលដៅ វត្ថុបំណង និងផែនការ សកម្មភាព សម្រាប់រាជរដ្ឋាភិបាលនិងក្រសួងត្រូវសម្រេចឲ្យបានក្នុងអណត្តិទី៥និងអណត្តិក្រោយៗ។ ផែនការយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៣កំណត់ពី "អាទិភាពចំនួន៤" ដោយរួមមានការឆ្លើយតបចំពោះការអភិវឌ្ឍទីក្រុង (សូមមើលផ្នែក ១៤ ប្រយោគទី២) ដែលរួមចំណែកក្នុងលទ្ធផលរួមមាន: (i) តម្លៃដឹកជញ្ជូនទាប (ii)ទំនុកចិត្តនិងប្រសិទ្ធភាពមានការប្រសើរឡើង (iii)មានភាពប្រសើរឡើងក្នុងការប្រកួតប្រជែង (iv) បង្កើនការវិនិយោគ (ការអភិវឌ្ឍសេដ្ឋកិច្ចនិងឧស្សាហកម្ម)និងពាណិជ្ជកម្ម"។ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣បានលើកឡើងពីតម្រូវការក្នុងការគ្រប់គ្រងបរិស្ថាននិងបម្រែបម្រួលអាកាសធាតុដែលជាបញ្ហា ប្រឈមមួយផ្សេងទៀតនៃនិរន្តរភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេសកម្ពុជាដោយហេតុថាមានសម្ពាធពីកំណើនប្រជាជន និង នគរូបនីយកម្ម។

ដើម្បីសម្រេចបាននូវគោលបំណងជាអាទិភាពទាំងនេះរាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់លើ (i) ការលើក កំពស់គោលនយោបាយកម្មសិទ្ធិដីធ្លីឲ្យបានទូលំទូលាយដែលហៅថា"White Paper on Land") ,(ii)ការរៀបចំច្បាប់ស្តីអំពីការរៀបចំដែនដីនិងនគរូបនីយកម្មដែលដំណើរការផែនការរៀបចំយុទ្ធសាស្ត្រនឹងផ្តល់ជាវិភាគទាន។ យុទ្ធ

សាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុងនឹងផ្តល់ជាជំនួយផងដែរក្នុងការទាក់ទាញចំណាប់អារម្មណ៍លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រុងនិងទំនើបភាវូបនីយកម្មដែលជាកត្តាចម្បងជំនួយក្នុងការលូតលាស់និងអភិវឌ្ឍសេដ្ឋកិច្ច ធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពសេដ្ឋកិច្ចក៏ដូចជាពង្រឹងការប្រកួតប្រជែងនិងលើកកម្ពស់សេដ្ឋកិច្ចចម្រុះ ក្នុងការកាត់បន្ថយភាពក្រីក្រ។ រាជរដ្ឋាភិបាលបានដាក់ចេញជាគន្លឹះអាទិភាព មួយចំនួនដែលមានគោលបំណង៖

“ធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពរបស់ប្រជាជននិងធានានិរន្តរភាពបរិស្ថានស្របទៅនឹងក្របខណ្ឌនៃការរៀបចំដែនដីនិងនគរូបនីយកម្ម( យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផ្នែក៧៣) រួមមានគោលនយោបាយជាតិ ស្តីពីលំនៅដ្ឋាននិងការបង្កើតច្បាប់ថ្មីទាក់ទងនឹងការរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និង យុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍទីក្រុងនិងទីប្រជុំជន ( យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផ្នែក៧៧ ប្រយោគ៦ )។

“រៀបចំផែនការមេសម្រាប់ការអភិវឌ្ឍហេដ្ឋរចនាសម្ព័ន្ធក្រុងនិងធានា ឲ្យស្របគ្នានឹងក្របខណ្ឌច្បាប់គតិយុត្ត ស្តីពី ការរៀបចំដែនដី និងនគរូបនីយកម្ម ហើយនិងរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងនិង ទីប្រជុំជន (យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុងនិងទីប្រជុំជនផ្នែក ៤.១០៣ ប្រយោគ៦ )។

“បង្កើតគោលនយោបាយក្នុងការគ្រប់គ្រងលំហូរនៃប្រជាជនក្នុងប្រទេសស្របគ្នាទៅនឹងការអនុវត្តការពង្រឹង ការអនុវត្តគោលនយោបាយផែនការរៀបចំដែនដីនិងនគរូបនីយកម្ម និងយកចិត្តទុកដាក់លើ៖ (1)ការអភិវឌ្ឍ ទីក្រុងភ្នំពេញនិងប៉ូលសេដ្ឋកិច្ចសំខាន់ៗ ផ្សេងទៀត ក្រុងរណបនិងទីប្រជុំជនដ៏ទៃទៀតនៃប្រទេសកម្ពុជា ព្រមទាំងខិតខំប្រឹងប្រែងបង្កើតការងារនៅក្នុងសហគមន៍ទាំងនេះ និង (2) ការតភ្ជាប់ក្រុងរណបនិងទីប្រជុំជន ជាមួយនឹងប៉ូល និងមជ្ឈមណ្ឌលសេដ្ឋកិច្ចសំខាន់ៗទាំងនោះនិងមជ្ឈមណ្ឌលនានា ដើម្បីបង្កើតបានជា របៀងសេដ្ឋកិច្ច” (យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផ្នែក១៣៣ )។

“ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០១៤-២០១៨ ក៏បានទទួលស្គាល់ពីការប្រឈមនានាដើម្បីឲ្យមាននិរន្តរភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេសកម្ពុជាដោយសារកំណើនប្រជាជន កំណើននគរូបនីយកម្មនិងបម្រែបម្រួលអាកាសធាតុព្រមទាំងកត្តាផ្សេងៗទៀត (យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុងនិងទីប្រជុំជន ផ្នែក៤.៣៩ )។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុងនិងទីប្រជុំជនមានរយៈពេល៥ឆ្នាំរបស់រដ្ឋាភិបាលមានបំណងប្រាថ្នាក្នុងការធ្វើកំណែទម្រង់ដីធ្លី ដោយផ្តោតការយកចិត្តទុកដាក់លើការពង្រឹង ការគ្រប់គ្រង ការប្រើប្រាស់និងការបែងចែកដីដែលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងក្របខណ្ឌទីផ្សាររួមបញ្ចូលនិងការរៀបចំច្បាប់ស្តីអំពីផែនរៀបចំដែនដីនិងនគរូបនីយកម្ម”និងធាតុចូលផ្សេងៗទៀត។ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់បានប្តេជ្ញា អនុវត្តនូវសកម្មភាពទូលំទូលាយ មួយចំនួន( យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុងនិងទីប្រជុំជន ផ្នែក៤.៦២ ) ក្នុងអណត្តិរបស់ខ្លួនរួមមាន៖

- អនុម័តលើច្បាប់រៀបចំដែនដីនិងនគរូបនីយកម្មនិងឯកសារគោលនយោបាយច្បាប់ទាក់ទងដ៏ទៃទៀតក្នុងការអនុវត្តច្បាប់នេះ។
- អនុម័តនិងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវឋានានុក្រមដែលបានចែងក្នុងគោលនយោបាយជាតិ

ស្តីពីការរៀបចំដែនដីនិងព្រះរាជក្រឹត្យនិងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងដីធ្លីគ្រប់លំដាប់ថ្នាក់ក្នុងការធ្វើផែនការទីក្រុងនិងតាមបណ្តាខេត្តនានា។

- បន្តអនុម័តគោលនយោបាយលំនៅដ្ឋាន ដើម្បីដោះស្រាយបញ្ហាលំនៅដ្ឋានសម្រាប់ជនក្រីក្រ រស់នៅមានសន្តិសុខ សុវត្ថិភាពសង្គម និងភាពថ្លៃថ្នូរ។
- បន្តផ្តល់ការគាំទ្របច្ចេកទេសដល់ក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ និងឃុំ/សង្កាត់ ក្នុងការរៀបចំប្លង់មេ និងប្លង់ប្រើប្រាស់ដីធ្លី។
- ពង្រឹងប្រសិទ្ធភាពការងារស្តីពីការប្រមូលទិន្នន័យ ការចងក្រងទិន្នន័យ និងការផលិតទិន្នន័យ ក៏ដូចជាការផ្សព្វផ្សាយទិន្នន័យនិងស្ថិតិសម្រាប់ការគ្រប់គ្រងដែនដីនិងរៀបចំដែនដី។

កត្តាទាំងនេះនឹងនាំឲ្យមានឥទ្ធិពលលើការអភិវឌ្ឍជាតិនិងទីក្រុងក្នុងប្រទេសកម្ពុជានាពេលអនាគត និងមាន សារៈសំខាន់ក្នុងការផ្តល់និងបង្ហាញទិសដៅជារួមសម្រាប់ការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុង។កត្តាទាំងនេះក៏មានឥទ្ធិពលលើគោលនយោបាយជាតិ ការរៀបចំផែនការនិងយុទ្ធសាស្ត្រនានា នាពេល អនាគតដែលទាមទារឲ្យមានយុទ្ធសាស្ត្រគ្រប់គ្រងទីក្រុង ដែលមានភាពបត់បែនទន់ភ្លន់ ហើយអាចឆ្លើយតប និង ដោះស្រាយការប្រឈមជាអាទិភាពនិងការប្រែប្រួលនានា។

យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុងនឹងត្រូវពិចារណាឲ្យមានភាពស៊ីសង្វាក់គ្នាជាមួយនឹងគោលនយោបាយ វិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលនិងកម្មវិធីកំណែទម្រង់ព្រមទាំងដំណើរការធ្វើប្រតិភូកម្មអំណាច និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិឲ្យស៊ីសង្វាក់គ្នាទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលនៃរាជធានី ខេត្ត ក្រុង ស្រុក និង ខណ្ឌ ( ពិនិត្យមើលច្បាប់ រៀបចំអង្គការ ឆ្នាំ២០០៨)។

ប្រទេសកម្ពុជាបានរៀបចំច្បាប់ គោលនយោបាយ អនុក្រឹត្យ និងនិយ័តកម្មដែលបានរួមចំណែកដោយផ្ទាល់ និងដោយប្រយោល ចំពោះការអភិវឌ្ឍទីក្រុង[1]។ វាជាការចាំបាច់ណាស់ ក្នុងការពិនិត្យមើលឡើងវិញ និងដាក់បញ្ចូលគោលនយោបាយនានា សម្រាប់គាំទ្រការអភិវឌ្ឍទីក្រុង និងផ្នែកសំខាន់ៗរបស់វាដូចជា ដីធ្លី លំនៅដ្ឋាន និងបរិស្ថាន ក្នុងនោះរួមមានភាពបន្សុាំទៅនឹងបម្រែបម្រួលអាកាសធាតុ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលកំពុងតែមានសព្វថ្ងៃ។ កត្តាទាំងនេះនឹងត្រូវបានពិចារណា ប្រកបដោយប្រសិទ្ធភាព និងបាន ដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុងពេញលេញ។ ច្បាប់និង ឯកសារណែនាំនានា របស់រដ្ឋាភិបាលដែលមាននាពេលបច្ចុប្បន្ន ពាក់ព័ន្ធនឹងនគរូបនីយកម្មមាននៅក្នុងឧបសម្ព័ន្ធ៖

យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងត្រូវគាំទ្រវិស័យអាទិភាពរបស់រដ្ឋាភិបាលដែលប្រកាសអំពីការអភិវឌ្ឍប្រកបដោយចីរភាពក្នុងការជំរុញកម្ពុជាឲ្យចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួចឲ្យទៅជាប្រទេសមានចំណូល ទាប-មធ្យមនាឆ្នាំ២០១៨ និងជាប្រទេសមានចំណូលខ្ពស់នាឆ្នាំ២០៣០ ហើយខិតខំកាត់បន្ថយភាពក្រីក្រឲ្យបាន យ៉ាងហោចណាស់១%ក្នុងមួយឆ្នាំ (NSDP section 4.37)។ កម្ពុជាកំពុងតែ នៅលើផ្លូវ ឈានទៅសម្រេច គោលនយោបាយ

[1]UNFPA (2014) Report on Urbanisation and its Linkage to Socio-Economic & Environmental Issues makes reference to at least “261 legal and policy texts related to land management, urban planning, and construction for the period 1989 to 2014”.

នេះត្រឹមឆ្នាំ២០១៦។ ក៏ដូចគ្នាដែររួមចំណែកនិងគាំទ្រដល់ គោលនយោបាយ អាទិភាព និងសកម្មភាពសម្រាប់ផែនការអភិវឌ្ឍទីក្រុងនិងការគ្រប់គ្រងដីធ្លី ការបែងចែកដីធ្លីនិងការគ្រប់គ្រង ការអភិវឌ្ឍនិងវិស័យសំណង់ដូចមានចែងក្នុង NSDP 2014-2018 និងលើសពីនេះ។

## 3.2. គោលនយោបាយ និងយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុងនឹងត្រូវរៀបចំដោយយោងលើមូលដ្ឋាននៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣សម្រាប់ការបង្កើនការងារ ភាពស្មើគ្នា និងប្រសិទ្ធភាព ហើយនិងអនុវត្តស្របនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្ននិងអនាគត។ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ មិនមានគោលនយោបាយអភិវឌ្ឍក្រុងផ្ទាល់និងជាក់លាក់ ទោះបីបញ្ហាគោលនយោបាយក្រុងសំខាន់ដែលបានបញ្ចូលនិងរំលេច ក្នុងឯកសារជាច្រើនដូចជា **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុងនិងទីប្រជុំជន គោលនយោបាយជាតិអំពីការគ្រប់គ្រងដីធ្លី គោលនយោបាយជាតិអំពីការរៀបចំដីធ្លី គោលនយោបាយលំនៅដ្ឋាន និងក្នុងរង្វង់ក្របខណ្ឌនៃច្បាប់។ ទោះជាយ៉ាងណា យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុងនិងទីប្រជុំជននឹងក្លាយជា ឯកសារសំខាន់និងជាបន្ទាន់។**

យុទ្ធសាស្ត្រនេះគួរត្រូវបានចាត់ទុកជាឯកសារឌីណាមិចមួយដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពតាមរយៈបទពិសោធន៍និងមេរៀនដែលទទួលបាន។ យុទ្ធសាស្ត្រនេះមានបំណងជួយនិងគាំទ្រដល់អ្នកធ្វើការសម្រេចចិត្ត អ្នកជំនាញវិជ្ជាជីវៈ និងអ្នកពាក់ព័ន្ធដទៃទៀតព្រមទាំងសាធារណៈជនតាមរយៈការចង្អុលបង្ហាញនិងគាំទ្រការអភិវឌ្ឍក្រុងនិង ដំណើរការអភិវឌ្ឍនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងបរិបទនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

## 3.3. បញ្ហាប្រឈមនានារបស់ក្រុង

កម្ពុជាជួបនឹងបញ្ហាប្រឈមមួយចំនួនក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងរបស់ខ្លួនដែលនៅក្នុងនោះមាន៖

- ប្រទេសកម្ពុជាកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័សនូវទម្រង់សេដ្ឋកិច្ចនិងប្រជាសាស្ត្ររបស់ខ្លួនពីកសិកម្មទៅជាសេដ្ឋកិច្ចចម្រុះឧស្សាហកម្ម កសិកម្ម សេវាកម្មនិងសង្គម។
- នេះបានបង្ហាញលទ្ធផលយ៉ាងឆាប់រហ័សនូវកំណើននិងការប្រមូលផ្តុំប្រជាជនក្នុងក្រុងនាពេលបច្ចុប្បន្នមុនពេលនៃកំណើនសេដ្ឋកិច្ចមួយដែលមានតុល្យភាព។ ជាមួយនឹងលទ្ធផលនេះគេឃើញមានការបែងចែកមិនស្មើគ្នានៅទូទាំងប្រទេស។

- បច្ចុប្បន្ននេះនគរូបនីយកម្មត្រូវបានប្រមូលផ្តុំលើសលុបនៅក្នុងនិងជុំវិញរាជធានីភ្នំពេញនិងកំរងក្រុងមួយចំនួននៅភាគពាយ័ព្យ ប៉ុន្តែដោយស្ទើរតែគ្មានកំណើនក្នុងក្រុងនៅភាគឦសានឬនៅតាមតំបន់ ឆ្នេរសមុទ្រ។
- ការប្រមូលផ្តុំនៃចំនួនប្រជាជននៅក្នុងប្រទេសកម្ពុជា (90% នៃចំនួនប្រជាជនរស់នៅលើផ្ទៃដីតែ40%) គឺទំនងបណ្តាលមកពីកត្តានគរូបនីយកម្ម ទោះបីមូលដ្ឋានឧស្សាហកម្មទីក្រុងមិនមែនចាំបាច់ត្រូវ ទៅតាមការចែកចាយនៃធនធានកសិកម្ម។
- មានការប្រមូលផ្តុំឧស្សាហកម្មច្រើនលើសលុប ធៀបនឹងការងារនិងសេវាកម្ម នៅមជ្ឈមណ្ឌលទីក្រុងមួយចំនួនជាពិសេសរាជធានីភ្នំពេញ។ ការចែកចាយ និងគុណភាពហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់ទឹកស្អាត អាង

ប្រព្រឹត្តិកម្មសំណល់រាវ ការប្រមូលសំណល់រឹង និងបញ្ហាផ្សេងៗទៀត មានភាពលម្អៀង បើធៀបនឹងរាជធានីភ្នំពេញដែលមានលក្ខខណ្ឌប្រសើរជាងទីក្រុងតូចៗជាច្រើន និងទីប្រជុំជន ក៏ដូចជាជនបទនានា។

- នៅពេលដែលការកាត់បន្ថយភាពក្រីក្រត្រូវបាននឹងកំពុងសម្រេចនោះ វាលាក់បាំងការពិត ដែលថា មានប្រជាជនមួយចំនួនតូចប៉ុណ្ណោះស្ថិតនៅលើខ្សែបន្ទាត់នៃភាពក្រីក្រ និងគួរត្រូវចាត់ទុកថា ជាជនងាយរងគ្រោះ។ ដូច្នេះពួកគេស្ថិតក្នុងគ្រោះថ្នាក់នៃការធ្លាក់ចូលទៅក្នុងភាពក្រីក្រពិតប្រាកដ (ជនបទនិងទីក្រុង) ប្រសិនបើវិបត្តិណាមួយនឹងកើតមានឡើង។ យុទ្ធសាស្ត្រអភិវឌ្ឍក្រុងនិងលំនៅដ្ឋាន គួរតែរួមបញ្ចូល ការកាត់បន្ថយភាពក្រីក្រជាផ្នែកមួយនៃគោលបំណងដ៏សំខាន់នៃយុទ្ធសាស្ត្រនេះ។
- មានការពិចារណាបន្ថែម នៃការវិវត្តកំណែទម្រង់ក្រុងក្នុងលក្ខខណ្ឌប្រភេទនិងទីតាំងអភិវឌ្ឍ ដង់ស៊ីតេ និងផលប៉ះពាល់របស់វានិងការរួមចំណែកក្នុងការធ្វើឲ្យមានតុល្យភាពនិងការអភិវឌ្ឍក្រុងប្រកបដោយ សមធម៌ ការអនុវត្តជាក់ស្តែងបច្ចុប្បន្នជាញឹកញាប់នាំមកនូវការលាតសន្ធឹងគ្មានប្រសិទ្ធភាពនៃផ្ទៃដីទីក្រុង ដែលធ្វើឲ្យមានការកើនឡើងនៃតម្លៃផ្គត់ផ្គង់ការកែលំអនៃហេដ្ឋារចនាសម្ព័ន្ធ។
- ទំហំក្រុងបច្ចុប្បន្នបង្ហាញពីគម្លាតគួរពិចារណា ដូចជាចំនួនប្រជាជន សេវាកម្ម និង ហេដ្ឋារចនាសម្ព័ន្ធ រវាងរាជធានី ទីក្រុងធំមួយចំនួន (បាត់ដំបង សៀមរាប ប៉ោយប៉ែត ក្រុងព្រះសីហនុ) និងទីរួមខេត្តមានទំហំតូច និងទីប្រជុំជនដែលមិនមែនជាទីក្រុង។
- ការបែងចែកតំបន់សេដ្ឋកិច្ចពិសេសដែលមានស្រាប់និងថ្មីៗ កន្លែងធ្វើការរបស់វិស័យឧស្សាហកម្ម និងវិស័យ សេវាកម្ម ត្រូវបានប្រមូលផ្តុំស្រដៀងគ្នា ហើយប្រហែលជាមានការលំបាកក្នុងការលៃតម្រូវ ក្នុងរយៈពេលមធ្យម ដើម្បីរួមចំណែកដល់វត្ថុបំណងនៃការអភិវឌ្ឍជាតិឲ្យមានតុល្យភាព។ ទោះបីជាយ៉ាងណាការជំរុញឲ្យមាន ផែនការពិសេស និងការអភិវឌ្ឍក្រុង សម្រាប់ការអភិវឌ្ឍ ឧស្សាហកម្ម ចាំបាច់ផ្តល់វិភាគទានដល់ការបែងចែក ផលប្រយោជន៍សេដ្ឋកិច្ច របស់ឧស្សាហកម្ម និង នគរូបនីយកម្ម ។
- ការចូលរួមនិងការទទួលខុសត្រូវរបស់ស្ថាប័ននិងសមត្ថភាពរបស់មន្ត្រីជំនាញពាក់ព័ន្ធនៅមានកំរិត សម្រាប់ការធ្វើផែនការនិងការគ្រប់គ្រងទីក្រុង ទប់ស្កាត់សំណង់មិនស្របច្បាប់ និងការអភិវឌ្ឍមិនស្របច្បាប់ ទាំងនៅក្នុងបញ្ជីអនុញ្ញាត្តិឬមិនត្រូវតាមបទដ្ឋានបច្ចេកទេសបានកំណត់(**NSDP sec. 2.91**)។
- ការប្រឈមនិងបញ្ហានានាជាមួយនឹងនគរូបនីយកម្ម មិនទាន់ត្រូវបានគេទទួលស្គាល់ពេញលេញនិងត្រូវបានផ្តល់អាទិភាពដោយទីភ្នាក់ងាររដ្ឋបាលនានា ឬក៏ពីម្ចាស់ជំនួយនៅឡើយ។
- ផែនការភាពបន្សាំនឹងបម្រែបម្រួលអាកាសធាតុ ជាតម្រូវការមួយសម្រាប់ការអភិវឌ្ឍទីក្រុងទំនើប ដែលនឹងត្រូវរួមបញ្ចូលក្នុងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងនិងទីប្រជុំជនសម្រាប់ប្រទេសកម្ពុជា។ដូចជាការអនុវត្តពីការគ្រប់គ្រងគ្រោះមហន្តរាយ សម្រាប់ការគ្រប់គ្រង និងរៀបចំហេដ្ឋារចនាសម្ព័ន្ធក្រុង។

បញ្ហាប្រឈមទាំងនេះក៏ត្រូវបានរួមផ្សំដោយកត្តាកង្វះព័ត៌មានផ្ទៀងផ្ទាត់និងទិន្នន័យពីបណ្តា ក្រុង ទីប្រជុំជន និងខេត្តនានាក្នុងប្រទេសកម្ពុជាលើបញ្ហាដែលបានកំណត់ទាំងឡាយ(NSDP sectio 2.91)។ ការប្រមូលទិន្នន័យបច្ចុប្បន្នជាញឹកញាប់ មានភាពខ្វះខាតហើយនៅមានភាពមិនស៊ីសង្វាក់គ្នាក្នុងក្របខណ្ឌរបាយការណ៍ ដែល ស្ថាប័ននានាកំពុងប្រើប្រាស់ពេលគឺព័ត៌មានបច្ចុប្បន្នដែលប្រមូលដោយស្ថាប័នមានសមត្ថកិច្ចមួយចំនួននោះ មិនអាចធ្វើការផ្ទៀងផ្ទាត់និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៅឡើយ។

ព័ត៌មាននិងគម្លាតនានានៃបញ្ហាប្រឈមទាំងនេះទំនងជាតម្រូវឲ្យមានការផ្តល់ធនធាននិងការពិចារណា សម្រាប់ ការសិក្សាបន្ថែមនិងការវាយតម្លៃដើម្បីប្រមូលនិងផ្តល់សុពលភាពព័ត៌មានដើម្បីដាក់ចូលទៅក្នុងការរៀបចំ យុទ្ធសាស្រ្តជាតិស្តីពីការអភិវឌ្ឍក្រុង។ បើសិនជាមិនមាន ការសិក្សានិងវាយតម្លៃទេ ភាពទុកចិត្តលើឯកសារ យុទ្ធសាស្រ្តជាតិស្តីពីការអភិវឌ្ឍក្រុងអាចនឹងមានសំណួរ ដោយគ្មានភាពទូលំទូលាយច្រើនថែមទៀតនិង ការស្រាវជ្រាវស៊ីជម្រៅនិងការវិភាគស៊ីជម្រៅ។

## 3.4. ចក្ខុវិស័យ – អាទិភាពរយៈពេលវែង ខ្លី និងមធ្យម

ចក្ខុវិស័យរយៈពេលវែងនៃយុទ្ធសាស្រ្តនេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវទស្សនៈវិស័យមួយដែលមាន រយៈពេល 30 ឆ្នាំ។ បន្ទាប់មកឯកសារនេះ គួរតែត្រូវបានប្រើដើម្បីបង្កើតយុទ្ធសាស្រ្តរយៈពេលមធ្យម (គ្របដណ្តប់ រយៈពេល 10-15 ឆ្នាំ) ពោលគឺការបង្ហាញអំពីវិធីសាស្រ្តអភិវឌ្ឍទីក្រុង-ទីប្រជុំជនដែលបានបង្កប់នៅ ក្នុងក្របខណ្ឌទូទៅនៃគោលនយោបាយរបស់រដ្ឋាភិបាល។ គោលដៅរយៈពេលខ្លី មធ្យម និងវែងដែលត្រូវសម្រេចគួរតែ ត្រូវបាន បង្កើតឡើងដើម្បីដើរតួនាទីជាគោលដៅនិងចំណុចនៃដំណើរការអភិវឌ្ឍ ឆ្ពោះទៅសម្រេចបានចក្ខុវិស័យ និង គោលដៅជាយុទ្ធសាស្រ្តនេះ។

សម្រាប់រយៈពេលខ្លី(ការពិចារណាអាចចាំបាច់ត្រូវបានផ្តល់លើតុល្យភាពនិងគ្រប់គ្រងការអភិវឌ្ឍដីធ្លីនិងកំណើន ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធនិងសេវានិងការពង្រីក ផ្តល់លំនៅដ្ឋានដែលមានតម្លៃសមរម្យកំណើនការងារ និង ការអភិវឌ្ឍសេដ្ឋកិច្ចនិងឧស្សាហកម្ម)។ ទស្សនៈវិស័យនេះចាំបាច់ត្រូវដាក់បញ្ចូលក្នុងវត្ថុបំណងអភិវឌ្ឍនជាតិ និងវត្ថុ បំណងអភិវឌ្ឍទូទាំងវិស័យប្រកបដោយភាពច្បាស់លាស់សមរម្យ។

ទាក់ទិននឹងគោលនយោបាយជាតិស្តីពីចក្ខុវិស័យផែនការរៀបចំដែនដីដែលថាៈ «ដែនដីទាំងមូលនឹងត្រូវបាន ប្រើប្រាស់ រៀបចំ អភិវឌ្ឍ និងការពារដោយមានផែនការរួម ផែនការរៀបចំដែនដីជាយុទ្ធសាស្រ្ត និងភាពសុខដុម នៃវិធានការនិងឧបករណ៍ដ៏សំខាន់ក្នុងតំបន់ត្រូវបានពិចារណា»។ ចំណុចចាប់ផ្តើមនៃទស្សនវិស័យ ក្នុងការឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលស្តីពីការកាត់បន្ថយភាពក្រីក្រ ការរាប់បញ្ចូល និងភាពរីកចំរើន ត្រូវបានស្នើឡើងសម្រាប់ដំណើការភាពរីកចំរើននៃយុទ្ធសាស្រ្តជាតិស្តីពីការអភិវឌ្ឍទីក្រុងនិងទីប្រជុំជន។

*"ទីក្រុងនិងទីប្រជុំជននៅទូទាំងប្រទេសត្រូវបានកើតឡើងជាបន្តបន្ទាប់ក្នុងលក្ខណៈស៊ាំនៃបរិយាកាសនិងមាន និរន្តរភាពអាកាសធាតុផ្តល់នូវឱកាសតុល្យភាពសេដ្ឋកិច្ច ការរក្សាបានបរិស្ថាននិងគុណភាពនៃការផ្តល់សេវាដ៏ល្អមួយដែលបម្រើប្រជាជនក្នុងក្រុងនិងតំបន់ជុំវិញនិងប្រទេសកម្ពុជា។ ហេតុនេះការបង្កើតទីក្រុងនិងទីប្រជុំជនត្រូវគិតបញ្ចូល ផ្នែកអភិវឌ្ឍសង្គមគឺរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រការកែលម្អជីវភាពរស់នៅនិង សុខុមាលភាពកំណើនសេដ្ឋកិច្ច វប្បធម៌និងនិរន្តរភាពនៃការគ្រប់គ្រងនិងរដ្ឋបាលដីធ្លីដែលធ្វើឲ្យមានតុល្យភាពលើការអភិវឌ្ឍ ទីក្រុងនិងទីប្រជុំជនថ្នាក់ជាតិ "*។

## 3.5. គោលដៅ និងវត្ថុបំណង

យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុង គួរមានលក្ខណៈសម្បត្តិគ្រប់គ្រាន់និងក្បោះក្បាយនូវគោលដៅអភិវឌ្ឍទីក្រុងដើម្បីសម្រេចបានជាបណ្តើរៗ ក្នុងពេលអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងនិងទីប្រជុំជន។ វាទំនងជាមានវត្ថុបំណងចំរុះដើម្បីដោះស្រាយការប្តេជ្ញាចិត្តដែលមានលក្ខណៈជាតិនិងអន្តរជាតិ(រួមមានការទទួលយកកាលពីពេលថ្មីនូវគោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាព) មានការក្របដណ្តប់ទាំងបញ្ហាអភិវឌ្ឍសេដ្ឋកិច្ច និងបញ្ហា សង្គមដ៏ទូលំទូលាយ ក៏ដូចជាវិស័យជាក់លាក់ជាច្រើនដែលទាក់ទងនឹងបញ្ហានានា ដែលជារឿយៗប្រសព្វគ្នានិង មានផលប៉ះពាល់ទៅវិញទៅមក រវាងទីក្រុងនិងតំបន់កំពុងក្លាយជាក្រុង។ គោលដៅទាំងនេះ ត្រូវបានកំណត់ ជាគោលដៅរយៈពេលខ្លី(ក្នុងរយៈពេល5ឆ្នាំ) មធ្យម(5 ទៅ 15ឆ្នាំ) និងរយៈពេលវែង(15-30ឆ្នាំ)។ គោលដៅទាំងនេះជាបណ្តើៗគួរតែមានភាពស៊ីសង្វាក់គ្នានិងសមាហរណកម្មជាមួយនិងផែនការរដ្ឋបាលថ្នាក់ក្រោម ជាតិ ស្របនឹងច្បាប់នៃការគ្រប់គ្រងរាជធានីខេត្តក្រុងនិងស្រុកខណ្ឌ (ច្បាប់រៀបចំអង្គការ)។

ខាងក្រោមនេះគឺជាគោលដៅអភិវឌ្ឍទីក្រុងមួយចំនួន និងភស្តុតាងរបស់វាដោយផ្អែកលើភាពសមហេតុផល។ គោលដៅផ្សេងទៀតទំនងជាត្រូវបានកំណត់ ឬស្នើឡើងក្នុងពេលនៃដំណើរការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងនិងទីប្រជុំជនៈ

- ធានាការអភិវឌ្ឍផ្នែកសង្គមនិងការអភិវឌ្ឍប្រកបដោយសមធម៌យុទ្ធសាស្ត្រអភិវឌ្ឍទីក្រុងនឹងត្រូវធានាថាអត្ថប្រយោជន៍នៃការធ្វើផែនការទីក្រុងនិងការគ្រប់គ្រងនិងដំណើរការគាំទ្រអាចនាំទៅដល់ការសម្រេចបានសម្រាប់សង្គមទាំងមូលព្រមទាំងសេដ្ឋកិច្ចនិងវប្បធម៌ក្នុងតំបន់ទីក្រុងនិងប្រទេស។ យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងនិងទីប្រជុំជនគួរតែរួមចំណែកក្នុងការសម្រេចឲ្យបាននូវការកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិនិងគោលដៅនិងវត្ថុបំណងដ៏ទៃទៀតក៏ដូចជាការផ្តល់ឱកាសឲ្យមានការងារនិងការអភិវឌ្ឍសេដ្ឋកិច្ចដែលមានតុល្យភាពការកាត់បន្ថយគម្លាតប្រាក់ចំណូលហើយគម្លាតរវាងអ្នកក្រនិងអ្នកមាន។ ហេតុផលៈ ផែនការជាតិស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍ NSDP 2014-2018 បង្ហាញឲ្យឃើញថាជាមធ្យម 13% នៃចំនួនប្រជាជននៅទីក្រុងអាចជា "ជនក្រីក្រ" ដែលមានចំនួនប្រមាណ 540000នាក់នៅទូទាំងប្រទេស។ ភាគរយគួរឲ្យកត់សំគាល់នៃអ្នក កង្វះសុវត្ថិភាពនៃការកាន់កាប់ដីធ្លីនិងការទទួលបានលំនៅដ្ឋានសមរម្យ បានរាំងឱកាស ចិញ្ចឹមជីវិតនិងការអភិវឌ្ឍគ្រួសាររបស់ពួកគេ។ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត និងប្រកប ដោយភាពច្នៃប្រឌិតចាំបាច់ច្រើនទៀតត្រូវបាន បង្កើតនិងអនុវត្តក្នុងការផ្តល់នូវសុវត្ថិភាព នៃកម្មសិទ្ធិដីធ្លី និងការទទួលបានលំនៅដ្ឋានដែលមានតម្លៃសមរម្យ ដើម្បីឲ្យប្រជាជនតាមទីក្រុង ទទួលផលពីនគរូបនីយកម្ម។

- **ជំរុញការដឹកជញ្ជូនប្រកបដោយចីរភាព(ការប្រើប្រាស់ដីធ្លីនិងសមាហរណកម្មការដឹកជញ្ជូន)ៈ កំណើនការខាតបង់សេដ្ឋកិច្ចពីភាពរីកចំរើននិងការផ្លាស់ប្តូរឆាប់រហ័ស ក្នុងរបៀបប្រើប្រាស់ ការដឹកជញ្ជូននៅតំបន់ទីក្រុងគឺជាភស្តុតាងនៃ**ការកើនឡើងនូវអ្នកដំណើរប្រើប្រាស់ រថយន្តមួយ ម្នាក់ឯងពោលគឺមានការប្រើពេលវេលាកាន់តែច្រើនក្នុងការធ្វើដំណើរនិងមានភាពយឺតយ៉ាវ ដោយ សារការកកស្ទះចរាចរណ៍។ ដូចនេះមានការកាត់បន្ថយគុណភាពខ្យល់ កំណើនការបំពុលខ្យល់ ហើយធ្វើឲ្យ

ប៉ះពាល់ដល់សុខភាព ក៏ដូចជាគ្រោះថ្នាក់ចរាចរណ៍និងមរណៈភាព នៅក្នុងតំបន់ទីក្រុង ទាំងអស់នេះមានតម្លៃជាសេដ្ឋកិច្ច។ មានសេចក្តីត្រូវការកើនឡើងដើម្បីពិចារណា ពីការផ្តួចផ្តើម គំនិតច្នៃប្រឌិតបន្ថែមទៀតដើម្បីកាត់បន្ថយចំណាយបរិស្ថាននិងហិរញ្ញវត្ថុ ដូចជាប្រព័ន្ធការដឹក ជញ្ជូនសាធារណៈដែលធូរថ្លៃ តម្លៃផ្លូវ និងយន្តការដ៏ទៃទៀត។ យុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍក្រុង ចាំបាច់ត្រូវគាំទ្រនិងផ្តល់វិភាគទានដល់ការអភិវឌ្ឍផ្នែកគោលនយោបាយ និងដំណោះស្រាយ ការដឹកជញ្ជូនប្រកបដោយចីរភាពនៅក្នុងទីក្រុងនិងតំបន់ទីប្រជុំជននានា។

ហេតុផលៈ គិតត្រឹមឆ្នាំ2012មានយានយន្តជាង1.2លានគ្រឿងបានចុះបញ្ជីជាផ្លូវការ នៅក្នុងរាជធានីភ្នំពេញ(ម៉ូតូប្រហែលជា77% រថយន្តធុនស្រាល20% និងរថយន្តធុនធ្ងន់ប្រមាណ3%) **ហើយ** ចំនួនយានយន្តកំពុងប្រើប្រាស់នេះ បានកើនឡើងប្រមាណ170% ចាប់តាំងពីឆ្នាំ2000 ដែលបង្កឲ្យមានការកកស្ទះចរាចរណ៍នៅទូទាំងទីក្រុង។ ល្បឿនចរាចរណ៍នៅតំបន់ទីក្រុងជាមធ្យម បានថយចុះ34% គឺពី24គីឡូម៉ែត្រ/ម៉ោងក្នុងឆ្នាំ2001 មកនៅ15គីឡូម៉ែត្រ/ម៉ោងក្នុងឆ្នាំ2012 នៅលើវិថីចម្បងៗមួយចំនួន បើទោះជាមានការកែលម្អហេដ្ឋារចនាសម្ព័ន្ធក៏ដោយ។

- **លើកទឹកចិត្តនិងគាំទ្រការអភិវឌ្ឍឧស្សាហកម្មៈ** យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងបានកំណត់គោលដៅរយៈពេលមធ្យមនិងគោលដៅសម្រាប់ការធ្វើឲ្យមានភាពរីកចម្រើនលើការអភិវឌ្ឍសេដ្ឋកិច្ច។ រីឯ"គោលនយោបាយអភិវឌ្ឍឧស្សាហកម្មថ្មី (**IDP**) របស់រាជរដ្ឋាភិបាលមានបំណងបង្កើតចក្ខុវិស័យនិងក្របខណ្ឌអនុវត្តសម្រាប់វិស័យអភិវឌ្ឍឧស្សាហកម្មដែលមានការប្រកួតប្រជែង ជំរុញកំណើនសេដ្ឋកិច្ច ឲ្យមានភាពប្រសើរនៃការងារ និងបង្កើនប្រាក់ចំណូលសម្រាប់ប្រជាជនកម្ពុជា។ សេចក្តីត្រូវការទាំងនេះនឹងត្រូវពិចារណាឲ្យមានប្រសិទ្ធភាពនៅក្នុងដំណើការ យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងរួមបញ្ចូលទាំងផលប៉ះពាល់ពីកំរៃនៃតំបន់សេដ្ឋកិច្ចពិសេស ជាពិសេសតំបន់ដែលមិនសូវមានឧស្សាហកម្មដើម្បីធ្វើវិភាគទានឲ្យមានតុល្យភាពការរីកចំរើន។

ហេតុផលៈ ការធ្វើជំរឿនសេដ្ឋកិច្ចកម្ពុជាឆ្នាំ 2014 បានកំណត់តួលេខសហគ្រាសចំនួន 513759 នៅក្នុងប្រទេស ជិតពាក់កណ្តាល(46%)ដែលមានទីតាំងស្ថិតនៅក្នុងក្រុងចំនួន27 (19% នៅក្នុងរាជធានីភ្នំពេញ ចំនួន12%នៅក្នុងក្រុង១០ផ្សេងទៀតដែលមានទំហំធំៗ និង5%នៅក្នុងក្រុង មានទំហំតូចៗចំនួន16) ។ សហគ្រាសទីក្រុងទាំងនេះបានផ្តល់ការងារជាងពាក់កណ្តាល (53%) នៃប្រជាជន1.7លាននាក់បើតាមរបាយការណ៍ចំនួនការងារនៅក្នុងសហគ្រាសទាំងនោះ។ ការប្រមូលផ្តុំលើសលុបរបស់ឧស្សាហកម្មនិងសហគ្រាសខ្នាតមធ្យម នៅជុំវិញរាជធានីនិង តំបន់ទីក្រុងនានាចាំបាច់ត្រូវពិនិត្យឡើងវិញ និងវិធីដោះស្រាយត្រូវអភិវឌ្ឍដើម្បីលើកទឹកចិត្ត និង អាចគាំទ្រដល់ការធ្វើឲ្យប្រសើរឡើងនៃរបាយឧស្សាហកម្ម និងរបាយសហគ្រាសនៅតាមទីក្រុង និងទីប្រជុំជនផ្សេងៗទៀត។

- **គាំទ្រការរៀបចំដែនដី លំនៅដ្ឋាន និងការអភិវឌ្ឍពាណិជ្ជកម្ម:** យុទ្ធសាស្រ្តជាតិស្តីពីការអភិវឌ្ឍក្រុងគួរតែរួមចំណែកដល់កម្មវិធីដ៏មានប្រសិទ្ធភាពនិងការពិចារណាគ្រប់ជ្រុងជ្រោយអំពី គោលនយោបាយដីធ្លី គោលនយោបាយជាតិស្តីពីផែនការរៀបចំដែនដី និងគោលនយោបាយជាតិស្តីពីលំនៅដ្ឋានដើម្បីធានាឲ្យមានតុល្យភាពក្នុងការប្រើប្រាស់ផ្ទៃដីប្រកបដោយប្រសិទ្ធភាពក៏ដូចជាការអនុញ្ញាត្តិឲ្យទទួលបានលំនៅដ្ឋានគ្រប់គ្រាន់ និងឱកាសអភិវឌ្ឍសេដ្ឋកិច្ច។

**ហេតុផល:** ឯកសារប្រជាសាស្រ្តរបស់ប្រទេសកម្ពុជាបង្ហាញថា បច្ចុប្បន្ននេះប្រហែលជា **29%**នៃចំនួន ប្រជាជនមានអាយុក្រោម**15**ឆ្នាំ ហើយ**31%**ចាត់ទុកថាជាយុវជន(មានអាយុពី**15-29**ឆ្នាំ)[2]។ សរុបទាំងពីរប្រភេទ មានចំនួន 60%នៃប្រជាជនទាំងអស់ ដែលរាជរដ្ឋាភិបាលប្រឈមនឹងការលើកទឹកចិត្ត ក៏ដូចជាការគាំទ្រចំពោះ ឱកាសរកការងារផ្សេងៗដែលផ្តល់ប្រាក់ចំណូលសម្រាប់ការលើកស្ទួយជីវភាពរបស់ពួកគេ។ ទាំងនេះនឹងបន្តប្រឈម ទៅឆ្នាំក្រោយៗទៀត។កម្រិតនៃការងារផ្នែកកសិកម្មថយចុះដោយសារតែ ការផ្តល់ឱកាសរកប្រាក់ចំណូលនិងជីវភាព នៅមានកម្រិត។ នេះគឺទំនងជាផ្នែកមួយ នៃកត្តាជំរុញដែលធ្វើឲ្យមានចំណាកស្រុកចូលមកទីក្រុងដោយហេតុថា មនុស្សវ័យក្មេងស្វែងរកប្រាក់ចំណូលនិងជីវភាពល្អប្រសើរជាងមុនក្នុងទីក្រុង។ នាពេលបច្ចុប្បន្ននេះភាគច្រើន នៃជនអន្តោរប្រវេសន៍ដែលបានធ្វើដំណើរពីស្រុកស្រែមកកាន់ទីក្រុងភ្នំពេញដែលជាកន្លែងប្រមូលផ្តុំប្រមាណ មួយភាគប្រាំ (19%)នៃសេដ្ឋកិច្ចទាំងអស់ហើយបានផ្តល់ការងារជាងមួយភាគបី(33%) នៃការងារដែលមិនមែន ជាវិស័យកសិកម្ម។

ជារួមតំបន់ក្រុងចំនួន **27** ទទួលជិតពាក់កណ្តាល (**46%**) នៃគ្រឹះស្ថានសេដ្ឋកិច្ចទាំងអស់នៅក្នុងប្រទេស និងផ្តល់ជាងពាក់កណ្តាល(**52%**) នៃគ្រប់ការងារមិនមែនកសិកម្មនៅក្នុងប្រទេស (ដែលប្រើប្រាស់ផ្ទៃដីប្រមាណ**4.2%** នៃផ្ទៃដីទូទាំងប្រទេស ដោយឡែករាជធានីភ្នំពេញទទួល**ប្រហែល**ពីរភាគបី (**64%**) នៃការងារដែលមិនមែន ជាកសិកម្មក្រុង[3]។ តើការប្រមូលផ្តុំប្រជាជនលើសលុបនេះនៅរាជធានីនឹងមិនមានដំណោះស្រាយ ឬយ៉ាងណា? ជាចុងក្រោយគួរមានកិច្ចខិតខំប្រឹងប្រែងដើម្បីបែងចែកការងារប្រសើរជាងមុន ដើម្បីជាប្រយោជន៍របស់ការអភិវឌ្ឍ ប្រកបដោយតុល្យភាព?

- **ធានាការអភិវឌ្ឍប្រកបដោយចីរភាពរួមមានការគ្រប់គ្រងបរិស្ថានទីក្រុង:** ទីក្រុងនិងទីប្រជុំជនដែលមានប្រជាជនប្រមូលផ្តុំ មានសកម្មភាពសេដ្ឋកិច្ច និងសេវាកម្ម។ ការប្រមូលផ្តុំនេះនាំឲ្យមានការ ផ្តល់សេវាប្រើប្រាស់ ហើយបញ្ចេញមកវិញនូវបរិមាណសំណល់ច្រើន និងការបំពុល ដែលមានផលប៉ះពាល់លើទីក្រុងនិងធនធានបរិស្ថានដែលនៅជុំវិញទីក្រុង។

ការប្រមូលផ្តុំប្រជាជននៅតាមទីក្រុងនេះ បង្កបញ្ហាប្រឈមនានាសម្រាប់ការគ្រប់គ្រងនិងធ្វើផែនការ បរិស្ថានទីក្រុង ហើយបញ្ហាស្រដៀងគ្នានេះកំពុងតែមានការប្រឈមដោយសារកំណើនទីប្រជុំជននានាដែលមានចំនួនប្រជាជនក្នុងកម្រិតខុសៗគ្នា។ទាំងនេះចាំបាច់ត្រូវមានការពិចារណាឲ្យមានប្រសិទ្ធភាព

[2] NIS/ MoP (2013) Cambodian Inter-Censual Survey 2013
[3] NIS/ MoP (2011) Economic Census of Cambodia

ដោយយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុង។

ហេតុផលៈ ការព្យាករណ៍ថ្មីៗនេះបានបង្ហាញឲ្យឃើញថាប្រជាជនទីក្រុងជាង 30%នៃចំនួន ប្រជាជនសរុប (ផ្អែកទៅលើបេកគំហើញនៃការធ្វើចំណាត់ថ្នាក់ឡើងវិញនៃតំបន់ក្រុងឆ្នាំ2011) មានប្រជាជន រស់នៅទីក្រុងចំនួនលើសពី 4 លាននាក់ដែលប្រមាណជា 80% នៃប្រជាជនទាំងនេះ រស់នៅទីក្រុង មួយចំនួនប៉ុណ្ណោះនៃក្រុងទាំង27 ។ រាជធានីភ្នំពេញទទួលចំនួនប្រជាជនច្រើនជាងគេបំផុត ដោយមាន ជាង 40% នៃចំនួនប្រជាជនសរុបដែលលើសពី 50%នៃចំនួនប្រជាជននៅទីក្រុង។

- **ធានាការប្រើប្រាស់ធនធានធម្មជាតិនិងដីធ្លីប្រកបដោយគុណភាពៈ** សកម្មភាពនិងការអន្តរាគមន៍ **លើ**វិស័យទីក្រុងទាមទារឲ្យរៀបចំ/ធ្វើផែនការនិងពិចារណាដែលទប់ស្កាត់ផលប៉ះពាល់ឲ្យនៅ ត្រឹមកម្រិតតិចតួចបំផុតលើដីធ្លីនិងធនធានធម្មជាតិនៃប្រទេសជាតិ។ យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុង ចាំបាច់ត្រូវធានាដល់ការប្រើប្រាស់ធនធានដីធ្លី ឲ្យមានចីរភាពនិង ប្រសិទ្ធភាព កាត់បន្ថយផលប៉ះពាល់ពីសកម្មភាពនានា ដូច្នេះអាចបញ្ចៀសផលប៉ះពាល់ ធ្ងន់ធ្ងរលើផ្នែកបរិស្ថាន និងសង្គម។ យុទ្ធសាស្ត្រចាំបាច់ត្រូវអភិវឌ្ឍអំពីទិសដៅ ដើម្បីធ្វើសមាហរណកម្មទស្សនៈទាន នៃមជ្ឈមណ្ឌលទីក្រុងណែនណាន់តាន់តាប់ និងផ្តល់គោលការណ៍ណែនាំអំពីសណ្ឋានទំរង់ទីក្រុង សមស្រប និងដង់ស៊ីតេទីក្រុង ដើម្បីទប់ស្កាត់និងដោះស្រាយការអភិវឌ្ឍ រីករាលដាលទីក្រុង និងការរីករាលដាលតាមបណ្តោយផ្លូវវែង។

  ហេតុផលៈ ការសិក្សារបស់ធនាគារពិភពលោកថ្មីៗនេះ(នៅឆ្នាំ2015)[4] បានប៉ាន់ប្រមាណថា នៅក្នុងរាជធានីភ្នំពេញ ដោយផ្អែកលើការវិភាគលំហរនៃការផ្លាស់ប្តូរការប្រើប្រាស់ដីនៅទីក្រុង (តំបន់សាងសង់)ជាមធ្យមមាន 500ហិកតា (ប្រាំគីឡូម៉ែត្រការេ) ក្នុងមួយឆ្នាំ ចន្លោះពី 2000-2010 ស្មើនឹង50km2 ត្រឹមឆ្នាំ2010។ បើទោះបីជាទំហំ នៃតំបន់ប្រជុំជននៅតូច (បើប្រៀបធៀបទៅនឹងក្នុងតំបន់) អត្រានៃការរីករាលដាលនៃទីក្រុងមានល្បឿនលឿនបំផុត លំដាប់ទីពីរនៅក្នុងតំបន់នេះដែលជាមធ្យម គឺ4.3% ក្នុងមួយឆ្នាំ។

- លើកទឹកចិត្តការអភិវឌ្ឍទីក្រុងបៃតង "3Es" (សេដ្ឋកិច្ច បរិស្ថាន និងសមធម៌) និងការបន្សាំ ទៅនិងបម្រែបម្រួលអាកាសធាតុ (ការសម្របនិងបន្ធូរបន្ថយ) រាជរដ្ឋាភិបាលកម្ពុជា បានទទួល យកនូវគោលនយោបាយជាតិ យុទ្ធសាស្ត្រទូទាំងវិស័យ និងផែនការ ទាំងអស់នេះចាំបាច់ ត្រូវបញ្ចូល និងបញ្ជ្រាបគ្នាឲ្យបានប្រសើរចូលទៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុង។

  ហេតុផលៈ គណៈកម្មាធិការអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ IPCC-អង្គការលំនៅដ្ឋានសហប្រជាជាតិ បានរាយការណ៍ថាបណ្តាទីក្រុងទូទាំងពិភពលោកឥឡូវនេះមានការទទួលខុសត្រូវ

[4] World Bank.2015. *East Asia's Changing Urban Landscape: Measuring a Decade of Spatial Growth.* Urban Development Series. Washington, DC: World Bank

ច្រើនជាង 70% នៃកាបោននិង ការបំភាយឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាសដោយសារតែ ការប្រមូលផ្តុំនៃសកម្មភាពនិងប្រជាជននៅក្នុងទីក្រុង ដែលតាំងទីលំនៅតិចជាង 2% នៃផ្ទៃដី ពិភពលោក។

តើអ្វីទៅជាការរួមចំណែករបស់កម្ពុជាក្នុងការផ្លាស់ប្តូរ យ៉ាងឆាប់រហ័សរបស់ក្រុងនិងទីប្រជុំជនទាក់ទិននឹងកំណត់ត្រាថាមពលទីក្រុងនៃការបំភាយឧស្ម័នផ្ទះកញ្ចក់និងតំបន់រងការសាយភាយ។ កង្វះខាតប្រសិទ្ធភាពនៃការរៀបចំទីក្រុង នាំមកនូវការរីករាលដាលនៃទីក្រុង បង្កើនពេលវេលា ធ្វើដំណើរ និងកើនឡើងនូវតម្លៃការសាងសង់និងការអភិវឌ្ឍ។

យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងគួរតែត្រូវបានបង្កើតដោយផ្អែកលើការវិភាគព័ត៌មានដែលមានស្រាប់និង ការវាយតម្លៃស្ថានភាពបច្ចុប្បន្ននៅក្នុងទីក្រុងនិងទីប្រជុំជននានាទូទាំងប្រទេសដើម្បីធ្វើឲ្យមានសុពលភាពនិង បច្ចុប្បន្នភាពព័ត៌មានដែលមានស្រាប់បំពេញចន្លោះប្រហោងនិងកំណត់បញ្ហាបន្ថែមនានាសម្រាប់ការពិចារណា ដែលនឹងផ្តល់ភស្តុតាង ផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍ។

យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងគួរគាំទ្រនិងផ្តល់គោលការណ៍ណែនាំ ដើម្បីកំណត់ផែនការ ការអនុវត្ត ដ៏ល្អប្រកបដោយជំនាញវិជ្ជាជីវៈ (ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អ្នកដែលជាប់ពាក់ព័ន្ធនឹងការធ្វើផែនការ) ក៏ដូចជាការកំណត់និយមន័យ តម្រូវការអប្បបរមា និងសូចនករមួយចំនួន សម្រាប់ធ្វើផែនការថ្នាក់ក្រោមជាតិ។ តាមទិដ្ឋភាពទាំងពីរ យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងនឹងយោងលើការអនុវត្ត និងពិពណ៌នាលំអិតលើ គោលនយោបាយជាតិនិងច្បាប់ជាតិស្តីពី ការធ្វើផែនការទីក្រុងនិងតំបន់និងការអភិវឌ្ឍជាតិ។

វត្ថុបំណងនៃការអភិវឌ្ឍអាចសំដៅលើវិស័យគន្លឹះនិងភូមិសាស្ត្រតំបន់មួយចំនួន សម្រាប់ការអភិវឌ្ឍដែលមានតុល្យភាព (ជាតុចូលបន្ថែមអាចត្រូវកំណត់ ដោយហេតុថាសេចក្តីព្រាងនៃវិស័យគន្លឹះក្នុងក្របខណ្ឌយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុងនេះមិនទាន់មានចំណាត់ថ្នាក់និងតាមលំដាប់ត្រឹមត្រូវនៅឡើយ)។

## 3.6. សមាសធាតុជាយុទ្ធសាស្ត្រ/ វិស័យគន្លឹះ

ដើម្បីបង្កើតយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍទីក្រុងសមាសធាតុដូចខាងក្រោមត្រូវបានលើកយកមកពិចារណាៈ

**<u>និយមន័យបែបរដ្ឋបាល</u>**លើផ្នែកអភិវឌ្ឍនយោបាយ ពន្ធដារ និងការធ្វើផែនការរូបវន្ត យុទ្ធសាស្ត្រនេះនឹងត្រូវការកំណត់ ថាអ្វីជា "ទីប្រជុំជន" ក្នុងខ្លឹមសារជាមុខងារនិងជារដ្ឋបាល (ដែលត្រូវបានប្រើក្នុងពេលបច្ចុប្បន្ន) ខណៈពេលដែលតំបន់ជាច្រើនទៀតត្រូវបានរៀបចំនិងបានប្រកាសជាទីក្រុងនិងបានដាក់ចូលទៅក្នុងស្ថិតិជាតិនិងខេត្ត ហើយនិងក្នុងដំណើរការធ្វើផែនការផ្សេងទៀត ក្នុងនោះនឹងមានតម្រូវការបន្ថែមក្នុងការអភិវឌ្ឍប្រព័ន្ធមុខងារ សម្រាប់ចំណាត់ថ្នាក់ ក្រុង ឬតំបន់សេដ្ឋកិច្ចដើម្បីធ្វើឲ្យប្រសើរឡើងនូវការធ្វើផែនការនិងការគ្រប់គ្រងទីក្រុង។

ដំណើរការធ្វើផែនការនេះទាមទារឲ្យមានការពិគ្រោះយោបល់និងឯកភាពជាមួយក្រសួងនិងភាគីពាក់ព័ន្ធដ៏ទៃទៀត ដើម្បីពិនិត្យនិយមន័យ ឬ លក្ខណៈវិនិច្ឆ័យនៃទីក្រុង ក៏ដូចជា ពាក្យពេចន៍និងវិធីដោះស្រាយមួយចំនួន ដើម្បី

ជានាពីភាពសុីគ្នាពីពាក្យថា ទីក្រុងនិងទីប្រជុំជន រួមទាំងពាក្យថាសង្កាត់នៅក្នុងស្រុក។ និយមន័យបែបរដ្ឋបាល ក៏នឹងផ្តល់នូវ មូលដ្ឋានច្បាប់សម្រាប់ការផ្លាស់ប្តូរក្នុងការរៀបចំរដ្ឋបាលនិងនយោបាយពន្ធដារ និងការធ្វើផែនការរូបវន្តែដែលត្រូវបានផ្សារភ្ជាប់នឹងចំណាត់ថ្នាក់របស់តំបន់ជនបទនិងទីក្រុង។ វាក៏អនុញ្ញាត្តិសម្រាប់ការកំណត់ គោលដៅ ក្នុងការគាំទ្រសម្រាប់ទីប្រជុំជនតូចៗនិងមុខងាររបស់វា( ឧទាហរណ៍ក្រុងតាមព្រំដែន ការកែច្នៃផលិតផលកសិកម្ម និងវិស័យទេសចរណ៍។

នឹងមានការធ្វើចំណាត់ថ្នាក់តាមពេលកំណត់ និងការចាត់ថ្នាក់ឡើងវិញនៃអាជ្ញាយុកាលទីក្រុងថាជា«ក្រុង»និង«ទីក្រុង»ដែលមានកម្រិតរដ្ឋបាលផ្សេងគ្នា និងអាជ្ញាធររដ្ឋបាល (សូមមើលចំណុចក្រោយ)។ ចំនួនក្រុងនាពេលបច្ចុប្បន្ន (27) ទំនងជានឹងរីកលូតលាស់ឡើងបន្ថែមក្នុងរយៈពេលពី10-15ឆ្នាំខាងមុខ។ បច្ចុប្បន្ននេះប្រទេសកម្ពុជាមាន សក្តានុពល"ទីប្រជុំជន"ច្រើនជាង40 (សូមមើលបញ្ជីដែលមិនទាន់បានកំណត់ជាក្រុងចំនួន40ក្នុងឧបសម្ព័ន្ធ) ដែលចូលក្នុងលក្ខណៈវិនិច្ឆ័យ[5]ចំណាត់ថ្នាក់ទីប្រជុំជន (ចំនួនទីប្រជុំជនទាំងនេះខ្លះអាចពិចារណាធ្វើចំណាត់ថ្នាក់ ឡើងវិញ និងបញ្ចូលជាទីក្រុងថ្មី។ បច្ចុប្បន្ននេះមិនទាន់មានការពិចារណាពីកំរងទីក្រុង(cluster city) នោះទេ (ដែលភូមិ/ឃុំសង្កាត់ពីរឬច្រើន ក្នុងឃុំផ្សេងគ្នាភ្ជាប់/ជួបគ្នានិងរួមគ្នាដែលអាចមានលក្ខណៈ ប្រមូលផ្តុំជាទីប្រជុំជនថ្មី តែបើដាច់គ្នាមួយៗមិនអាចបានទេ។ ចំណាត់ថ្នាក់ឬចំណាត់ថ្នាក់ឡើងវិញ បែបនេះគឺតម្រូវ ឲ្យមាន ការពិចារណាហ្មត់ចត់ណាស់អំពីការគ្របដណ្តប់នៃហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មការប្រើប្រាស់សាធារណៈនិងសហគ្រាសសេដ្ឋកិច្ច។

**ប្រភេទទីប្រជុំជន**ះ មានការកំណត់ចាំបាច់ដើម្បីចាត់ថ្នាក់នៃទីក្រុងដែលមានស្រាប់ឬក្រុង (បន្ទាប់មកទីក្រុង ផ្សេងៗទៀត) ដោយសារដង់សុីតេ ចំនួនប្រជាជន សកម្មភាពសេដ្ឋកិច្ច និងសក្តានុពលផ្សេងៗទៀត ការធ្វើបែបនេះតម្រូវឲ្យមានការពិគ្រោះយោបល់ជាមួយក្រសួងខ្សែបណ្តោយដ៏ទៃទៀត និងអាចធ្វើវិសោធនកម្ម នៃច្បាប់រៀបចំ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ច្បាប់អង្គការ)។ បន្ទាប់មកប្រភេទទីក្រុង អាចបកស្រាយទៅក្នុង យុទ្ធសាស្ត្រសម្រាប់ជាប្រភេទផ្សេងៗនៃទីក្រុងនិងទីប្រជុំជន រួមទាំងការពិចារណាអំពីតំបន់រីកចំរើនថ្មីៗ។

**ទីក្រុងលំដាប់ទីពីរ** ប្រជាជនរាជធានីភ្នំពេញមាន(ចំនួន១.៨លាននាក់) គឺជាចំនួនដ៏ច្រើនលើសលុបប្រៀបធៀប ទៅនឹងតំបន់ក្រុងដ៏ទៃទៀតនៃប្រទេសកម្ពុជា។ ចំណែកក្រុងចំនួន៥ផ្សេងទៀតមានប្រជាជនលើសពី ១០០០០០ នាក់ (២០១៤)[6] គួរតែត្រូវបានចាត់ជាក្រុងលំដាប់ទីពីរពោលគឺមានសេដ្ឋកិច្ចខ្លាំងនិងមាន សក្តានុពលអភិវឌ្ឍជាងក្រុងដ៏ទៃទៀត។

ការកំណត់ទីប្រជុំជនតាមវិធីសាស្ត្រសាមញ្ញដែលចំណាត់ថ្នាក់ តំបន់នានាជាទីប្រជុំជននោះមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយ។ លក្ខណៈវិនិច្ឆ័យក្នុងការកំណត់ជាទីក្រុងលំដាប់ទីពីរ គឺយោងលើចំនួនប្រជាជន សក្តានុពល ភាពរីកចំរើន ការគ្របដណ្តប់ហេដ្ឋារចនាសម្ព័ន្ធ សេវាមូលដ្ឋាន(ទឹកស្អាត ការគ្រប់គ្រងសំណល់ ចរន្តអគ្គិសនី) សក្តានុពលសេដ្ឋកិច្ច(ប្រភេទសេវាកម្មនិងឧស្សាហកម្មពិសេស) និងទីតាំង (នៅឆ្ងាយសមស្រប ពីតំបន់រាជធានី)។

[5]The method utilised for urban reclassification is based on: a population density exceeded 200 per square kilometre; the percentage of people (female and male) employed in agriculture is below 50 per cent, and the total population of the commune exceeds 2,000 people.
[6]The four municipalities are; Siem Reap, Battambang, Paoy Paet, Serei Saophoan and Preah Sihanouk Municipalities.

ទីក្រុងលំដាប់ទីពីរនេះមានសក្តានុពល ក្នុងការប្រើជាទីតាំងជម្រើសចុងក្រោយ និង អភិវឌ្ឍឬប៉ូលអភិវឌ្ឍ ដើម្បីគាំទ្រដល់រាជធានី ដើម្បីកុំឲ្យមានការប្រមូលផ្តុំ ការវិនិយោគឧស្សាហកម្ម ដូចនេះនាំឲ្យមានរបាយស្មើគ្នា នៃប្រជាជន និងការបែងចែកការអភិវឌ្ឍសេដ្ឋកិច្ចស្មើគ្នា។ បច្ចុប្បន្ន បេក្ខភាពក្រុង ដែលទំនងជាចាត់ចូលជាទីក្រុងលំដាប់ទីពីរគឺ ក្រុងសៀមរាប បាត់ដំបង ប៉ោយប៉ែត សិរីសោភ័ណ និងក្រុងព្រះសីហនុ។

ទាំងនេះអាចឈានទៅបង្កើតគោលនយោបាយនិងគោលការណ៍ណែនាំសម្រាប់ទីប្រជុំជនតូចៗ និងទីក្រុងតូចបន្ទាប់ទៀត(ទីប្រជុំជនលំដាប់ទីបីឬទីបួន) និងតំបន់មិនមែនជាក្រុងដែលបានគ្រោងទុកដ៏ទៃទៀត។ ទាំងនេះគួរគាំទ្រតំបន់ ទីក្រុងឲ្យទៅជាមជ្ឈមណ្ឌលដែលមានតួនាទីប្រសើរនិងផ្តល់សេវាកម្មកំរិតខ្ពស់/មានសេវាកម្ម ហេដ្ឋរចនាសម្ព័ន្ធ អប់រំ សុខាភិបាល ពាណិជ្ជកម្ម/ការអភិវឌ្ឍសេដ្ឋកិច្ច និងជាកន្លែងគាំទ្រផ្នែករដ្ឋបាលសម្រាប់តំបន់ជនបទ និងការអភិវឌ្ឍ របស់គេ។

| សំណើរប្រភេទឬលំដាប់ថ្នាក់នៃទីក្រុង (សម្រាប់ការពិភាក្សានិងពិចារណា) | | | | |
|---|---|---|---|---|
| កម្រិត | ទីតាំងគ្រោងទុក | ទីតាំងបេក្ខភាព | លក្ខណៈវិនិច្ឆ័យ | |
| 1 | រាជធានី | ភ្នំពេញ | >1 លាននាក់ | បច្ចុប្បន្ន ស្ថានភាពទីក្រុងទាំងនេះ បានប្រកាសពីព្រោះលក្ខន្តិកៈរបស់គេ ជារាជធានី និង ទីរួមខេត្ត |
| 2 | ទីក្រុង (ទីក្រុងលំដាប់ទីពីរ) | សៀមរាប, បាត់ដំបង, ប៉ោយប៉ែត, សិរីសោភ័ណ, ព្រះសីហនុ | >100000នាក់ | |
| 3 | ទីក្រុង (ទីក្រុងលំដាប់ទីបី) | កំពង់ចាម, តាខ្មៅ, ស្វាយរៀង, ច្បារមន, ពោធិ៍សាត់, ស្ទឹងសែន, បាវិត, កំពត, សំរោង, ខេមរភូមិន្ទ, ដូនកែវ, ក្រចេះ, ប៉ៃលិន, សួង, ស្ទឹងត្រែង, បានលុង | >30000នាក់ | |
| 4 | ក្រុងលំដាប់ទីបួន | ព្រះវិហារ, កែប សែនមនោរម្យ, | >10000នាក់ | |
| 5 | តំបន់ប្រជុំជនដ៏ទៃទៀត (ទីប្រជុំជនមិនមែនជាក្រុង- សូមមើលឧបសម្ព័ន្ធ) | 11 | >20000នាក់ | |
| | | 18 | 10000នាក់ | |
| | | 11 | >2000-10000នាក់ | |

ការប្រឈមនាពេលបច្ចុប្បន្ននោះគឺថាតំបន់ប្រជុំជនមួយចំនួន(យ៉ាងហោច)៤០ទីក្រុងទីប្រជុំជន (មិនទាន់ប្រកាសជាក្រុង)។ មានចំនួនធំជាងមួយចំនួននៃទីរួមខេត្ត២៥និងទីក្រុងពីរទៀតនៅតាមព្រំដែននៃការគ្រោងទុកថ្មីៗនេះ។

<u>**សារៈសំខាន់នៃដំណាក់កាលអន្តរកាលរវាងទីក្រុងនិងជនបទ**</u> និងតម្រូវការក្នុងការបកស្រាយ ការតភ្ជាប់រវាង តំបន់ជនបទនិងទីក្រុង ទៅក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍនៅក្នុង តំបន់ទីក្រុង មានការអភិវឌ្ឍតិចតួច និងអនុតំបន់ (ក្របខណ្ឌការគ្រប់គ្រងដែនដីថ្នាក់តំបន់ រួមទាំងការតភ្ជាប់រវាង ទីក្រុងនិង ជនបទ)។ ចាំបាច់ត្រូវមានការពិចារណាទៅលើពាក្យពេចន៍ផ្អែកលើវិស័យសេដ្ឋកិច្ច និងផ្អែកលើវិស័យសង្គម សម្រាប់តំបន់"ជាយក្រុង"

និងតំបន់ដាច់ស្រយាលនៃទីក្រុងនិង ទីប្រជុំជនជុំវិញដើម្បីជានាតុល្យភាព សក្តានុពលនៃដីដែលមាន និង សក្តានុពលនៃការប្រើប្រាស់សម្រាប់ជម្រើសចុងក្រោយ ក៏ដូចជាការពិចារណាក្នុង ការពង្រីកនិងអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធ។

ត្រូវមានការគិតគូរអំពីប៉ូលនៃការអភិវឌ្ឍ ប្រករបៀងតំបន់ព្រំដែន ទីមជ្ឈមណ្ឌលប្រជុំជន ធំនិងតូច(លំដាប់ ទីពីរ ទីបី និង ទីបួន) (ឧទាហរណ៍ទីក្រុងកំពង់ផែ តំបន់សេដ្ឋកិច្ចពិសេស) ក៏ដូចជាអភិវឌ្ឍតំបន់ទីក្រុងថ្មីៗ។

**គោលនយោបាយគាំទ្រពិសេស សម្រាប់ទីក្រុងតូចនិងមធ្យម**: អាចដាក់នៅក្រោមចំណងជើង នៃការតភ្ជាប់រវាងជនបទនិង ទីក្រុងឬចាត់ទុកជាចំណុចដោយឡែកក៏បាន។ គោលនយោបាយនេះ តម្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមលើផ្នែករឹង(ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត)និងផ្នែកទន់(ការអភិវឌ្ឍសមត្ថភាព) នៅទីប្រជុំជនតូចនិងមធ្យម ដើម្បីអាចឆ្លើយតបទៅនឹង សម្ពាធពីនគរូបនីយកម្ម។

ការប្រតិបត្តិការលើគោលនយោបាយអភិវឌ្ឍទីក្រុង និងយុទ្ធសាស្ត្រ។ ការទទួលខុសត្រូវផ្អែកលើរដ្ឋបាលសម្រាប់ អនុវត្ត ជាមួយគោលនយោបាយអភិវឌ្ឍទីក្រុង។ គណៈកម្មាធិការជាតិសម្រាប់ការរៀបចំដែនដី និង នគរូបនីយកម្ម ទទួលខុសត្រូវ ដើម្បីសហប្រតិបត្តិការនៃដំណោះស្រាយ របស់រាជរដ្ឋាភិបាល ចំពោះការរៀបចំដែនដី និង នគរូបនីយកម្ម ជាមួយនិងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ជាសេនាធិការជាតិដើម្បីដឹកនាំការអនុវត្ត ការរៀបចំទីក្រុង និងដំណើរការដែលជាប់ពាក់ព័ន្ធ។ ដំណើរការកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ និងកំណើន សេចក្តីត្រូវការសម្រាប់តម្លាភាព និង គណនេយ្យភាព ក្នុងការធ្វើការសម្រេចចិត្ត និងក្នុងន័យអភិបាលកិច្ចទីក្រុង ចាំបាច់ត្រូវការពិចារណាឲ្យបានប្រសើរថែមទៀត។

<u>**ការរៀបចំផែនសម្រាប់ផែនការ កម្រិតថ្នាក់ជាតិ តំបន់ និងក្នុងស្រុក ដើម្បីការងារគ្រប់គ្រងដែនដីទាំងមូល**</u>: **ប្រព័ន្ធផែនការទីក្រុងនិងឧបករណ៍**នេះ តម្រូវឲ្យមានការយកចិត្តទុកដាក់និងភាពស៊ីសង្វាក់គ្នាជាមួយនឹង គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនិងច្បាប់រៀបចំ ខេត្ត ក្រុង ស្រុក/ខណ្ឌ។ យុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍក្រុងគួរចូលរួមក្នុងការផ្តល់មគ្គុទ្ទេសក៏ដល់បទដ្ឋានគតិយុត្តដែលមានស្រាប់ សម្រាប់ការធ្វើផែនការមេ និងផែនការប្រើប្រាស់ដីធ្លី ផែនការលំអិត និងផែនការដាក់លាក់មួយចំនួនទៀត (ដូចបានគ្រោងទុក) ដោយហេតុថាវាត្រូវបានព្រាងនិងអនុវត្តនៅគ្រប់កម្រិតនៃ រដ្ឋបាលថ្នាក់ក្រោមជាតិ។ ពេលអនាគត ផែនការ វិស័យ ពាក់ព័ន្ធគួរដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុង ដើម្បីជាឧបករណ៍មួយក្នុងការ សម្របសម្រួល គោលដៅនិងវត្ថុបំណងថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន ក្នុងតំបន់ទីក្រុង។

**ក្របខណ្ឌរួមនៃបរិស្ថាននិងដីធ្លីនិងរចនាសម្ព័ន្ធរដ្ឋបាល** (រាជធានី ខេត្ត ក្រុង ស្រុក/ខណ្ឌនិង តំបន់រដ្ឋបាល ថ្នាក់ក្រោមជាតិដូចជាឃុំ/សង្កាត់) បង្កើតជាទម្រង់មូលដ្ឋាន សម្រាប់ធ្វើឋានានុក្រមផែនការដែលអាច ទាមទារ ឲ្យមានការបង្កើតច្បាប់ដើម្បីជំរុញនិងធ្វើសំយោគវិស័យនានាផ្អែកលើផែនការដែលអាចអភិវឌ្ឍបាន។ ការកំណត់ច្បាស់លាស់នូវតួនាទីរបស់អាជ្ញាធរមូលដ្ឋានដែលមានស្រាប់ ច្បាប់ស្តីពីការគ្រប់គ្រងរៀបចំ រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ (ច្បាប់រៀបចំអង្គការ) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ គោលនយោបាយជាតិ ស្តីពីការធ្វើផែនការដីធ្លី និងអនុក្រឹតស្តីពី ការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិង នគរូបនីយកម្ម(នៅកំរិតផ្សេងៗគ្នា)។ មានសេចក្តីត្រូវការចាំបាច់

ដើម្បីអភិវឌ្ឍសមត្ថភាពនិងគោលការណ៍ណែនាំ ក៏ដូចជាការពន្យល់ឲ្យបានច្បាស់អំពីតួនាទីការទទួលខុសត្រូវ និងធាតុចូលត្រូវបានផ្តល់ដោយភ្នាក់ងារជាតិ និងអង្គភាពថ្នាក់ក្រោមៗដ៏ទៃទៀត។

ផែនការការអភិវឌ្ឍទាំងអស់ នឹងតម្រូវឲ្យមានធនធានមួយចំនួនដូចជា (ធនធានធម្មជាតិ ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស) ហើយនេះតម្រូវឲ្យមានការគិតគូរពិចារណាចាប់តាំងពីពេលចាប់ផ្តើមដំបូង ដើម្បីធានាថាប្រសិទ្ធភាពនៃតម្លៃវិនិយោគនិងផែនការត្រូវបានអភិវឌ្ឍនិងអនុម័ត។

**ផែនការអភិវឌ្ឍក្នុងតំបន់និងថ្នាក់ជាតិ ហើយនិងតម្រូវការសហប្រតិបត្តិការនិងកត្តាផ្សេងៗទៀត (រួមមានការសម្របសម្រួលផែនការ រវាងក្រុង/តំបន់នៃប្រទេសជិតខាង និងរបាយប្រជាជននិងការងារ)**: មានសេចក្តីត្រូវការចាំបាច់សម្រាប់ឲ្យមានគោលគំនិតទស្សនៈវិស័យទូលំទូលាយក្នុងការបែងចែកដែនដីឲ្យទៅជាតំបន់អភិវឌ្ឍមួយចំនួនដូចជា (ផ្នែកកសិកម្ម ផ្នែកទេសចរណ៍ ផ្នែកឧស្សាហកម្ម ឬនៅទីណាដែលមានតំបន់សេដ្ឋកិច្ចពិសេសរួចមកហើយ និងតំបន់លំនៅដ្ឋានទីក្រុង) ហើយនិងតំបន់ការពារដូចជា (ឧទ្យានជាតិ តំបន់អភិរក្សធម្មជាតិ និងតំបន់អភិរក្ស ជីវៈចម្រុះព្រមទាំងការអភិរក្សបេតិកភណ្ឌនិងវប្បធម៌)។ តំបន់ឆ្នេរត្រូវមានការយកចិត្តទុកដាក់ ជាពិសេសដើម្បី រក្សាតុល្យភាពក្នុងការប្រកួតប្រជែងអាជីវកម្មធនធានធម្មជាតិ(ប្រេងនិងឧស្ម័ន)ឧស្សាហកម្ម ទេសចរណ៍ និងលំនៅដ្ឋានទីក្រុង (ក្រុងកំពង់ផែ និងតំបន់ឧស្សាហកម្មចំរុះ) ព្រមទាំងតំបន់កំសាន្ត និង តំបន់អភិរក្សធនធានធម្មជាតិ និងហានិភ័យកើនឡើងពីបម្រែបម្រួលអាកាសធាតុ។ រួមទាំងការពិចារណា **នៃមជ្ឈមណ្ឌល**ទីក្រុងថ្មីៗដែលអាចស្នើនិងបង្កើតឡើងដោយយោងលើកត្តារបាយការងារនិងចំនួនប្រជាជន។

**ការបែងចែកជាតំបន់សម្រាប់ធ្វើការវិភាគនិងគោលបំណងរបស់គោលនយោបាយ**:បច្ចុប្បន្នប្រព័ន្ធស្ថិតិតំបន់ចំនួន៥ទៅ៦អាចត្រូវរៀបចំឡើងដើម្បីឲ្យក្លាយជាប្រព័ន្ធមួយសមស្របទៅនឹងផែនការក្នុងតំបន់ នេះនឹងតម្រូវឲ្យមាន ការពិគ្រោះយោបល់និងធ្វើជំរឿនជាមួយនឹងក្រសួង/ស្ថាប័នរបស់រដ្ឋាភិបាលនិងអ្នកជាប់ពាក់ព័ន្ធផ្សេងៗទៀតដើម្បី ធានាការសម្របសម្រួលនិងការឯកភាពរវាងស្ថាប័ននានារបស់រដ្ឋាភិបាល។ លទ្ធភាពសំណើរ សម្រាប់តម្រឹម ផែនការតំបន់ត្រូវបានពិចារណា។ ទីក្រុងធំភ្នំពេញ តំបន់ព្រំដែន និងតំបន់ធ្វើផែនការផ្សេងៗទៀត ផ្អែកលើលក្ខណៈ វិនិច្ឆ័យភូមិសាស្រ្ត លក្ខណៈវិនិច្ឆ័យសេដ្ឋកិច្ច និងលក្ខណៈវិនិច្ឆ័យរដ្ឋបាល។ ត្រូវមានការលើកទឹកចិត្ត និងគាំទ្រផែនការតំបន់ថ្នាក់ក្រោមជាតិ ដោយមានកិច្ចសហប្រតិបត្តិការរវាងទីក្រុងនានានិងទីប្រជុំជន និង តំបន់ជនបទ តាមបណ្តោយរបៀងសេដ្ឋកិច្ចដើម្បីផលប្រយោជន៍រួមគ្នាទៅវិញទៅមក។

**ក្របខណ្ឌអភិវឌ្ឍតំបន់ម៉ាក្រូ** នៃមហាអនុតំបន់ទន្លេមេគង្គ និងអាស៊ានក៏ត្រូវពិចារណាជាពិសេសផងដែរ ចំពោះ ខេត្តនានាជាប់ព្រំប្រទល់ និងតំបន់ទីប្រជុំជនដែលការអភិវឌ្ឍទីក្រុងឆ្លងកាត់ព្រំប្រទល់ប្រទេសគឺត្រូវទទួលបន្ទុក ដោយក្រុមការងារបច្ចេកទេសពិសេសក្រោមសន្និសិតរដ្ឋមន្ត្រីនៃប្រទេសមហាអនុតំបន់ទន្លេមេគង្គ (**GMS**)។ សន្និសិតបន្តទៀតចាំបាច់ប្រហែលជាត្រូវធ្វើសមាហរណកម្ម និងបញ្ចូលគោលនយោបាយពីប្រទេសអាស៊ាន និងចុងក្រោយពីសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។

**គោលនយោបាយវិស័យចំបងៗត្រូវមានភាពសុខដុមជាមួយនឹងការអភិវឌ្ឍទីក្រុង: ការរៀបចំយុទ្ធសាស្រ្តជាតិស្តីពី** ការ

អភិវឌ្ឍទីក្រុងចាំបាច់ត្រូវពិនិត្យឡើងវិញនិងពិចារណានូវគោលនយោបាយនិយ័តកម្មមួយចំនួនទៅលើដីធ្លី ការរីកចំរើននៃពណ៌បៃតង ឧស្សាហកម្ម និងលំនៅដ្ឋាន ហើយនិងការដឹកជញ្ជូនព្រោះវាមានការវិវត្តនិង ការទទួលយក។

- **គោលនយោបាយជាតិស្តីពីលំនៅដ្ឋាន**ៈទំនងជាសមាសជាតុសំខាន់មួយនៃយុទ្ធសាស្ត្រជាតិ ស្តីពី ការអភិវឌ្ឍក្រុង ដូចដែលវាបានកំរិត និងសម្របសម្រួលដំណើរការដើម្បីផ្តល់និងលើកទឹកចិត្តឲ្យមានតម្លៃលំនៅដ្ឋានសមរម្យ និងអាចលៃលកទិញបាន សម្រាប់គ្រួសារក្រីក្រនិងគ្រួសារងាយរងគ្រោះ។ ក៏ដូចជា ការដោះស្រាយបញ្ហាសំណង់មិនស្របច្បាប់។
- **គោលនយោបាយដីធ្លីទូលំទូលាយ**: “Land White Papper” ការកែលំអកម្មសិទ្ធិដីធ្លីតាមរយៈការចេញ ប័ណ្ណកម្មសិទ្ធិលើអចលនទ្រព្យតម្រូវធ្វើឲ្យប្រសើរឡើងបន្ថែមទៀតដោយហេតុថាតម្លៃអចលនទ្រព្យ មានការកើនឡើងតាមរយៈការរីកវិសាលភាពនៃទីក្រុងដែលរដ្ឋាភិបាលមិនទាន់មានឥទ្ធិពលគ្រប់គ្រង។ ឱកាសបង្កើនពន្ធមូលធនតាមរយៈការបង្កើតឱកាសនានា សម្រាប់ការប្រមូលពន្ធតាមមូលដ្ឋាន ដើម្បី រួមចំណែកបង្កើនប្រាក់ចំណូលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវតែធ្វើការពិចារណា ដែលក្នុងនោះ ការផ្លាស់ប្តូរប្រភេទដីនិងការផ្លាស់ប្តូរបម្រើបម្រាស់មុខងារដីធ្លីធ្វើឲ្យមានការកើនឡើងនៃតម្លៃ ដែលផ្នែកខ្លះ ចាំបាច់ត្រូវគ្រប់គ្រងដោយអាជ្ញាធរមូលដ្ឋាន សម្រាប់ទទួលបានថវិកាដំណើរការ។ ទិដ្ឋភាពផ្សេងទៀត នៃគោលនយោបាយ នឹងចាំបាច់ត្រូវបញ្ជ្រាបនិងបញ្ចូលទៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុង។
- រដ្ឋាភិបាលបានអនុម័តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍបៃតងក្នុងឆ្នាំ២០១៣ ហើយដែលបាន បញ្ជ្រាបចូល ទៅក្នុងផែនការជាតិស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍ ឆ្នាំ២០១៤-២០១៨ ដែលជាមធ្យោបាយ មូលដ្ឋានក្នុងការអភិវឌ្ឍប្រកបដោយចីរភាព ហើយទិដ្ឋភាពមួយភាគធំនៃគោលនយោបាយនេះនឹងត្រូវ បានប្រើជាលំនាំនិងដាក់បញ្ចូល ទៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុង។ ជាមួយគ្នានេះដែរ ក៏ត្រូវពិចារណាលើ “វិធីសាស្ត្រដោះស្រាយ3E”(សេដ្ឋកិច្ច បរិស្ថាន និងសមភាព)។
- គោលនយោបាយអភិវឌ្ឍឧស្សាហកម្មដែលបានអនុម័តកាលពីពេលថ្មីៗបានរំលេចនូវសេចក្តីត្រូវការ ដើម្បីពិចារណាឲ្យបានប្រសើរអំពីការផ្លាស់ប្តូរសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនិងសេដ្ឋកិច្ចមានលក្ខណៈចំរុះ នោះបានធ្វើឲ្យកម្ពុជាស្ថិតក្នុងអន្តរកាល។ វាបានធ្វើឲ្យមានការជឿទុកចិត្តលើការអភិវឌ្ឍឧស្សាហកម្ម ដែលនឹងតភ្ជាប់ដើម្បីពង្រីកទៅនឹងមជ្ឈមណ្ឌលនិងរបៀងដែលមានការរីកចំរើន ហើយលទ្ធភាព តួនាទីនាពេលអនាគតនៃការពង្រីកក្រុង។ ក៏ដូចជាសំណើរការអភិវឌ្ឍតំបន់ឧស្សាហកម្ម និងប្លង់មេ សម្រាប់អភិវឌ្ឍ ដែលមានបំណងជំរុញសហគ្រិនខ្នាតតូចនិងមធ្យមឲ្យមានលក្ខណៈប្រកួតប្រជែង នៅក្នុងខេត្តនានាដែលបានគ្រោងទុក។
- រាជរដ្ឋាភិបាលមានបំណងផ្តល់ការគាំទ្ររួមមាន(ជំរុញផែនការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍក្រុងនៅ ក្នុងតំបន់ឧស្សាហកម្មដែលបានគ្រោងទុក ដូចជា ខេត្តស្វាយរៀង ខេត្តព្រះសីហនុ និងខេត្តកោះកុង ហើយ និងក្រុងប៉ោយប៉ែត ដើម្បីសម្របសម្រួលសកម្មភាពឧស្សាហកម្ម មានបំណងជំរុញឲ្យមានការធ្វើផែនការ ប្រើប្រាស់ដីធ្លី ការគ្រប់គ្រងបរិស្ថាន ការអភិវឌ្ឍលំនៅដ្ឋាន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ ការអភិវឌ្ឍ រាជធានីភ្នំពេញទៅជាតំបន់ឧស្សាហកម្មទំលាយចូលគ្នា តាមរយៈការអនុវត្តផែនការអភិវឌ្ឍទីក្រុង រយៈពេល

វែង ដែលមានការគ្រោងទុកច្បាស់លាស់នូវ តំបន់ឧស្សាហកម្ម តំបន់រដ្ឋបាល និង តំបន់ លំនៅដ្ឋានមាន បំណងកែទម្រង់រាជធានីភ្នំពេញ ទៅក្នុងមជ្ឈមណ្ឌលឱណាមិចនៃវប្បធម៌ ចំណេះដឹង និង ឧស្សាហកម្ម។

- **សមាហរណកម្មការដឹកជញ្ជូននិងធ្វើផែនការប្រើប្រាស់ដីធ្លី:** ភាគច្រើននៃផ្លូវដឹកជញ្ជូនសព្វថ្ងៃ ជាផ្លូវ ឆ្លងកាត់ និងតភ្ជាប់ក្រុងនានាក្នុងប្រទេសមានការកើនឡើង បង្កើនការឆ្លងកាត់និងចរាចរណ៍មមាញឹក ក្នុងមូលដ្ឋាន និងជាចលនាចល័តទំនិញនិងផលិតផល ដែលនឹងចំណាយពេលវេលាច្រើន ដើម្បីទៅដល់ គោលដៅ។ បញ្ហាទាំងនេះនឹងតម្រូវឲ្យមានការពិនិត្យតាមដាននិងជម្រើសល្អចុងក្រោយ ធ្វើផែនការ និងអភិវឌ្ឍផ្លូវថ្នល់។ លើសពីនេះទៅទៀតក្រុងមួយចំនួននៅរាយប៉ាយនិងឆ្ងាយពីគ្នា ដែលត្រូវ ការចរាចរណ៍ដោយយានយន្តក្នុងការធ្វើដំណើរដែលបណ្តាលឲ្យមានភាពខ្វះខាតថាមពលនិងធនធាន។ នៅក្នុងបរិបទនេះ ថាតើគួរកាត់បន្ថយបន្ទុកអ្នកជិះយានយន្តយ៉ាងដូចម្តេច? តាមរយៈការធ្វើផែនការ និងការអភិវឌ្ឍជារឿងសំខាន់។ ការរៀបចំក្រុងដែលមានដង់ស៊ីតេណែនណាន់(Compact)និង គោលគំនិតនៃការរៀបចំតំបន់ប្រជុំជនក៏ដូចជាគោលនយោបាយការដឹកជញ្ជូនសាធារណៈនិងវិធី ដោះស្រាយ សម្រាប់ក្រុងតូចៗ ត្រូវតែពិចារណាឲ្យបានហ្មត់ចត់ល្អិតល្អន់។

**កត្តាពិសេសដែលមានឥទ្ធិពលលើការអភិវឌ្ឍថ្នាក់ជាតិ តំបន់ និងទីក្រុងមូលដ្ឋាន:** សក្តានុពលនៃការរុករក ឧស្ម័ន/ប្រេងឥន្ធនៈ និងឧស្សាហកម្មទាញយកផលដ៏ទៃទៀត ក៏ដូចជាការកែច្នៃផលិតផល កសិ-ឧស្សាហកម្ម ទៅលើ ការអភិវឌ្ឍទីក្រុង។ ការអភិវឌ្ឍ**ឧស្ម័ន**/ប្រេងឥន្ធនៈនៅតំបន់ឈូងសមុទ្រនៃប្រទេសកម្ពុជា ឬ ឧស្សាហកម្ម ទាញយក រ៉ែនិងការកែច្នៃដ៏ទៃទៀតអាចផ្លាស់ប្តូរតំបន់ឆ្នេរទាំងមូលនិងតំបន់ផ្សេងៗទៀតនៃប្រទេស(ដូចជាភូមិភាគឦសាន្ត) ដែលមានឧស្សាហកម្មចម្បងៗនិងអ្នកផ្តល់សេវាធំៗ នៅក្នុងតំបន់ឆ្នេរបច្ចុប្បន្ននិងតំបន់ឆ្នេរថ្មីៗ ឬតំបន់ដ៏ទៃទៀត នៃប្រទេសកម្ពុជា។ មានការប្រមូលផ្តុំកើតឡើងពីសកម្មភាពអាជីវកម្មនិងការកែច្នៃនៅខេត្តមួយចំនួនក្នុងប្រទេស។

**តម្រូវការនៃការវិនិយោគ និងប្រភពធនធាន(ការអភិវឌ្ឍ ហិរញ្ញវត្ថុ):** ឯកសារយុទ្ធសាស្ត្រគួរតែចាប់ផ្តើមលាតត្រដាងពីប្រភេទនិងកម្រិតសូចនករនៃការវិនិយោគតម្រូវឲ្យផ្តល់ភាពរីកចំរើននៃនគរូបនីយកម្មប្រកបដោយចីរភាព ព្រមទាំងលទ្ធភាពប្រភពធនធានហិរញ្ញវត្ថុទីក្រុងផងដែរ។ ដូចដែលការវិនិយោគមានការពន្យារទំនងជានឹងមាន ការខូចប្រយោជន៍ ដល់តម្លៃផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមនិងផ្នែកបរិស្ថានរបស់ប្រទេសជាតិ និងការប្រកួតប្រជែង ក្នុងតំបន់និងជាសកលផងដែរ។ គោលបំណងនៃយុទ្ធសាស្ត្រនេះគឺស្វែងរកតម្រូវការហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ ទីក្រុង និងវិធីដោះស្រាយប្រកបដោយភាពច្នៃប្រឌិតក្នុងការវិនិយោគ ជាឧទាហរណ៍រួមមានការវិនិយោគផ្ទាល់ពី បរទេសជាមួយនិងឯកជន ដៃគូវិនិយោគ រវាងឯកជននិងសាធារណៈនិងនៅក្នុងទីក្រុងផ្ទាល់។

**ប្រព័ន្ធត្រួតពិនិត្យជាប្រចាំរបស់ការអភិវឌ្ឍទីក្រុងតាមអណត្តិស្ថាប័នរដ្ឋាភិបាល:** ប្រព័ន្ធត្រួតពិនិត្យគួរបង្កើតឡើង នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍទីក្រុង នេះនឹងទាមទារទាំងប្រព័ន្ធសូចនករច្បាស់លាស់សម្រាប់វាស់ស្ទង់ការផ្លាស់ប្តូរ ក្នុងរយៈពេលមួយ និងស្ថាប័នដែលមានសិទ្ធិក្នុងអណត្តិ និងមានសមត្ថភាព ក្នុងការអនុវត្តការងារត្រួតពិនិត្យ ជាប្រចាំ។

### 3.7. វិធីដោះស្រាយ/របៀបដោះស្រាយ

ការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុង និងការអនុវត្តត្រូវបានរៀបចំឡើងនិងផ្តល់ជូនតាមរយៈរបៀប ដោះស្រាយពិគ្រោះយោបល់ និងជាមួយអ្នកពាក់ព័ន្ធជាច្រើនថ្នាក់ ដែលលើកទឹកចិត្តនិងគាំទ្រ ការចូលរួម ប្រកបដោយប្រសិទ្ធភាពនិងជាលក្ខណៈសង្គម និងលើកទឹកចិត្តដល់ការចូលរួមពីអ្នកអនុវត្ត ស្ថាប័នពាក់ព័ន្ធនានា និងពីសាធារណៈក្នុងការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងនិងទីប្រជុំជន។

- កិច្ចការនេះគួរមានការចូលរួមពីអ្នកអនុវត្ត ពីភាគីពាក់ព័ន្ធទាំងអស់ដើម្បីធានាការទទួលបានទស្សនៈគ្រប់ជ្រុងជ្រោយ ក្នុងការចងក្រង យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុង ដែលបន្ទាប់មកនឹងត្រូវអនុវត្ត។
- គួរមានការចូលរួមពីយេនឌ័រ ហើយការរួមបញ្ចូលលក្ខណៈសង្គមនិងវប្បធម៌ ក្នុងដំណើរការរៀបចំ និងផ្តល់ឱកាស ដល់ក្រុមតំណាងផ្សេងៗទៀតក្នុងប្រទេស ដើម្បីជួយផ្តល់មតិ យោបល់/ ការយល់ឃើញក្នុងដំណើរការ និងការអនុវត្ត។

បច្ចុប្បន្នមានតម្រូវការចាំបាច់ដើម្បីរៀបចំបង្កើត អនុម័ត និងផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុង ដោយហេតុថាចំនួនប្រជាជននៅទីក្រុងមានការកើនឡើង ដែលធ្វើឲ្យមានតម្រូវការដីធ្លី ហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មនានា ត្រូវមានការដោះស្រាយតាមបែបផែននៃការធ្វើផែនការនិងគ្រប់គ្រង ជាជាងអនុញ្ញាត្តិ ឲ្យក្រុងរីកកាន់តែធំទៅៗ។ កត្តាទាំងនេះបានធ្វើឲ្យរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់ក្រោមជាតិប្រឈម នឹងការ លំបាកក្នុងការដោះស្រាយបញ្ហានានាដូចជាៈ

(i) កង្វះលំនៅដ្ឋាន សេវាកម្មមូលដ្ឋាន តម្រូវការហេដ្ឋារចនាសម្ព័ន្ធសម្រាប់ដឹកជញ្ជូន អគ្គិសនី ទឹកស្អាត សំណល់រាវ ប្រព័ន្ធបង្ហូរ ការទប់ស្កាត់ការជន់លិច និងអ្វីៗជាច្រើនទៀត។

(ii) ឱកាសសេដ្ឋកិច្ចតាមរយៈការគាំទ្រការអភិវឌ្ឍពាណិជ្ជកម្មនិងឧស្សាហកម្មក្នុងក្រុងនិងទីប្រជុំជននានា។

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចាំបាច់ត្រូវធ្វើការសម្រេចចិត្តដោយមានការដឹងឮ អំពីការរីកលូតលាស់ និងទម្រង់នៃទីក្រុង និងទីប្រជុំជនរបស់ខ្លួន ដែលទាមទារឲ្យមានព័ត៌មាននិងទិន្នន័យមូលដ្ឋានរួមមានៈ

- គុណភាពនិងបរិមាណការប្រើប្រាស់ដីធ្លី ការរីកពាលដាលនៃក្រុង ការផ្លាស់ប្តូរនិងនិន្នាការ។ ការធ្វើឲ្យក្រុងមានភាពប្រសើរឡើង និងការគ្រប់គ្រងដីធ្លី គឺជាការចាំបាច់ ដើម្បីរក្សាដីធ្លីបម្រុងទុកនិងសម្រាប់ការប្រើប្រាស់នាពេលអនាគត ។
    - ព័ត៌មានស្តីពីប្រភេទនិងការប្រើប្រាស់ដី អាគារ និងរចនាសម្ព័ន្ធក្នុងក្រុងនិងទីប្រជុំជនទាក់ទង នឹងគម្រប កំពស់ និងទំហំកម្រាល។ល។
    - ព័ត៌មានអំពីប្រភេទផ្ទះ គុណភាព (អាយុកាល)និងចំនួនដែលមាន។
- ការផ្លាស់ប្តូរប្រជាសាស្ត្រ សេដ្ឋកិច្ច និងនិន្នាការក្នុងក្រុង និងក្រុងដែលមានការរីកចម្រើន និងៈ
    - របាយប្រជាជនក្នុងនិងជុំវិញតំបន់ប្រជុំជន (ជាពិសេសជាយក្រុង) ដោយសារមានការរីក លូតលាស់និងលាតសន្ធឹងនៃទីក្រុង ដែលតម្រូវឲ្យមានការត្រួតពិនិត្យ។

- o ចំនួន ប្រភេទ និងរបាយនៃឧស្សាហកម្ម សកម្មភាពសេដ្ឋកិច្ច នៅក្នុងនិងជុំវិញតំបន់ប្រជុំជន។
- o ចំនួននិងរបាយនៃជនក្រីក្រ និងក្រុមងាយរងគ្រោះ ព្រមទាំងលំនៅដ្ឋានបណ្ដោះអាសន្ននានា។

- ការការពារបរិស្ថានពីផលប៉ះពាល់នៃដំណើរការនិងសកម្មភាពនៃទីក្រុង ការបញ្ចេញសំណល់ ជាតុពុល (ដី ទឹក ខ្យល់) ទឹកជំនន់ ភាពស៊ាំនឹងអាកាសធាតុ ការអភិវឌ្ឍបៃតង(៣E) ការវាយតម្លៃ និរន្តរភាពក្រុងជារួម និងការវិនិយោគបៃតង ការប្រកួតប្រជែង និងការជួយគាំទ្រតាមរយៈកំណែទម្រង់ រដ្ឋបាលនិងការកែលម្អប្រព័ន្ធ អាចជាផែនការកាបោន ទឹក ដើម្បីគាំទ្រដល់ភាពណឹតរបស់កាបោន ភាពរស់រវើក និងទីក្រុងដែលមានណែនណាន់តាន់តាប់ (compact city)។
- ភាពទទួលបាននិងការប្រើប្រាស់សេវាកម្មទីក្រុង (អគ្គិសនី ទឹកស្អាត អនាម័យ ប្រព្រឹត្តកម្មទឹកកខ្វក់ ការគ្រប់គ្រងសំណល់រឹង) ព្រមទាំងសេវាកម្មសុខាភិបាលនិងការសិក្សាអប់រំ។
- ចរាចរណ៍និងការដឹកជញ្ជូន ចំនួននិងប្រភេទយានយន្ត ការកកស្ទះចរាចរណ៍ (ទីតាំង ល្បឿនចរាចរណ៍ជាមធ្យម (ម៉ោងចង្អៀតនិងមិនចង្អៀត) ពេលវេលាធ្វើដំណើរ។

តម្លាភាព គណនេយ្យភាព និងអភិបាលកិច្ចល្អនិងការអភិវឌ្ឍក្រុងមានប្រសិទ្ធភាពទៅបានលុះណាតែ មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនិងផ្នែកសាធារណៈក្នុងការបង្កើតនិងការអនុវត្តតាមបែបចូលរួមក៏ដូចជា ការអនុម័ត និងសេចក្ដីសម្រេចចិត្ត ដែលប៉ះពាល់ដល់ពួកគេ។ សាធារណៈជនគួរទទួលបានព័ត៌មាន អំពីភាពជឿនលឿនទៅមុខនៃការអភិវឌ្ឍទីក្រុងក៏ដូចជាបញ្ហាប្រឈម និងការលំបាកនានាដែលបានជួបប្រទះ ព្រមទាំងព័ត៌មានអំពីអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រង ការធ្វើការសម្រេចចិត្ត និងអនុវត្តផែនការអភិវឌ្ឍ។

យុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍ ក្រុងនិងទីប្រជុំជន ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ ថាតើឯកសារនេះ នឹងរួមចំណែកដល់គោលដៅអភិវឌ្ឍជាតិយ៉ាងដូចម្ដេច រួមមានការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍប្រកបដោយចីរភាព ការរួមបញ្ចូល ផ្នែកយេនឌ័រនិងផ្នែកសង្គម ហើយថា សកម្មភាពគាំទ្រអ្វីខ្លះដែលគួរអនុវត្ត ដើម្បីដោះស្រាយគោលបំណងទាំងនេះ។

ការកសាងសមត្ថភាព: យុទ្ធសាស្ត្រនេះត្រូវបង្ហាញវិស័យជាក់លាក់នានា ដែលក្នុងនោះការកសាងសមត្ថភាពត្រូវផ្ដល់ជូនជាបន្តបន្ទាប់ ចំពោះនរណាម្នាក់ និងតាមវិធីសាស្ត្រអ្វី។ ការកំណត់វិស័យនិងប្រធានបទ ក្នុងការកសាងសមត្ថភាពគឺជាផ្នែកមួយនៃយុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍក្រុង ។ គោលដៅនៃការកសាង សមត្ថភាពគួរតែមន្ត្រីសាលាក្រុងនិងក្រុមប្រឹក្សាស្រុកពាក់ព័ន្ធ ព្រមទាំងមន្ត្រីទទួលបន្ទុកនៃមន្ទីរខ្សែបណ្ដោយ និងការិយាល័យនៅថ្នាក់ខេត្ត ក្រុង/ស្រុក។ ជាតម្រូវការផងដែរ ក្នុងការវាយតម្លៃនៃការផ្ដល់ ជូនការអប់រំអំពីផែនការក្រុងនិងតំបន់ តាមរយៈប្រព័ន្ធអប់រំបញ្ចូលគ្នា និងកំណត់ថាតើ អ្វីខ្លះដែលពាក់ព័ន្ធ ត្រូវផ្ដល់ជូនបន្ថែម។

ការពិចារណាមួយចំនួនអំពីតម្រូវការនានាក្នុងការវិនិយោគក្នុងក្រុង ត្រូវបានដាក់បញ្ចូលដើម្បីឲ្យមានផែនការ ហិរញ្ញវត្ថុ និងថវិកាសម្រាប់តម្រូវការក្នុងការអភិវឌ្ឍក្រុងប្រកបដោយនិរន្តរភាពក្នុងក្របខណ្ឌទូទាំងប្រទេស។

### 3.8. ការអនុវត្ត ការគ្រប់គ្រង និងការពិនិត្យតាមដាន របស់យុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍក្រុង និងទីប្រជុំជន

គណៈកម្មការជាតិគ្រប់គ្រងដែនដី និងនគរូបនីយកម្មដែល មានការចូលរួមពីតំណាងក្រសួង និងភ្នាក់ងារនានា ចំនួន ២៧រូប និងមានក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ជាប្រធាន នឹងដើរតួនាទីដ៏សំខាន់ក្នុងការជានាសហប្រត្តិបត្តិការក្នុងការអនុវត្ត និងការត្រួតពិនិត្យយុទ្ធសាស្ត្រជាតិស្ដីពីការ អភិវឌ្ឍក្រុងប្រកបដោយប្រសិទ្ធភាពនៅថ្នាក់ជាតិ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏មានតួនាទីសំខាន់ក្នុងការកសាងសមត្ថភាព ណែនាំ និងត្រួតពិនិត្យការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាគីដ៏ទៃៗទៀត ក្នុងការធ្វើសមាហរណកម្ម យុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍក្រុងទៅក្នុងដំណើរការធ្វើផែនការនៅថ្នាក់មូលដ្ឋាន។

ទីក្រុង និងតំបន់ប្រជុំជនដែលមានស្រាប់មួយចំនួន ត្រូវការជាចាំបាច់នូវផែនការនិងការគ្រប់គ្រង ទីក្រុងដែលបានអនុម័ត ហើយយុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍក្រុងនិងទីប្រជុំជនអាចជួយ សម្រួលដល់ តម្រូវការទាំងនោះ។ ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ទំនងជាមិនអាច អនុវត្តគ្រប់ជាតុទាំងអស់នៃយុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍក្រុងនិងទីប្រជុំជនឡើយ ហើយនឹងត្រូវការ កិច្ចសហការ និងសម្របសម្រួលសកម្មភាពពីក្រសួងនានា និងភ្នាក់ងារនៃខ្សែបណ្តោយក្នុងការជានាការអនុវត្ត យុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍក្រុង ប្រកបដោយប្រសិទ្ធភាព។ វានឹងមានតម្រូវការ ក្នុងការលើកទឹកចិត្ត និងគាំទ្រ ក្នុងកិច្ចសហការនិងទំនាក់ទំនងភ្នាក់ងារអនុវត្តប្រកបដោយប្រសិទ្ធភាព។

ការដាក់បញ្ចូលការត្រួតពិនិត្យទៅក្នុងដំណើរការផែនការមូលដ្ឋានដែលមានស្រាប់ ទំនងជាវិធីមួយ ដ៏មានប្រសិទ្ធភាព និងជានាគណនេយ្យភាពចំពោះក្រុមប្រឹក្សាខេត្ត ក្រុងស្រុកខណ្ឌនិង សង្កាត់ដែលបាន ជ្រើសតាំង។ កិច្ចការនេះមានការប្រឈមផ្សេងៗ ដោយហេតុថាប្រព័ន្ធត្រួតពិនិត្យ និងផែនការមូលដ្ឋាន មានសូចនករច្រើនពេក។ មានប្រព័ន្ធត្រួតពិនិត្យក្រុង និងសូចនករនានា ដែលមានស្រាប់ ក៏ដូចជា មានសំណើរផ្សេងៗទៀត បានលើកឡើង។ ក្នុងចំណោមនោះ អ្វីដែលគួរឲ្យចាប់អារម្មណ៍ ជាងគេ គឺការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តឲ្យបានសម្រេចនូវគោលដៅអភិវឌ្ឍ ប្រកបដោយ ចីរភាពត្រឹមឆ្នាំ២០៣០ ដែលត្រូវបានអនុម័តនាខែកញ្ញាឆ្នាំ២០១៥។ ប្រព័ន្ធនិងសូចនករ ដែលបាន កំណត់ រួមមាន៖

- គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs) ជាពិសេសគោលបំណងទី១១ "ធ្វើឲ្យក្រុងនិង លំនៅដ្ឋាននានាមានសុវត្ថិភាព បន្សាំ និងប្រកបដោយចីរភាព"។ គោលបំណងនេះមានគោលដៅ អនុវត្តចំនួន១០ (គោលដៅចម្បងចំនួន៧ និងគោលដៅអមចំនួន៣)។ បញ្ជីនៃគោលដៅ ទាំង១០រួមមានសូចនករដែលត្រូវអនុម័តមានភ្ជាប់ក្នុងឧបសម្ព័ន្ធ។

- តាមអង្គការស្តង់ដារអន្តរជាតិ (ឆ្នាំ២០១៤) អំពី "ការអភិវឌ្ឍប្រកបដោយចីរភាពរបស់សហគមន៍៖ សូចនករសម្រាប់សេវាកម្មនានារបស់ទីក្រុង និងគុណភាពជីវិត" (ISO37120:2014) ដែលកំណត់ និងបង្កើតវិធីដោះស្រាយដើម្បីអនុវត្តសូចនករ ក្នុងការដឹកនាំ និងវាស់វែងពិនិត្យមើលសេវាកម្មក្រុង

និងគុណភាពជីវិត។ ISO នេះអះអាងថា ស្តង់ដានេះអាចអនុវត្តបានចំពោះគ្រប់ក្រុងទាំងអស់ ឬក៏ថា រដ្ឋបាលមូលដ្ឋានអាចវាស់វែងការអនុវត្តរបស់ខ្លួនតាមរយៈការផ្ទៀងផ្ទាត់ ប្រៀបធៀប ដោយមិនគិតអំពីទំហំ និងទីតាំង។ វាបានលើកឡើងអំពីវិស័យធំៗចំនួន១៧ ដែលមានសូចនករ ចំនួន១០០ ក្នុងនោះសូចនករចម្បងមានចំនួន៤៦ និងសូចនករអមចំនួន៥៤។

- ដែលនៅក្នុងនោះ សូចនករ "ចម្បង" ជាសូចនករដែលក្រុងត្រូវតែរាយការណ៍ ដើម្បីទទួលបានវិញ្ញាបនប័ត្រ ហើយសូចនករ "អម" ជាសូចនករដែលបានធ្វើអនុសាសន៍។ គួរកត់សម្គាល់ថា សូចនករនានាទទួលបានពីខាងសង្គម និងទំនងជា បានប្រមូល រួចមកហើយតាមរយៈប្រព័ន្ធត្រួតពិនិត្យរបស់រដ្ឋាភិបាលដែលមានស្រាប់។

សន្ទស្សន៍អំពីការអភិវឌ្ឍទីក្រុងរបស់អង្គការសហប្រជាជាតិស្តីពីលំនៅដ្ឋាន-UNHabitat ( សមាសធាតុ សន្ទស្សន៍នៃហេដ្ឋារចនាសម្ព័ន្ធ + សំណល់ + ការអប់រំ + សុខាភិបាល + ផលិតផលទីក្រុង ) និងមានច្រើនទៀត នៅក្នុងសន្ទស្សន៍វិបុលភាពរបស់ទីក្រុងថ្មីៗនេះ។

# A ឧបសម្ព័ន្ធ

## A.i. ឯកសារយោង

ADB 2012 Urban Sector Assessment, Strategy, and Roadmap. ADB, Manila,

CLP (2009) Declaration of the Royal Government on Land Policy.

Council for Land Policy-CLP, (2012) Land Policy 'White Paper', Ministry of Land Management Urban Planning and Construction.

General Secretariat of the Council for Land Policy, (2011) National Policy on Spatial Planning

Kammeier, H.D. Sin, S., Tep, M., (2014) Urbanization Study Cambodia 1998 - 2030: Assessment, Trends, Scenarios, Faculty of Architecture and Design, Pannasastra University of Cambodia,

MLMUPC (2013) Circular on the Development of Coastal Areas in the Kingdom of Cambodia and associated Framework Plan.

Nation Council on Green Growth CGG, (2013), tThe National Policy and Strategic Plan for Green Growth 2013-2030, Ministry of the Environment,

National Committee for Land Management & Urban Planning (2013) Documentation on Mechanism for Coordination of Land Management & Urban Planning in Cambodia

National Institute of Statistics-NISIS, (2012) Reclassification of Urban Areas 2011, Ministry of Planning

NIS/ MoP (2013) Cambodian Inter-Censual Survey 2013

NIS/ MoP General Population Census of Cambodia 2008

NIS/MoP Economic Census of Cambodia 2011, MoP

RGC, (2013) Rectangular Strategy Phase III

RGC, (2014) National Strategic Development Plan 2014-2018

Royal Government of Cambodia-RGCGC, (2008). Law on Administrative Management of the Capital, Provinces, Municipalities, Districts and Khans-"The Organic Law", Royal Kram (No.NS/RKM/0508/017)

World Bank.2015. East Asia's Changing Urban Landscape: Measuring a Decade of Spatial Growth.Urban Development Series. Washington, DC: World Bank

## ឯកសារគោលនយោបាយដែលជាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិដែលទាក់ទិននឹងនគរូបនីយកម្ម

| ឯកសារ | កាលបរិច្ឆេទ |
|---|---|
| ច្បាប់ភូមិបាល | 2001 |
| យុទ្ធសាស្ត្រស្តីពីក្របខណ្ឌគោលនយោបាយដីធ្លី | 2002 |
| ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលនៃរាជធានី ខេត្ត ក្រុង ស្រុកនិងខណ្ឌ, "ច្បាប់អង្គការ". | 2008 |
| សេចក្តីប្រកាសស្តីពីគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាល | 2009 |
| គោលនយោបាយអភិវឌ្ឍឧស្សាហកម្ម (IDP) | 2014 |
| គោលនយោបាយជាតិស្តីពីផែនការរៀបចំដែនដីធ្លី | 2011 |
| គោលនយោបាយដីធ្លីទូលំទូលាយ"White Paper" | 2012 |
| សារាចរស្តីពីការអភិវឌ្ឍតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា និងផែនការក្របខណ្ឌដែលពាក់ព័ន្ធ | 2013 |
| សៀវភៅផែនការរៀបចំដែនដី: ផែនការរៀបចំដីធ្លីថ្នាក់ខេត្ត | 2013 |
| ផែនការយុទ្ធសាស្ត្រនិងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង 2013-2030 | 2013 |
| យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី៣ | 2013 |
| ច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម (ពង្រាង) | ពង្រាង, 2014 |
| ច្បាប់អស្សាមិករណ៍ | 2010 |
| អនុក្រឹត្យស្តីពីការគ្រប់គ្រងនិងរៀបចំបុរី (គ្រប់គ្រងវីឡា អាគារលំនៅដ្ឋាននិងខុនដូ) | 2011 |
| គោលនយោបាយជាតិស្តីពីលំនៅដ្ឋាន | 2014 |
| ឯកសារស្តីពីយន្តការសម្របសម្រួលការរៀបចំដែនដីនិងនគរូបនីយកម្មក្នុងប្រទេសកម្ពុជា | 2013 |
| ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) 2014-2018 | 2014 |

## A.ii. សេចក្តីពន្យល់សង្ខេបអំពីបញ្ហាប្រឈមគន្លឹះ

| បញ្ហាប្រឈមគន្លឹះមួយចំនួន | សេចក្តីអធិប្បាយ |
|---|---|
| ប្រទេសកម្ពុជាស្ថិតនៅក្នុងដំណាក់កាលដំបូង ការផ្លាស់ប្តូរប្រជាសាស្ត្រនិងសេដ្ឋកិច្ចពីកសិកម្មទៅជា | ល្បឿននៃនគរូបនីយកម្មនៅក្បាលដែលឬមានការកើនឡើងដោយសារមានឱកាសក្នុងការកែលម្អសេដ្ឋកិច្ច និងឱកាសការងារ |

| បញ្ហាប្រឈមគន្លឹះមួយចំនួន | សេចក្ដីអធិប្បាយ |
|---|---|
| សង្គមនិងសេដ្ឋកិច្ចចំរុះបែបសេវាកម្ម កសិកម្ម ឧស្សាហកម្ម | មាន នៅទីក្រុង។ ឱកាសទាំងនេះនឹងផ្ដល់ចំណូល ដែលអាចរកបាន ច្រើនជាងនៅទីជនបទហើយដែលជំរុញឲ្យប្រជាជនចង់មករស់ នៅក្នុងទីក្រុង |
| ការរីកលរបស់ទីក្រុងធំជាងការលូតលាស់សេដ្ឋកិច្ច | ការងារនិងឱកាសទាក់ទាញនានានឹងបន្តមានឬកើនឡើងជាពិសេសទីក្រុងភ្នំពេញនិងតំបន់ជុំវិញដោយហេតុថាសព្វថ្ងៃនេះមានឱកាសការងារនិងមានការវិនិយោគឧស្សាហកម្មជាច្រើនកំពុងកើនឡើង។ ដោយមើលឃើញនូវកំណើនភាពមិនស្មើគ្នាកាន់តែខ្ពស់នោះទាមទារឲ្យមានការខិតខំយ៉ាងខ្លាំងក្នុងការបែងចែកផលប្រយោជន៍សេដ្ឋកិច្ចពីឧស្សាហកម្មនិងការប្រមូលផ្ដុំផ្សេងៗទៀតដែលមាននៅក្នុងទីក្រុង។ |
| ការរីកលរបស់ទីក្រុងមានភាពមិនស្មើគ្នា (បច្ចុប្បន្នមានការប្រមូលផ្ដុំនៅទីក្រុងភ្នំពេញនិងតំបន់ជុំវិញ ការរីកមួយចំនួននាភាគពាយ័ព្យតែមិនមានការរីកនៃទីក្រុងនាប៉ែកឥសាននិងតំបន់ឆ្នេរនៅឡើយ) | កង្វះខាតក្នុងការគ្រប់គ្រងការរីកចំរើនបង្កឲ្យមានការអភិវឌ្ឍមិនស្មើគ្នា ហើយធ្វើឲ្យមានរីកចម្រើនដោយលម្អៀងទៅរករាជធានី។ នេះតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងខ្លាំងនាពេលអនាគតក្នុង ការថ្លឹងថ្លែងតុល្យភាពនៃការអភិវឌ្ឍ |
| ប្រវត្តិគួរឲ្យកត់សម្គាល់នៃកំណើនប្រជាជនក្នុងប្រទេសកម្ពុជាគឺនគរូបនីយកម្ម ទោះជាឧស្សាហកម្មនៅទីក្រុងមួយចំនួនមិនស៊ីសង្វាក់ទៅតាមការបែងចែកជនជានកសិកម្មក៏ដោយ (៩០%នៃចំនួនប្រជាជនបានរស់នៅលើទឹកដីចំនួន៤០%នៃផ្ទៃដីទាំងមូល) មើលផែនទីក្នុងឧបសម្ព័ន្ធទី១ | ការអភិវឌ្ឍជាប្រវត្តិសាស្ត្រនិងជម្លោះកាលពីអតីតបានធ្វើឲ្យ មានការប្រមូលផ្ដុំប្រជាសាស្ត្រជុំវិញ ឬតាមបណ្ដាល ច្រករបៀង សេដ្ឋកិច្ច និងតំបន់ផលិតកម្មកសិកម្ម ដែលមានសុវត្ថិភាព |
| ការប្រមូលផ្ដុំឧស្សាហកម្ម, ការងារនិងសេវាកម្មនៅក្នុងតំបន់មួយចំនួននៃទីក្រុង | ជាភស្តុតាងគឺការរីកចម្រើននៃការងារនិងសេវាកម្មដែលពាក់ព័ន្ធនឹងវិស័យឧស្សាហកម្មនៅក្នុងតំបន់មួយចំនួននៃក្រុង (ជាពិសេស រាជធានីភ្នំពេញ) ដែលកំពុងតែបង្កការកកស្ទះចរាចរណ៍ដែលតម្រូវ ឲ្យយកមកពិចារណាក្នុងការរៀបចំយុទ្ធសាស្ត្រជាតិស្ដីពីការ អភិវឌ្ឍក្រុង។ |
| បើពិចារណាទៅលើការកាត់បន្ថយភាពក្រីក្រដែលសម្រេចបាន គេសង្កេតឃើញថាប្រជាជន មួយចំនួនធំ ទើបតែងើបផុតពីខ្សែបន្ទាត់នៃ ភាពក្រីក្រ ហើយពួកគេត្រូវបានចាត់ទុកថា ងាយរងគ្រោះនៅ | នៅពេលដែលភាពក្រីក្របានថយចុះនៅតែមានសហគមន៍ក្រីក្រដែលត្រូវទទួលបានការយកចិត្តទុកដាក់ក្នុងការកែលម្អជីវភាពនិងស្ថានភាពរស់នៅរបស់គេ។ ចំពោះគ្រួសារមានចំណូលទាបក្នុង ទី |

| បញ្ហាប្រឈមគន្លឹះមួយចំនួន | សេចក្តីអធិប្បាយ |
| --- | --- |
| ឡើយ។ ពួកគេស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដែលងាយ ត្រលប់ទៅរកភាពក្រីក្រវិញ បើសិនជាមានវិបត្តិអ្វីមួយកើតមានឡើង (នៅជនបទនិងទីក្រុង) | ក្រុង ការរក្សានូវកម្មសិទ្ធិដីធ្លី និងការលើកទឹកចិត្តឲ្យមានការ កែលម្អនៅនឹងកន្លែងត្រូវបានគេមើលឃើញថាមានប្រសិទ្ធភាព |
| គោលនយោបាយលំនៅដ្ឋាននិងការអភិវឌ្ឍទីក្រុងត្រូវតែគិតបញ្ចូលការកាត់បន្ថយភាពក្រីក្រជាផ្នែកមួយនៃគោលបំណងចម្បង | ហេដ្ឋារចនាសម្ព័ន្ធ លំនៅឋាន និងគោលនយោបាយសង្គមតម្រូវ ឲ្យមានដំណោះស្រាយ និងផ្តោតការយកចិត្តទុកដាក់លើបញ្ហាដែលទាក់ទងទៅនឹងការកាត់បន្ថយភាពក្រីក្រ ឬកាត់បន្ថយ ហានិភ័យនិងភាពងាយរងគ្រោះ<br><br>គួរមានការពិចារណាក្នុងការផ្តល់លំនៅដ្ឋានដែលមានតម្លៃសមរម្យដល់គ្រប់គ្រួសារដើម្បីឲ្យពួកគេបន្តការធ្វើកំណែលម្អលំនៅដ្ឋានជាបន្តបន្ទាប់ស្របជាមួយនឹងគោលនយោបាយលំនៅដ្ឋាន ដែលតម្រូវឲ្យមានការគាំទ្រពីរដ្ឋាភិបាលចូលរួមដើម្បីបង្កើនការរួមចំណែករបស់វិស័យឯកជន |
| ការបែងចែកនិងគុណភាពនៃដំណោះស្រាយ ហេដ្ឋារចនាសម្ព័ន្ធ (ការផ្គត់ផ្គង់ទឹកស្អាត ប្រព្រឹត្តកម្មសំណល់រាវ ការប្រមូលសំរាម និងសេវាកម្មផ្សេងៗទៀត) ច្រើនប្រមូលផ្តុំនៅ ទីក្រុងភ្នំពេញសេវាកម្មទាំងនេះ មានភាពប្រសើរ ជាងបើប្រៀបធៀបទៅនឹងក្រុងតូចៗនិងទីជនបទ | បញ្ហាបរិស្ថានទីក្រុងបានបង្ហាញឲ្យឃើញកាន់តែច្បាស់ក្នុងទីក្រុងនិងទីប្រជុំជននានាទូទាំងប្រទេសដែលតម្រូវឲ្យមានដំណោះស្រាយតាមរយៈការវិនិយោគប្រកបដោយប្រសិទ្ធភាព និង បច្ចេកវិទ្យាមានតម្លៃសមរម្យដើម្បីកាត់បន្ថយផលប៉ះពាល់ អវិជ្ជមានដល់អ្នករស់នៅក្នុងទីក្រុងនិងបរិស្ថានទាំងមូល |
| ការពិចារណាបន្ថែមចំពោះការរីកចម្រើននៃទម្រង់របស់ក្រុង ទាក់ទងនឹងប្រភេទនិងទីតាំងអភិវឌ្ឍ និងផលប៉ះពាល់របស់វាព្រមទាំងការរួមចំណែក ក្នុងការធ្វើឲ្យមានសមធម៌ក្នុងការអភិវឌ្ឍក្នុងទីក្រុង។ | ការកកើតនិងរីកលូតលាស់របស់បុរី (gated communities) និងការហៅខ្លួនឯងថាជាក្រុងរណប និងការរួមចំណែកក្នុងការ ធ្វើឲ្យមានតុល្យភាពនិង សមភាពក្នុងការអភិវឌ្ឍក្រុង។ លើសពីនេះតម្រូវការផ្នែកផ្គត់ផ្គង់និងសេវាកម្មទីក្រុងជាបញ្ហាមួយ ដែលត្រូវពិចារណាឲ្យបានស៊ីជម្រៅ។ |
| ទំហំទីក្រុងបច្ចុប្បន្នបង្ហាញពីគម្លាតខុសគ្នាយ៉ាងខ្លាំងរវាងរាជធានី ក្រុងធំៗដូចជាបាត់ដំបង សៀមរាប និងព្រះសីហនុ និងក្រុងតូចៗនៅតាមបណ្តាខេត្ត។ | បច្ចុប្បន្នភាពរីកដុះដាលនៃទីក្រុងបានបណ្តាលឲ្យមានរបាយ ដង់ស៊ីតេទាប និងភាពរាយប៉ាយនៃលំនៅដ្ឋានក្នុងទីក្រុងធ្វើឲ្យការ ផ្តល់សេវាកម្មមានតម្លៃខ្ពស់។ ជាចាំបាច់ត្រូវពិចារណាទៅលើ វិធីដោះស្រាយក្នុងការលើកទឹកចិត្តឲ្យមាន "ការអភិវឌ្ឍប្រកបដោយ ភាពឆ្លាតវៃ"ក្រុងមានដង់ស៊ីតេខ្ពស់ និងមជ្ឈមណ្ឌលទីក្រុង" ដែលមាន |

| បញ្ហាប្រឈមគន្លឹះមួយចំនួន | សេចក្តីអធិប្បាយ |
|---|---|
| | ផ្នែតម្រូវការបម្រុង របស់ទីក្រុងតូច និងការវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់។ |
| ការបែងចែកតំបន់ឧស្សាហកម្មចាស់និងថ្មី និងទីតាំងតំបន់ការងារសេវាកម្ម ត្រូវបានប្រមូលផ្តុំប្រហាក់ប្រហែលគ្នាដែរ និងបង្កការលំបាកក្នុងការដោះស្រាយក្នុងរយៈពេលមធ្យមនាពេលអនាគត។ | ការប្រមូលផ្តុំនៃតំបន់ឧស្សាហកម្មជុំវិញរាជធានី និងនៅតាមផ្លូវច្រករបៀងសំខាន់ៗចូលទីក្រុង បានកាត់បន្ថយឱកាសនិង ឥទ្ធិពលសេដ្ឋកិច្ចនៃឧស្សាហាភាវូបនីយកម្ម។ រដ្ឋាភិបាលគួរ ពិចារណាយន្តការលើកទឹកចិត្តក្នុងការពង្រាយតំបន់អភិវឌ្ឍ សេដ្ឋកិច្ចនិងឧស្សាហកម្មឲ្យមានតុល្យភាព។ |
| ការប្រឈមនិងបញ្ហានគរូបនីយកម្មនានា មិនទាន់បានទទួលស្គាល់ និងចាត់ជាអាទិភាពដោយភ្នាក់ងាររដ្ឋាភិបាលមួយ ចំនួន ព្រមទាំងអ្នកផ្តល់ជំនួយនៅឡើយទេ។ | ដោយសារកង្វះខាតនៃគោលនយោបាយនគរូបនីយកម្ម យុទ្ធសាស្ត្រ និងរបៀបវារៈ អ្នកសម្រេចចិត្តទាំងឡាយមិនទាន់ ទទួលស្គាល់អំពីសារៈសំខាន់និងអាទិភាពនានាហើយបន្តផ្តោត ការវិនិយោគនៅតែមួយផ្នែកធំក្នុងតំបន់ក្រុងគេគួរចងចាំថា ភាពក្រីក្រភាគច្រើននៅតាមតំបន់ជនបទដាច់ស្រយាលហើយ ដែលពិបាកឆ្លើយតបចំពោះគ្រួសារក្រីក្រ។ |
| ភាពស៊ាំនឹងអាកាសធាតុជាតម្រូវការសម្រាប់ ការអភិវឌ្ឍក្រុងទំនើប ដែលត្រូវដាក់បញ្ចូល ក្នុងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍក្រុងនៃកម្ពុជា។ | គ្រប់ក្រុងទាំងអស់ជាប្រភពយ៉ាងធំនៃកាបោនអុកស៊ីត និងឧស្ម័នផ្ទះកញ្ចក់ដ៏ទៃៗទៀតក៏ដូចជាកន្លែងដែលត្រូវការ ថាមពលច្រើនជាងគេហេតុនេះត្រូវមានការខិតខំប្រឹងប្រែងក្នុងការ ធ្វើឲ្យកាបោនណឹត និងការអភិវឌ្ឍក្រុងដែលបន្សាំនឹងបម្រែ បម្រួល អាកាសធាតុ។ |

## A.iii. ការកំណត់តំបន់មិនមែនជាក្រុង

តារាងខាងក្រោមបានកំណត់ទីប្រជុំជនចំនួន ៤០ ដែលមានប្រជាជនសរុបពី៤៧០០ ទៅជាង៥០០០០នាក់ដែលមានចរិកលក្ខណៈជាក្រុង។ ទីប្រជុំជនមួយចំនួនមានការលូតលាស់និងជាតំបន់សេដ្ឋកិច្ចយ៉ាងសំខាន់តាមស្ថានភាពសក្តានុពលជាក់ស្តែង ប៉ុន្តែ(បច្ចុប្បន្ននេះ) មិនទាន់ចំណាត់ថ្នាក់ជាក្រុងឬមណ្ឌលប្រជុំជន នៅឡើយដោយហេតុថាមានកង្វះខាតប្រព័ន្ធកំណត់មុខងារសម្រាប់តំបន់ក្រុងការធ្វើចំណាត់ថ្នាក់ដោយពឹង ផ្អែកតែទៅលើប្រព័ន្ធរដ្ឋបាលដូចដែលកំពុងអនុវត្តសព្វថ្ងៃនេះ។

| | ការកំណត់ថាមិនមែនក្រុង "ការតាំងលំនៅដ្ឋានក្នុងក្រុង" និងចំនួនប្រជាជន | | | | | |
|---|---|---|---|---|---|---|
| ខេត្ត | ទីតាំងលំនៅដ្ឋាន | >20000 | ទីតាំងលំនៅដ្ឋាន | <19999 | ទីតាំងលំនៅដ្ឋាន | <9999 |
| កណ្តាល | ស្អាង | 53649 | ខ្សាច់កណ្តាល | 18395 | កណ្តាលស្ទឹង | 9644 |

| | | | | | | |
|---|---|---|---|---|---|---|
| | អង្គស្នួល | 40463 | | | | |
| | គៀនស្វាយ | 34898 | | | | |
| | ពញាឮ | 26979 | | | | |
| | មុខកំពូល | 22898 | | | | |
| កំពង់ចាម | មេមត់ | 36994 | ព្រៃឈរ | 14982 | កងមាស | 6770 |
| | ចំការលើ | 35750 | ជើងព្រៃ | 13620 | ផ្អាវ | 7386 |
| | ត្បូងឃ្មុំ | 19273 | ស្រីសន្ធរ | 12569 | | |
| | | | កំពង់សៀម | 14939 | | |
| ស្វាយរៀង | | | | | | |
| ព្រៃវែង | | | ពាមរក៍ | 18531 | ស៊ីធរកណ្ដាល | 6492 |
| តាកែវ | | | | | | |
| បន្ទាយមានជ័យ | មង្គលបុរី | 22,124 | | | ម៉ាឡៃ | 8092 |
| បាត់ដំបង | សង្កែ | 22,358 | តាពូង | 13651 | | |
| | | | តាម៉ឺន | 15192 | | |
| | | | គោកឃ្មុំ | 11477 | | |
| | | | ឯកភ្នំ | 11085 | | |
| | | | សំពៅលូន | 10595 | | |
| កំពង់ឆ្នាំង | | | | | | |
| កំពង់ធំ | | | | | បារាយណ៍ | 7315 |
| សៀមរាប | | | សូទ្រនិគម | 14,038 | ក្រឡាញ់ | 5603 |
| | | | ពួក | 13679 | | |
| ឧត្តរមានជ័យ | | | | | | |
| ប៉ៃលិន | | | | | | |
| ពោធិ៍សាត់ | | | | | កណ្ដៀង | 4782 |
| កំពត | | | ទឹកឈូរ | 15029 | កំពង់ត្រាច | 9455 |
| កោះកុង | | | មណ្ឌលសីម៉ា | 12236 | | |
| | | | ស្រែអំបិល | 12676 | | |
| កែប | | | | | | |
| ព្រះសីហនុ | ស្ទឹងហាវ | 20277 | ព្រៃនប់ | 10228 | | |
| កំពង់ស្ពឺ | | | សំរោងទង | 17356 | ឧដុង្គ | 7655 |
| ក្រចេះ | | | | | ឆ្លូង | 6931 |
| មណ្ឌលគិរី | | | | | | |
| ព្រះវិហារ | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| រតនៈគិរី | | | | | | |
| ស្ទឹងត្រែង | | | | | | |

## A.iv. សន្ទានុក្រមនៃពាក្យ

Carbon Footprint

**Climate resilience** can be generally defined as the capacity for a socio-ecological system (the environment and the society which depends on it) to: (1) absorb stresses and maintain function in the face of external stresses imposed upon it by climate change and (2) adapt, reorganize, and evolve into more desirable configurations that improve the sustainability of the system, leaving it better prepared for future climate change impacts

Compact Cities /urban centre

Smart Growth

**Sustainable transport** can be defined as one which (i) allowsthe basic access and development needs of individuals, companies and society to be met safely and in a manner consistent with human and ecosystem health, and promotes equity within and between successive generations. (ii) Is affordable, operates fairly and efficiently, offers a choice of transport mode, and supports a competitive economy, as well as balanced regional development. (iii) Limits emissions and waste (to) the planet's ability to absorb them, uses renewable resources at or below their rates of generation, and uses non-renewable resources at or below the rates of development of renewable substitutes, while minimizing the impact on the use of land and the generation of noise.

# ឧបសម្ព័ន្ធទី ៤
# អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ៥៦ អនក្រ . បក

# អនុក្រឹត្យ
# ស្តីពី
# លិខិតអនុញ្ញាតសាងសង់

* * * *

# រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត ១០៩៤/ ៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត ១០៩៤/ ៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/ រកត/ ០៨៩៧/ ១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០៤ នស ៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។
- តាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌និងវិចិត្រសិល្បៈ រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

## សំរេច

*បុគ្គលដែលទទួលស្គាល់ដោយក្រសួងខ្លាប់ជាសាធារណៈ*

មាត្រា ១ : រាល់រូបវន្តបុគ្គល ឬនីតិបុគ្គល សាធារណៈ ឬឯកជន មានសិទ្ធិសាងសង់អគារលើដីដែលជាកម្មសិទ្ធិរបស់ខ្លួន ហើយសិទ្ធិសាងសង់នេះត្រូវបានទទួលការការពារដោយអនុក្រឹត្យនេះ ។ លិខិតអនុញ្ញាតសាងសង់ដែលត្រូវបានចេញអោយមុនការសាងសង់ ជាគ្រឹះនៃភាពស្របច្បាប់របស់សំណង់ ។ ឯរបៀបសុំលិខិតអនុញ្ញាតសាងសង់មានអធិប្បាយនៅក្នុងវគ្គទី ១ នៃអនុក្រឹត្យនេះ ។

ដើម្បីឱ្យប្រជាពលរដ្ឋ ជាពិសេសប្រជាជនក្រីក្រមានលំនៅដ្ឋានសម្រាប់រស់នៅ រាល់សំណង់តូចតាចធ្វើអំពីឈើ ឬស្លឹក វត្ថុជាតិនានា ពុំទាមទារអោយសុំលិខិតអនុញ្ញាតសាងសង់ឡើយ ស្របតាមបទបញ្ញត្តិដែលមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ។

ដើម្បីធានាសុខមាលភាពនៃសំណង់ និង សុវត្ថិភាពសាធារណៈ ព្រមទាំងដើម្បីការពារដីធ្លីសាធារណៈចាំបាច់ សំរាប់ធានាដល់ដំណើរការរៀបចំទីក្រុង និងតំបន់កសិកម្មបានល្អប្រសើរ បទបញ្ញត្តិទូទៅនៃសំណង់មានកំណត់អំពីសិទ្ធិ និងអំពីករណីយកិច្ចនៃប្រជាពលរដ្ឋ និងស្ថាប័នសាធារណៈ · ក្នុងការសាងសង់សំណង់សាធារណៈ និង សំណង់ឯកជន ។

រាល់ការគោរពនូវបទបញ្ញត្តិដែលមានចែងក្នុងវគ្គទី ២នៃអនុក្រឹត្យនេះ នឹងត្រូវបានទទួលលិខិតអនុញ្ញាតសាងសង់ ។

បទបញ្ញត្តិទាំងនេះ ត្រូវយកមកអនុវត្តក្នុងពេលពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លី និង ប្លង់គោល អនុម័តដោយរាជរដ្ឋាភិបាល ។

បទបញ្ញត្តិនេះអាចនឹងបំពេញបន្ថែម ដើម្បីឱ្យស្របទៅស្ថានភាពមូលដ្ឋាន ដោយស្ថិតក្នុងបទបញ្ញត្តិសំណង់ជាក់ស្តែងក្នុងប្លង់ប្រើប្រាស់ដីធ្លីរបស់ខេត្ត-ក្រុង ។

អនុក្រឹត្យនេះមិនយកទៅអនុវត្ត លើសំណង់មានស្រាប់ដែលមានការអនុញ្ញាត ។ ចំពោះសំណង់មានស្រាប់ដែលគ្មានការអនុញ្ញាត ហើយដែលប៉ះពាល់យ៉ាងខ្លាំងធ្ងន់ដល់ប្រយោជន៍ ឬសោភ័ណភាពសាធារណៈ ការរុះរើត្រូវសំរេចដោយរាជរដ្ឋាភិបាល ឬតំណាងដែលបានទទួលសិទ្ធិប្រទាន តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ច ។

# ជំពូកទី ១

# លិខិតអនុញ្ញាតសាងសង់ និង លិខិតអនុញ្ញាតប្រើ

## ផ្នែក ១

## វាលប្រតិបត្តិនៃលិខិតអនុញ្ញាតសាងសង់

មាត្រា ២: **សំណង់ដែលតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ជាមុន**

រាល់ការសាងសង់ក្នុងទីក្រុង និង ទីប្រជុំជន ត្រូវមានលិខិតអនុញ្ញាតសាងសង់

រាល់សំណង់ថ្មី សុទ្ធតែត្រូវមានលិខិតអនុញ្ញាតសាងសង់ ។

ការសាងសង់ឡើងវិញជាថ្មី ការពង្រីក និង ការសង់បន្ថែមពីលើអគារដែលមានស្រាប់ ក៏សុទ្ធតែតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ដែរ ។

ការប្តូរទ្រង់ទ្រាយអគារដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតសាងសង់ បើការងារនេះកែប្រែ :

- ការប្រើប្រាស់របស់ផ្នែកអគារ
- ទិដ្ឋភាពនៃអគារ ( Aspect des Bâtiments )
- ការធ្វើបង្គន់អនាម័យ និង ការបន្តភ្ជាប់ទៅបំពង់លូ
- ការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់ តភ្ជាប់ទៅបំពង់លូ
- បង្កើនផ្ទៃក្រឡាកម្រាលសំណង់
- កន្លែងទទួលសាធារណៈជន ( Locaux ouverts au public )
- ទំរង់ដី (ចាក់ដីបំពេញ ជីកយកដីចេញ ប្តូរប្រភេទដីស្រែចំការជាដីសាងសង់) ឬ ប៉ះពាល់ខ្លាំងដល់ទិដ្ឋភាពទីជួនណាមួយ ដូចជាលប់បំបាត់បឹង ឬប្រឡាយបង្ហូរទឹក ឬផ្នែកណាមួយនៃប្រព័ន្ធបង្ហូរទឹកចេញ ការកាប់ដើមឈើដែលមានស្រាប់ ។ល។

ការសាងសង់ ឬ ការកែទ្រង់ទ្រាយបនភណ្ឌផ្សេងៗ ដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គីភ័យ (ការដាក់ស៊ីទែនកន្លែងស្តុកប្រេងឥន្ធនៈ រោងជាងដែលមានផលិតផលគ្រឿងឆេះ កន្លែងទទួលសាធារណៈជន) ។ល។ ការប្តូរទ្រង់ទ្រាយអគារឧស្សាហកម្ម ការដាក់ផ្លាកផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍ និងទូរគមនាគមន៍ ផ្លាកស្រូបពន្លឺព្រះអាទិត្យ ក៏ដូចជារាល់គ្រឿងដទៃទៀតដែលបំពាក់ទៅនឹងអគារ ហើយស្ថិតនៅជិតមាត់ផ្លូវ ឬ តាំងចំទិសដែលគេអាចមើលឃើញ សាលាក្រុង និង សាលាខេត្តនឹងធ្វើការណែនាំដោយឡែក ។

មាត្រា ៣: សំណង់ដែលពុំទំណុះក្រោមលិខិតអនុញ្ញាតសាងសង់

- សំណង់ជាលំនៅដ្ឋានប្រជាពលរដ្ឋដែលស្ថិតនៅទីជនបទ ឬតំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និង ឆ្ងាយពីតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភ័ណ្ឌជាតិ តំបន់រក្សាទុកការពារដោយពុំគិតពីទំហំ ឬ សម្ភារៈសំណង់ប្រើប្រាស់ឡើយ ។

- ការជួសជុល និងថែរក្សាទាំងឡាយដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬទិដ្ឋភាពសំណង់ លើលែងតែការជួសជុលនោះអាចបណ្តាលអោយប៉ះពាល់ដល់អ្នកជិតខាង ។

- បណ្តាសំណង់ដូចខាងក្រោមនេះ ដោយគ្រាន់តែជូនដំណឹងអំពីគំរោងសាងសង់ទៅអាជ្ញាធរមូលដ្ឋាន ដូចតទៅ :

- ទីសក្ការៈបូជា

- សាលាសំណាក់សាធារណៈ

- បណ្តាការស្ថាបនារបស់រដ្ឋសំរាប់សេវាសាធារណៈ ដែលរដ្ឋជាម្ចាស់កិច្ចការ

## ជំពូក ២

## សមត្ថកិច្ច ដែលចេញលិខិតអនុញ្ញាតសាងសង់

មាត្រា ៤ : សមត្ថកិច្ចរបស់សាលាខេត្ត និង សាលាក្រុង

៤.១ ខេត្ត-ក្រុង មានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាងសង់ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ។

៤.២ លិខិតអនុញ្ញាតសាងសង់ ត្រូវបានចុះហត្ថលេខាដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុង ឬ ដោយអភិបាលខេត្ត-ក្រុង ឬ អភិបាលរងដែលបានទទួលសិទ្ធិប្រទាន ។ រាល់ការបដិសេធមិនផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរ នូវមូលហេតុច្បាស់លាស់ ។

មាត្រា ៥ : សមត្ថកិច្ចរបស់រាជរដ្ឋាភិបាល

៥.១ មានលិខិតអនុញ្ញាតសាងសង់មួយចំនួន ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលមានសមត្ថកិច្ចសំរេចផ្តល់ លិខិតអនុញ្ញាតសាងសង់ ចំពោះប្រភេទសំណង់ដូចតទៅ :

- បណ្តាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម និង ឧស្សាហកម្ម ដែលមានផ្ទៃក្រឡាកម្រាលលើសពី ៣.០០០ ម៉ែត្រទ្វេគុណ ។

- រាល់សណ្ឋាគារ ត្រូវចាត់ទុកជាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម ។

- បណ្តាអគារសំរាប់ការបង្កបង្កើនផលកសិកម្ម សំរាប់ធ្វើអាជីវកម្មពី ៥០០ហិចតាឡើងទៅ ។

- បណ្តាអាកាសយានដ្ឋាន កំពង់ផែ ស្ថានីយអយស្ម័យយាន និង ស្ថានីយរថយន្ត ។

- បណ្តាសំណង់សាធារណៈ និង ឯកជន ដែលមានផ្ទៃក្រឡាកម្រាលលើសពី ៣.០០០

ម៉ែត្រទ្វេគុណ និងផ្នែកពង្រីកបន្ថែមលើផលិតទាំងអគារមានស្រាប់ ដែលលើសពី ៣.០០០ ម៉ែត្រទ្វេគុណ ( វប្បធម៌ អប់រំកីឡា រដ្ឋបាល ទេសចរណ៍ សុខាភិបាល ថាមពលទឹក...) ។

- បណ្តាសំណង់សំខាន់ ៗ ក្នុងទីដ្ឋានការពារ និងក្នុងក្របខ័ណ្ឌបរិស្ថាន ទេសភាព បេតិកភ័ណ្ឌ ប្រវត្តិសាស្ត្រ បូរាណវត្ថុ និង វប្បធម៌ ។

- ការកែប្រែបណ្តាអគារ ជាផលប្រយោជន៍បេតិកភ័ណ្ឌដែលបានកំណត់ទុក ។

- បណ្តាសំណង់លើទីដីក្នុងភាពមើលឃើញទៅវិញទៅមក ជាមួយប្រាង្គប្រាសាទប្រវត្តិសាស្ត្រ។

- បណ្តាសំណង់ និង ការ សំរាប់ការពារ និង អគារយោធា ។

៥.២ ក្នុងករណីនេះ លិខិតអនុញ្ញាតសាងសង់ ត្រូវចុះហត្ថលេខា ដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

**មាត្រា ៦ : គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់របស់សាលាខេត្ត ឬ សាលាក្រុង**

៦.១ សមត្ថកិច្ច

អនុលោមតាមមាត្រា ១៨ នៃច្បាប់រៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់មួយ ត្រូវបានបង្កើតឡើងក្នុងពេលពុំទាន់មានប្លង់ប្រើប្រាស់ដី-ធ្លី និង សំណង់ ។ គណៈកម្មការនេះ ត្រូវដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬ អភិបាលខេត្ត ។

គណៈកម្មការនេះពិនិត្យរាល់សំណុំលិខិតសុំអនុញ្ញាតសាងសង់ ។

ចំពោះលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ក្រោយពីគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ ពិនិត្យសំណុំលិខិតហើយ ប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុង និង អភិបាលខេត្ត-ក្រុង បញ្ជូនរបាយការណ៍ និង យោបល់ទៅគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ ដើម្បីសំរេច ។

៦.២ សមាសភាពរបស់គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ :

គណៈកម្មការមានសមាសភាពដូចតទៅ :

- ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬ អភិបាលខេត្ត ជាប្រធាន
- មន្ទីរ សុរិយោដី សមាជិក
- មន្ទីរ រៀបចំក្រុង និង សំណង់ ឬ ការិយាល័យសំណង់ ក្នុងករណីដែលមាន សមាជិក
- មន្ទីរ សាធារណការ សមាជិក

- មន្ទីរ បរិស្ថាន សមាជិក
- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- តំណាងស្ថាប័នពាក់ព័ន្ធទៅលើគំរោងសំណង់នោះ សមាជិក
- ការិយាល័យ (មូលដ្ឋាន) កិច្ចការនគរោបនីយកម្ម សមាជិក

គណៈកម្មការមានសិទ្ធិកោះអញ្ជើញដើម្បីសាកសួរ ឬស្តាប់រាល់បុគ្គលដែលបានដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និង ម្ចាស់កម្មសិទ្ធិ បើម្ចាស់កម្មសិទ្ធិនោះពុំមែនជាអ្នកដាក់ពាក្យសុំ នៅពេលដែលសំណុំលិខិតអនុញ្ញាតសាងសង់នោះ បានចុះបញ្ជីជាផ្លូវការរួចហើយ ។

## ជំពូក ៣

## ការពិនិត្យមើលលើការចេញលិខិតអនុញ្ញាតសាងសង់

មាត្រា ៧ : គ្មានលិខិតអនុញ្ញាតសាងសង់ណាមួយ អាចចេញអោយបានទេ បើលិខិតអនុញ្ញាតសាងសង់នោះពុំគោរពតាមប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី (ក្នុងករណីដែលមានប្លង់ទាំងពីរនេះ) ឬ ប្រសិនបើពុំមានប្លង់ទាំងពីរនេះទេ នោះការអនុញ្ញាត ត្រូវអនុវត្តតាមបទបញ្ញាទូទៅស្តីពីការប្រើប្រាស់ដីធ្លីវិញ ។

ជនទាំងឡាយដូចជា នីតិបុគ្គល សាធារណៈ ឬ ឯកជន ត្រូវគោរពវិធានការនេះជាចាំបាច់ ។

មាត្រា ៨ : សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ចំពោះក្រុងភ្នំពេញ និង ទីក្រុងដទៃទៀត ត្រូវដាក់នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុង និង សំណង់) ហើយ ចំពោះខេត្ត ត្រូវដាក់នៅសាលាស្រុក ឬ សាលាខេត្ត (មន្ទីរសំណង់) ។ បង្កាន់ដៃទទួលពាក្យសុំលិខិតអនុញ្ញាតសាងសង់មួយ ត្រូវបានចេញអោយអ្នកសុំ កាលណាសំណុំលិខិតពាក្យសុំមានគ្រប់គ្រាន់ហើយ ។

មាត្រា ៩ : **បណ្តាឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់**

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើលើគំរូលិខិតជាផ្លូវការ ហើយត្រូវមានភ្ជាប់សំណុំលិខិត ដែលមានយ៉ាងតិចបំផុតនូវបណ្តាប្លង់ដូចបញ្ជាក់ខាងក្រោមនេះ ជា១០ច្បាប់ បត់ទំហំ (២១×២៩,៧ស.ម) :

៩.១ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ អចលនវត្ថុ ឬលិខិតកាន់កាប់ដីជាបណ្តោះអាសន្ន ។

៩.២ សលាកប័ត្រដីឡូតិ៍ :

ប្លង់ដីនេះធ្វើឡើងដោយភ្នាក់ងារមន្ទីរសុរិយោដី ឬ ដោយវេខាគណិតឯកជន ។ ប្លង់នេះ ត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយអ្នកធ្វើ និង អនុម័តដោយមន្ទីរសុរិយោដី ។

នៅលើប្លង់នេះមានបញ្ជាក់អំពី :

- ទីតាំងនៃដីឡូតិ៍ដែលជាកម្មវត្ថុនៃពាក្យសុំ ទីតាំងនៃដីឡូតិ៍ដែលនៅជាប់គ្នា ផ្លូវចូលទៅដីឡូតិ៍នោះ ហើយនិងលក្ខណៈរបស់ផ្លូវនោះ (សាធារណៈ ឬ ឯកជន ឈ្មោះម្ចាស់កម្មសិទ្ធិ) ។
- ឈ្មោះ ឬ លេខ ផ្លូវធំ និង ផ្លូវតូច

- ផ្ទៃក្រឡាដីឡូតិ៍
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូតិ៍ ( ទីតាំង និង កំពស់ )
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូតិ៍ជាប់គ្នា ផ្ទៃបាត និងកំពស់របស់វា
- មាត្រដ្ឋានប្លង់រង្វាស់ជ្រុង និងមុំនីមួយៗ ការកំណត់ទិស
- ចំណុចនីវេលស៊ំរាប់ជាគោលសំគាល់កំពស់ ដែលបោះនៅលើដីឡូតិ៍
- បន្ទាត់ជួរតម្រង់ផ្លូវសាធារណៈ

✓៩.៣ ប្លង់ទីតាំងអគារក្នុងដីឡូតិ៍ :

មាត្រដ្ឋាន ១:២០០ (ឬ ១:៥០០ ក្រោយទទួលការយល់ព្រមពីបណ្តាមន្ទីរទទួលបន្ទុកដីឡូតិ៍ធំ ៗ )។

នៅលើប្លង់នេះមានបញ្ជាក់អំពី :

- ការបោះទីតាំងនៃសំណង់ក្នុងដីឡូតិ៍ដែលជាកម្មវត្ថុនៃពាក្យសុំ ដោយមានការបញ្ជាក់អំពីចម្ងាយ រវាងអគារមួយឬច្រើន និង ព្រំប្រទល់ដីឡូតិ៍ ហើយនិងចំងាយទៅបណ្តាអគារនៅជិតខាងដែលមានស្រាប់ ។

- រាល់ការរៀបចំផ្នែកផ្សេងៗ នៃដីទំនេរ ដោយបញ្ជាក់ប្រភេទដីនិងដំណាំមានស្រាប់ និង ទៅអនាគត បណ្តាកន្លែងចតរថយន្ត និងរបង (កំពស់ និង ទីតាំង) ។

- បំពង់លូក្រៅអគារ (រូបធាតុ វិម្ឋមាត្រ ចំណោត កំរិតកំពស់ រណ្តៅពិនិត្យ) រហូតដល់កន្លែងតភ្ជាប់ទៅបណ្តាញសាធារណៈ សំរាប់បញ្ចេញទឹកស្អុយ និងសំរាប់ទឹកស្អាត អាងបង្គន់អនាម័យ អណ្តូង។

- ចំណុចនីវេលនៃកំពស់ដីឡូតិ៍ ក្រោយការងាររៀបចំហើយ ។

✓៩.៤ ប្លង់អគារគ្រប់ជាន់ : មាត្រដ្ឋាន ១ : ១០០

នៅលើប្លង់នេះមានបញ្ជាក់ពី :

- គោលដៅប្រើប្រាស់រាល់បន្ទប់ និង ផ្ទៃក្រឡារបស់វា
- បណ្តាបន្ទប់ទឹកអនាម័យ និង កន្លែងដាក់បំពង់លូ
- ចំពោះការរៀបចំទីតាំងឧស្សាហកម្ម : របៀបរៀបចំទីតាំងគ្រឿងយន្ត

✓៩.៥ ប្លង់ផ្នែកបណ្តាញក្រោមដីនានា និង អាងបង្គន់អនាម័យ មាត្រដ្ឋាន ១ : ១០០

✓៩.៦ ប្លង់មុខភាពនៃអគារ : (Façades) មាត្រដ្ឋាន ១ : ១០០

នៅលើបណ្តាប្លង់មុខភាពមានបង្ហាញអំពី :

- កំរិតកំពស់កំរាលនីមួយៗ កំរិតកំពស់ដីនៅជើងអគារ ដោយបញ្ជាក់កំរិតកំពស់ដីធម្មជាតិ ដីចាក់បំពេញ ឬ ដីចូកចេញ ។

- កំរិតកំពស់ដំបូល និង ព្រំដំបូល ឬ កំរិតកំពស់នៅពេលសង់ហើយនៃដំបូលតែរ៉ាស់ និង ក្បាំងក្បាលជញ្ជាំង ។

- កំរិតកំពស់សង់ហើយនៃទ្រើងផ្សារ

- រូបធាតុសំរាប់មុខភាព (Matériaux de façade)

៩.៧ ប្លង់ពុះពីរយ៉ាងតិច : មាត្រដ្ឋាន ១ : ១០០

នៅលើប្លង់ពុះមានការបង្ហាញដូចប្លង់មុខភាព ពុះមួយបង្ហាញអាងបង្គន់អនាម័យ ។

៩.៨ តារាងផ្ទៃក្រឡាមួយសំរាប់ជាន់នីមួយៗ

៩.៩ សលាកបំត្រគណនាផ្ទៃបាតផ្ទាល់ដី និង សន្ទស្សន៍នៃការប្រើប្រាស់ ។

ចំពោះបណ្តាការផ្លាស់ប្តូរទ្រង់ទ្រាយ ពង្រីកទំហំ ពង្រីកតឡើងលើ ប្លង់ត្រូវបង្ហាញរបៀបខុសពីគ្នាចំពោះផ្ទៃកមានពីមុន ការរុះរើ និង សភាពគ្រោងថ្មី ។

សាលាក្រុង និង សាលាខេត្តនីមួយៗ ត្រូវចេញសារាចរបញ្ជាក់អំពីឯកសារចាំបាច់ និង ឯកសារបន្ថែមពាក់ព័ន្ធនឹងសំណុំលិខិតអនុញ្ញាតសាងសង់ ។

អាចអោយអ្នកសុំសាងសង់ផ្តល់បណ្តាលិខិតស្នាមបន្ថែម ដោយមូលហេតុផ្នែកធារាសាស្ត្រ ផ្នែកការពារប្រឆាំងធាតុរំខានគ្រប់ប្រភេទ ផ្នែកសណ្តាប់ធ្នាប់សាធារណៈ ការពារបេតិកភ័ណ្ឌ និង ទេសភាព ។

៩.១០ ក្រោយពីបានទទួលលិខិតអនុញ្ញាតសាងសង់ហើយ ត្រូវមានប្លង់លំអិតគ្រឿងផ្គុំសំណង់ ដែលត្រូវពិនិត្យដោយក្រសួងសាធារណការ និង ដឹកជញ្ជូនមុនបើកការដ្ឋានសាងសង់ ។

**មាត្រា ១០ : ភាសាផ្លូវការ**

សំណុំលិខិតពាក្យសុំលិខិតអនុញ្ញាតសាងសង់ទាំងអស់ ត្រូវជាភាសាខ្មែរ ។ អត្ថបទជាភាសាអង់គ្លេស ឬ បារាំងអាចផ្តល់ភ្ជាប់ជាមួយនឹងលិខិតនេះ ។

**មាត្រា ១១ : ហត្ថលេខាលើពាក្យសុំ**

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និងបណ្តាប្លង់ ត្រូវចុះហត្ថលេខាដោយម្ចាស់ដី និងអ្នកធ្វើគំរោង ។

កាលណាអ្នកសុំពុំមែនជាម្ចាស់កម្មសិទ្ធិ អ្នកសុំដែលបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ក៏ត្រូវចុះហត្ថលេខាលើសំណុំលិខិតពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ដែរ ។

អ្នកធ្វើគំរោងត្រូវតែជាស្ថាបត្យករខ្មែរ ឬបុគ្គលមានការរួមចំណែកជាមួយស្ថាបត្យករខ្មែរ ហើយដែលត្រូវបានទទួលស្គាល់ពីរាជរដ្ឋាភិបាល ស្នើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច ឬដោយគណៈស្ថាបត្យករ បន្ទាប់ពីគណៈស្ថាបត្យករខ្មែរនេះ ត្រូវបានបង្កើតឡើង ។

ក្នុងករណីដែលសំណង់មានទំហំលើសពី ៥០០ ម៉ែត្រទ្វេគុណ គំរោងអាចធ្វើបានដោយស្ថាបត្យករតែប៉ុណ្ណោះ ។

**មាត្រា ១២ : ការផ្សព្វផ្សាយលិខិតអនុញ្ញាតសាងសង់ និង អង្កេតសាធារណៈ**

អាជ្ញាធរមានសមត្ថកិច្ចផ្សព្វផ្សាយដំណឹងដល់សាធារណៈជន អំពីការដាក់ពាក្យសុំដោយបិទប្រកាសផ្សាយនៅសាលាខ័ណ្ឌ ស្រុក ខេត្ត និងនៅកន្លែង សាងសង់ គម្រោង ។

កាលបរិច្ឆេទជាផ្លូវការនៃការដាក់ពាក្យស្នើសុំ ត្រូវចារក្នុងសំណុំលិខិត ហើយជូនដំណឹងដល់អ្នកសុំ ។

ម្យ៉ាងទៀតចំពោះអគារ និង បណ្តាការ្យធំៗ ឬ ដែលមានប្រភេទអាចធ្វើអោយរំខានដល់សុវត្ថិភាព សុខមាលភាពសាធារណៈនោះ ត្រូវផ្សព្វផ្សាយដល់សាធារណៈជន ពីការដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដោយវិធីណាមួយផ្សេងទៀត ដែលគេយល់ឃើញថាមានប្រសិទ្ធិភាពជាង ដោយផ្អែកលើមធ្យោបាយផ្សាយពត៌មាន នៅតាមមូលដ្ឋាន ។

ប្រកាសមួយរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគររូបនីយកម្ម និង សំណង់ កំណត់បញ្ជីអគារ និង ការ្យដែលពាក់ព័ន្ធ ។

រាល់បុគ្គលពាក់ព័ន្ធអាចសាកសួរសុំមើលសំណុំលិខិត នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុង និង សំណង់ ) ចំពោះក្រុងភ្នំពេញ និងសាលាស្រុក ឬសាលាខេត្ត (មន្ទីរសំណង់) ចំពោះខេត្ត ក្នុងរយៈពេល ២៥ ថ្ងៃ និងអាចធ្វើការតវ៉ា ឬ ទាមទារទៅអាជ្ញាធរមានសមត្ថកិច្ច ។

បណ្តឹងតវ៉ាទាំងនេះត្រូវដាក់បញ្ចូលទៅក្នុងសំណុំលិខិតពាក្យសុំ ។

អាជ្ញាធរមូលដ្ឋានពិនិត្យមើលការជំទាស់ ដែលទទួលបានក្នុងពេលអង្កេត និង ធ្វើរបាយការណ៍មួយ ជូនទៅសាលាខេត្ត សាលាក្រុង ក្នុងរយៈពេល ៥ ថ្ងៃ ។ សាលាខេត្ត សាលាក្រុង ឬ គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) គណៈកម្មការនេះត្រូវសំរេចអំពីសុពលភាពនៃបណ្តឹងតវ៉ា ។

**មាត្រា ១៣ : អង្កេតនៅតាមបណ្តាមន្ទីរមានសមត្ថកិច្ច**

គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) ឬ ក្នុងករណីផ្សេងទៀត មន្ទីររៀបចំក្រុង និង សំណង់ នៃបណ្តាខេត្ត-ក្រុង ប្រមូលយោបល់ពីមន្ទីរមានសមត្ថកិច្ច ហើយធ្វើសំយោគមួយ ។

យោបល់ និង សំយោគទាំងនោះជាលាយល័ក្ខអក្សរ ត្រូវដាក់ជូនអភិបាលខេត្ត ឬប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងពិនិត្យ និង សំរេច ។

បណ្តាមន្ទីរដែលត្រូវចូលរួមពិភាក្សាជាចាំបាច់ ក្នុងពេលពុំទាន់មានគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់រួមមាន :-

- មន្ទីរសុរិយោដី
- មន្ទីររៀបចំក្រុង និង សំណង់
- មន្ទីរសាធារណៈការ
- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ
- មន្ទីរហិរញ្ញវត្ថុ
- មន្ទីរបរិស្ថាន
- និងតំណាងស្ថាប័នពាក់ព័ន្ធ

**មាត្រា ១៤ : រយៈពេលពិនិត្យសំណុំលិខិត**

រយៈពេលសំរាប់ពិនិត្យសំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ត្រូវបានកំណត់ត្រឹម ៤៥ ថ្ងៃធ្វើការ ។ រយៈពេលនេះគិតចាប់ពីថ្ងៃ ដែលរាល់លិខិតស្នាមភ្ជាប់ជាមួយនឹងពាក្យសុំលិខិត អនុញ្ញាតសាងសង់បានបំពេញ

សព្វគ្រប់ ។ នៅចុងរយៈពេលកំណត់នេះ អ្នកស្នើសុំត្រូវបានទទួលដំណឹងអំពីសេចក្តីសម្រេច ជាលាយលក្ខណ៍អក្សរ ស្តីពីការអនុញ្ញាត ឬ ការមិនអនុញ្ញាត ឬមួយការអនុញ្ញាតដែរ តែស្នើសុំអោយកែសំរួលបន្ថែម ។

ក្នុងករណីគ្មានចម្លើយណាមួយពីអាជ្ញាធរ នោះត្រូវចាត់ទុកបានចម្លើយជាវិជ្ជមាន ។

កាលបរិច្ឆេទថ្ងៃទី ០១ នេះ ត្រូវបានកំណត់ដោយគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) ឬ ដោយមន្ទីររៀបចំក្រុង និង សំណង់ក្នុងករណីផ្សេងទៀត ។

បើអាជ្ញាធរមានសមត្ថកិច្ច បានស្នើដល់អ្នកសុំអោយធ្វើការកែប្រែតម្រូវនោះ រយៈពេល ៤៥ ថ្ងៃធ្វើការថ្មីមួយទៀត នឹងត្រូវគិតចាប់ពីថ្ងៃដាក់ពាក្យសុំមានការកែតម្រូវជាផ្លូវការ ។

ការបដិសេធផ្តល់លិខិតអនុញ្ញាតសាងសង់ និងការស្នើសុំអោយកែសំរួល ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកសុំ ដោយអាជ្ញាធរមានសមត្ថកិច្ច ។

## ជំពូក ៤

## ទម្រង់បែបបទបន្ទាប់ពីបានលិខិតអនុញ្ញាតសាងសង់

**មាត្រា ១៥ : ការប្រគល់លិខិតអនុញ្ញាតសាងសង់**

លិខិតអនុញ្ញាតសាងសង់ ត្រូវប្រគល់អោយអ្នកសុំដោយអាជ្ញាធរដែលបានអនុញ្ញាតអោយ ។

លិខិតអនុញ្ញាតសាងសង់មួយច្បាប់ អមដោយសំណុំលិខិតគ្រប់សព្វ (ប្លង់ លិខិតស្នាមជាឧបសម្ព័ន្ធ យោបល់...) ត្រូវរក្សាទុកជាឯកសារដាច់ខាត ដោយសាលាខេត្ត ឬ សាលាក្រុង ។

ក្នុងករណីដែលលិខិតអនុញ្ញាតសាងសង់ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល នោះគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ ត្រូវរក្សាទុកជាឯកសារ ១ ច្បាប់ផងដែរ ។

**មាត្រា ១៦ : លិខិតអនុញ្ញាតសាងសង់ផុតកំណត់កាល និង ការងាររបោះបង់ចោល**

១៦.១ លិខិតអនុញ្ញាតសាងសង់អស់សុពលភាព បើការងារពុំដំណើរការក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាចេញលិខិតអនុញ្ញាតសាងសង់ ។

លិខិតនេះ អាចអនុញ្ញាតពន្យារពេលបានមួយដង ។

សំណង់ដែលត្រូវចាត់ទុកថាបានចាប់ផ្តើមសាងសង់ កាលណាជើងគ្រឹះត្រូវបានធ្វើហើយ ។

ចំពោះការសាងសង់បន្ថែមជាន់ ត្រូវចាត់ទុកថាបានចាប់ផ្តើម កាលណាសសរទីមួយត្រូវបានធ្វើហើយ។

១៦.២ កាលណាការងារសាងសង់ ត្រូវបានផ្អាកលើសពីមួយឆ្នាំ អាជ្ញាធរក្រុង ឬ ខេត្ត អាចបង្គាប់អោយធ្វើបញ្ចប់ ឬបង្គាប់អោយរុះរើសំណង់ដែលបានចាប់ផ្តើម និងអោយរៀបចំទីកន្លែងអោយបានត្រឹមត្រូវដូចដើមវិញ ក្នុងរយៈពេលមួយដែលបានកំណត់ និងដោយសោហ៊ុយរបស់ម្ចាស់លិខិតអនុញ្ញាតសាងសង់ ។

**មាត្រា ១៧ : ការចាប់ដំណើរការការដ្ឋាន**

ការដ្ឋាន ពុំត្រូវចាប់ដំណើរការមុនពេលបានទទួលលិខិតអនុញ្ញាតសាងសង់ និងមុនពេលទទួលបានការអនុម័ត លើប្លង់លំអិតគ្រឿងផ្គុំសំណង់ឡើយ ។

រាល់សហគ្រិនទទួលបន្ទុកស្ថាបនាសំណង់ ត្រូវបញ្ជាក់អោយដឹងច្បាស់ថា លិខិតអនុញ្ញាតសាងសង់ត្រូវបានអនុញ្ញាតរួចហើយ ពីព្រោះជាប់ទទួលខុសត្រូវរួមជាមួយម្ចាស់សំណង់ ។

អ្នកកាន់លិខិតអនុញ្ញាតសាងសង់ ត្រូវតំកល់ទុកនៅការដ្ឋាន នូវសេចក្តីចម្លងឯកសាររដ្ឋបាលពីការចេញលិខិតអនុញ្ញាតសាងសង់មួយច្បាប់ សំរាប់មន្ទីរ ក្រុង ឬ ខេត្ត ត្រួតពិនិត្យ ។

ប្លង់អនុវត្តការសាងសង់ និង ប្លង់លំអិតសំណង់មួយច្បាប់ ត្រូវតំកល់ទុកជាប្រចាំនៅការដ្ឋាន សំរាប់មន្ទីរ ក្រុង ឬ ខេត្ត ត្រួតពិនិត្យ ។

**មាត្រា ១៨ : ដំណើរការទៅមុខនៃការងារ**

១៨.១ ក្រោយពីបានទទួលលិខិតអនុញ្ញាតសាងសង់ និង ប្លង់លំអិតគ្រឿងផ្គុំសំណង់ ហើយម្ចាស់សំណង់ត្រូវជូនដំណឹងទៅសាលាស្រុក-ខណ្ឌ និង ចុះទិដ្ឋាការនៅមន្ទីរមានសមត្ថកិច្ច ។

មុនចាប់ដំណើរការការដ្ឋាន ម្ចាស់សំណង់ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋាន ពីមន្ទីររៀបចំក្រុង និងសំណង់ ឬការិយាល័យខេត្ត-ក្រុង ។

ស្ថាប័នសមត្ថកិច្ចបច្ចេកទេស ត្រូវតាមដានការអនុវត្តជាជំហាន ៗដូចតទៅ :

- ក្រោយការបោះបង្គោលកំណត់ទីតាំងសំណង់
- ក្រោយការងារផ្នែកគ្រឹះ និងមុនការធ្វើកម្រាលក្រោមនៃជាន់ផ្ទាល់ដី
- នៅទីបញ្ចប់នៃការងារធំៗ (គ្រឹះ-សសរ-ជញ្ជាំង-កម្រាល...) ផ្នែកសំខាន់ៗ នៃសំណង់
- នៅពេលតភ្ជាប់ទៅបណ្តាញលូទឹកស្អុយ ទឹកស្អាត និង បណ្តាញអគ្គីសនី

១៨.២ រាល់ការផ្លាស់ប្តូរម្ចាស់សំណង់ ក្នុងពេលកំពុងដំណើរការសាងសង់ ត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ១៩ : ការរៀបចំការដ្ឋានសំណង់**

ការដាក់គរសំភារៈសំណង់លើផ្លូវសាធារណៈត្រូវហាមឃាត់ ៖

- កាលណាសំណង់ ត្រូវការកន្លែងតាំងការដ្ឋានលយទៅលើផ្លូវសាធារណៈ កន្លែងលយនោះត្រូវកំណត់ត្រឹម ២ម ទៅលើចិញ្ចើមផ្លូវ ។ កន្លែងនោះត្រូវធ្វើរបងហ៊ុំព័ទ្ធ ក្នុងរយៈពេលដំណើការរបស់ការដ្ឋាន ។
- រាល់កន្លែងតាំងការដ្ឋាន ត្រូវរុះរើចេញក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពេលចប់ការដ្ឋាន។
- គំនរសំភារៈ កាកសំណល់បានមកពីការរុះរើ ឬពីការសាងសង់ ឬការជួសជុលត្រូវយកចេញក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពេលចប់ការងារ ។

- ក្នុងករណីពុំបានរើយកសំភារៈកាកសំណល់ចេញពីកន្លែងតាំងការដ្ឋានទេ សាលាខ័ណ្ឌ ឬ សាលាស្រុកមានភារកិច្ច ចាត់ចែងរើកជញ្ជូនចេញដោយស្វ័យប្រវត្តិ ។ ចំណាយជាបន្ទុករបស់ម្ចាស់សំណង់ ។

**មាត្រា ២០ : ការត្រួតពិនិត្យ និង ការបញ្ចប់ការងារ**

អាជ្ញាធរក្រុង ឬ ខេត្ត អាចចូលមើលនិងត្រួតពិនិត្យការដ្ឋានគ្រប់ពេលវេលា ហើយនិងពិនិត្យប្លង់ដែលបានអនុម័តរួច ។ បើពិនិត្យឃើញភាពមិនត្រឹមត្រូវ អាជ្ញាធរនោះជំរាបជាលាយល័ក្ខណ៍អក្សរទៅម្ចាស់សំណង់ អោយកែតម្រូវក្នុងរយៈពេលកំណត់មួយ ។

ក្នុងករណីពុំបានអនុវត្ត ឬ បានអនុវត្តពុំត្រឹមត្រូវតាមបញ្ជា ការផ្អាកការងារត្រូវចេញបញ្ជាជាបន្ទាន់ ដោយអាជ្ញាធរ ក្រុង ឬ ខេត្ត ។

សាលាក្រុង ឬ សាលាខេត្ត អាចប្តឹងទៅតុលាការមានសមត្ថកិច្ចអោយចេញដីកាកិច្ចការប្រញាប់ អោយផ្អាកការសាងសង់ ឬ ផ្លាស់ប្តូរទ្រង់ទ្រាយសំណង់ដែលពុំត្រឹមត្រូវ ឬគ្មានច្បាប់នោះ ។ ចំណាយជាបន្ទុករបស់ម្ចាស់សំណង់ ។

អនុលោមទៅតាមសភាពធ្ងន់ធ្ងរនៃការខុសឆ្គង បណ្តាសំភារៈនិងឧបសំភារៈរបស់ការដ្ឋាន អាចត្រូវរឹបអូសតាមបង្គាប់តុលាការ ។

**មាត្រា ២១ : វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ**

អ្នកសុំលិខិតអនុញ្ញាតសាងសង់ ត្រូវប្រកាសប្រាប់អំពីការចប់ការងារ ដល់សាលាខ័ណ្ឌ ឬសាលាស្រុក។

ពេលបញ្ចប់ការដ្ឋាន សាលាខ័ណ្ឌ ឬសាលាស្រុកជាមួយនិងការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីរ រៀបចំក្រុង និង សំណង់) អាចត្រួតពិនិត្យភាពត្រឹមត្រូវស្របគ្នា រវាងសំណង់ដែលធ្វើរួចហើយ និង លិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ត្រូវចាត់ទុកថាពុំត្រឹមត្រូវ បើផ្ទៃបាតសំណង់ ឬ ផ្ទៃក្រឡាកម្រាលបានសាងសង់ លើសពីលិខិតអនុញ្ញាត។

អាចចាត់ទុកថាពុំត្រឹមត្រូវ បើរូបភាពនៃអគារមានភាពងាយឃើញខុសគ្នា ពីលិខិតអនុញ្ញាតសាងសង់ ដែលបានចេញអោយ ។

ក្នុងករណីពុំត្រឹមត្រូវទេ អាជ្ញាធរក្រុង ឬ ខេត្តអាចបង្ខំម្ចាស់សំណង់ អោយកែតម្រូវអគារអោយបាន ត្រឹមត្រូវ ស្របគ្នានឹងលិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ក្នុងករណីមិនគោរពតាមទេ សាលាក្រុង ឬសាលាខេត្ត ត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ច អោយចេញសាលក្រម ឬ សាលដីកា ។

វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវមួយ ដែលចេញអោយដោយអាជ្ញាធរក្រុង ឬ ខេត្ត ត្រូវតែមានជាចាំបាច់ខានពុំបាន ចំពោះបណ្តាអគារសំរាប់ទទួលសាធារណៈជន សណ្ឋាគារ ការិយាល័យ ក៏ដូចជាចំពោះបណ្តាកន្លែងធ្វើការរបស់អ្នកមានបៀវត្ស ។ វិញ្ញាបនប័ត្រនេះ ត្រូវបានទទួលមុនការបើកប្រើប្រាស់កន្លែងធ្វើការនោះ ។

វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវមួយ ចេញអោយដោយអាជ្ញាធរក្រុង ឬ ខេត្ត ត្រូវតែមានជាចាំបាច់ខានពុំបាន មុនពេលបើកអោយប្រើប្រាស់ ចំពោះបណ្តាអគារដែលសាងសង់នៅក្នុងរមណីយដ្ឋាន និងទេសភាពធម្មជាតិ ឬ ក្រុង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ បុរាណសាស្ត្រ បេតិកភ័ណ្ឌ ឬនៅកន្លែងមើលឃើញទៅវិញទៅមក ជាមួយប្រាង្គប្រាសាទប្រវត្តិសាស្ត្រណាមួយ ។

## ជំពូក ៥

## លិខិតអនុញ្ញាតរុះរើ

<u>មាត្រា ២២</u> : រាល់ម្ចាស់កម្មសិទ្ធិ ឬ អ្នកទទួលសិទ្ធិតំណាងក្នុងអាណត្តិ ដែលមានបំណងរុះរើអគារណាមួយដែលមានស្រាប់ ក្រៅពីសំណង់បណ្តោះអាសន្នមិនថិតថេរ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតរុះរើ នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ ។

សំណុំពាក្យសុំលិខិតអនុញ្ញាតរុះរើត្រូវមាន :

ប្លង់ដីឡូតិ៍ និង ប្លង់អគារ រូបថតអគារ ឬឯកសារផ្សេង ។ ទៀតដែលចាំបាច់ ។

ចំពោះរាល់អគារដែលមានចុះក្នុងបញ្ជីបេតិកភ័ណ្ឌ ពាក្យសុំអនុញ្ញាតរុះរើ ត្រូវឆ្លងតាមគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ ហើយត្រូវបានអនុញ្ញាតដោយអភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ។

លិខិតអនុញ្ញាតរុះរើ ត្រូវផ្សព្វផ្សាយភ្លាមជាសាធារណៈ ដោយការបិតប្រកាសនៅកន្លែងដែលអាចមើលឃើញពីផ្លូវសាធារណៈ នៅកន្លែងគ្រោងធ្វើការរុះរើ ។ ការងាររុះរើ ពុំអាចចាប់ផ្តើមក្នុងរយៈពេលតិចជាង ១៥ ថ្ងៃ បន្ទាប់ពីការចេញលិខិតអនុញ្ញាតឡើយ ។

លិខិតអនុញ្ញាតរុះរើ ត្រូវចាត់ទុកយល់ព្រម បើពុំមានចំឡើយណាមួយក្រោយពីថ្ងៃដាក់ពាក្យសុំ ៣ខែ ។

រាល់ចំទាស់ ត្រូវផ្តល់ដំណឹងទៅអ្នកសុំជាលាយលក្ខណ៍អក្សរ ។

<u>មាត្រា ២៣</u> : បណ្តាបទបញ្ញត្តិពីសមត្ថកិច្ច និង ការពិនិត្យពាក្យសុំដែលអនុវត្តចំពោះលិខិតអនុញ្ញាតសាងសង់ត្រូវអនុវត្តបានដូចគ្នាចំពោះពាក្យសុំលិខិតអនុញ្ញាតរុះរើ ។

## ជំពូក ៦

## បទល្មើស និង បណ្តឹងតវ៉ា

<u>មាត្រា ២៤</u> : **ករណីបទល្មើស**

រាល់សំណង់ ដែលបានចាប់ផ្តើមដំណើរមុនចេញលិខិតអនុញ្ញាតសាងសង់ ដោយអាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់ទុកជាល្មើសច្បាប់ ។ ការដ្ឋានត្រូវបញ្ឈប់ជាបន្ទាន់ ។

បណ្តាបុគ្គល ដែលបានប្រព្រឹត្តល្មើសនឹងបញ្ជារបស់មន្ត្រី និង ភ្នាក់ងាររបស់រាជការ ត្រូវជាប់ចោទ ហើយឧបករណ៍ទាំងឡាយនៅក្នុងការដ្ឋានត្រូវរឹបអូស ។ ក្នុងករណីមិនរាងចាល ត្រូវពិន័យជាបទលហុ ។ បើពុំព្រមបញ្ឈប់ការងារ ត្រូវបញ្ជូនជនល្មើសទៅតុលាការ ដែលត្រូវវិនិច្ឆ័យតាមច្បាប់ជាធរមាន ។

<u>មាត្រា ២៥</u> : បណ្តឹងតវ៉ា

រាល់សេចក្តីសំរេចទាក់ទងនឹងពាក្យសុំលិខិតអនុញ្ញាតសាងសង់ មុនឡើងទៅតុលាការមានសមត្ថកិច្ច អាចជាកម្មវត្ថុនៃបណ្តឹងតវ៉ា ទៅអាជ្ញាធរមានសមត្ថកិច្ច ដូចបានបញ្ជាក់ក្នុងមាត្រា ៤ និង ៥ នៃអនុក្រឹត្យនេះ ដើម្បីធ្វើការពិនិត្យលើបណ្តឹងតវ៉ានេះ ។

អាជ្ញាធរមានសមត្ថកិច្ច មាននីតិសម្បទាសំរបសំរួលជាមួយម្ចាស់បណ្តឹង ។ ក្នុងករណីមិនបានសំរេច អ្នកប្តឹងអាចតវ៉ា ទៅដល់ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ បើអាជ្ញាធរមានសមត្ថកិច្ចជាអភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬនឹងទៅដល់នាយករដ្ឋមន្ត្រី បើអាជ្ញាធរមានសមត្ថកិច្ច ជា តំណាងរាជរដ្ឋាភិបាល ។

សំរាប់កិច្ចការនេះ ត្រូវបានបង្កើតផ្នែកវិវាទមួយនៅគ្រប់សាលាខេត្ត ឬសាលាក្រុង និងក្នុងគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។

## **ជំពូកទី ២**

## **<u>បទបញ្ជាទូទៅនៃការប្រើប្រាស់ដី-ធ្លី</u>**

<u>មាត្រា ២៦</u> : បទបញ្ជាទូទៅនៃការប្រើប្រាស់ដី-ធ្លីនេះ ត្រូវយកមកអនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ហើយតំរូវអោយរាល់បុគ្គលសាធារណៈ និង ឯកជន ជារូបវន្តបុគ្គលក្តី ឬ នីតិបុគ្គលក្តី គោរពប្រតិបត្តិតាមលិខិតអនុញ្ញាតសាងសង់ ក្នុងរយៈពេលដែលពុំទាន់មានប្លង់ប្រើប្រាស់ដី-ធ្លី និង ប្លង់គោលនៅឡើយនោះ ។

### **ជំពូក ១**

### **ប្រភេទ ការកំណត់ទីតាំង និង ផ្លូវចាក់ចេញចូលរបស់ទីតាំងសំណង់**

<u>មាត្រា ២៧</u> : **សុវត្ថិភាព និង សុខមាលភាពសាធារណៈ**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះសំណង់ទាំងឡាយណាដែលទីតាំង ប្រភេទ ឬ ទំហំ មានលក្ខណៈនាំអោយប៉ះពាល់ដល់សុខមាលភាព ឬ ដល់សុវត្ថិភាពសាធារណៈ នាំអោយរំខាន ឬ បណ្តាលអោយមានមហន្តរាយ ។

២៧.១ ទីដីគ្រោះថ្នាក់ ( ទីដីដែលអាចមានគ្រោះថ្នាក់ )

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះទីដីដែលអាចមានមហន្តរាយ ៈ តំបន់ជាប់[illegible] តំបន់ដីសើមដែលត្រូវការពារ តាមមាត់ច្រាំង ទន្លេ ព្រែក ស្ទឹង បឹងបួរ ដែលពុំមានការពាររឹងមាំគ្រប់គ្រាន់

ហើយអាចបណ្ដាលអោយមានគ្រោះថ្នាក់ ចំពោះសុវត្ថិភាពរបស់មនុស្ស និងសម្បត្តិទ្រព្យ លើកលែងតែភូមិដ្ឋានទាំងនោះបានអនុម័តតាមប្លង់គោល ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្ដល់ជូនឡើយ ចំពោះដីអាចលិចទឹក កាលណាសំណង់នោះស្ថិតតាមមាត់ច្រាំងទន្លេ ឈើព្រែក ស្ទឹង ឬបឹង បណ្ដាលអោយថយចុះលទ្ធភាពរក្សាទឹកទុក ឬ លទ្ធភាពបង្ហូរទឹកពីទីដីនោះ និង ទីដីជិតខាង និងប៉ះពាល់ដល់គុណភាពទឹក ។

២៧.២ ធាតុរំខានដោយសម្លេង

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្ដល់ជូនឡើយ ឬអាចអនុញ្ញាតអោយតែក្នុងករណីក្រោមបញ្ញត្តិពិសេស បើសំណង់នោះអាចត្រូវទទួលរងធាតុរំខានដោយសំលេងខ្លាំង ៗ ឬ បើសំណង់នោះអាចបង្កធាតុរំខានដោយសំលេងខ្លាំង ៗ ។

មាត្រា ២៨ : ការការពាររមណីយដ្ឋាន

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្ដល់ជូនឡើយ បើសំណង់នោះមានប្រភេទ ទំហំ ឬ ទីតាំង អាចបណ្ដាលអោយអន្តរាយដល់ការអភិរក្ស ឬ អន្តរាយដល់ការលើកតម្លៃនៃរមណីយដ្ឋានធម្មជាតិ ឬក្រុង ឬ ភូមិតំណែលប្រវត្តិសាស្ត្រ និងបុរាណវត្ថុ ឬ អាចអនុញ្ញាតអោយតែក្នុងករណីក្រោមបញ្ញត្តិពិសេស ។

មាត្រា ២៩ : បណ្ដាញផ្លូវពាក់ព័ន្ធ និង ចំណត

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្ដល់ជូនឡើយ ចំពោះដីដែលពុំមានផ្លូវចេញ-ចូល ដូចជា : ផ្លូវសាធារណៈ ផ្លូវឯកជន ច្រកផ្លូវ ឬ ផ្លូវឆ្លងកាត់ ដែលទទឹងត្រូវសមាមាត្រសមស្របទៅនឹងទំហំ និង ការប្រើប្រាស់នៃអគារ ។

រាល់ផ្លូវ ផ្លូវឆ្លងកាត់ ច្រកផ្លូវ សំរាប់ប្រើប្រាស់ចំពោះសំណង់មួយ ឬ ច្រើន ពុំអាចមានទទឹងតិចជាង ៣,៥០ម ដែលជាទំហំចាំបាច់សំរាប់អោយរថយន្តពន្លត់អគ្គីភ័យចូលបាន ។

ចំណតរថយន្ត ត្រូវមានគ្រប់គ្រាន់តាមសេចក្ដីត្រូវការរបស់អគារ ហើយត្រូវស្ថិតនៅក្រៅពីផ្លូវសាធារណៈ។

បទដ្ឋានចំណតរថយន្តត្រូវបានកំណត់ដោយបណ្ដាសាលាក្រុង និងសាលាខេត្ត ប៉ុន្តែពុំអាចតិចជាង :

- ចំពោះសណ្ឋាគារ :
  . ចំណតរថយន្តតូច ១កន្លែង សំរាប់ ៥ បន្ទប់
  . ចំណតរថយន្តធំ ១កន្លែង សំរាប់ ៣០ បន្ទប់
- ចំពោះការិយាល័យឯកជន និង រដ្ឋបាលសាធារណៈ
  . ចំណតរថយន្ត ១កន្លែង សំរាប់ផ្ទៃក្រឡាកម្រាលសរុបទំហំ ២៥០ម៉ែត្រទ្រេគុណ

- ចំពោះបណ្តាសកម្មភាព ឧស្សាហកម្ម សិប្បកម្ម និងឃ្លាំងស្តុកទំនិញ ចំនួនចំណតរថយន្តត្រូវមានគ្រប់គ្រាន់សំរាប់ការលើកដាក់ ផ្ទុក និង ផ្ទេរទំនិញនៅក្រៅពីផ្លូវសាធារណៈ និងចំណតរថយន្តគ្រប់ប្រភេទនៅក្នុងបរិវេណដីឡូត៍ ។

## មាត្រា ៣០: ការបោះទីតាំងសំណង់ តាមបងផ្លូវសាធារណៈ

៣០.១ ការបោះទីតាំងសំណង់នៅតាមបងផ្លូវជាតិ និង ផ្លូវទំនប់ព័ទ្ធជុំវិញទីក្រុង អភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងនានា និង រាជធានីភ្នំពេញ ត្រូវកំណត់ដោយមានការយល់ព្រម ពីគណៈកម្មាធិការជាតិរៀបចំទឹកដីនគរោបនីយកម្ម និង សំណង់ នូវដីចំណីសាធារណៈ និងបន្ទាត់ម្ខាងនៃផ្លូវជាតិ ផ្លូវសំខាន់ៗដែលពាក់ព័ន្ធនឹងការរៀបចំទីក្រុង និង នគរោបនីយកម្ម ជាអាទិ៍ផ្លូវទំនប់ ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ នៅក្នុងតំបន់ដែលបានរៀបរាប់ខាងលើ ។

### ៣០.២ ការបោះទីតាំងសំណង់ នៅតាមបងផ្លូវសាធារណៈក្នុងក្រុង

សំណង់ទាំងឡាយ ត្រូវបោះទីតាំងលើជួរតម្រង់ផ្លូវសាធារណៈ ឬឃ្លាតឆ្ងាយពីជួរតម្រង់យ៉ាងតិច ៥ម ។

នៅតាមច្រកផ្លូវ បណ្តាសំណង់អាចបោះទីតាំងលើជួរតម្រង់ផ្លូវច្រក ។

អភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងនានា និង រាជធានីភ្នំពេញ កំណត់ជួរតម្រង់នៃផ្លូវសាធារណៈ និង បន្ទាត់ម្ខាងលើប្លង់មួយហៅថា ប្លង់ជួរតម្រង់ ។ ប្លង់ជួរតម្រង់នេះ ត្រូវទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរោបនីយកម្ម និង សំណង់ ចំពោះក្រុងទាំងឡាយណាដែលមានប្រជាជនលើសពី ២០.០០០នាក់ ។ ប្លង់ទាំងនោះ ត្រូវផ្សព្វផ្សាយអោយសាធារណៈជនបានដឹង ។

## មាត្រា ៣១ : ការផ្គត់ផ្គង់ទឹកស្អាត និង ការបញ្ចេញចោលទឹកកខ្វក់

៣១.១ ការផ្គត់ផ្គង់ទឹកស្អាត ត្រូវធានាអោយបានចំពោះរាល់សំណង់ ដែលតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ ។

ក្នុងករណីដែលបណ្តាញទឹកស្អាត ពុំផ្គត់ផ្គង់អោយទៅដល់ទីដីដែលនៅលើទីដីនោះ មានសំណង់មួយត្រូវបានគ្រោងទុកនោះ អ្នកស្នើសុំត្រូវបង្ហាញភស្តុតាងថា ខ្លួនអាចនឹងផ្គត់ផ្គង់ទឹកស្អាតក្នុងបរិមាណគ្រប់គ្រាន់ដល់អគាររបស់ខ្លួន និងបញ្ជាក់ថាតាមមធ្យោបាយអ្វី ទោះបីតាមការបន្តភ្ជាប់ទៅនឹងបណ្តាញទឹកស្អាតណាមួយដែលនៅជិត ឬជាអណ្តូងទឹកដែលមានស្រាប់នៅជិតនោះ ឬដែលត្រូវជីកថ្មីក្តី ។

អ្នកស្នើសុំត្រូវបញ្ជាក់អំពីលក្ខណៈបច្ចេកទេសរបស់អណ្តូង និងគុណភាពទឹក ។ ក្នុងករណីការប្រើប្រាស់អណ្តូងសមូហភាព សំណុំលិខិតនៃលិខិតអនុញ្ញាតសាងសង់ ត្រូវមានសេចក្តីយល់ព្រមឱ្យប្រើប្រាស់ទឹកជាលាយលក្ខណ៍អក្សរ ។

៣១.២ បណ្ដាដីឡូតិ៍ ឬសំណុំលំនៅដ្ឋាន ត្រូវតែមានការផ្គត់ផ្គង់ដោយបណ្ដាញចែកចាយទឹកស្អាត និងមានប្រព័ន្ធលូទឹកស្អុយ ដែលនាំបង្ហូរចេញដល់ទីដៅតែម្ដង ដោយគ្មានកន្លែងណាមួយអាចអោយទឹកស្អុយដក់នៅបាន ។

៣១.៣ – ក្នុងករណីគ្មានប្រព័ន្ធលូទឹកស្អុយ ម្ចាស់សំណង់មានកាតព្វកិច្ចត្រូវគ្រោងសំអាត និងបញ្ចេញទឹកដែលប្រើប្រាស់ហើយទៅទីធម្មជាតិ តាមរយៈអាងបង្គន់អនាម័យ និងបណ្ដាញបំពង់មានប្រហោងរាយកប់ក្នុងដី ។

បណ្ដាញនេះបែងចែកទឹកដែលចេញពីបង្គន់អនាម័យ នៅក្រោមដីធ្វើអោយជ្រាប និង ជម្រះបាន ។

ម្ចាស់កម្មសិទ្ធនៅក្នុងក្រុង ចាំបាច់ត្រូវធ្វើអាងបង្គន់អនាម័យ ហើយបន្តភ្ជាប់ទៅប្រព័ន្ធលូ ។

បទដ្ឋានអាងបង្គន់អនាម័យ កំណត់ដូចតទៅ :

ទំហំប្រើប្រាស់នៃអាងបង្គន់អនាម័យ ដោយគិតពីបាតអាងឡើងមកដល់បំពង់បង្ហូរចេញ :

- ជាអប្បបរមា ៣ម៉ែត្រគ្រីគុណសំរាប់លំនៅដ្ឋានមួយ ឬ ៣ម៉ែត្រគ្រីគុណក្នុងមួយជាន់នៃផ្ទះល្វែង ឬនៃភូមិគ្រឹះ ឬ ៣ម៉ែត្រគ្រីគុណសំរាប់ផ្ទៃក្រឡាកំរាលសរុបទំហំ ៨០ម៉ែត្រទ្វេគុណ ។

ចំពោះសណ្ឋាគារ ២ ម៉ែត្រគ្រីគុណ បូកបន្ថែម ០,៥ម៉ែត្រគ្រីគុណក្នុងមួយបន្ទប់ :

- កំពស់អាងបង្គន់អនាម័យពុំអាចទាបជាង ១,៥០ម ។
- អាងបង្គន់អនាម័យត្រូវមានរន្ធបង្ហុយបន្តខ្ពស់ទៅលើ ។
- មិនត្រូវអោយទឹកភ្លៀងហូរចូលទៅក្នុងអាងបង្គន់អនាម័យជាដាច់ខាត់ ។

៣១.៤ – សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ត្រូវមានគំនូរអាងបង្គន់អនាម័យ និង ប្រព័ន្ធបន្តភ្ជាប់ទៅលូបង្ហូរទឹកស្អុយ ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្ដល់ជូនឡើយ បើពុំបង្ហាញការធានាគ្រប់គ្រាន់អំពីអនាម័យ និងសុខមាលភាពចំពោះសំណង់ដែលបានគ្រោង និងបណ្ដាសំណង់នៅជុំវិញដែលមានស្រាប់ ។

<u>មាត្រា ៣២</u> : **តំបន់មិនអាចសាងសង់បាន**

ខេត្ត និង ក្រុង នីមួយៗ ត្រូវកំណត់ជាបន្ទាន់នូវប្លង់តំបន់មិនអាចសាងសង់បាន ។

ប្លង់នេះ ត្រូវមានបញ្ចូលតំបន់ការពារធម្មជាតិ តំបន់កសិកម្ម តំបន់ព្រៃឈើ និង រ៉ែ ដែលជាគោលដៅប្រើប្រាស់ពុំអាចផ្លាស់ប្ដូរបានដោយមូលហេតុផលប្រយោជន៍សេដ្ឋកិច្ច និង បរិស្ថាន ។

ប្លង់នេះ ត្រូវមានបញ្ចូលរមណីយដ្ឋានធម្មជាតិ ដូចជា ឆ្នេរសមុទ្រ មាត់ទន្លេ ព្រែក ស្ទឹង បឹងបួរ ដោយមូលហេតុផលប្រយោជន៍បេតិកភ័ណ្ឌ និង បរិស្ថាន ។

ប្លង់នេះ ត្រូវមានបញ្ចូលគ្រប់តំបន់អាចលិចទឹក ដែលត្រូវការពារដោយមូលហេតុជាផលប្រយោជន៍ សំរាប់បង្ហូរទឹកភ្លៀងចេញ និង ការប្រយុទ្ធប្រឆាំងនឹងទឹកជំនន់ ។

អាជ្ញាធរតាមមូលដ្ឋានត្រូវចាត់វិធានការសមស្រប ដើម្បីការពារ និងបង្កើនគុណសម្បត្តិតំបន់មិនអាចសាងសង់បានទាំងនោះ ។

រាល់លិខិតអនុញ្ញាតសាងសង់ មិនផ្តល់ជូនឡើយក្នុងតំបន់ទាំងនោះ ។

ក្នុងករណីមានការសាងសង់ដោយល្មើសច្បាប់ ក្នុងតំបន់ហាមឃាត់ទាំងនេះ អាជ្ញាធរដែនដីត្រូវបង្ខំឱ្យជនល្មើសរុះរើដោយខ្លួនឯង ហើយធ្វើអោយកន្លែងនោះមានសភាពដូចដើមវិញ ក្នុងរយៈកាលមួយកំណត់ ។

ក្នុងករណីមិនអនុវត្តតាមការកំណត់ អាជ្ញាធរដែនដីត្រូវធ្វើការផាកពិន័យ និង ចាត់អោយរុះរើ និងធ្វើអោយកន្លែងនោះមានសភាពដូចដើមវិញ ដោយចាប់បង្ខំអោយអ្នកល្មើសច្បាប់ ត្រូវតែចេញសោហ៊ុយចំណាយទាំងអស់នោះ ឬ ក្នុងករណីចាំបាច់ អាជ្ញាធរមូលដ្ឋានត្រូវប្តឹងទៅតុលាការ ដើម្បីអោយចេញដីការកិច្ចការប្រញាប់បញ្ជាអោយរុះរើ ។

ប្លង់នេះ ត្រូវទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ និងត្រូវផ្សព្វផ្សាយជាសាធារណៈដល់មន្ត្រីរាជការ ផ្នែកអាជ្ញាធរដែនដីមូលដ្ឋាន និងមន្ត្រីជំនាញទទួលខុសត្រូវលើ << តំបន់មិនអាចសាងសង់បាន >> ដែលពុំបានចាត់វិធានការចាំបាច់ ដើម្បីអោយមានការគោរពតំបន់ទាំងនោះទេ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់ជាធរមាន ។

**មាត្រា ៣៣ : ផលប៉ះពាល់ពីសំណង់ឧស្សាហកម្ម**

សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់សំណង់ឧស្សាហកម្ម ត្រូវបញ្ជាក់អំពីការបំពុលបណ្តាលមកពីសកម្មភាពឧស្សាហកម្ម និងវិធីដែលបានគ្រោងទុក ដើម្បីលុបបំបាត់ការបំពុលទាំងនោះ ។

គំរោងស្ថានីយសំរាប់ធ្វើសំអាតតាមយថាប្រភេទ ត្រូវមានបញ្ចូលក្នុងសំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ។

រាល់កាកសំណល់ពីឧស្សាហកម្ម ត្រូវតែបានទទួលការសំអាតជាមុន ដើម្បីបង្ការកុំអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់ ឬ សុខភាពសាធារណៈ ។ ទឹកកខ្វក់សំណល់ឧស្សាហកម្ម ពុំត្រូវឱ្យលាយឡំជាមួយទឹកភ្លៀង និងជាមួយទឹកកខ្វក់ដទៃទៀត ហើយក៏ពុំត្រូវបង្ហូរចូលត្រង់ៗទៅកន្លែងធម្មជាតិ ដោយពុំបានធ្វើការសំអាតជាមុនឡើយ ។

ចម្ងាយអប្បបរមា ដែលត្រូវគោរពរវាងសំណង់ឧស្សាហកម្មមួយដែលមានធាតុកខ្វក់ និង លំនៅឋាននៅជិតបំផុត ត្រូវបានរដ្ឋអំណាចមូលដ្ឋានអនុវត្ត ស្របទៅតាមការណែនាំផ្ទាល់របស់រាជរដ្ឋាភិបាល ។

ចំពោះឃ្លាំងស្តុកឧទ្ទារ និង អាងប្រេងឥន្ធនៈទាំងឡាយ ត្រូវគោរពបទបញ្ញត្តិអន្តរជាតិ អនុម័តដោយរាជរដ្ឋាភិបាល ។

រាល់អំពើល្មើសនឹងបណ្តាបទបញ្ញត្តិខាងលើនេះ រដ្ឋអំណាចមូលដ្ឋានអាចបញ្ជាផ្អាកសកម្មភាពជាបន្ទាន់ ហើយត្រូវរាយការណ៍ជូនស្ថាប័នជំនាញ ។ រដ្ឋអំណាច ត្រូវជូនដំណឹងតាមផ្លូវច្បាប់ដល់ម្ចាស់សំណង់ នូវបណ្តាបទបញ្ញត្តិដែលត្រូវគោរពតាម ។

## ជំពូក ២

## ការបោះទីតាំង និង ទំហំសំណង់

**មាត្រា ៣៤ : ការបោះទីតាំងធៀបនឹងព្រំដីឡូត៍ជិតខាង**

ធៀបនឹងព្រំដីឡូតិ៍ សំណង់ទាំងឡាយនឹងត្រូវសាងសង់ ឬមួយនៅជាប់នឹងព្រំ ឬមួយជាជញ្ជាំងអឌ្ឍសិទ្ធិ ឬមួយនៅចម្ងាយអប្បបរមា ២ម ពីព្រំ ។ ចន្លោះ ២ម នេះ ត្រូវទុកអោយនៅទំនេរពុំមានសំណង់អ្វីឡើយ ។

ហាមមិនអោយចោះទ្វារ ឬ បង្អួច នៅលើជញ្ជាំងអឌ្ឍសិទ្ធិ ឬជញ្ជាំងជាប់ព្រំ ។

ចំពោះសំណង់ជាប់ព្រំ ឬ សំណង់ជាជញ្ជាំងអឌ្ឍសិទ្ធិ នឹងមានកំណត់ក្នុងសេចក្តីណែនាំអនុវត្ត របស់គណៈ-កម្មាធិការជាតិរៀបចំទឹកដី នគរោបនីយកម្ម និង សំណង់ តាមសំណើរបស់ខេត្ត-ក្រុង ។

ត្រូវបានចាត់ទុកថាជាបន្ទប់រស់នៅ រាល់បន្ទប់ទាំងអស់លើកលែងតែផ្ទះបាយ បន្ទប់អនាម័យ បន្ទប់សេវាផ្សេងៗ និង ចន្លោះដើរក្នុងអគារ ។ បទបញ្ញត្តិនេះ ត្រូវដាក់អោយអនុវត្តផងដែរចំពោះសណ្ឋាគារ ។

ក្នុងករណីនេះ រាល់បន្ទប់ដេក ក៏ដូចជារាល់បន្ទប់ទទួលភ្ញៀវ សុទ្ធតែត្រូវចាត់ទុកថាជាបន្ទប់រស់នៅ ។

បទបញ្ញត្តិនេះ ក៏ត្រូវដាក់អោយអនុវត្តផងដែរ ចំពោះកន្លែងធ្វើការ ។ ក្នុងករណីនេះ រាល់បន្ទប់ដែលមានមុខងារជាការិយាល័យ ឬ រោងជាងប្រើប្រាស់ជាទម្លាប់ ឬជាប្រចាំថ្ងៃ ត្រូវចាត់ទុកដូចជាបន្ទប់រស់នៅដែរ លើកលែងតែបន្ទប់មិនត្រូវការជាចាំបាច់នូវពន្លឺថ្ងៃ តាមមុខងារយថាប្រភេទរបស់វា ដូចជាបន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍ ស្ទូឌីយោភាពយន្ត ។ ល ។

សាលាក្រុង ឬ សាលាខេត្ត អាចមានសិទ្ធិអោយបិទរាល់ច្រកប្រហោងណា ដែលពុំគោរពតាមចម្ងាយដូចបានរៀបរាប់ខាងលើនេះ ។

ចំពោះអគារមានពីមុនស្រាប់ ដែលពុំគោរពតាមបទបញ្ញត្តិដូចបានរៀបរាប់ខាងលើនេះទេ សាលាក្រុង ឬ សាលាខេត្ត អាចទាមទារអោយបង្កើតរបាំងការពារ កុំអោយមានគំហើញត្រង់ទៅលើដីឡូត៍អ្នកជិតខាង ។

របាំងការពារទាំងនេះ អាចជាជញ្ជាំងមានប្រឡោះខ្យល់ ផ្ទាំងឈើ ឬអ្វីៗផ្សេងទៀត ដែលពុំរាំងខ្ទប់ដំណើរខ្យល់បក់ចេញចូលក្នុងបន្ទប់រស់នៅ ។

ចាត់ទុកជាបង្អួច រាល់ប្រហោងនានាដែលបណ្តាលអោយមានគំហើញត្រង់ ឆ្ពោះទៅលើអ្នកជិតខាង ។ ក្នុងករណីណាក៏ដោយ គេអាចប្រើប្រាស់បានរាល់របាំងធ្វើពីឈើ ឬបេតុង ស្លាបព្រីលបាក់បើក ធ្វើពីឈើ ឬកញ្ចក់ស្រអាប់ និង ស្លាបព្រីលនៅនឹងថ្កល់ ។

**មាត្រា ៣៥ : ផ្ទៃបាត**

ចំពោះផ្ទះល្វែង និង អគារលំនៅដ្ឋានសមូហភាព ផ្ទៃបាតសំណង់ធៀបទៅនឹងផ្ទៃក្រឡារបស់ដីឡូត៍ ពុំអាចលើសពី ៧៥% ឡើយ ។

ចំពោះផ្ទះជាយំនៅឋាន ផ្ទៃបាតសំណង់នោះពុំអាចលើសពី ៥០% នៃផ្ទៃក្រឡាដីឡូត៍ឡើយ ។

ផ្ទៃក្រឡាដីឡូត៍ ដែលនៅសល់ពីការសាងសង់ ត្រូវរៀបចំជាសួនដោយដីជ្រាបទឹក អោយបានយ៉ាងតិចពាក់កណ្ដាលផ្ទៃក្រឡានេះ ។

ចំពោះអគារដែលមានយ៉ាងតិច ១៥លំនៅ សណ្ឋាគារ អគារការិយាល័យ និង អគារឧស្សាហកម្ម ផ្ទៃបាតសំណង់ពុំអាចលើសពី ៥០% នៃផ្ទៃក្រឡាដីឡូត៍ឡើយ ។

ផ្ទៃក្រឡាដែលនៅសល់ពីសំណង់ នឹងត្រូវរៀបចំជាសួនដោយដីជ្រាបទឹក អោយបានយ៉ាងតិចពាក់កណ្ដាលផ្ទៃក្រឡានេះ ។

សាលាក្រុង និង សាលាខេត្ត ត្រូវកំណត់តំបន់រៀបចំក្រុង ដែលត្រូវយកបទបញ្ញាខាងលើនេះមកអនុវត្ត ហើយនឹងត្រូវកំណត់បទបញ្ញត្តិពិសេស ចំពោះស្ថានភាពជាក់ស្ដែង ។

**មាត្រា ៣៦ : ប្លង់កំពស់**

សាលាក្រុង និង សាលាខេត្តនីមួយៗ នឹងលើកគំរោងប្លង់កំពស់ក្នុងរយៈពេលមួយឆ្នាំ ក្រោយពីបានការអនុម័តលើអនុក្រឹត្យនេះរួច ដោយកំណត់អោយតំបន់នីមួយៗនៃក្រុងនូវកំពស់អតិបរិមានៃសំណង់ ។

ប្លង់កំពស់នេះត្រូវគិតដល់ :

. កំពស់មធ្យមបច្ចុប្បន្នតាមសង្កាត់នីមួយ ៗ ។

. លក្ខណៈសំខាន់នៃតំបន់ (ពាណិជ្ជកម្ម លំនៅឋាន ឧស្សាហកម្មនៅកណ្ដាលក្រុង ឬជាយក្រុង ដីចាក់បំពេញ ឬអត់ ការប្រើប្រាស់ទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធ ។ ល ។) ។

. ប្រភេទនៃសំណង់ (ផ្ទះល្វែង ភូមិគ្រឹះ គ្រឹះស្ថាន ឃ្លាំងស្តុកទំនិញ និង អគារឧស្សាហកម្ម...។ ល ។) ។

ប្លង់កំពស់នេះ ត្រូវបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ហើយផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៣៧ : ការការពារប្រាង្គប្រាសាទ និង ទេសភាព**

សាលាក្រុង និង សាលាខេត្តនីមួយ ៗ អាចកំណត់កំពស់អតិបរិមាទាបជាងកំពស់អតិបរិមាក្នុង << ប្លង់កំពស់ >> ដើម្បីការពារបូជនីយស្ថានប្រវត្តិសាស្ត្រ រមណីយដ្ឋានធម្មជាតិ ក៏ដូចជាកន្លែងនៅជិត ៗ ប្រាង្គប្រាសាទប្រវត្តិសាស្ត្រ ឬ ដើម្បីរក្សាទុកនូវទស្សនវិស័យ នៃប្រាង្គប្រាសាទ និង ទស្សនវិស័យដ៏ស្អិតស្អាង ។

ការបន្ថយកំពស់នេះ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ និង ប្រាប់ដល់អ្នកសុំលិខិតអនុញ្ញាតសាងសង់មុនពេលដាក់សំណុំលិខិតស្នើសុំ ។

## ជំពូក ៣

## ទិដ្ឋភាពនៃសំណង់

មាត្រា ៣៨ : លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់ដែលគ្រោងនោះមានទីតាំង ស្ថាបត្យកម្ម (Architecture) ទំហំ ឬ ទិដ្ឋភាពក្រៅអាចនាំអោយប៉ះពាល់ដល់លក្ខណៈ ឬ ផលប្រយោជន៍របស់ទីតាំងនៅជុំវិញ ប៉ះពាល់ដល់ទេសភាពធម្មជាតិ ឬទីក្រុង ភាពស្ងប់របស់ទីសក្ការបូជា រមណីយដ្ឋានប្រវត្តិសាស្ត្រ ឬ បុរាណសាស្ត្រ រាជវាំង និង រាជព្រង្គប្រសាទ ។

មាត្រា ៣៩ : លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើង បើលក្ខណៈសំណង់នោះមិនធានាសុខមាលភាព បន្ទប់ស្នាក់នៅ ឬ បន្ទប់ធ្វើការនីមួយ ៗ ត្រូវអោយមានខ្យល់ចេញ-ចូល ហើយត្រូវមានបង្អួចមួយយ៉ាងតិច ។

ផ្ទៃក្រឡាបញ្ចូលពន្លឺថ្ងៃសំរាប់បន្ទប់នីមួយ ៗ ត្រូវមានយ៉ាងតិច ១,៥០ម$^{២}$ ។

មាត្រា ៤០ : បណ្តាសំណង់ឧស្សាហកម្ម អាចតម្រូវអោយគោរពល័ក្ខខ័ណ្ឌពិសេសចំពោះការរៀបចំ ឬការបោះទីតាំង ដើម្បីធានាការបញ្ចូលឱ្យបានល្អទៅក្នុងទេសភាព និង រមណីយដ្ឋានធម្មជាតិ ឬ ទីក្រុង ។

មាត្រា ៤១ : នៅតាមឆ្នេរសមុទ្រ តាមមាត់បឹង ស្ទឹង និងទន្លេ លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់នោះធ្វើអោយខូចទ្រង់ទ្រាយសោភ័ណភាពរបស់ទេសភាព និង រមណីយដ្ឋាន ដោយសារទិដ្ឋភាព ឬ កំពស់របស់សំណង់ បើមើលពីមាត់ឆ្នេរ ពីមាត់ច្រាំង ពីសមុទ្រ ស្ទឹង ទន្លេ ឬបឹងបួរ និង ប៉ះពាល់ដល់គុណភាពទឹក ។

## ជំពូក ៤

## សន្ទភាព ( ដង់ស៊ីតេ ) : កំរិតស្របច្បាប់នៃសន្ទស្សន៍ប្រើប្រាស់

មាត្រា ៤២ : ការស្ថាបនាសំណង់មួយមានសន្ទភាព លើសពីកំរិតអតិបរមាស្របច្បាប់ តម្រូវអោយអ្នកទទួលលិខិតអនុញ្ញាតសាងសង់ បង់ប្រាក់ស្មើនឹងតំលៃដីដែលចាំបាច់ ដើម្បីអោយ << សន្ទស្សន៍ប្រើប្រាស់ >> សំណង់មិនលើស ពីកំរិតនេះ ។

មាត្រា ៤៣ : << សន្ទស្សន៍ប្រើប្រាស់ >> ត្រូវបានកំណត់ដោយអនុបាតរវាងផ្ទៃក្រឡាកម្រាលសរុបជាផ្លូវការ ( Hors oeuvre nette ) នៃសំណង់នោះ និងផ្ទៃក្រឡាដីដែលសំណង់នោះនឹងត្រូវ ឬបានតាំងនៅលើ ។

កាលណាសំណង់ថ្មីមួយ បានត្រូវសាងសង់លើដីមួយកន្លែងដែលមានអគារចាស់មួយ ឬច្រើន ហើយគ្មានគម្រោងរុះរើពេលនោះទេ សន្ទភាពត្រូវគណនាដោយថែមផ្ទៃក្រឡាកម្រាលនៃសំណង់ចាស់ ទៅលើផ្ទៃក្រឡាកំរាលនៃសំណង់ថ្មី ។

<u>មាត្រា ៤៤</u> : កំរិតអតិបរមាស្របច្បាប់នៃសន្ទស្សន៍ប្រើប្រាស់ ត្រូវកំណត់ដល់ (១) សំរាប់ទូទាំងដែនដីក្នុងព្រះរាជាណាចក្រកម្ពុជា ។

<u>មាត្រា ៤៥</u> : ការផ្តល់លិខិតអនុញ្ញាតសាងសង់ នាំមកអោយអ្នកបានទទួលលិខិតអនុញ្ញាតសាងសង់ នូវកាតព្វកិច្ចអោយបង់ប្រាក់នោះ ។ ការបង់ប្រាក់ត្រូវធ្វើជាបីភាគស្មើគ្នា ភាគទី ១ នៅពេលបានទទួលលិខិតអនុញ្ញាតសាងសង់ ភាគទី ២ នៅពេលបើកការដ្ឋាន ភាគទី ៣ នៅពេលបញ្ចប់សំណង់ ។

<u>មាត្រា ៤៦</u> : តំលៃដីសំរាប់ការគណនាចំនួនទឹកប្រាក់ដែលត្រូវបង់ ត្រូវបានកំណត់ដោយក្រសួងហិរញ្ញវត្ថុ ។

<u>មាត្រា ៤៧</u> : កំរិតស្របច្បាប់នៃ << សន្ទស្សន៍ប្រើប្រាស់ >> ពុំត្រូវអនុវត្តឡើយ ចំពោះសំណង់ដែលពុំតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ ចំពោះគ្រឹះស្ថានសាធារណៈ និង ចំពោះអគាររដ្ឋបាលសាធារណៈសំរាប់បំរើផ្ទាល់មុខ ជាកន្លែងធ្វើការសំរាប់ស្ថាប័នសាធារណៈ ។

នាយករដ្ឋមន្ត្រី អាចសំរេចលើកលែងការអនុវត្តកំរិតស្របច្បាប់នៃ << សន្ទស្សន៍ប្រើប្រាស់ >> ចំពោះបណ្តាតំបន់រៀបចំពិសេស បន្ទាប់ពីបានយោបល់ពីគណៈកម្មាធិការជាតិ រៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។

<< វាសនដ្ឋានសង្គម >> ទាំងឡាយអាចទទួលនូវការលើកលែងមិនអោយបង់ពន្ធអាករ តាមសេចក្តីសំរេចរបស់អភិបាលខេត្ត-ក្រុង បន្ទាប់ពីបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។

## ជំពូក ៥

## បទបញ្ញាពិសេស សំរាប់អនុវត្តលើភាគខ្លះ នៃដែនដី

<u>មាត្រា ៤៨</u> : ជាការបន្ថែមដល់បទបញ្ញាទូទៅនៃការប្រើប្រាស់ដី-ធ្លី ការណែនាំមួយចំនួនសំរាប់ការរៀបចំតំបន់ និង បទបញ្ញានគរូបនីយកម្មពិសេសមួយចំនួន អាចត្រូវដាក់តែងឡើងដោយអនុក្រឹត្យដែលអាច មានរហូតដល់ការហាមមិនអោយសាងសង់នៅក្នុង << តំបន់ចាប់អារម្មណ៍ >> ដូចជា ឆ្នេរសមុទ្រ មាត់ច្រាំងទន្លេ និង បឹងធំ ៗ ។ រាល់ឯកសារ << នគរូបនីយកម្មមូលដ្ឋាន >> និង ប្លង់ខេត្តនៃ តំបន់ហាមមិនអោយមានសំណង់ ដែលចែងក្នុងមាត្រា ៣២ វគ្គទី ២ នៃអនុក្រឹត្យនេះត្រូវទុកជាការណែនាំ ទាំងនេះ និង ការហាមជាយថាហេតុមិនអោយសាងសង់ ។

<u>មាត្រា ៤៩</u> : បទបញ្ញត្តិទាំងឡាយមានពីមុនដែលផ្ទុយនឹងអនុក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

មាត្រា ៥០ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និង វិចិត្រសិល្បៈ រៀបចំទឹកដីនគររូបនីយកម្ម និង សំណង់ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង អភិបាលខេត្ត សមាជិកគណៈកម្មាធិការជាតិរៀបចំទឹកដី នគររូបនីយកម្ម និង សំណង់ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមតួនាទីចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ ៨ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

អ៊ុង ហួត ហ៊ុន សែន

កន្លែងទទួល :
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យឯកឧត្តមនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- ដូចមាត្រា ៥០
- ឯកសារ-កាលប្បវត្តិ

ជំរាបជូន :
ឯកឧត្តមនាយករដ្ឋមន្ត្រីទី ១
សម្តេចនាយករដ្ឋមន្ត្រីទី ២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ
រៀបចំទឹកដី នគររូបនីយកម្ម និង សំណង់

វណ្ណ ម៉ូលីវណ្ណ